# ✍ ជីវប្រវត្តិរបស់ព្រះមោឃរាជត្ថេរ ✍

## “ ដែលជាឯតទគ្គៈផ្នែកខាងទ្រទ្រង់ចីវរសៅហ្មង ”

ព្រះមោឃរាជត្ថេរ លោកជាព្រះអរហន្ត និងជាព្រះមហាសាវ័កមួយរូប ដែលបានទទួលការលើកតម្កើងអំពីព្រះភគវា កាលដែលព្រះអង្គគង់ប្រថាប់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ដូចមានរឿងសម្តែងទុកនៅក្នុង**គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ លូខចីវរធរានំ យទិទំ មោឃរាជា ។** ប្រែថា ម្នាលភិក្ខុទាំងឡាយ ព្រះមោឃរាជត្ថេរជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកខាងទ្រទ្រង់ចីវរសៅហ្មង ។ ព្រះមោឃរាជត្ថេរលោកបានសម្រេចវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ។

ជីវប្រវត្តិរបស់ព្រះមោឃរាជត្ថេរ ដូចដែលមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** និងក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** បានសម្តែងជីវប្រវត្តិអតីតជាតិរបស់លោកទុកថា ៖

ការកសាងបុណ្យបារមី របស់ព្រះមោឃរាជត្ថេរ បានធ្វើទុកមកអំពីអតីតជាតិ ដោយលោកធ្លាប់កសាង សន្សំបុណ្យកុសលជារឿយៗ

រហូតកន្លងមកដល់ភទ្ទកប្បនេះ រាប់ប្រមាណបានមួយសែនកប្ប ដោយការរាប់ថយក្រោយអំពីភទ្ទកប្បនេះ ការធ្វើបុណ្យកុសលរបស់លោកនៅមានទៀត ក្នុងពុទ្ធកាលរបស់ព្រះបទុមុត្តរសម្ពុទ្ធ ។ ព្រះមោឃរាជត្ថេរបានកើតនៅក្នុងត្រកូលអ្នកមានធនធានម្នាក់ នៅក្នុងនគរហង្សវតី ។ លុះកាលលោកចម្រើនពេញវ័យហើយ បានមានសទ្ធាជ្រះថ្លានៅក្នុងព្រះពុទ្ធសាសនា ថ្ងៃមួយ លោកបានទៅស្ដាប់ធម៌ទេសនា ទាំងបានឃើញព្រះបទុមុត្តរៈប្រកាសតែងតាំងភិក្ខុមួយរូប ផ្នែកខាងទ្រទ្រង់នូវចីវរសៅហ្មងធ្វើឲ្យលោកមានការពេញចិត្តក្នុងតំណែងនោះ និងជាហេតុធ្វើឲ្យកើតចិត្តជ្រះថ្លា ធ្វើបុណ្យកុសល ហើយប្រាថ្នាឲ្យបាននូវតំណែងនោះ លោកបានធ្វើសេចក្ដីល្អយ៉ាងនេះជារឿយៗ រហូតដល់អស់ជីវិត ។ ពេលដែលលោកអស់ជីវិតអំពីជាតិនេះទៅ បានត្រាច់វន្តត់ទៅក្នុងមនុស្ស និងទេវតាអស់កាលដ៏យូរ ដោយបានទទួលនូវសេចក្ដីសុខ ដែលកើតអំពីបុណ្យកុសលរបស់ខ្លួន ដែលបានធ្វើទុកមកហើយ ។

ចំណែកជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះមោឃរាជត្ថេរ តាមដែលមានសម្ដែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** មានការពោលអំពីជីវប្រវត្តិខ្លួនឯង ដូចមានសេចក្ដីថា ៖

ព្រះមុនីព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ធ្វើនូវប្រយោជន៍ដល់សត្វលោកទាំងពួង ទ្រង់កើតឡើងក្នុងកប្បទី

មួយសែន អំពីកប្បនេះ ។ ព្រះអង្គទ្រង់ឈ្នះសក្នុងទេសនា ទ្រង់ប្រទាន ឱវាទញ៉ាំងសត្វឲ្យត្រាស់ដឹង ចម្លងសត្វទាំងពួង ទ្រង់ញ៉ាំងពួកជនច្រើន ឲ្យឆ្លងចាកលោក ទ្រង់មានសេចក្តីអនុគ្រោះ មានករុណា ស្វែងរកនូវ ប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញ៉ាំងពួកតិរ្ថិយទាំងពួង ដែលមកប្រជុំ គ្នា ឲ្យតាំងនៅក្នុងសីល ៥ ។ កាលយ៉ាងនេះ សាសនានេះឯង មិនរីករវ សូន្យចាកពួកតិរ្ថិយ វិចិត្រដោយពួកព្រះអរហន្ត ជាអ្នកស្ទាត់ជំនាញ ប្រកប ដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកម្ពស់ ៥៨ ហត្ថ ប្រាកដស្មើ ដោយគ្រឿងបូជាជាវិការនៃមាស មានបុរិសលក្ខណៈ ៣២ ប្រការ ។ មានព្រះជន្មាយុមួយសែនឆ្នាំ កាលព្រះអង្គទ្រង់គង់នៅឡើយ ទ្រង់ញ៉ាំង ពួកជនច្រើនគ្នាឲ្យឆ្លង ( ចាកលោក ) ។ កាលនោះ ខ្ញុំកើតក្នុងត្រកូល មួយ នៅក្នុងនគរហង្សវតី ជាអ្នកប្រកបការងារឲ្យបុគ្គលដទៃ ខ្ញុំឥតមាន វត្ថុតិចតួចជាទ្រព្យរបស់ខ្លួនឡើយ ។ កាលខ្ញុំនៅក្នុងបដិក្កមនសាលា ដែល គេធ្វើជាថ្នាក់ ក៏អុជភ្លើងក្នុងបដិក្កមនសាលានោះ ផែនដីដែលក្រាលដោយ ថ្ម ត្រូវភ្លើងឆេះខ្មោចខ្មៅ ។ កាលនោះ ព្រះលោកនាថកំពុងប្រកាសសច្ចៈ ៤ ក្នុងកណ្តាលបរិស័ទ ទ្រង់សរសើរសាវ័កដែលទ្រទ្រង់ចីវរសៅហ្មង ។ ខ្ញុំត្រេកអរក្នុងគុណរបស់សាវ័កនោះ បានប្រតិបត្តិព្រះតថាគត ហើយ ប្រាថ្នាតំណែងដ៏ខ្ពង់ខ្ពស់ ជាកំពូលនៃការទ្រទ្រង់ចីវរសៅហ្មង ។ គ្រានោះ ព្រះបទុមុត្តរៈដ៏មានជោគ ស្តេចទ្រង់ត្រាស់នឹងពួកសាវ័កថា អ្នកទាំងឡាយ

ចូរមើលបុរសនុ៎ះ ដែលមានសំពត់កខ្វក់ មានខ្លួនស្គើង ។ មានមុខជ្រះថ្លា
ដោយបីតិ ទាំងមានទ្រព្យប្រសើរ គឺសទ្ធាជាប់តាមហើយ មានរោមដ៏រៀវ
ង.ឡើង រីករាយ ឥតមានកម្រើកដូចជាដុំឈើ ។ បុរសនុ៎ះ ប្រាថ្នានូវ
តំណែងនៃភិក្ខុអ្នកមានសច្ចៈជារបស់ខ្លួន ទ្រទ្រង់នូវចីវរសៅហ្មងនោះ មាន
អធ្យាស្រ័យតាំងនៅក្នុងគុណនៃភិក្ខុនោះ ។ លុះខ្ញុំស្តាប់ព្រះពុទ្ធតម្រាស់
នោះហើយ ក៏កើតសេចក្តីរីករាយ ក្រាបទៀបព្រះជិនស្រីដោយសិរសា
ធ្វើនូវអំពើល្អក្នុងសាសនាព្រះជិនស្រី ដរាបដល់អស់ជីវិត ។ ដោយអំពើ
ដែលខ្លួនធ្វើល្អនោះផង ដោយបានតម្កល់ទុកនូវសេចក្តីប្រាថ្នានោះផង លុះ
ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។
ដោយអំពើដែលខ្ញុំបានដុតថ្នាក់ក្នុងបដិក្កមនសាលា ខ្ញុំត្រូវវេទនាគ្របសង្កត់
ចេះនៅក្នុងនរកអស់មួយពាន់ឆ្នាំគត់ ។ ដោយសំណល់កម្មនោះ ខ្ញុំបាន
កើតនៅក្នុងត្រកូលមនុស្ស មានលក្ខណៈគេស្គាល់បាន តាមលំដាប់អស់
៥០០ ជាតិ ។ ពេញប្រៀបដោយរោគឃ្លង់គ្រប់ ៥០០ ជាតិ រងសេចក្តី
ទុក្ខធំ ដោយផលនៃកម្មនោះ ។ ក្នុងកប្បនេះ ខ្ញុំមានចិត្តជ្រះថ្លា បានញ៉ាំង
ព្រះបច្ចេកពុទ្ធព្រះនាមឧបរិដ្ឋៈដ៏មានយស ឲ្យឆ្អែតស្កប់ស្កល់ដោយបង្អាន់
បិណ្ឌបាត ។ ដោយអំពើវិសេសនោះផង ដោយការតម្កល់ទុកនូវចេតនា
នោះផង លុះខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ ក៏បានទៅកើតក្នុង
ឋានតាវត្តិង្ស ។ លុះដល់បច្ឆិមភព ខ្ញុំបានកើតក្នុងត្រកូលក្សត្រ អំណឹះ

អត់ពីបិតាទៅ ខ្ញុំក៏បានឆ្អែតស្កប់ស្កល់ដោយរាជសម្បត្តិធំៗ ខ្ញុំត្រូវរោគឃ្លង់គ្របសង្កត់ ឥតបានសុខក្នុងរាត្រីណានីមួយឡើយ សេចក្តីសុខក្នុងរាជសម្បត្តិ ជារបស់សោះសូន្យទទេ ព្រោះហេតុណា ព្រោះហេតុនោះ បានជាខ្ញុំមានឈ្មោះថា មោឃរាជ ។ ខ្ញុំឃើញទោសរបស់កាយហើយ ក៏ចូលទៅកាន់ផ្នួស បានចូលទៅធ្វើជាសិស្ស របស់អាចារ្យពាវរីព្រាហ្មណ៍ដែលជាកំពូលព្រាហ្មណ៍ ។ ខ្ញុំមានបរិវារច្រើនចូលទៅគាល់ព្រះពុទ្ធ ជានាយកនៃនរជន ហើយសួរប្រស្នាដ៏ល្អិតល្អន់ ជាប្រស្នានៃបុគ្គលមានថ្វីមាត់ ជាទីហូរមកនៃវាទៈថា លោកនេះ បរលោក ព្រហ្មលោក ព្រមទាំងទេវលោក ( មានដែរឬទេ ) ខ្ញុំព្រះអង្គមិនដឹងទិដ្ឋិរបស់ព្រះអង្គជាគោតម ដ៏មានយសទេ ។ ដែលខ្ញុំព្រះអង្គមកនេះ ដើម្បីសួរប្រស្នាចំពោះព្រះអង្គ ទ្រង់ឃើញវិសេសយ៉ាងនេះ ចុះមច្ចុរាជមិនឃើញបុគ្គលដែលពិចារណាឃើញច្បាស់នូវលោក តើយ៉ាងណា ? ព្រះពុទ្ធទ្រង់ព្យាបាលរោគគ្រប់មុខ បានត្រាស់ឆ្លើយនឹងខ្ញុំវិញថា ម្នាលមោឃរាជ អ្នកចូរមានស្មារតីសព្វកាល ពិចារណានូវលោកថាសូន្យចុះ បុគ្គលដែលបានដកនូវអត្តានុទិដ្ឋិចេញហើយ រមែងឆ្លងចាកមច្ចុរាជបាន ។ មច្ចុរាជ រមែងមិនឃើញនូវបុគ្គលអ្នកពិចារណាឃើញច្បាស់ នូវលោកយ៉ាងនេះ ។ គ្រាន់តែចប់គាថា ខ្ញុំរៀរស្រឡះចាកសក់ និងពុកមាត់ ស្លៀកសំពត់កាសាវៈ បានក្លាយទៅជាអរហន្តភិក្ខុភ្លាម ។ ខ្ញុំត្រូវរោគបៀតបៀនហើយ មិនហ៊ាន

នៅក្នុងវិហាររបស់សង្ឃ ត្រូវគេរុកកួនដោយសម្តីថា អ្នកកុំប្រទូស្តវិហារ ។ លំដាប់នោះ ខ្ញុំបាននាំយកសំពត់អំពីគំនរសម្រាមខ្លះ ព្រៃស្មសានខ្លះ ប្រកខ្លះ មកធ្វើជាសង្ឃាដិ ហើយប្រើប្រាស់តែចីវរសៅហ្មង ។ ព្រះពុទ្ធ ជាមហាពេទ្យ ដឹកនាំសត្វ ទ្រង់ត្រេកអរក្នុងគុណរបស់ខ្ញុំនោះហើយ ក៏តាំងខ្ញុំក្នុងតំណែងជាឯតទគ្គៈ ជាអ្នកប្រសើរជាងភិក្ខុ ទ្រទ្រង់នូវចីវរសៅហ្មង ។ ខ្ញុំជាបុគ្គលអស់បុណ្យ និងបាប វៀរស្រឡះចាករោគគ្រប់យ៉ាង ឥតមានអាសវៈ ដូចជាភ្លើងឥតកំញម នឹងបរិនិព្វាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជា ដំរីកាត់ផ្តាច់នូវទន្ទីង ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

លុះដល់កាលពុទ្ធសម័យ របស់ព្រះអត្ថទស្សី ស្តេចទ្រង់ឧប្បត្តិឡើងក្នុងលោកហើយ ព្រះមោឃរាជត្ថេរ បានមកកើតនៅក្នុងត្រកូលព្រាហ្មណ៍ កាលបើចម្រើនធំពេញវ័យហើយ ថ្ងៃមួយ លោកបានទៅជួបព្រះអត្ថទស្សី ក៏បានកើតសេចក្តីជ្រះថ្លាចំពោះមហាបុរិសលក្ខណៈ និងពុទ្ធចរិយា ទើបថ្វាយបង្គំ និងបានពោលសរសើរព្រះពុទ្ធគុណថា ៖

បណ្តាសត្វទាំងពួងដែលមាននៅក្នុងលោក ទាំងដែលមានរូបរាង និងមិនមានរូបរាង ទាំងដែលរស់នៅលើគោក និងក្នុងទឹក រមែងមិនប្រសើរប្រហាក់ប្រហែលជាមួយព្រះអង្គបានឡើយ ។ ព្រះពុទ្ធទ្រង់ប្រសើរលើសជាងសត្វទាំងពួង ។ ក្រោយពីកុលបុត្រនោះ បានសរសើរគុណព្រះពុទ្ធដូច្នេះហើយ ទើបដាក់ទឹកឃ្មុំពេញក្នុងភាជនៈ ចូលទៅប្រគេនចំពោះព្រះមហាមុនី ។ ព្រះអត្ថទស្សីទ្រង់ព្យាករទុកថា បុរសដែលមានសេចក្តីជ្រះថ្លា រហូតដល់ពោលសរសើរគុណ និងបានថ្វាយទឹកឃ្មុំដល់តថាគតនេះ គេនឹងមិនទៅកាន់ទុគ្គតិឡើយ នឹងបានជាទេវរាជ ៦៤ ជាតិ ជាស្តេចចក្រពត្តិ ៥០០ ជាតិទៀត ជាព្រះរាជាគ្រប់គ្រងប្រទេសរាប់ជាតិមិនអស់ និងក្នុងជាតិចុងក្រោយ បានមកកើតជាព្រាហ្មណ៍ ដែលទ្រទ្រង់វិជ្ជាត្រៃវេទ ថែមទាំងបានជាសាវ័ករបស់ព្រះសមណគោតម មានឈ្មោះថា មោឃរាជ ។ មូលហេតុដែលឈ្មោះថា មោឃរាជ ព្រោះលោកបានកើតក្នុងត្រកូលក្សត្រ ក្នុងកាលព្រះជនកស្តេចសោយទិវង្គតទៅ ហើយលោកបានជាព្រះមោឃរាជ ប៉ុន្តែការកើតរោគឃ្លង់ ពេលយប់ មិនបានទទួលនូវសេចក្តីសុខឡើយ ព្រោះដូច្នោះ សេចក្តីសុខដែលកើតអំពីស្តេចគ្រប់គ្រងផែនដី រមែងរកប្រយោជន៍មិនបាន ទើបលោកមានឈ្មោះថា មោឃរាជ សេចក្តីថា ព្រះរាជាដែលព្រាត់ចាកប្រយោជន៍ ដែលគប្បីបាន ឬជាព្រះរាជាទទេ ទាំងនេះជាហេតុធ្វើឲ្យលោកមើលឃើញទោស

របស់រូបកាយ ទើបលះបង់ភាពជាព្រះរាជាចោល ។

ជីវប្រវត្តិរបស់ព្រះមោឃរាជត្ថេរ ដូចដែលមានសម្ដែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** និងក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ថា ៖

ក្នុងអតីតកាល ក្នុងពុទ្ធសម័យរបស់ព្រះកស្សបៈ ព្រះមោឃរាជកើតនៅក្នុងក្រុងពារាណសី ដោយបានជាកូនសិស្សរបស់មេជាងឈើម្នាក់ ដែលជាអ្នកមានចំណេះចេះដឹងផ្នែកខាងធ្វើជាង មិនមានអ្នកណាមកប្រៀបផ្ទឹមជាគម្រប់ពីរបានឡើយ ទាំងមេជាងឈើនោះ មានកូនសិស្សរហូតដល់ ១៦ នាក់ សិស្សម្នាក់ៗ មានកូនសិស្សមួយពាន់នាក់ទៀត រួមទាំងកូនសិស្ស និងអាចារ្យ មានមួយម៉ឺនប្រាំមួយពាន់ដប់ប្រាំពីរនាក់ ។ បណ្ដាជាងឈើទាំងនោះ បានធ្វើការចិញ្ចឹមជីវិតនៅក្នុងក្រុងពារាណសី មានការប្រកបការងារជាជាងឈើ ដោយពួកគេបាននាំគ្នាទៅក្នុងព្រៃ ដើម្បីរកកាប់ដើមឈើមកធ្វើប្រាសាទបែបផ្សេងៗ កាលបើរៀបចំរួចជាស្រេចហើយ រុះរើយកមកដាក់លក់ក្នុងក្រុងពារាណសី ប្រសិនបើព្រះរាជាត្រូវការប្រាសាទមួយជាន់ ឬប្រាំជាន់ ពួកគេនឹងជួយគ្នាធ្វើថ្វាយ ប៉ុន្តែប្រសិនបើព្រះរាជាមិនមានបំណងធ្វើទេ ពួកគេនឹងលក់ឲ្យដល់ជនដទៃ ដើម្បីយកទ្រព្យមកចិញ្ចឹមបុត្រ និងភរិយា ។ នៅថ្ងៃមួយ អាចារ្យរបស់ពួកជាងឈើនោះគិតថា យើងមិនអាចចិញ្ចឹមជីវិត ដោយអាជីពជាជាងឈើអស់

កាលជានិច្ចបានទេ ព្រោះក្នុងពេលដែលយើងចាស់ទៅ ការងារជាជាង ឈើនេះ ជាការងារធ្ងន់ ធ្វើបានដោយលំបាក ទើបហៅកូនសិស្សមក ប្រាប់ថា ពួកអ្នកទាំងអស់គ្នា ចូរនាំគ្នាទៅរកឈើដែលមិនមានខ្ទឹម មាន ដើមល្អជាដើមមក ។

ទើបពួកកូនសិស្សព្រមគ្នាទទួលពាក្យថា បាទ បាទ ហើយនាំគ្នា ទៅរកឈើដែលមិនមានខ្ទឹមមកជាច្រើន មេជាងដែលជាអាចារ្យ បាននាំ ឈើទាំងនោះ មកធ្វើជាសត្វ និងធ្វើជាគ្រឿងយន្តដាក់ខាងក្នុងខ្លួនសត្វ នោះ ។ សត្វឈើនោះ ពេលទទះស្លាបឡើងទៅលើអាកាស មានលក្ខណៈ ដូចគ្នានឹងស្តេចហង្ស ហើយទទះស្លាបចុះទៅក្នុងព្រៃ ដែលជាបរិវេណ របស់ពួកកូនសិស្សទាំងនោះ ។ គ្រានោះ មេជាងដែលជាអាចារ្យប្រាប់ ដល់ពួកកូនសិស្សថា ពួកអ្នកអាចធ្វើពាហនៈសត្វឈើ ដើម្បីដណ្តើមយក រាជសម្បត្តិក្នុងជម្ពូទ្វីបទាំងអស់ ដូច្នេះ អ្នកទាំងអស់គ្នា ចូរជួយធ្វើពាហនៈ ឈើចុះ ពួកយើងនឹងដណ្តើមយករាជសម្បត្តិ ឲ្យជារបស់យើងទាំងអស់ ព្រោះការចិញ្ចឹមជីវិតដោយធ្វើជាជាងឈើលំបាកណាស់ ។ ពួកកូនសិស្ស ទាំងអស់ បានធ្វើតាមពាក្យណែនាំរបស់អាចារ្យ កាលបើធ្វើរួចជាស្រេច ហើយ ទើបប្រាប់ឲ្យអាចារ្យបានជ្រាប ។ ចំណែកអាចារ្យសួរកូនសិស្ស ថា ពួកយើងនឹងដណ្តើមយករាជសម្បត្តិក្នុងក្រុងណាមុនទើបល្អ ? ពួក កូនសិស្សតបថា គួរដណ្តើមយករាជសម្បត្តិក្នុងក្រុងពារាណសីមុន អាចារ្យ

ពោលហាមថា កុំឡើយ អ្នកទាំងអស់គ្នា ពួកអ្នកកុំពេញចិត្តក្នុងការដណ្តើមយករាជសម្បត្តិក្នុងក្រុងពារាណសីមុនអី ទីបំផុតនឹងជារបស់ពួកយើងដដែល បុគ្គលទាំងអស់នឹងនាំគ្នាហៅយើងថា ព្រះរាជាជាងឈើ អ្នកទាំងអស់គ្នា ក្នុងជម្ពូទ្វីបនេះធំណាស់ ពួកយើងនឹងនាំគ្នាទៅដណ្តើមយកក្នុងទីដទៃសិនចុះ ។ កាលបើពួកជាងឈើទាំងអស់នោះ គិតដូច្នេះហើយ ទើបព្រមព្រៀងគ្នាឡើងជិះពាហនះឈើ ចងសៀតអាវុធគ្រប់សព្វ ហើយនាំគ្នាបែរមុខទៅកាន់ព្រៃហិមពាន្ត និងបានចូលទៅកាន់ក្រុងទីមួយៗ ដែលនៅក្បែរនឹងព្រៃហិមពាន្តនោះ ក៏បានចូលទៅសម្រាកក្នុងព្រះរាជនិវេសន៍របស់ក្រុងនោះ ។

ពួកជាងឈើដណ្តើមរាជសម្បត្តិក្នុងក្រុងនោះបានហើយ ទើបអភិសេកអាចារ្យជាមេជាង ឲ្យឡើងជាព្រះរាជា ទ្រង់មាននាមប្រាកដថា ព្រះរាជាកដ្ឋវាហនៈ ប្រែថា ព្រះរាជាពាហនះឈើ ក្នុងក្រុងនោះ មានឈ្មោះថា ក្រុងកដ្ឋវាហនៈ ដូចព្រះនាមរបស់ព្រះរាជាដែរ រហូតសូម្បីដែនទាំងអស់ ក៏មានឈ្មោះថា ដែនកដ្ឋវាហនៈ ដោយកាន់យកព្រះនាមព្រះរាជាជាគោល ។ ព្រះរាជាកដ្ឋវាហនៈ ទ្រង់ជាអ្នកតាំងនៅក្នុងទសពិធរាជធម៌ ព្រះយុវរាជដែលជាឧបរាជ ឬរជ្ជទាយាទក៏ដូចគ្នា ចំណែកកូនសិស្សទាំង ១៦ នាក់ បានទទួលតំណែងជាអាមាត្យឲ្យនៅក្នុងរាជសម្នាក់ ។ រាជធម៌ គឺធម៌សម្រាប់ស្តេចគ្រប់គ្រងផែនដី សំដៅដល់គុណ

សម្បត្តិរបស់អ្នកគ្រប់គ្រងដ៏ល្អ អាចគ្រប់គ្រងផែនដីបានដោយធម៌ និង ញ៉ាំងនូវប្រយោជន៍ឲ្យកើតដល់មហាជន រហូតដល់កើតការពោលសរសើរ គ្រគកអរអំពីមហាជនជាច្រើន **ទសពិធរាជធម៌មាន ១០ ប្រការ** គឺ ៖

**១ ទាន** គឺការឲ្យទ្រព្យសម្បត្តិ **២ សីល** គឺការប្រព្រឹត្តល្អស្អាត តាមកាយវាចា **៣ បរិច្ចាគៈ** គឺការលះបង់ **៤ អាជ្ជវៈ** គឺការស្មោះត្រង់ **៥ មទ្ទវៈ** គឺភាពទន់ភ្លន់ **៦ តបៈ** គឺការដុតកិលេសតណ្ហា **៧ អក្កោធៈ** គឺការមិនក្រេវក្រោធ **៨ អវិហិង្សា** គឺការមិនគំរាមកំហែងបៀតបៀន **៩ ខន្តី** គឺការអត់ធន់ **១០ អវិរោធនៈ** គឺការមិនឆាប់ពិរោធន៍ឃ្លាតចាកធម៌ ។ ព្រះរាជាទ្រង់មានទសពិធរាជធម៌ ទ្រង់សង្គ្រោះមហាជនក្នុងដែន ដោយ រាជសង្គហវត្ថុ គឺគោលការណ៍សង្គ្រោះ គឺជួយសង្គ្រោះគ្នា រាប់អានគ្នា ទំនាក់ទំនងជាមួយមហាជន **មាន ៤ ប្រការ** បានដល់ ៖

**១- សស្សមេធ** ទ្រង់មានភាពឈ្លាសវៃក្នុងការទ្រទ្រង់ ទំនុក បម្រុងធញ្ញាហារដ៏ឧត្តម ដោយទ្រង់គាំទ្រផ្នែកកសិកម្មឲ្យដល់ព្រមដោយ គ្រាប់ពូជធញ្ញាហារ ។

**២- បុរិសមេធ** ទ្រង់មានភាពឈ្លាសវៃក្នុងរាជកិច្ច ដោយទ្រង់ លើកតម្កើងអ្នកមានចំណេះចេះដឹង ឲ្យជួយធ្វើរាជកិច្ច ។

**៣- សម្មាបាស** ទ្រង់បំបាត់ទុក្ខ នាំសេចក្ដីសុខឲ្យដល់រាស្ត្រ ដូច ទ្រង់គាំទ្រអាជីពរបស់មហាជន ដោយព្រះទ័យពេញចិត្ត ។

៤- **រាជបេយ្យ** ត្រាស់រាំចាពីកេះ ផ្អែមល្ហែម ជាមួយនឹងមហាជន គ្រប់ឋានៈ ដោយទ្រង់មានព្រះរាជតម្រាស់ដែលជាប្រយោជន៍ និងពោលពាក្យឲ្យចេះសាមគ្គីគ្នា ។

ដោយព្រះរាជាទ្រង់មានរាជធម៌ ទើបជួយឲ្យដែនដីចម្រុងចម្រើនបរិបូណ៌ដោយធញ្ញជាតិផ្សេងៗ ថែមទាំងមិនមានអន្តរាយយ៉ាងណាទីមួយកើតឡើងក្នុងក្រុង ឬជនបទ ពួកមហាជនមានការគោរពរាប់អានព្រះ-រាជាកដ្ឋវាហនៈ រហូតដល់រាជបរិវារដ៏ល្អថា ពួកយើងបានព្រះរាជាដែលទ្រទ្រង់ធម៌ និងរាជបរិវារក៏មានគុណធម៌ដែរ ។ នៅថ្ងៃមួយ មានពួកឈ្មួញនាំទំនិញមកពីក្រុងពារាណសី ដែលស្ថិតនៅក្នុងមជ្ឈិមប្រទេសមកដល់ក្រុងកដ្ឋវាហនៈ ហើយពួកឈ្មួញបាននាំគ្នាយកគ្រឿងបណ្ណាការ ចូលទៅគាល់ ទូលថ្វាយដល់ព្រះរាជាកដ្ឋវាហនៈៗ ត្រាស់សួរថា ពួកអ្នកមកពីទីណា ? ពួកឈ្មួញក្រាបបង្គំទូលថា ពួកខ្ញុំទាំងឡាយមកពីក្រុងពារាណសី ព្រះករុណាថ្លៃវិសេស ។ ព្រះរាជាទ្រង់សាកសួរដល់ការមក របស់ពួកឈ្មួញ និងត្រាស់ថា ចូរពួកអ្នកធ្វើជាមិត្តរបស់ពួកខ្ញុំ យើងខ្ញុំក៏ជាមិត្តជាមួយនឹងព្រះរាជារបស់ពួកលោកដែរ ។ ពួកឈ្មួញទាំងនោះ មានសេចក្តីត្រេកអរចំពោះមិត្តភាពនេះថា ព្រះករុណាថ្លៃវិសេស យល់ព្រម ។ ព្រះរាជាកដ្ឋវាហនៈ ទ្រង់សព្វព្រះហឫទ័យជាមួយនឹងពួកឈ្មួញទាំងនោះ ទើបទ្រង់ត្រាស់ឲ្យព្រះរាជទានស្បៀងអាហារដល់ពួកអ្នកទាំងនោះ ពេលនោះ

ពួកឈ្មួញក៏ក្រាបបង្គំទូលលាត្រឡប់ទៅវិញ ព្រះរាជាទ្រង់ប្រាស្រ័យដោយភាពអើពើទៀត ធ្វើឲ្យពួកឈ្មួញមានសេចក្តីពេញចិត្តចំពោះទឹកព្រះទ័យរបស់ព្រះរាជា ។ កាលបើពួកឈ្មួញត្រឡប់ទៅដល់ក្រុងពារាណសីហើយ បានចូលគាល់ក្រាបបង្គំទូលដល់ព្រះបាទពារាណសី ឲ្យទ្រង់ជ្រាបចំពោះមិត្តភាពរវាងព្រះរាជាកដ្ឋវាហនៈ ។ ព្រះបាទពារាណសីទ្រង់ជ្រាបសេចក្តីនោះហើយ ត្រាស់ឲ្យវាយស្គរស្រែកប្រកាសថា ចាប់ពីថ្ងៃនេះតទៅ ចូរអ្នកទាំងឡាយវៀរចាកការយកពន្ធដារពីពួកឈ្មួញ ដែលមកពីដែនកដ្ឋ-វាហនៈ ព្រោះព្រះរាជាអង្គនោះ ជាមិត្តរបស់ពួកយើង ។

មានសេចក្តីថា ព្រះរាជាទាំងពីរព្រះអង្គនោះ ទ្រង់បានជាសម្លាញ់នឹងគ្នា ដោយមិនធ្លាប់បានជួបមុខគ្នាឡើយ ដោយទ្រង់អាស្រ័យពួកឈ្មួញជាអ្នកចងសម្ព័ន្ធមេត្រីភាពឲ្យ ។ ចំណែកព្រះរាជាកដ្ឋវាហនៈ ក៏បានត្រាស់ឲ្យវាយស្គរ ស្រែកប្រកាសក្នុងក្រុងរបស់ព្រះអង្គថា ចាប់ពីថ្ងៃនេះតទៅ ពួកអ្នកចូរវៀរចាកការយកពន្ធដារពីពួកឈ្មួញ ដែលមកពីក្រុងពារាណសី ។ រីឯព្រះបាទព្រះពារាណសី ទ្រង់មានព្រះរាជសាសន៍បញ្ជូនទៅថ្វាយដល់ព្រះរាជាកដ្ឋវាហនៈ ប្រសិនបើមានវត្ថុណាមួយ ជាវត្ថុអស្ចារ្យ សមគួរមើល ឬសមគួរស្តាប់កើតឡើងនៅក្នុងក្រុងរបស់ព្រះអង្គ សូមឲ្យខ្ញុំព្រះអង្គមានឱកាសបានមើល បានស្តាប់ផង ។ ចំណែកព្រះរាជាកដ្ឋវាហនៈ ក៏ទ្រង់តបព្រះរាជសាសន៍ទៅវិញដូចគ្នាដែរ ។ កាល

បើព្រះរាជាទាំងពីរព្រះអង្គ ទ្រង់ធ្វើកតិកានឹងគ្នាទុកយ៉ាងនេះហើយ ។ កាលតមក មានសំពត់កម្ពលសាច់ហ្មត់យ៉ាងល្អបំផុត មានតម្លៃច្រើនក្រៃលែង និងមានពណ៌ដូចរស្មីព្រះអាទិត្យ ទើបតែរះ បានកើតឡើងដល់ព្រះរាជាកដ្ឋវាហនៈៗ ទតឃើញហើយ ទ្រង់ត្រិះរិះថា យើងនឹងបញ្ជូនសំពត់កម្ពលនេះទៅថ្វាយដល់សម្លាញ់របស់យើង ទើបត្រាស់ឲ្យជាងក្តុកមកក្រឡឹងក្លុងក្តុក ៨ ក្លុង ឲ្យដាក់សំពត់កម្ពលទាំងនោះ ចុះទៅក្នុងក្លុងក្តុកនោះ ឲ្យពួកជាងអាចម៍ល័ខ ប្រើអាចម៍ល័ខរុំខាងក្រៅ ឲ្យដូចគ្នានឹងដុំអាចម៍ល័ខ ហើយដាក់ដុំអាចម៍ល័ខទាំង ៨ ដុំ ចូលក្នុងប្រអប់មួយ ឲ្យយកសំពត់រុំសង្កត់ និងឲ្យប្រថាប់ត្រាផែនដី ហើយទ្រង់ប្រគល់ប្រអប់ ឲ្យដល់ពួកអាមាត្យ ព្រមជាមួយនឹងព្រះហស្តលេខា ទាំងត្រាស់ថា ចូរពួកអ្នកនាំរបស់ទាំងនេះ ទៅថ្វាយដល់ព្រះបាទពារាណសី និងចូរក្រាបបង្គំទូលថា គ្រឿងបណ្ណាការទាំងនេះ ព្រះរាជារបស់ខ្ញុំបញ្ជូនមកថ្វាយ ។

ពួកអាមាត្យនាំទៅថ្វាយដល់ព្រះបាទពារាណសីៗ ទ្រង់ទតព្រះហស្តលេខាហើយ ទើបត្រាស់ឲ្យប្រជុំពួកអាមាត្យ ហើយត្រាស់បញ្ជាឲ្យហែកត្រាផែនដីចេញ ស្រាយសំពត់ដែលខ្ចប់ ហើយទ្រង់បើកប្រអប់មើល បានទតឃើញដុំអាចម៍ល័ខ ៨ ដុំ ទ្រង់កើតអាការអាក់អន់ស្រពន់ចិត្ត ដោយទ្រង់ត្រិះរិះថា សម្លាញ់របស់យើង បានបញ្ជូនដុំអាចម៍ល័ខមកឲ្យយើងដូចគ្នានឹងបញ្ជូនមកឲ្យពួកក្មេងៗ ដែលចូលចិត្តលេងដុំអាចម៍ល័ខ ទើប

ទ្រង់គប់គ្រវែងដុំអាចម៍ល័ខមួយដុំ ចុះទៅក្បែរទីគង់ប្រថាប់របស់ព្រះអង្គ ដុំអាចម៍ល័ខនោះបែកខ្ទាយភ្លាម ក្ដងក្អកដែលនៅក្នុងដុំអាចម៍ល័ខ បានប្រាកដចេញមកជាពីរចំណែក ព្រះអង្គទ្រង់ទតឃើញសំពត់កម្ពលមួយផ្ទាំងនៅក្នុងក្ដងនោះ ហើយទ្រង់បើកក្ដងដទៃៗ ទៀត សូម្បីក្ដងដទៃៗ ក៏មានសំពត់ដូចគ្នាដែរ ។ កាលបើព្រះបាទពារាណសី ទ្រង់ទតឃើញសំពត់កម្ពលដែលមានតម្លៃខ្ពស់ដូច្នោះ ក៏ទ្រង់បាត់ការអាក់អន់ស្រពន់ចិត្ត ។ សំពត់កម្ពលមួយផ្ទាំង មានបណ្ដោយ ១៦ ហត្ថ ទទឹង ៨ ហត្ថ កាលបើលាតសំពត់កម្ពលចេញមក បរិវេណនោះភ្លឺដូចពន្លឺនៃដួងព្រះអាទិត្យ ។ មហាជនបានក្រឡេកឃើញសំពត់កម្ពលផ្សេងៗ គ្នា នាំគ្នាលើកដៃ និងគ្រវីទង់ផ្សេងៗ សម្ដែងសេចក្ដីត្រេកអរថា ព្រះរាជាកដ្ឋវាហនៈ ទ្រង់ជាសម្លាញ់របស់ព្រះរាជាពួកយើងមែន ទើបទ្រង់បានជាបញ្ជូនគ្រឿងបណ្ណាការដ៏មានតម្លៃនេះមកថ្វាយ ភាពជាមិត្តជាមួយនឹងព្រះរាជានេះល្អណាស់ ។ ព្រះបាទពារាណសីត្រាស់ឲ្យពួកឈ្មួញវាយតម្លៃ សំពត់កម្ពលមួយផ្ទាំងៗ ថា មានតម្លៃប៉ុន្មាន ? សំពត់កម្ពលទាំងអស់នេះ មិនអាចនឹងវាយតម្លៃបានឡើយ ព្រោះជាសំពត់ដែលមានតម្លៃខ្ពស់ហួស របូតវាយតម្លៃមិនត្រូវ ព្រះរាជាទើបទ្រង់មានព្រះតម្រិះថា យើងនឹងបញ្ជូនបណ្ណាការទៅថ្វាយក្នុងពេលខាងក្រោយ គួរបញ្ជូនគ្រឿងបណ្ណាការឲ្យល្អជាងសម្លាញ់ដែលបញ្ជូនមកឲ្យដល់យើង ដោយរៀបចំយកគ្រឿងបណ្ណាការ ដែលប្រមាណតម្លៃមិន

បាន ប៉ុន្តែយើងគួរបញ្ជូនវត្ថុណាហ្ន៎ ដែលល្អឲ្យដល់សម្លាញ់របស់យើង ទើបឲ្យសមរម្យជាមួយនឹងតម្លៃសំពត់ទាំងនោះ ។

ក្នុងសម័យនោះ ព្រះកស្សបសម្មាសម្ពុទ្ធ ទ្រង់ឧប្បត្តិឡើងក្នុងលោក ព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុងក្រុងពារាណសី ។ ព្រះបាទពារាណសីទ្រង់ត្រិះរិះពិចារណាមើលថា វត្ថុណានីមួយដែលមានតម្លៃជាងព្រះរតនៈមិនមានឡើយ យើងគួរបញ្ជូនដំណឹង រឿងព្រះរតនត្រៃកើតឡើងក្នុងលោក ទៅឲ្យសម្លាញ់របស់យើងទើបជាការល្អ ទ្រង់ពិចារណាដូច្នេះហើយ ទើបត្រាស់ឲ្យចារឹកព្រះគាថា ថា ៖

ព្រះពុទ្ធស្តេចឧប្បត្តិឡើងក្នុងលោកហើយ ដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងពួង ព្រះធម៌បានឧប្បត្តិឡើងក្នុងលោកហើយ ដើម្បីសេចក្តីសុខដល់សត្វទាំងពួង ព្រះសង្ឃជាស្រែបុណ្យដ៏ប្រសើរ បានឧប្បត្តិឡើងក្នុងលោកហើយ ។ ទាំងព្រះអង្គត្រាស់ឲ្យចារឹក ខ.បដិបត្តិរបស់ភិក្ខុសង្ឃមួយរូបៗ ឲ្យដាក់ក្នុងផ្ទាំងមាស និងឲ្យដាក់បញ្ចុះក្នុងប្រអប់ ៧ បែប ដល់ ៧ ជាន់ ដោយឲ្យដាក់បញ្ចុះក្នុងប្រអប់កែវមណីមុន ហើយឲ្យដាក់ប្រអប់កែវមណីក្នុងប្រអប់ក្បាច់ ឲ្យដាក់ប្រអប់កែវក្បាច់ក្នុងប្រអប់កែវក្រហម ឲ្យដាក់ប្រអប់កែវក្រហមក្នុងប្រអប់មាស ឲ្យដាក់ប្រអប់មាសក្នុងប្រអប់ប្រាក់ ឲ្យដាក់ប្រអប់ប្រាក់ក្នុងប្រអប់ក្អុក ឲ្យដាក់ប្រអប់ក្អុកក្នុងប្រអប់ខ្លឹមឈើ ឲ្យដាក់ប្រអប់ខ្លឹមឈើក្នុងកំប្រោង ឲ្យរុំកំប្រោងដោយសំពត់ ឲ្យវាយត្រា

ប្រថាប់ និងដោយប្រដាប់តាក់តែងដំរីព្រះទីន័ងដោយទង់មាស គ្រឿងប្រដាប់មាស ឲ្យប្រើបណ្តាញមាសគ្របសង្កត់ពោង ឲ្យតម្កល់បល្ល័ង្កលើខ្នងដំរី ឲ្យលើកកំប្រោងនោះឡើងដាក់លើបល្ល័ង្ក បាំងដោយស្វេតច្ឆត្រ និងត្រាស់ឲ្យបូជាដោយផ្កា និងគ្រឿងប្រអូបជាដើម ទាំងឲ្យអ្នកតន្ត្រីចំនួនច្រើនរយនាក់ហែហមការពារ ទៅរហូតទាល់តែខាងចុងព្រះរាជាណាចក្ររបស់ព្រះអង្គ ហើយត្រាស់ឲ្យបញ្ជូនគ្រឿងបណ្ណាការ ទៅថ្វាយព្រះរាជាដែលនៅជិតខាងថា សូមព្រះរាជាទ្រង់ជួយបញ្ជូនបណ្ណាការមានតម្លៃច្រើននេះ តទៅដោយការធ្វើគ្រឿងសក្ការបូជាដូចគ្នានឹងគ្រាមុន ដែលទ្រង់ធ្វើរួចហើយ ។ ព្រះរាជាទាំងឡាយ ទ្រង់ជួយបញ្ជូនបណ្ណាការ មានតម្លៃច្រើននោះទៅជាលំដាប់ រហូតទៅដល់ក្រុងកដ្ឋវាហនៈ ។

ចំណែកព្រះរាជាកដ្ឋវាហនៈ ទ្រង់បានធ្វើសក្ការៈដូចគ្នា ហើយទ្រង់នាំចូលទៅកាន់ព្រះនគរ ឲ្យប្រជុំពួកអាមាត្យ និងអ្នកនគររួចហើយ បញ្ជាឲ្យដោះសំពត់គ្របចេញ ឲ្យបើកកំប្រោង ដែលមានសណ្ឋានដូចជាល ឬមានលក្ខណៈដូចហិបចេញមក បានទតឃើញប្រអប់ខ្លឹមឈើក្នុងកំប្រោងនោះ និងបើកប្រអប់ចេញជាបន្តបន្ទាប់ រហូតដល់បានទតឃើញផ្ទាំងមាសដែលចារឹកព្រះរតនត្រៃទុក ទ្រង់ក៏កើតការសប្បាយព្រះទ័យ យ៉ាងក្រៃលែងថា សម្លាញ់របស់យើងបានបញ្ជូនរតនៈជាគ្រឿងបណ្ណាការ ដែលរកបានដោយកម្រអស់កាលច្រើនសែនកប្ប ហើយត្រាស់ថា រឿងដែល

ព្រះពុទ្ធ ទ្រង់ឧប្បត្តិឡើងក្នុងលោក ជារឿងដែលយើងមិនធ្លាប់បានឮ ឥឡូវនេះ យើងបានឮហើយ ក៏ទ្រង់ត្រិះរិះទៀតថា យើងនឹងទៅថ្វាយបង្គំព្រះពុទ្ធ នឹងស្តាប់ព្រះធម៌ ហើយព្រះអង្គទើបត្រាស់ជាមួយពួកអាមាត្យថា រតនៈ គឺកែវ បានដល់ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានកើតឡើងក្នុងលោកហើយ តើពួកលោកនឹងធ្វើយ៉ាងណា ទើបល្អ ? ពួកអាមាត្យក្រាបបង្គំទូលថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ស្នាក់នៅក្នុងនគរនេះសិនចុះ ខ្ញុំព្រះអង្គទាំងឡាយ នឹងទៅស៊ើបមើលឲ្យដឹងរឿង ហើយនឹងត្រឡប់មកក្រាបបង្គំទូលឲ្យទ្រង់ជ្រាបវិញ ។ ពួកអាមាត្យ ១៦ នាក់ ព្រមជាមួយនឹងបរិវារម្នាក់ៗ មួយពាន់នាក់ រួមត្រូវជា ១៦.០១៦ នាក់ ក្រាបបង្គំទូលព្រះរាជាថា ប្រសិនបើព្រះពុទ្ធកើតឡើងក្នុងលោកពិតមែន ការត្រឡប់មកគាល់ព្រះអង្គទៀតនឹងមិនមាន ប៉ុន្តែប្រសិនបើព្រះពុទ្ធនៅមិនទាន់កើតឡើងក្នុងលោកទេ ខ្ញុំព្រះអង្គទាំងឡាយ នឹងត្រឡប់មកគាល់ព្រះអង្គវិញ កាលបើក្រាបបង្គំទូលដូច្នេះហើយ ក៏បានក្រាបបង្គំទូលលាព្រះរាជាទៅស៊ើបមើល ។

ចំណែកអាមាត្យជាជំនិតរបស់ព្រះរាជាកដ្ឋវាហនៈ បានក្រាបបង្គំទូលឡើងក្នុងពេលជាខាងក្រោយថា ខ្ញុំព្រះអង្គសូមទៅដែរ ព្រះរាជាត្រាស់ថា ប្រសិនបើអ្នកទៅស៊ើបដំណឹងបានថា ព្រះពុទ្ធកើតឡើងក្នុងលោកហើយ ចូរអ្នកត្រឡប់មកប្រាប់យើងផង ។ អាមាត្យដែលជាជំនិត

របស់ព្រះរាជា បានក្រាបបង្គំទទួលថា ព្រះករុណាព្រះអង្គ ហើយក៏ថ្វាយបង្គំលាទៅ ។ ពួកអាមាត្យទាំងអស់ បាននាំគ្នាធ្វើដំណើរទៅ ដោយសម្រាកតែពាក់កណ្ដាលយប់នៃយប់នីមួយៗ ប៉ុណ្ណោះ រហូតដល់ក្រុងពារាណសី ប៉ុន្តែកាលពួកអាមាត្យទាំងនោះ ធ្វើដំណើរមិនទាន់ទៅដល់ផង ព្រះសម្មាសម្ពុទ្ធកស្សបៈ ទ្រង់បានរំលត់ខន្ធបរិនិព្វានទៅមុនហើយ កាលបើពួកអាមាត្យទៅដល់ បានដើរសួររកគ្រប់ទីកន្លែងថា អ្នកណាជាព្រះពុទ្ធ ព្រះពុទ្ធទ្រង់គង់នៅក្នុងទីណា ប៉ុន្តែបានជួបត្រឹមតែសាវ័ក ហើយក្រាបបង្គំទូលសួរសេចក្ដីផ្សេងៗ ជាមួយនឹងសាវ័កទាំងឡាយ ។ សាវ័កទាំងឡាយបានតបពន្យល់ ថែមទាំងប្រាប់ថា ព្រះសម្មាសម្ពុទ្ធកស្សបៈ ស្ដេចរំលត់ខន្ធបរិនិព្វានទៅហើយ ពួកអាមាត្យនិងបរិវារទាំងអស់ម្នាក់ៗ នាំគ្នាត្អូញត្អែររៀបរាប់ថា ពួកខ្ញុំព្រះករុណាទាំងឡាយ មកអំពីផ្លូវឆ្ងាយ មិនទាន់បានឃើញព្រះពុទ្ធអង្គផង ព្រះអង្គក៏រំលត់ខន្ធបរិនិព្វានទៅហើយ ក៏បានសួរថា មានព្រះពុទ្ធោវាទណាៗ ខ្លះ ដែលព្រះពុទ្ធទ្រង់សម្ដែងទុកដែរឬទេ សាវ័កទាំងនោះបានតបថា មានដែរ ដូចជាព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានឱវាទថា

បុគ្គលគួរតាំងនៅក្នុងព្រះត្រៃសរណគមន៍ រក្សាសីល ៥ គួរតែសមាទានឧបោសថសីល ដែលមានអង្គ ៨ ប្រការ គួរឲ្យទាន និងគួរបព្វជ្ជា ។ បុគ្គលទាំងនោះ បានស្ដាប់ពាក្យណែនាំរបស់សាវ័កទាំងនោះ

ហើយ ម្នាក់ៗ នាំគ្នាបព្វជ្ជាទាំងអស់ វៀរតែអាមាត្យដែលជាជំនិតរបស់ព្រះរាជាកជ្ជវាហនៈតែម្នាក់ប៉ុណ្ណោះ ។ អាមាត្យដែលជាជំនិតបានទៅកាន់យកបរិភោគធាតុ ( បានដល់ បាត្រ ចីវរ និងគ្រឿងប្រើប្រាស់របស់ព្រះពុទ្ធ រួមទាំងដើមពោធិព្រឹក្សផង ) នាំត្រឡប់ទៅកាន់ដែនកជ្ជវាហនៈ ។ អាមាត្យដែលជាជំនិតទៅ ថែមទាំងបានកាន់យកបំពង់តម្រងទឹក របស់ព្រះពុទ្ធ ទាំងបាននិមន្តភិក្ខុជាវិន័យធរ ត្រឡប់មកជាមួយផងដែរ កាលត្រឡប់មកដល់ដែនហើយ ទើបចូលទៅគាល់ ក្រាបបង្គំទូលព្រះរាជាថា ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោកពិតប្រាកដមែន ប៉ុន្តែព្រះអង្គបរិនិព្វានទៅហើយ ។ ចំណែកព្រះថេរៈបានសម្តែងធម៌ ឲ្យព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ធ្វើឲ្យព្រះរាជាទ្រង់កើតសេចក្តីជ្រះថ្លា ក៏បានឲ្យគេកសាងព្រះវិហារ កសាងព្រះចេតិយ ឲ្យដាំដើមពោធិ៍ និងទ្រង់ដល់ព្រះត្រៃសរណគមន៍ ជាទីពឹងទីរឭក ថែមទាំងរក្សាសីល ៥ និងសមាទានឧបោសថសីល ដែលប្រកបដោយអង្គ ៨ មានការបរិច្ចាគទាន រហូតដល់អស់ព្រះជន្មាយុរបស់ព្រះអង្គ ក្រោយអំពីព្រះអង្គសោយទិវង្គតទៅហើយ ក៏បានទៅកើតក្នុងទេវលោក ។ ចំណែកអាមាត្យ និងបរិវារ ១៦.០០០ នាក់ ដែលបានបព្វជ្ជានោះ កាលបើអស់ជីវិតទៅ បានទៅកើតក្នុងទេវលោករហូតដល់មួយពុទ្ធន្តរ ។ កាលព្រះពុទ្ធជាម្ចាស់នៃយើង ទ្រង់នៅមិនទាន់បានឧប្បត្តិឡើងក្នុងលោក បុគ្គលទាំងនោះដែលកើតក្នុងទេវលោក បានចុតិចាក

ទេវលោកមកកើតជាមនុស្សវិញ ។ ចំណែកអាចារ្យ ឬព្រះរាជាកដ្ឋវាហនៈ ត្រឡប់មកកើតជាបុត្ររបស់ព្រាហ្មណ៍បុរោហិត នៃព្រះរាជបិតារបស់ព្រះបាទបសេនទិកោសល ក្នុងក្រុងសាវត្ថី ដែនកោសល មានឈ្មោះថា **ពាវរី** ។ អាចារ្យពាវរី ជាអ្នកមានបុគ្គលិកលក្ខណៈរបស់មហាបុរស ៣ គឺ

**១- មានអណ្តាតវែងធំ អាចលៀនមកបិទមុខបាន ។**

**២- មានរោមពណ៌សទន់ល្មើរញ ដុះនៅត្រង់ចន្លោះចិញ្ចើម ។**

**៣- មានរបស់កំបាំងនៅក្នុងស្រោម ។**

ទាំងលោកជាអ្នករៀនចប់វិជ្ជាត្រៃវេទ តមក កាលបិតាស្លាប់ទៅហើយ លោកក៏បានទទួលតំណែងជាបុរោហិតជំនួសបិតា ។ ចំណែកសិស្សជាបរិវារ ១៦.០០០ នាក់ បានមកកើតនៅក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថីដូចគ្នា ។ ចំណែកសិស្សច្បងទាំង ១៦ នាក់ បានមកសិក្សាវិជ្ជាត្រៃវេទនៅក្នុងសម្នាក់ របស់អាចារ្យពាវរី សិស្ស ១៦.០០០ នាក់ បានមកជាកូនសិស្សច្បងទាំង ១៦ នាក់នោះឯង ។ កាលបើព្រះបាទបសេនទិកោសលស្តេចសោយទិវង្គតទៅហើយ ប្រជាជន និងពួកអាមាត្យរាជបរិវារ ព្រមព្រៀងគ្នាអភិសេកព្រះបាទបសេនទិកោសលរាជកុមារ ឲ្យស្នងរាជ្យជំនួសព្រះរាជបិតា ដោយទ្រង់មានព្រះនាមថា ព្រះបាទបសេនទិកោសល ។ អាចារ្យពាវរី ដែលបានទទួលតំណែងជាបុរោហិត កាលដែលព្រះបាទបសេនទិកោសលទ្រង់មានព្រះជន្មនៅឡើយ តំណែងនោះ

ក៏នៅដដែល ដូចជាព្រះរាជបិតាទ្រង់គង់នៅដែរ ប៉ុន្តែព្រះបាទបសេនទិកោសលនៅវ័យក្មេង ទ្រង់បានសិក្សាសិល្បសាស្ត្រក្នុងសម្នាក់ អាចារ្យពាវរីព្រាហ្មណ៍ ។ ក្រោយមក អាចារ្យពាវរីព្រាហ្មណ៍ បានក្រាបបង្គំទូលជាមួយនឹងព្រះរាជាថា ខ្ញុំព្រះអង្គមានបំណងនឹងបព្វជ្ជា ព្រះរាជាត្រាស់ហាមឃាត់ថា លោកអាចារ្យ កាលបើលោករស់នៅក្នុងទីនេះ ក៏ដូចគ្នានឹងព្រះរាជបិតា របស់ខ្ញុំរស់នៅដែរ សូមលោកអាចារ្យ កុំចេញបព្វជ្ជាឡើយ ។ អាចារ្យពាវរីព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រមហារាជ សូមព្រះអង្គកុំឃាត់ខ្ញុំឡើយ ខ្ញុំព្រះអង្គតាំងចិត្តថា នឹងចេញបព្វជ្ជាហើយ ។ កាលបើព្រះបាទបសេនទិកោសល ទ្រង់មិនអាចឃាត់បាន ទើបត្រាស់ថា សូមលោកអាចារ្យបព្វជ្ជា នៅក្នុងព្រះរាជឧទ្យាន ដើម្បីឲ្យខ្ញុំបានឃើញទាំងពេលព្រឹក និងពេលល្ងាចផង ចំណែកសិស្ស ១៦ នាក់ ជាមួយនឹងសិស្ស ១៦.០០០ នាក់ ក្រោយពីបព្វជ្ជាហើយ ក៏សូមឲ្យស្នាក់នៅក្នុងព្រះរាជឧទ្យានដូចគ្នាដែរ ។ អាចារ្យពាវរីព្រាហ្មណ៍ ជាមួយនឹងកូនសិស្សច្បង ១៦ នាក់ ព្រមដោយសិស្សរបស់សិស្សច្បងទាំងអស់ ១៦.០០០ នាក់ កាលបព្វជ្ជជាតាបសហើយ បានទៅស្នាក់អាស្រ័យនៅក្នុងព្រះរាជឧទ្យាន តាមព្រះរាជបំណងរបស់ព្រះរាជា ។

ព្រះរាជាទ្រង់ទំនុកបម្រុងដោយបច្ច័យ ៤ និងស្តេចយាងទៅរកទាំងពេលព្រឹក ទាំងពេលល្ងាច ។ នៅថ្ងៃមួយ បណ្តាសិស្សទាំងអស់

បានប្រាប់ដល់អាចារ្យពាវរីព្រាហ្មណ៍ថា ការរស់នៅជិតស្រុក រមែងធ្វើឲ្យមានកង្វល់ច្រើនណាស់ ពួកខ្ញុំនឹងនាំគ្នាទៅនៅក្នុងទី ដែលប្រាសចាកមនុស្សអ៊ូអរ កាលនៅក្នុងសេនាសនៈស្ងាត់ រមែងជាប្រយោជន៍ ដល់បព្វជិតទាំងឡាយ ។ អាចារ្យពាវរីព្រាហ្មណ៍ពោលថា ល្អណាស់ យើងនឹងទៅដែរ ហើយទើបថ្វាយបង្គំលាព្រះបាទបសេនទិកោសល ។ ព្រះបាទបសេនទិកោសលទ្រង់ជ្រាប បានត្រាស់ហាមឃាត់រហូត ៣ ដង ប៉ុន្តែទ្រង់មិនអាចឃាត់បាន ក៏បានព្រះរាជទានទ្រព្យ ២ សែនកហាបណៈ ទាំងត្រាស់បញ្ជាប្រាប់ពួកអាមាត្យថា លោកអាចារ្យមានបំណង នឹងរស់នៅទីណា ចូរពួកលោកកសាងអាស្រមថ្វាយក្នុងទីនោះ ។ អាចារ្យពាវរីជាមួយនឹងពួកកូនសិស្សទាំងអស់ ដោយមានពួកអាមាត្យរង់ចាំទៅតាមជាមួយផងដែរ បាននាំគ្នាចេញចាក **ឧត្តរជនបទ** គឺស្រុកក្រុង ទិសខាងជើងបុរីអ្នកកោសល បែរមុខឆ្ពោះទៅកាន់ទក្ខិណាជនបទ ស្រុកក្រុង ទិសខាងត្បូង រហូតទៅដល់ក្បែរប្រាំងនៃ **ស្ទឹងគោធាវរី** កាលបានឃើញបរិវេណប្រាំងនៃស្ទឹងគោធាវរី ជាទីដ៏សមរម្យដល់បព្វជិត ទើបប្រាប់ដល់ពួកអាមាត្យបានជ្រាប ។ មួយទៀត ទីស្ទឹងគោធាវរីនេះ សម័យមុនធ្លាប់ជាទីលំនៅរបស់តាបសទាំងឡាយមានសរភង្គតាបសជាដើម ស្ទឹងគោធាវរីនោះ បានបែកចេញជាពីរដៃ មានកោះទូលំទូលាយប្រមាណ ៣ យោជន៍ នៅលើកោះសម្បូណ៌ទៅដោយដើមខ្វិត អាចារ្យពាវរីយល់ឃើញថា ជា

ទីដ៏សមរម្យដល់សមណធម៌ ទើបប្រាប់បំណងដល់ពួកអាមាត្យ ដែលព្រះបាទបសេនទិកោសលទ្រង់បញ្ជូនមក ។ ពួកអាមាត្យនាំគ្នាយកប្រាក់មួយសែនកហាបណៈទៅថ្វាយដល់ **ព្រះបាទអស្សកៈ** ដែលជាព្រះរាជាក្នុងដែននោះ និងមួយសែនទៀតថ្វាយដល់ **ព្រះបាទមូឡកៈ** ដែលជាព្រះរាជានៅក្នុង **ក្រុងមាហិស្សតី** ក្នុង **ដែនមូឡកៈ** ដើម្បីសុំទិញដីក្នុងបរិវេណនោះ ។ ទីកន្លែងដីនោះ តាំងនៅព្រំដែនរបស់ព្រះរាជាទាំងពីរព្រះអង្គ ទ្រង់ព្រះរាជទានទីឲ្យមួយព្រះអង្គពីរយោជន៍ រួមជាផ្ទៃដីទាំងអស់ ៤ យោជន៍ ។ ពួកអាមាត្យរៀបចំការកសាងអាស្រមឡើងនៅក្នុងផ្ទៃដីទាំងនោះ ហើយឲ្យនាំយកទ្រព្យមួយចំនួនទៀត មកពី **ក្រុងសាវត្ថី** ដើម្បីយកមកប្រើប្រាស់ជាតម្លៃកសាងអាស្រម ឲ្យជាទីគោចរគ្រាមនៃពួកតាបសទាំងនោះ ។

រឿងក្នុងវគ្គតទៅនេះ ក្រៅអំពីដែលមានប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** និង **អដ្ឋកថាមនោរថបូរណី** នៅមានសេចក្តីពោលទុកក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** និងក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ**ទៀត ដូចមានសេចក្តីថា ៖

អាចារ្យពាវរីព្រាហ្មណ៍ ព្រមដោយបរិវារ បានអាស្រ័យនៅក្នុងស្រុកនោះ ជាទីគោចរភិក្ខាចារ និងមានការត្រាច់ស្វែងរកផ្លែឈើមកចិញ្ចឹមជីវិត ។ ពួកអ្នកស្រុកទាំងនោះ ម្នាក់ៗ មានការប្រកបការងារ មានកសិកម្មជាដើម ធ្វើឲ្យមានតម្លៃស្បៀងសារអាករកើតឡើង ពីអ្នកស្រុកមួយ

ឆ្នាំៗ ប្រមាណមួយសែនកហាបណៈ ពួកអ្នកស្រុកនាំគ្នាឡើងទូលថ្វាយដល់ព្រះបាទអស្សកៈ ប៉ុន្តែព្រះអង្គទ្រង់មិនទទួល ត្រឡប់ត្រាស់បញ្ជាថា ចូរពួកអ្នកនាំទៅជូនដល់អាចារ្យពាវរីព្រាហ្មណ៍ចុះ ពួកអ្នកស្រុកទាំងនោះក៏បានធ្វើតាមព្រះតម្រាស់របស់ព្រះរាជា កាលបើអាចារ្យពាវរី បានទទួលសួយសារអាករនោះគ្រប់ចំនួនហើយ លោកក៏មិនទុកដើម្បីប្រយោជន៍ខ្លួនឯងទេ គឺទុកដើម្បីឲ្យទានជារៀងប្រចាំឆ្នាំ រហូតធ្វើឲ្យដំណឹងនោះ ផ្សព្វផ្សាយទូទាំងជម្ពូទ្វីបថា អាចារ្យពាវរីព្រាហ្មណ៍បានធ្វើមហាយញ្ញ ដោយការឲ្យទាន ។ កាលបើអាចារ្យពាវរីព្រាហ្មណ៍ ឲ្យទានរួចស្រេចក្នុងមួយឆ្នាំៗ ហើយ បានចេញចាកស្រុកត្រឡប់ទៅកាន់អាស្រម កាលទៅដល់អាស្រម ក៏ចូលទៅអង្គុយពិចារណាដល់ទានរបស់ខ្លួន សារចុះសារឡើងថា យើងបានឲ្យទានជាការល្អណាស់ ។ គ្រានោះ មាននាងព្រាហ្មណី ដែលជាភរិយា របស់ព្រាហ្មណ៍ចាស់ជរាម្នាក់ ដែលកើតក្នុងត្រកូលវង្សរបស់តាជូជកដែលនៅក្នុង **ស្រុកទុន្នវិដ្ឋគ្រាម** ក្នុង **ដែនកលិង្គរដ្ឋ** នាងបានជ្រាបដំណឹងការបរិច្ចាគទានរបស់អាចារ្យពាវរីព្រាហ្មណ៍ហើយ ទើបបានពោលជាមួយព្រាហ្មណ៍ដែលជាស្វាមីថា បានឮថា អាចារ្យពាវរីព្រាហ្មណ៍បានលះបង់ទ្រព្យបរិច្ចាគទានមួយឆ្នាំៗ ប្រមាណមួយសែនកហាបណៈ នៅក្បែរប្រាំងស្ទឹងគោធាវរី ចូរលោកទៅសូមត្រឹមតែប្រាំរយកហាបណៈមកចុះ ។ ព្រាហ្មណ៍ជរា ដែលមានជើងពិការ ធ្មេញបាក់ ទាំងមានសិរសា

ប្រឡាក់ធូលី ដែលត្រូវនាងព្រាហ្មណីជាកិរិយាក្មេងគិតអាក្រក់ ពេលដែលប្តីមិននៅ មានបុរសដទៃ ពេលដែលនាងប្រើដូច្នេះហើយ ទើបធ្វើដំណើរទៅរហូតដល់ដើរពេញជើង បានធ្វើដំណើរទៅដល់សម្នាក់អាចារ្យពាវរី ក្នុងពេលដែលអាចារ្យពាវរីព្រាហ្មណ៍បរិច្ចាគទាន រួចជាស្រេចរៀបរយហើយ ដែលកំពុងតែអង្គុយពិចារណាដល់ទានរបស់ខ្លួន នៅនាបណ្ណសាលានោះ ។

កាលបើអាចារ្យពាវរី បានក្រឡេកឃើញព្រាហ្មណ៍ចាស់ជរាដើរចូលមក ទើបអញ្ជើញឲ្យអង្គុយ និងសួរដល់សេចក្តីសុខសប្បាយ ប៉ុន្តែព្រាហ្មណ៍ជរានោះ បានពោលថា ខ្ញុំមកសូមទ្រព្យប្រាំរយកហាបណៈពីអ្នក ។ អាចារ្យពាវរីព្រាហ្មណ៍បានប្រាប់ថា យើងបានឲ្យទានអស់ទៅហើយ យើងមិនមានទ្រព្យឲ្យទៀតទេ ។ ព្រាហ្មណ៍ជរាបានពោលឡើងដោយការមិនពេញចិត្តថា ប្រសិនបើលោកមិនឲ្យដល់ខ្ញុំទេ សិរសារបស់លោកនឹងត្រូវបែកជាប្រាំពីរភាគ ក្រោយពីគេនិយាយបំភ័យហើយ ទើបគិតធ្វើវិធីបញ្ឆោតឡើង ដោយទៅប្រមូលយកអាចម៍គោស្រស់ ផ្កាឈើ ស្បូវជាដើម មករៀបចំលាបផ្ទៃទ្វារអាស្រមរបស់អាចារ្យពាវរីព្រាហ្មណ៍ ដោយយកអាចម៍គោស្រស់ រោយផ្កាឈើ ក្រាលស្បូវ ហើយលើកជើងខាងឆ្វេងឡើង ស្រោចដោយទឹកក្នុងឃ្នោករួចស្រេចហើយ ថយចេញទៅឈរចម្ងាយប្រមាណប្រាំពីរជំហាន យកដៃស្ទាបខ្នងជើងរបស់ខ្លួន ធ្វើជាឧបាយកលបញ្ឆោត ថែមទាំងពោលថា ប្រសិនបើអ្នកមិនមានទ្រព្យឲ្យយើងទេ

សិរសារបស់អ្នក នឹងត្រូវបែកជាប្រាំពីរភាគ ក្នុងប្រាំពីរថ្ងៃខាងមុខទៀតនេះ ។ អាចារ្យពាវរីបានឃើញពិធី និងស្ដាប់សម្ដីរបស់ព្រាហ្មណ៍ជរាហើយ យល់ថាជាការពិត ទើបកើតទុក្ខ រហូតដល់សៅហ្មងចិត្ត មានរាងកាយស្គមស្លេកស្លាំង ព្រោះបរិភោគអាហារមិនបាន ក្នុងខណៈដែលពាវរីព្រាហ្មណ៍កើតទុក្ខនោះ ចិត្តក៏មិនត្រេកអរក្នុងឈាន ។

ក្នុងពេលនោះ មានទេវតាមួយអង្គ ដែលអាស្រ័យនៅក្នុងអាស្រមរបស់អាចារ្យពាវរីព្រាហ្មណ៍នោះ ជាអ្នកមានបំណងល្អ ដោយឃើញការភ័យខ្លាចរបស់អាចារ្យពាវរី ទើបចូលទៅរក ហើយប្រាប់អាចារ្យពាវរីថាព្រាហ្មណ៍ជរានោះមិនស្គាល់ក្បាល ប៉ុន្តែគេធ្វើឧបាយកលបញ្ឆោត ដើម្បីត្រូវការទ្រព្យតែប៉ុណ្ណោះ គេមិនស្គាល់អ្វីជាក្បាលទេ ធម៌អ្វីដែលធ្វើឲ្យក្បាលបែកនោះក៏គេមិនដឹងដែរ ។ ទើបអាចារ្យពាវរីសួរថា ប្រសិនបើយ៉ាងនេះ តើនរណាជាអ្នកដឹងក្នុងរឿងនេះ សូមលោកប្រាប់ដល់ខ្ញុំផងចុះ ។ ទេវតាតបថា សូម្បីខ្ញុំក៏មិនដឹងក្នុងរឿងដែលធ្វើឲ្យក្បាលបែក ឬធ្លាក់ចុះនោះដែរ ដែលអាចដឹងទៅបាននោះ មានតែព្រះភគវា ព្រះអង្គមាននូវបញ្ញាចក្ខុ ចូរលោកទៅក្រាបបង្គំទូលសួរព្រះលោកនាយកចុះ ។ អាចារ្យពាវរីបានស្ដាប់ពាក្យថា ព្រះពុទ្ធ ក៏មានចិត្តរីករាយសប្បាយឡើង បានសួរទេវតាថា ព្រះជិនស្រីទ្រង់គង់នៅក្នុងទីណា ? ទេវតាក៏ប្រាប់ថា ព្រះអង្គទ្រង់គង់នៅក្រុងសាវត្ថី ។ អាចារ្យពាវរី បានហៅតាបសទាំងឡាយ

ដែលជាកូនសិស្សមកថា ចូរអ្នកទាំងអស់គ្នាស្តាប់សម្តីខ្ញុំ ការប្រាកដឡើង ក្នុងលោករបស់អ្នករកបានដោយកម្រ ថ្ងៃនេះ យើងបានជ្រាបហើយ ថា លោកអ្នកនោះ ព្រះនាមថា ព្រះពុទ្ធ ចូរពួកអ្នកប្រញាប់ទៅកាន់ក្រុង សាវត្ថី ទៅមើលព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ។

ពួកកូនសិស្សសួរថា បពិត្រលោកអាចារ្យ ធ្វើយ៉ាងណា ទើប អាចដឹងបានថាជា **ព្រះពុទ្ធ** សូមលោកអាចារ្យប្រាប់ចំណុចពិសេសដល់ ខ្ញុំផងចុះ ? ពាវរីព្រាហ្មណ៍ក៏ប្រាប់ថា ជាអ្នកប្រកបមហាបុរិសលក្ខណៈ ៣២ ប្រការ បុគ្គលនោះ រមែងមានគតិពីរតែប៉ុណ្ណោះ គឺ ៖

១ ប្រសិនបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ មានមហា សមុទ្រទាំង ៤ ជាព្រំដែន ទ្រង់គ្រប់គ្រងផែនដីប្រកបដោយធម៌ ថែម ទាំងគ្មានការប្រើអាជ្ញា និងសស្ត្រាឡើយ ។

២ ប្រសិនបើបុគ្គលនោះ ចេញទៅបព្វជ្ជា នឹងបានសម្រេចជាព្រះ សម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដឹងដោយប្រពៃ ជាសាស្តាឯកក្នុងលោក ។

កាលបើអ្នកទាំងឡាយបានជួបហើយ ចូរនឹកដល់លក្ខណៈពិសេស យ៉ាងនេះ ហើយទូលសួរដល់ជាតិ ត្រកូល រូបស្រេចហើយ គប្បីសួរ បញ្ហារបស់យើងផងថា អ្វីជាក្បាល មានធម៌អ្វីដែលធ្វើឲ្យក្បាលបែក ឬ ធ្លាក់ចុះ ។ មាណពដែលជាកូនសិស្ស របស់អាចារ្យពាវរីព្រាហ្មណ៍ទាំង ១៦ នាក់នោះ ជាអ្នកបានសន្សំបុណ្យកុសលបារមីរួចមកហើយ គ្រប់ៗ

គ្នា ។ មាណពសិស្សច្បងទាំង ១៦ នាក់ ដែលទ្រទ្រង់នូវជដា និងជណ្ដប់ស្បែកខ្លា បានស្ដាប់ពាក្យរបស់ពាវរីព្រាហ្មណ៍ហើយ ព្រមគ្នាក្រាបសំពះលាអាចារ្យ ធ្វើប្រទក្សិណ គឺដើរវិលជុំវិញខាងស្ដាំអាចារ្យពាវរីព្រាហ្មណ៍ដោយសេចក្ដីគោរព ហើយទើបនាំគ្នាចេញ ធ្វើដំណើរបែរមុខឆ្ពោះទៅតាមផ្លូវទិសឧត្តរ ។ មុនចេញដំណើរ បណ្ដាសិស្សរបស់អាចារ្យពាវរីដែលបួសជាតាបស ឬដែលហៅថាជដិលនោះ មានទាំងអស់មួយម៉ឺនប្រាំមួយពាន់នាក់ បានសម្រេចចិត្តនឹងទៅរកព្រះបរមសាស្ដា រួមសិស្សច្បងដប់ប្រាំមួយនាក់ ក្នុងម្នាក់ៗ មានបរិវារមួយពាន់នាក់ បាននាំគ្នាធ្វើដំណើរចេញទៅ ។ ក្នុងពេលដែលពួកមាណពកំពុងធ្វើដំណើរទៅនោះមានគេសួរថា លោកម្ចាស់ទាំងឡាយនាំគ្នាទៅណា ពួកយើងនាំគ្នាទៅទូលសួរបញ្ហាចំពោះព្រះវិជិតមារ មានការពោលតបយ៉ាងនេះ ទៅតាមផ្លូវរហូតច្រើនរយយោជន៍ទៀតផង ។

កាលបើសិស្សច្បងដប់ប្រាំមួយនាក់ ដែលជាកូនសិស្សរបស់ពាវរីព្រាហ្មណ៍ ព្រមដោយមាណពជាបរិវារមួយម៉ឺនប្រាំមួយពាន់នាក់ បានរួមដំណើរទៅដើម្បីចូលគាល់ព្រះសម្ពុទ្ធ ។ ក្នុងពេលនោះ ព្រះភគវាទ្រង់ជ្រាបជាមុនថា ពួកមាណពទាំងនោះ នឹងនាំគ្នាមកក្នុងទីនេះ ប៉ុន្តែថាឥន្ទ្រិយរបស់ពួកគេនៅមិនទាន់ចាស់ក្លា ទាំងទីនេះក៏មិនជាទីសប្បាយដល់ពួកគេ ចំណែកបាសាណកចេតិយ ក្នុងដែនមគធៈ ទើបជាទីសប្បាយ

ដល់ពួកគេ កាលបើតថាគតសម្ដែងធម៌ក្នុងទីនោះ ការបានសម្រេចមគ្គផលនឹងមានដល់មហាជន បើតថាគតធ្វើដំណើរឆ្វេងកាត់ក្រុងទាំងពួងទៅនឹងមានមហាជនធ្វើដំណើរទៅតាមជាច្រើន ទ្រង់ពិចារណាឃើញដូច្នេះហើយ ទើបព្រមដោយភិក្ខុសង្ឃស្ដេចចេញចាកក្រុងសាវត្ថី ទ្រង់បែរព្រះភក្ត្រឆ្ពោះទៅកាន់ក្រុងរាជគ្រឹះ ។ ចំណែកសិស្សទាំងឡាយរបស់អាចារ្យពាវរីព្រាហ្មណ៍ កាលធ្វើដំណើរទៅដល់ក្រុងសាវត្ថីហើយ ទើបនាំគ្នាចូលទៅកាន់វិហារដើម្បីស្វែងរកព្រះពុទ្ធ តើព្រះអង្គទ្រង់គង់ប្រថាប់ក្នុងទីណា ប៉ុន្តែបានជួបតែស្នាមព្រះបាទប៉ុណ្ណោះ ទើបពិចារណាមើលថា

ធម្មតាស្នាមបាតជើងរបស់បុគ្គលអ្នកមានរាគៈ រមែងផតកណ្ដាលបាតជើង, ស្នាមបាតជើងនៃបុគ្គលអ្នកមានទោសៈ រមែងធូនខាងចុងម្រាមជើង, ស្នាមបាតជើងនៃបុគ្គលអ្នកមានមោហៈ រមែងធូនត្រង់កែងជើង ។

ចំណែកស្នាមជើងនេះ ជាស្នាមជើងរបស់បុគ្គលអ្នកមិនមានកិលេសគឺរាគៈ ទោសៈ មោហៈ អ្នកនេះប្រាកដជាព្រះសព្វញ្ញុពុទ្ធ ទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឯងយ៉ាងពិតប្រាកដ ។ កាលព្រះពុទ្ធស្ដេចនិមន្តឆ្វេងកាត់ក្រុងផ្សេងៗ មានក្រុងសេតព្យៈ និងក្រុងកបិលពស្តុជាដើម ទៅដោយលំដាប់ មានមហាជនធ្វើដំណើរទៅតាមជាច្រើនរហូតទៅដល់បាសាណកចេតិយ ព្រះអង្គក៏យាងចូលទៅគង់ប្រថាប់ក្នុងមហាមណ្ឌល ដែលសក្កទេវរាជ ទ្រង់និម្មិតថ្វាយត្រង់កន្លែងបាសាណក

ចេតិយនោះ ។ បាសាណកចេតិយ កាលពីមុនជាទេវស្ថាន គឺជាទីតាំងនៃពួកទេពារក្ស ដែលតាំងនៅខាងលើផ្ទាំងសិលាដ៏ធំ ប៉ុន្តែសម័យដែលព្រះវិជិតមារទ្រង់ត្រាស់ដឹងក្នុងលោកហើយ ទីនោះក្លាយជាវិហារ និងមានឈ្មោះតាមនាមដើមថា **បាសាណកចេតិយ** ។ ពួកមាណពទាំងអស់បានដឹងថា ព្រះអង្គទ្រង់គង់នៅក្នុងបាសាណកចេតិយ ទើបនាំគ្នាធ្វើដំណើរឆ្លងកាត់ក្រុងផ្សេងៗ ទៅទៀត គឺ **ក្រុងមាហិស្សតី ជាក្រុងដំបូងហើយ ទៅដល់ក្រុងឧជ្ជេនី ក្រុងគោនទ្ធៈ ក្រុងវេទិសៈ ក្រុងកោសម្ពី ក្រុងសាកេត ក្រុងសាវត្ថី ក្រុងសេតព្យៈ ក្រុងកបិលពស្តុ ក្រុងកុសិនារា ក្រុងបាវា ក្រុងភោគៈ ក្រុងវេសាលី ក្រុងមគធៈ ទើបទៅដល់ក្រុងបាសាណកចេតិយ** ដែលជាទីគួរត្រេកអររីករាយ ។ ពួកមាណពទាំងនោះ ម្នាក់ៗ នាំគ្នាប្រញាប់ប្រញាល់ចូលទៅរកបាសាណកចេតិយ ដោយសេចក្តីត្រេកអរយ៉ាងក្រៃលែង ដូចបុគ្គលកំពុងស្រេកទឹក បានជួបនូវទឹកដ៏ថ្លាត្រជាក់ មានសេចក្តីត្រេកអរ ឬដូចបុគ្គលដែលកំពុងធ្វើដំណើរ ផ្លូវឆ្ងាយក្តៅហែង បានចូលទៅសម្រាកកាយក្រោមម្លប់ដ៏ត្រជាក់ ដូច្នេះ ជាដើម ។ ក្នុងពេលដែលពួកមាណពទាំងនោះ បានទៅដល់បាសាណកចេតិយហើយ ពេលនោះ ព្រះសយម្ភូទ្រង់បរិបូណ៌ដោយគុណរាប់ប្រមាណមិនបាន មានភិក្ខុសង្ឃគង់ចោមរោមព័ទ្ធជុំវិញ ព្រះអង្គកំពុងតែសម្តែងធម៌ ដល់ភិក្ខុទាំងឡាយដោយអាការៈដ៏អង់អាច ដូចគ្នានឹងរាជសីហ៍ ដែលបន្លឺសំឡេងនៅ

ក្នុងព្រៃដូច្នោះដែរ ។

អជិតមាណពដែលជាប្រធាន រួមដោយប្រធាន ១៥ នាក់ទៀត ដែលមានមោឃរាជមាណពម្នាក់ដែរ នៅក្នុងចំណោមនោះ បាននាំបរិវារទាំងអស់ចូលទៅគាល់ព្រះលោកនាយក នៅត្រង់ផ្ទាំងសិលាបាសាណកចេតិយ កាលក្រឡេកឃើញភាពសម្បូណ៌ដោយមហាបុរិសលក្ខណៈ នៃព្រះសរីរៈរបស់ព្រះមានជោគ ទ្រង់មានព្រះរស្មីដូចដួងនៃព្រះអាទិត្យដែលប្រាសចាកពពកបាំង ឬដូចព្រះច័ន្ទក្នុងថ្ងៃ ១៥ កើត ធ្វើឲ្យប្រាកដក្នុងចិត្តថាអ្នកនេះជាព្រះសម្មាសម្ពុទ្ធយ៉ាងពិតប្រាកដ ទើបមានចិត្តត្រេកអររីករាយនឹកសួរបញ្ហាឡើងដោយចិត្ត តាមដែលពាវរីព្រាហ្មណ៍ប្រៀនប្រដៅមក ។ ក្នុងថ្ងៃនេះ មានមហាជនជាច្រើន មករួមប្រជុំគ្នានៅត្រង់បាសាណកចេតិយដែលមានទីប្រមាណ ១២ យោជន៍ ។ ដោយមានមោឃរាជមាណពដែលនៅក្នុងចំណោមប្រធាន ១៦ នាក់នោះដែរ លោកជាអ្នកមានភាពរឹងត្អឹងដោយមានះ គឺប្រកាន់ខ្លួនថា យើងជាបណ្ឌិត ជាអ្នកប្រសើរជាងអន្តេវាសិកទាំងពួង មោឃរាជនេះឧបនិស្ស័យនៅមិនទាន់ចាស់ក្លា លោកមានបំណងនឹងសួរបញ្ហាមុនគេ តែពិចារណាឃើញថា អជិតមាណពជាសិស្សច្បង និងជាប្រធានគណៈផង ជាការមិនសមរម្យទេ នឹកអៀនខ្មាសចំពោះអជិតមាណព ទើបមិនក្រាបបង្គំទូលសួរបញ្ហាមុនគេ សុខចិត្តព្រមឲ្យអជិតមាណពសួរមុនចុះ ហើយលោកមានបំណងនឹងទូលសួរបញ្ហា

បន្ទាប់អំពីអជិតមាណពមក ក្នុងពេលដែលព្រះអង្គទ្រង់ព្យាករបញ្ហាអជិតមាណពចប់ហើយ ។ ប៉ុន្តែខណៈដែលមោឃរាជមាណព តាំងចិត្តទូលសួរបញ្ហានោះ ព្រះភគវា ទ្រង់ត្រិះរិះថា តថាគតគួរទម្លាក់មានះរបស់គេជាមុនសិន ទើបទ្រង់ត្រាស់ហាមថា នែមោឃរាជ ចូរអ្នកឈប់សិន រង់ចាំឲ្យមាណពដទៃៗ សួរសិន ។ មោឃរាជ គេក៏អង្គុយនៅស្ងៀម បើកឱកាសឲ្យដល់ពួកមាណពដទៃក្រាបបង្គំទូលសួរមុន ។

កាលបើមាណពដទៃក្រាបបង្គំទូលសួរ តាមលំដាប់ដល់លេខរៀងទី ៨ ចប់ហើយ មោឃរាជដែលជាលេខរៀងទី ៩ បានក្រោកឡើង ប៉ុន្តែព្រះបរមសាស្តាទ្រង់ត្រាស់ហាមទៀត មោឃរាជអ្នកចូរអង្គុយស្ងៀមសិនចុះ ដោយគេគិតថា ឥឡូវនេះ ដល់លេខរៀងយើងទី ៩ ត្រូវរង់ចាំឲ្យមាណពដទៃៗ ក្រាបទូលសួររហូតដល់លេខរៀងទី ១៤ ចប់ហើយ មកដល់លេខរៀងទី ១៥ ។ កាលដែលព្រះសម្ពុទ្ធទ្រង់ជ្រាបថា មោឃរាជមានញាណចាស់ក្លាហើយ ទើបទ្រង់អនុញ្ញាតឲ្យសួរបញ្ហា មោឃរាជបានក្រាបទូលសួរបញ្ហាថា បពិត្រព្រះអង្គជាសក្កៈ ព្រះអង្គមាននូវពុទ្ធចក្ខុ ខ្ញុំព្រះអង្គ បានក្រាបបង្គំទូលសួរពីរដងមកហើយ ប៉ុន្តែព្រះអង្គមិនព្រមអនុញ្ញាតឲ្យទេ នេះជាវារៈទី ១៥ ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរបញ្ហាដូចតទៅនេះថា ៖

បពិត្រព្រះសុគតសាស្តា តើបុគ្គលពិចារណាឃើញដូចម្តេច ទើប

មច្ចុរាជរកមើលមិនឃើញ ? ព្រះជិនស្រីទ្រង់ព្យាករថា ម្នាលមោឃរាជ ចូរអ្នកមានស្មារតីគ្រប់កាល សម្លឹងឃើញលោកដោយសភាពជារបស់សូន្យ ព្រោះបុគ្គលដកអត្តានុទិដ្ឋិចេញ ទើបឆ្លងផុតចាកមច្ចុ បុគ្គលសម្លឹងឃើញលោកយ៉ាងនេះ ទើបមច្ចុរាជរកមិនឃើញ ។

សូមអធិប្បាយតាមនិទ្ទេស ពាក្យដែលមោឃរាជបានពោលថា សក្កៈ សំដៅដល់ព្រះមានព្រះភាគ ទ្រង់ចេញចាកសក្យត្រកូល ដើម្បីសាងផ្នួស ឬសំដៅដល់ការដែលព្រះអង្គ ទ្រង់មាននូវអរិយទ្រព្យ ន័យមួយវិញទៀត សំដៅដល់ទ្រង់អង់អាច ញ៉ាំងនូវភាពក្លៀវក្លាឲ្យកើតឡើងក្នុងសន្តានរបស់ពួកមហាជនដទៃ ។ ចំណែកពាក្យថា ព្រះអង្គមាននូវពុទ្ធចក្ខុនោះ គឺព្រះសម្ពុទ្ធទ្រង់មាននូវពុទ្ធចក្ខុ ៥ ប្រការគឺ **១. មំសចក្ខុ ២. ទិព្វចក្ខុ ៣. បញ្ញាចក្ខុ ៤. ពុទ្ធចក្ខុ ៥. សមន្តចក្ខុ** ។

***មំសចក្ខុរបស់ព្រះលោកនាថ*** មាន ៥ ពណ៌ គឺ ១. ខៀវ ២. លឿង ៣. ក្រហម ៤. ខ្មៅ ៥. ស ។

***ទិព្វចក្ខុរបស់ព្រះសយម្ភូ*** បរិសុទ្ធក្រៃលែងជាងចក្ខុមនុស្សធម្មតា ទ្រង់អាចមើលឃើញសត្វលោកទាំងពួងបាន ទាំងសេចក្តីស្លាប់ ឬកើត អាក្រក់ ឬល្អ ថោកទាប ឬប្រណីត ដែលមានគតិល្អ ឬមិនល្អ និងត្រូវបានទទួលផលកម្មផ្សេងៗ គ្រប់ជំពូកបាន ។

***បញ្ញាចក្ខុ*** គឺព្រះអង្គទ្រង់មានបញ្ញាច្រើន មានបញ្ញាក្រាស់ ទ្រង់

ដឹងទាន់នូវធម៌ទាំងពួងដែលជាអតីត អនាគត បច្ចុប្បន្ន មិនមានអ្នកណាប្រៀបផ្ទឹមបាន ទ្រង់ជាអ្នកចង្អុលប្រាប់ផ្លូវដល់បុគ្គលដែលវង្វេងផ្លូវ ។

**ពុទ្ធចក្ខុ** គឺកាលព្រះអង្គទ្រង់ទតមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វលោកទាំងឡាយ មានធូលីតិច ឬច្រើន មានឥន្ទ្រិយចាស់ក្លា ឬទន់ខ្សោយ ល្អ ឬអាក្រក់ ជាអ្នកត្រាស់ដឹងបានងាយ ឬលំបាក ដូចបុគ្គលឈរនៅលើកំពូលភ្នំ រមែងមើលឃើញពួកមហាជនដែលនៅខាងក្រោមយ៉ាងណា ព្រះជិនស្រីទ្រង់មើលឃើញសត្វលោកក៏ដូច្នោះដែរ ។

**សមន្តចក្ខុរបស់ព្រះមានជោគ** បានដល់ ទ្រង់មើលដោយជុំវិញ សំដៅដល់សព្វញ្ញុតញ្ញាណ គឺទ្រង់ដឹងសព្វគ្រប់ ។

ក្នុងពាក្យថា លោកនេះ បានដល់ មនុស្សលោក ចំណែកលោកដទៃ វៀរលែងមនុស្សចេញហើយ ក្រៅអំពីនេះ ហៅថា លោកដទៃ ។

ពាក្យថា **លោក** សំដៅដល់ សភាពដែលមានការបែកធ្លាយ ។

ពាក្យថា **មិនដឹងការយល់របស់ព្រះអង្គ** គឺមិនដឹងថា ព្រះអង្គទ្រង់យល់យ៉ាងណា មានសេចក្តីពេញចិត្តយ៉ាងណា មានលទ្ធិយ៉ាងណា មានអារម្មណ៍យ៉ាងណា មានបំណងយ៉ាងណា ។ សេចក្តីដែលព្រះភគវាទ្រង់ត្រាស់ថា ចូរពិចារណាឃើញលោកនេះថា ជារបស់សោះសូន្យទទេនោះ គឺបុគ្គលរមែងមិនមានអំណាចអ្វីក្នុងរូប វេទនា សញ្ញា សង្ខារ

វិញ្ញាណ សមដូចព្រះពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអនត្តា គឺមិនមែនតួខ្លួន ព្រោះបើរូបជាដើមជាអត្តា បុគ្គលក៏អាចបង្គាប់បានតាមចិត្តថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណរបស់យើង ចូរជាយ៉ាងនេះ កុំជាយ៉ាងនោះ ប៉ុន្តែព្រោះវត្ថុទាំងនេះជាអនត្តា ទើបមានជំងឺកើតឡើង បុគ្គលទើបបង្គាប់មិនបានតាមការពេញចិត្ត ។ ពាក្យថា **ចូរអ្នកមានសតិសព្វកាល** គឺឲ្យមានសតិនៅក្នុងសតិប្បដ្ឋាន ៤ មានការពិចារណាកាយ វេទនា ចិត្ត ធម៌ ឬបានដល់ការរឭកចំពោះព្រះពុទ្ធជាម្ចាស់ ព្រះធម៌ ព្រះសង្ឃ សីល ទាន គុណធម៌របស់ទេវតា ខ្យល់ដកដង្ហើមចេញចូល និងការរឭកដល់សេចក្ដីស្លាប់ ។

ពាក្យថា **ចូរដកសក្កាយទិដ្ឋិ** បានដល់ការឃើញថា ខ្លួនរបស់យើង ២០ ប្រការ ។ ពាក្យថាដកនោះ គឺលះចោល កម្ចាត់ចោល ធ្វើឲ្យអស់ទៅ ធ្វើមិនឲ្យមាននៅ ក្នុងពេលទីបំផុតនៃការដោះស្រាយបញ្ហា មោឃរាជព្រមទាំងជដិលមួយពាន់នាក់ ដែលជាបរិវាររបស់លោកបានសម្រេចព្រះអរហត្តផលមុនឧបសម្បទា និងជដិលទាំងនោះអស់អាសវក្កិលេស វៀរតែបិង្គិយមាណព ដែលរវល់តែគិតដល់អាចារ្យពាវរីព្រាហ្មណ៍ ទើបបានត្រឹមតែព្រះអនាគាមីប៉ុណ្ណោះ ។

មាណពទាំង ១៦ នាក់ ព្រមទាំងបរិវារ ទូលសូមឧបសម្បទា ព្រះអង្គអនុញ្ញាតដោយភាពជាឯហិភិក្ខុ ។ ចំណែកបិង្គិយត្ថេរ ក្រាបទូល

លាព្រះមានព្រះភាគជាម្ចាស់ ត្រឡប់ទៅប្រាប់ដំណឹងដល់អាចារ្យពាវរីព្រាហ្មណ៍ ហើយសម្ដែងធម៌ដោះស្រាយបញ្ហា ១៦ ខ.ឲ្យស្ដាប់ ជួយឲ្យពាវរីបានសម្រេចធម្មាភិសម័យថ្នាក់សេក្ខភូមិ ។ ចំណែកមោឃរាជត្ថេរនោះ ចាប់ពីបានជាព្រះអរហន្ត និងឧបសម្បទារួចហើយ តែងត្រេកអរនឹងចីវរសៅហ្មង ៣ ប្រការ គឺសំពត់សៅហ្មង ១ អំបោះដេរ សំពត់សៅហ្មង ១ ទឹកជ្រលក់សៅហ្មង ១ ។ ខាងក្រោយមក ព្រះមានព្រះភាគទ្រង់តែងតាំងមោឃរាជត្ថេរក្នុងតំណែងឯតទគ្គៈថា ជាកំពូលជាងភិក្ខុទាំងឡាយអ្នកទ្រទ្រង់ចីវរសៅហ្មង ។ លុះក្រោយមកទៀត ព្រះមោឃរាជត្ថេរក៏កើតរោគឃ្ល៉ង់ ដោយបុព្វកម្មរបស់លោក ក៏គិតថា រោគនេះធ្វើឲ្យសេនាសនៈខូចទៅ ទើបយកចម្បើងមកក្រាលសិង ។

**ថ្ងៃមួយ លោកបានចូលទៅគាល់ព្រះមានព្រះភាគ ព្រះអង្គក៏ទ្រង់ត្រាស់ព្រះគាថា ដូចមានសេចក្ដីថា ៖**

ម្នាលមោឃរាជ ជាអ្នកមានសម្បុរអាក្រក់ តែមានចិត្តល្អ អ្នកជាភិក្ខុមានចិត្តតម្កល់មាំរឿយៗ អស់រាត្រីទាំងឡាយ ក្នុងកាលត្រជាក់ប្រកបដោយហេមន្តរដូវ តើអ្នកនឹងធ្វើដោយប្រការដូចម្ដេច ?

មោឃរាជត្ថេរក្រាបទូលថា ខ្ញុំព្រះអង្គបានឮដូច្នេះថា ដែនមគធៈទាំងមូល ជាដែនមានសន្ទូងបរិបូណ៌ ពួកភិក្ខុដទៃមានការរស់នៅជាសុខ ( ដោយកម្រាល និងគ្រឿងស្លៀកដណ្ដប់ដ៏ល្អ ) យ៉ាងណា ខ្ញុំព្រះអង្គ

( ក្រាល ) បិទបាំងស្លឹកឈើ សម្រេចនូវការដេក ( យ៉ាងនោះដែរ ) ។

មោឃរាជត្ថេរទ្រទ្រង់សំពត់ចីវរចាស់នេះ នាំឲ្យមហាជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ព្រោះក្នុងសម័យនោះ ពួកមនុស្សនិយមបុគ្គលក្នុងលក្ខណៈផ្សេងៗគ្នា ។ ដូច្នេះហើយ ទើប**អដ្ឋកថាគម្ពីរធម្មបទ** ក្នុងរឿង**ព្រះនាងរូបនន្ទាថេរី** និង **គម្ពីរអង្គុត្តរនិកាយ ចតុកនិបាត ក្នុងរូបសូត្រ** សម្ដែងថា ៖

បុគ្គលពួកខ្លះ លោកហៅថា រូបប្បមាណិកា គឺអ្នកនិយមប្រកាន់ប្រមាណក្នុងរូប គឺពេញចិត្តក្នុងការមើល ការឃើញ ។ បុគ្គលជំពូកនេះ បានឃើញការបង្ហាញឥរិយាបថផ្សេងៗ ដែលជាប់ដោយធ្វើពិធី ដូចមានការហែព្រះពុទ្ធរូប ធ្វើសក្ការបូជាព្រះពុទ្ធបដិមា ព្រះចេតិយ និងការសម្ដែងរឿងព្រះសម្មាសម្ពុទ្ធ ទ្រង់ចុះចាកស្ថានតាវត្តិង្សក្ដី ការសម្ដែងឥរិយាបថព្រះសង្ឃធ្វើសង្គាយនាក្ដី ជាឧបាយដឹកនាំ ទើបជាឧបាយដឹកនាំជនពួកនេះឲ្យជ្រះថ្លា ។ បុគ្គលខ្លះទៀត លោកហៅថា ឃោសប្បមាណិកា បានដល់អ្នកនិយមប្រកាន់ក្នុងសំឡេង គឺពេញចិត្តស្ដាប់សំឡេង ។ ជនជំពូកនេះបានស្ដាប់ព្រះធម្មកថិក ដែលមានសំឡេងពីរោះ រមែងជ្រះថ្លាដោយងាយ, ការសូត្រដោយទំនង ដូចបទសរភញ្ញក្ដី ការទេសនាដោយទំនងដូចទេសនាមហាជាតិក្ដី ការធ្វើការបូជា និងឧបសម្បទាជាដើម ដែលមានភ្លេងពិណពាទ្យប្រគំ ក៏ញុំាំងជនជំពូកនេះឲ្យជ្រះថ្លា ។ មានអ្នកខ្លះទៀត

លោកហៅថា លូខប្បមាណិកា បានដល់ អ្នកនិយមប្រកាន់ប្រមាណក្នុងរបស់សៅហ្មង គឺពេញចិត្តមនុស្សប្រព្រឹត្តកខ្វក់សៅហ្មង ការប្រើប្រាស់សំពត់ចាស់គ្រាំគ្រា ជាការប្រព្រឹត្តរបស់ភិក្ខុអ្នកប្រព្រឹត្តល្អ រមែងជាទីជ្រះថ្លារបស់ជនពួកនេះ ម្យ៉ាងទៀត បុគ្គលអ្នកប្រព្រឹត្តខុសផ្សេងៗ សូម្បីវិកលចរិត មនុស្សទាំងឡាយតែងនាំគ្នាទៅមើល គោរពរាប់អាន ។

មានបុគ្គលខ្លះទៀត លោកហៅថា ធម្មប្បមាណិកា បានដល់អ្នកនិយមប្រកាន់ប្រមាណក្នុងធម៌ គឺពេញចិត្តចំពោះខ.បដិបត្តិ ។ ជនពួកនេះបានឃើញភិក្ខុដែលតាំងនៅក្នុងសំវរៈ មានមារយាទរៀបរយ និងស្តាប់ធម៌ដែលធម្មកថិកសម្តែងទើបជ្រះថ្លា ដូចព្រះសារីបុត្រឃើញព្រះអស្សជិហើយ បានស្តាប់ធម៌ ក៏មានសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

ដូច្នោះ ការបានពិចារណា ដល់ការប្រព្រឹត្តល្អ របស់មោឃរាជដែលទ្រទ្រង់សំពត់ចីវរសៅហ្មង ក៏ព្រមទទួលការរាប់អាន គោរពបដិបត្តិតាមឱវាទរបស់លោក ទើបជាអ្នកបានទទួលតំណែងឯតទគ្គៈថា ជាកំពូលលើភិក្ខុទាំងឡាយ ផ្នែកខាងទ្រទ្រង់ចីវរសៅហ្មង ។ល។

*( ជីវប្រវត្តិរបស់ព្រះមោឃរាជត្ថេរ ចប់ )*

# ✍ ជីវប្រវត្តិរបស់ព្រះរដ្ឋបាលត្ថេរ ✍

**“ ដែលជាឯតទគ្គៈផ្នែកខាងចេញបួសដោយសទ្ធា ”**

*ព្រះរដ្ឋបាលត្ថេរ លោកបានទទួលនូវកិត្តិយសដ៏ប្រសើរ ថែមទាំងជាអសីតិមហាសាវក ដែលជាសាវកធំរបស់ព្រះបរមសាស្ដា ៨០ រូប និងបានជាកម្លាំងដ៏សំខាន់ ក្នុងការផ្សព្វផ្សាយព្រះធម៌វិន័យ ទាំងបានទទួលការតែងតាំងពីព្រះមហាមុនី ឲ្យជាឯតទគ្គៈមួយរូបក្នុងព្រះពុទ្ធសាសនានេះ ដូចមានប្រាកដក្នុង* ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** *ថា* ***ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ*** *ម្នាលភិក្ខុទាំងឡាយ រដ្ឋបាលជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងចេញបួសដោយសទ្ធា ។*

*មុននឹងជ្រាបប្រវត្តិរបស់លោក សូមនាំហេតុផលដែលទាក់ទងនឹងឈ្មោះរបស់ព្រះរដ្ឋបាលត្ថេរ មានសម្ដែងនៅក្នុង* ***អដ្ឋកថាមនោរថបូរណី*** *និង* ***គម្ពីរបបញ្ចសូទនី*** *ដែលបានអធិប្បាយរឿងឈ្មោះរបស់ព្រះរដ្ឋបាលទុកដូច្នេះថា ៖*

*ដែលឈ្មោះថារដ្ឋបាល មានសេចក្ដីថា ជាអ្នករក្សាដែន ឬជាអ្នកអាចប្រមូលដែនដែលបែកបាក់ឲ្យរួបរួមគ្នាបាន ។*

*ជីវប្រវត្តិទាក់ទងនឹងបុព្វវាសនាបារមីរបស់ព្រះរដ្ឋបាលនោះ ដែល*

មានសេចក្ដីសម្ព័ន្ធជាមួយនឹងប្រវត្តិព្រះរាហុលត្ថេរខ្លះ ក្នុងវគ្គដែលពោលដល់អតីតជាតិ ដូចមានរឿងតំណាលទុកក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្ដីថា ៖

ព្រះរដ្ឋបាលត្ថេរជាមួយនឹងព្រះរាហុលត្ថេរ កើតនៅក្នុងត្រកូលគហបតី ដែលមានធនធានច្រើននៅក្នុងក្រុងសាវត្ថី មុនកាលកើតឡើងនៃព្រះបទុមុត្តរៈ ដោយកន្លងមួយសែនកប្បមកហើយ ។ កាលលោកចម្រើនវ័យធំហើយ ក្រោយពីបិតាធ្វើកាលកិរិយាទៅ ទើបលោកបានទទួលនាទីគ្រប់គ្រងមើលទ្រព្យសម្បត្តិបន្តមក ។ ប៉ុន្តែ ពេលដែលលោកចាប់ផ្ដើមទទួលនាទីគ្រប់គ្រងទ្រព្យសម្បត្តិនោះ ក៏ឲ្យហៅពួកអ្នករក្សាឃ្លាំងមកសាកសួរចំពោះទ្រព្យសម្បត្តិ ក៏បានជ្រាបថា មាសប្រាក់នៅសល់ច្រើន រហូតរាប់ប្រមាណមិនបាន ទើបគិតពិចារណា មើលហេតុផលថា

ជនទាំងឡាយ មានជីដូនជីតាជាដើម ដែលស្លាប់ទៅហើយ មិនមាននរណា អាចនាំយកទ្រព្យសម្បត្តិទាំងអស់នោះ ជាប់ទៅតាមខ្លួនបានឡើយ ។ ឥឡូវនេះ យើងទាំងពីរនាក់ គួរនឹងនាំយកទ្រព្យសម្បត្តិទាំងអស់នេះឲ្យជាប់ទៅតាមខ្លួន ដោយការបរិច្ចាគទាន ។ បុគ្គលទាំងពីរនាក់នោះគិតពិចារណាដូច្នេះហើយ ទើបចាប់ផ្ដើមបរិច្ចាគមហាទានដល់មនុស្សទាំងឡាយ ដោយមានអ្នកកំព្រា និងអ្នកធ្វើដំណើរផ្លូវឆ្ងាយជាដើម ដោយ

សាងរោងទានឡើងត្រង់ទ្វារស្រុកទាំង ៤ ទិសរបស់ខ្លួន ។

បុគ្គលទាំងពីរនាក់នោះ មានការគិតម្យ៉ាងម្នាក់ៗ មុននឹងឲ្យទាន ម្នាក់កាលមានមនុស្សមកដល់រោងទានហើយ ត្រូវសួរជាមុនថា អ្នកត្រូវការបាយ ត្រី អាហារ ឬសំពត់ជាគ្រឿងស្លៀកដណ្តប់ យ៉ាងណាទីមួយហើយ ទើបឲ្យវត្ថុនោះ ហេតុដែលត្រូវសួរមុននោះ គឺដើម្បីឲ្យបានទ្រព្យសមតាមសេចក្តីត្រូវការ បុរសនោះមាននាមថា **អាគតវាចក:** មានសេចក្តីថា សាកសួរអ្នកមកសុំមុនឲ្យ ។ ចំណែកម្នាក់ទៀត មិនបានសាកសួរអ្នកមកសុំឡើយ ពេលមានអ្នកមកសុំដល់រោងទាន ក៏រៀបចំនាំយកវត្ថុដែលនឹងឲ្យទានដាក់ចុះក្នុងភាជនៈរបស់អ្នកមកសុំ ហើយក៏ឲ្យទៅ បុរសនេះទើបមានឈ្មោះថា **អនាគតវាចក:** មានសេចក្តីថា មិនបានសួរអ្នកដែលមកសុំមុនឲ្យ ។

ថ្ងៃមួយ អ្នកទាំងពីរនាក់នោះ គឺអាគតវាចក: និងអនាគតវាចក: បាននាំគ្នាចេញទៅលុបលាងមុខខាងក្រៅផ្ទះពីព្រឹកព្រលឹម ។ ពេលនោះមានតាបសពីររូបហោះចេញមកអំពីព្រៃហិមពាន្តដើម្បីមករកភិក្ខា ក៏មកចុះជិតកន្លែងគហបតីទាំងពីរនាក់នោះ ។ កាលតាបសនោះ រៀបចំគ្រឿងបរិក្ខារមានភាជនៈសំបកឃ្លោកជាដើម ត្រៀមនឹងចូលទៅកាន់ស្រុក អ្នកទាំងពីរនាក់នោះបានឃើញហើយ នាំគ្នាសំពះតាបសទាំងពីររូប ទើបតាបសសួរថា អ្នកមកដល់ទីនេះតាំងតែពីពេលណា ? ខ្ញុំមកដល់អម្បាញ់មិញនេះ

ឯង ទើបនាំគ្នាទទួលយកកាជនៈសំបកឃ្លោក របស់តាបសម្នាក់មួយៗ រៀងៗ ខ្លួន ។ ក្រោយពីតាបសទាំងពីររូបនោះ បានទទួលចង្ហាន់រួចស្រេច ហើយ ជនទាំងពីរនាក់នោះ ទើបនិមន្តឲ្យតាបសមកឆាន់ក្នុងផ្ទះរបស់ខ្លួន ជាប្រចាំ ។ តាបសទាំងពីរនោះ មានលក្ខណៈ ក្នុងការរស់នៅផ្សេងៗ គ្នា តាបសម្នាក់ ជាអ្នកពេញចិត្តទៅសម្រាកពេលថ្ងៃក្នុងពិភពនាគ ដែល ស្ថិតនៅខាងក្រោមនៃមហាសមុទ្ទ ពេលត្រឡប់ឡើងមកវិញ ត្រូវទៅឆាន់ ចង្ហាន់ក្នុងផ្ទះឧបដ្ឋាករបស់ខ្លួន ពេលឆាន់រួចជាស្រេចហើយ បានពោល ពាក្យអនុមោទនាទានថា សូមលោកបានសម្បត្តិដូចពិភពនាគ ដែលមាន ឈ្មោះថា **បឋវិនធរៈ** ។

នៅថ្ងៃមួយ ឧបដ្ឋាកបានស្តាប់ពាក្យអនុមោទនាទាននោះហើយ នឹក ចាប់ចិត្តទើបសួរថា ពាក្យដែលលោកម្ចាស់ពោលអនុមោទនាថា សូម ឲ្យខ្ញុំបានសម្បត្តិដូចពិភព របស់ស្តេចបឋវិនធនាគរាជនោះ មានសេចក្តី យ៉ាងណា ? តាបសពោលតបថា សូមឲ្យសម្បត្តិរបស់លោក ចូរដូចជា សម្បត្តិរបស់ស្តេចបឋវិនធរៈ ក្នុងពិភពនាគនោះ ។ ចាប់ពីថ្ងៃនោះមក កុដុម្ពិកនោះធ្វើបុណ្យកុសលគ្រប់ពេលវេលា តែងតែតាំងចិត្តប្រាថ្នាដើម្បី ឲ្យបានសម្បត្តិរបស់ស្តេចនាគនោះ ។ ចំណែកតាបសម្នាក់ទៀត បានឡើង ទៅសម្រាកពេលថ្ងៃក្នុងស្ថានតាវត្តិង្ស ក្នុងសិរីសក្កវិមានមួយដែលទំនេរ ដែលមិនមានទេវបុត្រអាស្រ័យនៅ បានឃើញសម្បត្តិរបស់ព្រះឥន្ទ្រ ។

ពេលដែលត្រឡប់មកវិញ បានទៅធាន់ចង្ហាន់នៅផ្ទះកុដុម្ពិករួចស្រេចហើយ ទើបពោលអនុមោទនាទានថា សូមឲ្យលោកបានសម្បត្តិដូចវិមានរបស់ស្តេចសក្កទេវរាជចុះ ។ កុដុម្ពិកនឹកគិតចង់ដឹងហេតុផល របស់ពាក្យអនុមោទនាទាន ទើបសួរថា លោកម្ចាស់ដ៏ចម្រើន ហេតុអ្វី ទើបលោកម្ចាស់ពោលពាក្យអនុមោទនាដូច្នេះ ? កាលបើតាបសបានពន្យល់ឲ្យដឹងហេតុផលហើយ ពេលដែលលោកធ្វើបុណ្យកុសលអ្វី យ៉ាងណាទីមួយ តែងតែតាំងសេចក្តីប្រាថ្នាឲ្យបានសម្បត្តិរបស់សក្កទេវរាជ ។

លុះតមក កុដុម្ពិកទាំងពីរនាក់ បានអស់ជីវិតអំពីជាតិនេះទៅហើយ ម្នាក់បានទៅកើតក្នុងទីដែលខ្លួនតាំងបណិធាន គឺការប្រាថ្នាទុក ។ កុដុម្ពិកម្នាក់ទៅកើតជាស្តេចនាគ ទ្រង់ព្រះនាមថា **បបរិនធរ:** តាមដែលឈ្មោះរបស់ស្តេចនាគមុន ប៉ុន្តែក្នុងអដ្ឋកថា ហៅថា **ស្តេចបាលិត:** លុះបានកំណើតនោះហើយក៏តូចចិត្ត ព្រោះបានឃើញរាងកាយរបស់ខ្លួន មិនគួរពេញចិត្តឡើយ ទើបត្រឡប់គិតឡើងវិញថា តាបសបានពណ៌នាគុណនៃទីមិនជាទីពេញចិត្តរបស់យើង ដោយថា កំណើតរបស់នាគនេះ ជាកំណើតដែលត្រូវលូនដោយពោះ តាបសអាចស្គាល់ចំពោះតែទីនេះ លោកគង់មិនស្គាល់ទីដទៃយ៉ាងពិតប្រាកដ ។

ក្នុងខណៈពេលនោះ ពួកនាងនាគដែលមានរាងកាយ ប្រដាប់ប្រដាយ៉ាងល្អហើយ នាំគ្នាមកប្រគំតន្ត្រីទាំងពួង ជាការទទួលស្តេចនាគ

បឋវិនធរៈទើបតែមកដល់ថ្មី ។ ក្នុងមួយរំពេចនោះ ស្ដេចនាគក៏លះអត្តភាពរបស់នាគ ក្លាយជាមាណពកំលោះដ៏ស្រស់សង្ហា ។ ប្រក្រតីរបស់ពួកស្ដេចមហារាជទាំង ៤ ត្រូវចូលទៅគាល់ស្ដេចសក្កទេវរាជ រាល់កន្លះខែម្ដង ស្ដេចនាគបឋវិនធរៈដែលជាបរិវាររបស់ស្ដេចវិរូបក្ខៈ បានចូលទៅគាល់ស្ដេចសក្កទេវរាជ រួមជាមួយនឹងស្ដេចវិរូបក្ខៈ ។ កាលបើសក្កទេវរាជទតឃើញស្ដេចបឋវិនធរៈមកពីចម្ងាយ ក៏ទ្រង់ចាំបាន ក្នុងពេលដែលស្ដេចនាគចូលមកឈរនៅជិតហើយ ទើបត្រាស់សួរដល់ស្ដេចនាគនោះថា នែសម្លាញ់ អ្នកទៅកើតក្នុងទីណា ? ស្ដេចនាគបឋវិនធរៈ បានក្រាបទូលថា បពិត្រទេវរាជ សូមព្រះអង្គកុំត្រាស់សួរឡើយ ខ្ញុំព្រះអង្គបានទៅកើតក្នុងកំណើតពួកសត្វ ដែលលូនទៅដោយពោះ ចំណែកព្រះអង្គវិញបានមកកើតក្នុងស្ថានតាវត្តិង្សនេះ ព្រោះបានមិត្តល្អ ។

ព្រះឥន្ទ្រត្រាស់លួងលោមចិត្ត និងណែនាំឲ្យធ្វើបុណ្យតទៅទៀតថា នែសម្លាញ់ កុំគិតតូចចិត្តថា បានកើតក្នុងទីមិនល្អឡើយ ពេលនេះព្រះបទុមុត្តរៈទ្រង់បានឧប្បត្តិឡើងក្នុងលោកហើយ ចូរសម្លាញ់ទៅធ្វើបុណ្យកុសលក្នុងសម្នាក់ព្រះបទុមុត្តរៈចុះ ហើយប្រាថ្នាឲ្យបានមកកើតក្នុងទីនេះយើងទាំងពីរនាក់រស់នៅជាសុខរួមគ្នា ។ ស្ដេចនាគក្រាបទូលថា បពិត្រទេវរាជ ខ្ញុំព្រះអង្គនឹងធ្វើតាមពាក្យណែនាំរបស់ព្រះអង្គ កាលបើស្ដេចនាគទទួលពាក្យនោះហើយ ក៏ក្រាបទូលលាត្រឡប់ទៅវិញ ប៉ុន្ដែមុននឹង

ទៅកាន់ពិភពនាគ បានចូលទៅគាល់ក្រាបទូលនិមន្តព្រះបទុមុត្តរៈ ដើម្បីឲ្យស្ដេចយាងទៅទទួលចង្ហាន់នៅក្នុងពិភពនាគរបស់ខ្លួន ទើបត្រឡប់មករៀបចំគ្រឿងសក្ការបូជាមួយយប់ទល់ភ្លឺ រួមជាមួយនឹងពួកនាគនៅក្នុងពិភពរបស់ខ្លួន ។ ព្រឹកឡើង ព្រះបទុមុត្តរៈត្រាស់ប្រាប់ព្រះសុមនត្ថេរ ដែលជាឧបដ្ឋាករបស់ព្រះអង្គ ឲ្យទៅប្រាប់ភិក្ខុទាំងឡាយ ដែលជាអ្នកជំនាញក្នុងព្រះត្រៃបិដក និងបានសម្រេចអភិញ្ញា ៦ ថែមទាំងមិនឲ្យភិក្ខុដែលជាបុថុជ្ជនទៅជាមួយឡើយ ថ្ងៃនេះ តថាគតទៅបិណ្ឌបាតឆ្ងាយ ។

ព្រះសុមនត្ថេរ ទទួលព្រះពុទ្ធដីកាហើយ ប្រាប់ឲ្យភិក្ខុទាំងពួងដែលជ្រាបដល់ព្រះបំណងនោះ ។ ព្រះបទុមុត្តរៈ ស្ដេចយាងទៅក្នុងពិភពនាគគ្រានោះ មានភិក្ខុមួយសែនរូបហែហមជាបរិវារ ។ ស្ដេចនាគបឋវិនធរៈព្រមដោយនាគជាបរិវារ ម្នាក់ៗ នាំគ្នាទៅទទួលភិក្ខុសង្ឃ ដែលមានព្រះបទុមុត្តរៈជាប្រធាន ។ ក្នុងចំនួនភិក្ខុសង្ឃទាំងអស់ មានសាមណេរឧបរេវតៈមួយរូប ជាព្រះឱរសរបស់ព្រះបទុមុត្តរៈ លោកមានព្រះជន្មតិចជាងគេ ប៉ុន្តែជាទីពេញចិត្តរបស់ស្ដេចនាគខ្លាំងណាស់ ព្រោះមានឥទ្ធានុភាពគួរឲ្យអស្ចារ្យដ៏លើសលប់ និងក្រៃលែងជាងនោះ កាលព្រះបទុមុត្តរៈទ្រង់ប្រថាប់គង់ហើយ ទើបសាមណេរឧបរេវតៈគង់លើអាសនៈនៅត្រង់ហ្នឹងពុទ្ធាសនៈ ។ កាលស្ដេចនាគសម្លឹងមើលព្រះបទុមុត្តរៈ ហើយបែរត្រឡប់មកសម្លឹងមើលសាមណេរឧបរេវតៈវិញ បានឃើញមហាបុរិស-

លក្ខណៈ ៣២ ប្រការ ប្រាកដមានក្នុងរាងកាយរបស់សាមណេរឧបរេវតៈ ស្រដៀងគ្នានឹងព្រះវរកាយរបស់ព្រះបទុមុត្តរៈ ដែលជាហេតុធ្វើឲ្យស្ដេចនាគគិតថា សាមណេរនេះ ប្រហាក់ប្រហែលនឹងព្រះបទុមុត្តរៈ លោកជាអ្វីនឹងព្រះអង្គហ្ន៎ ? ទើបសួរព្រះថេរៈមួយរូបនៅជិតនោះថា លោកម្ចាស់ដ៏ចម្រើន សាមណេរនេះត្រូវជាអ្វីនឹងព្រះទសពល ? ព្រះថេរៈតបថា សាមណេរនេះ ជាព្រះឱរសរបស់ព្រះភគវា ។ កាលបើស្ដេចនាគបានស្ដាប់យ៉ាងនេះហើយ ក៏គិតថា សាមណេរនេះ ប្រសើរក្រៃលែង ទើបបានជាព្រះឱរសរបស់ព្រះពុទ្ធ យើងគួរឲ្យបានភាពប្រសើរយ៉ាងនេះក្នុងកាលជាអនាគត កាលបើគិតដូច្នេះហើយ បានថ្វាយមហាទានរហូតអស់ ៧ ថ្ងៃ ហើយតាំងសេចក្ដីប្រាថ្នាថា សូមឲ្យខ្ញុំព្រះអង្គបានជាព្រះឱរសរបស់ព្រះពុទ្ធក្នុងកាលជាអនាគត ដូចគ្នានឹងសាមណេរឧបរេវតៈ ដោយបុណ្យកុសលដែលខ្ញុំបានធ្វើនេះ ។

ព្រះបទុមុត្តរៈ ទ្រង់ឃើញការសម្រេចចិត្តនៃសេចក្ដីប្រាថ្នារបស់ស្ដេចនាគ ទើបទ្រង់ព្យាករថា អ្នកនឹងបានជាព្រះឱរសរបស់ព្រះសមណគោតមក្នុងកាលជាអនាគត កាលបើត្រាស់ព្យាករយ៉ាងនេះហើយ ទ្រង់និមន្តចេញចាកពិភពនាគ ត្រឡប់មកវិញ ។ កាលបើដល់ពេលកន្លះខែ ស្ដេចនាគឡើងទៅគាល់សក្កទេវរាជ រួមជាមួយនឹងស្ដេចវិរូបក្ខៈតាមប្រក្រតី ។ សក្កទេវរាជ ទើបត្រាស់សួរស្ដេចនាគថា នែសម្លាញ់ អ្នកធ្វើ

បុណ្យប្រាថ្នាមកកើតក្នុងទេវលោកហើយឬ ? ស្តេចនាគក្រាបទូលតបថា បពិត្រទេវរាជ ខ្ញុំព្រះអង្គបានធ្វើបុណ្យហើយ ប៉ុន្តែមិនបានប្រាថ្នាមកកើតក្នុងទេវលោកឡើយ ។ តើលោកឃើញហេតុមិនល្អយ៉ាងណា ទើបមិនប្រាថ្នាមកកាន់ទេវលោក ? ស្តេចនាគក្រាបទូលថា គ្មានបានឃើញភាពមិនល្អទេ ប៉ុន្តែខ្ញុំបានសម្លឹងឃើញសាមណេរឧបរេវតៈ ជាពុទ្ធឱរសហើយពេញចិត្ត ទើបតាំងសេចក្តីប្រាថ្នាឲ្យបានជាព្រះឱរស របស់ព្រះពុទ្ធក្នុងកាលជាអនាគត កាលបើស្តេចនាគក្រាបទូលតបហើយ បានក្រាបទូលណែនាំព្រះឥន្ទ្រថា ចំណែកព្រះអង្គវិញ គប្បីប្រាថ្នាអ្វីមួយក្នុងកាលជាអនាគត ។ ចំណែកព្រះឥន្ទ្រ ទ្រង់ទទួលពាក្យរបស់ស្តេចនាគ ថែមទាំងបានថ្វាយមហាទានដល់ព្រះបទុមុត្តរៈ ព្រមដោយភិក្ខុសង្ឃអស់ ៧ ថ្ងៃតមក ទ្រង់ឃើញភិក្ខុមួយរូបមានអានុភាព ទើបទ្រង់ពិចារណាថា កុល-បុត្រនេះចេញបួសចាកត្រកូលណា ហើយទើបទ្រង់ជ្រាបថា កុលបុត្រនេះជាបុត្ររបស់ត្រកូលដែលមានសមត្ថភាពអង់អាច ទ្រង់បានទុកនូវរាជសម្បត្តិដែលខ្ទាត់ខ្ទាយហើយ និងព្រមអត់អាហារដល់ ១៤ ថ្ងៃ ជាការជំទាស់នឹងឪពុកម្តាយ ដែលមិនព្រមអនុញ្ញាតឲ្យបួស ទីបំផុតម្តាយឪពុកព្រមឲ្យទៅបួស ព្រោះឃើញការតាំងចិត្តរបស់កូន លោកឃើញហេតុដ៏អស្ចារ្យយ៉ាងនេះ ទើបតាំងសេចក្តីប្រាថ្នាថា ខ្ញុំព្រះអង្គ បានធ្វើសក្ការៈរហូតអស់ ៧ ថ្ងៃជាប់គ្នា សូមឲ្យបានជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ

ផ្នែកខាងចេញបួសដោយសទ្ធា ក្នុងព្រះសាសនារបស់ព្រះពុទ្ធអង្គណាមួយ ក្នុងកាលខាងមុខនោះ ដូចភិក្ខុរូបនេះដែរ ។

ព្រះបទុមុត្តរៈ ទ្រង់ជ្រាបសេចក្តីប្រាថ្នានេះមិនមានហេតុអ្វីជាទៃមកជំទាស់បាន ទើបទ្រង់ព្យាករថា មហាបពិត្រនឹងបានជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងចេញបួសដោយសទ្ធា ក្នុងសាសនារបស់ព្រះសមណគោតម ក្នុងកាលជាអនាគត ហើយព្រះអង្គនិមន្តទៅកាន់វិហារវិញ ។ ចំណែកសក្កទេវរាជ ក៏ត្រឡប់ទៅកាន់វិមានរបស់ព្រះអង្គវិញដែរ ។ កាលបើសក្កទេវរាជ និងបឋវិនធរនាគរាជចុតិចាកជាតិនោះហើយ ក៏ត្រាច់រង្គត់សោយទិព្វសម្បត្តិ និងមនុស្សសម្បត្តិនៅច្រើនពាន់កប្ប ដោយអំណាចបុណ្យកុសលដែលសន្សំទុកដូចពោលមកហើយ ។ កន្លងមកដល់កប្បទី ៩២ ដោយរាប់ថយក្រោយពីកទ្ទកប្បនេះទៅ មានព្រះពុទ្ធមួយព្រះអង្គព្រះនាមផុស្សៈ ទ្រង់កើតឡើងក្នុងលោក ។ ព្រះបិតារបស់ព្រះពុទ្ធផុស្សៈព្រះនាមថា **មហិន្ទ** ។ ព្រះពុទ្ធផុស្សៈ មានព្រះអនុជផ្សេងព្រះមាតាគ្នា ៣ ព្រះអង្គ ។ ចំណែកព្រះពុទ្ធបិតា ពេលទ្រង់ថ្វាយទានដល់ព្រះសង្ឃ ទ្រង់បន្លឺព្រះវាចាដោយសេចក្តីសម្គាល់ក្នុងព្រះទ័យថា ព្រះពុទ្ធរបស់យើង ព្រះធម៌របស់យើង ព្រះសង្ឃរបស់យើង ដូច្នេះរាល់ថ្ងៃ ម្យ៉ាងទៀត ទ្រង់ថ្វាយទានដល់ព្រះពុទ្ធផុស្សៈ ព្រមទាំងភិក្ខុសង្ឃដោយព្រះអង្គឯង មិនឲ្យអ្នកណាមួយថ្វាយទានដល់ព្រះពុទ្ធផុស្សៈឡើយ ។

ថ្ងៃមួយ ក្នុងបច្ចន្តគ្រាម មានចលាចលកើតឡើង ព្រះរាជាត្រាស់បញ្ជាព្រះរាជបុត្រទាំងបីព្រះអង្គថា នែបាទាំងបី ឥឡូវនេះ បច្ចន្តជនបទមានពួកចោរ ចូរបាទាំងបីទៅបង្ក្រាបឲ្យស្ងប់រំងាប់ រាជបុត្រទាំងបីអង្គក្រាបទូលថា បពិត្រព្រះបិតា ទូលព្រះបង្គំនឹងទៅ ហើយក៏ថ្វាយបង្គំលាទៅបង្ក្រាបពួកចោររហូតបានសម្រេច ធ្វើឲ្យប្រជាជនរស់នៅយ៉ាងសុខក្សេមក្សាន ទើបស្តេចត្រឡប់មកវិញ ។ ក្នុងរវាងផ្លូវដែលស្តេចត្រឡប់មកនោះ ទ្រង់ប្រឹក្សានឹងពួកអាមាត្យថា បើព្រះរាជបិតានឹងប្រទានពរដល់ពួកយើង គួរទទួលពរអ្វីហ្ន៎ ? ពួកអាមាត្យក្រាបទូលថា បពិត្រព្រះរាជបុត្ររឿងរាជសម្បត្តិនោះ មិនលំបាកទេ ព្រោះព្រះរាជបិតាសោយទិវង្គតទៅនឹងធ្លាក់មកដល់ព្រះរាជបុត្រទាំងបី ប៉ុន្តែការបានឱកាសថ្វាយទានចំពោះព្រះពុទ្ធជាម្ចាស់ ទើបជាការលំបាកក្រៃលែង ដូច្នេះសូមព្រះរាជបុត្រទូលសូមពរ ដើម្បីបានទំនុកបម្រុងព្រះមហាមុនីនោះ ទើបជាពរដ៏ល្អ ។

ចំណែកព្រះរាជបុត្រទាំង ៣ ព្រះអង្គ ទ្រង់ស្តាប់ពាក្យសម្តីរបស់ពួកអាមាត្យដូច្នេះហើយ ទ្រង់យល់ថាជាការល្អ ទើបទ្រង់នាំគ្នាធ្វើដំណើរមកបន្តបន្ទាប់ ដោយទ្រង់សង្ឃឹមក្នុងព្រះទ័យថា នឹងក្រាបទូលសូមពរនោះ រហូតមកដល់ព្រះនគរ ។ កាលបើដឹងដំណឹងការយាងត្រឡប់មកកាន់ព្រះនគររបស់ព្រះរាជបុត្រទាំង ៣ ព្រះអង្គហើយ ដោយការសព្វព្រះទ័យ ទើបព្រះរាជទានពរឲ្យដល់ព្រះរាជបុត្រទាំង ៣ អង្គ តើត្រូវការពរ

អ្វី ឲ្យទ្រង់ជ្រើសរើសសូមពរតាមសព្វព្រះទ័យចុះ ទើបព្រមគ្នាក្រាបទូលឡើងថា បពិត្រព្រះបិតា សូមទ្រង់ព្រះរាជទានឲ្យបុត្រទាំង ៣ អង្គ បានឱកាសបដិបត្តិចំពោះព្រះសម្មាសម្ពុទ្ធ រហូតអស់មួយត្រៃមាសផងចុះ ។

ព្រះមហិន្ទរាជ ទ្រង់មិនសព្វព្រះទ័យព្រះរាជទានពរនេះទេ ប៉ុន្តែព្រះរាជបុត្រទាំង ៣ អង្គ ទ្រង់ក្រាបទូលជំទាស់ថា ព្រះបិតាទ្រង់ត្រាស់អនុញ្ញាត ឲ្យជ្រើសរើសពរតាមសេចក្តីពេញចិត្តនោះអី ពេលនេះហេតុអ្វីក៏ព្រះបិតាត្រាស់យ៉ាងដូច្នេះ កាលបើព្រះរាជបុត្រទាំង ៣ អង្គបានទទួលការព្រះរាជទានពរនោះហើយ ទើបទ្រង់ប្រឹក្សាគ្នាថា ពួកយើងគួរធ្វើអ្វីជាមុន ហើយបដិបត្តិចំពោះព្រះបរមសាស្តា ទើបបានផលច្រើន ។ បន្ទាប់ពីទ្រង់ប្រឹក្សាគ្នារួចហើយ ទ្រង់រួមគំនិតគ្នាតែមួយ ដើម្បីឲ្យបានបុណ្យកុសលច្រើន ដោយមុនដំបូងត្រូវសមាទានសីល ១០ ហើយទ្រង់បបួលគ្នាទៅគង់ប្រថាប់នៅក្នុងវិហារ ។ ចំណែកព្រះរាជនិវេសន៍ ទ្រង់តែងតាំងបុរស ៣ នាក់ ឲ្យជាអ្នកចាត់ចែងការជំនួស គឺម្នាក់ឲ្យជាអ្នកមើលខាងទ្រព្យសម្បត្តិនិងគ្រឿងបរិភោគ ម្នាក់ទៀតឲ្យជាអ្នកត្រួតពិនិត្យការងារ និងម្នាក់ទៀតឲ្យជាអ្នករៀបចំទេយ្យធម៌ផ្សេងៗ ថ្វាយដល់ព្រះសម្ពុទ្ធព្រមទាំងភិក្ខុសង្ឃ ។

**មួយទៀត ផលល្អបានកើតឡើងដល់អ្នកទាំង ៣ នាក់ ជាអ្នកមានការតាំងចិត្តធ្វើសេចក្តីល្អ ដែលបានទទួលការតែងតាំងឲ្យធ្វើកិច្ចការងារជំនួសនោះ គឺ ៖**

- បុរសដែលទទួលនាទីជាអ្នកមើលខាងទ្រព្យសម្បត្តិ និងគ្រឿងបរិភោគ បានមកកើតជាព្រះបាទពិម្ពិសារ ។

- បុរសដែលទទួលនាទីជាអ្នកត្រួតពិនិត្យការងារនោះ បានមកកើតជាវិសាខឧបាសក ។

- បុរសម្នាក់ទៀត ដែលទទួលនាទីរៀបចំទេយ្យធម៌ ថ្វាយដល់ភិក្ខុសង្ឃ ព្រមទាំងព្រះភគវានោះ បានមកកើតជាព្រះរដ្ឋបាលត្ថេរ ។

ចំណែកព្រះរាជបុត្រទាំង ៣ អង្គ កាលបើសោយទិវង្គតទៅហើយ បានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិអស់កាលដ៏យូរ ។

លុះមកដល់ពុទ្ធកាល ព្រះសមណគោតមសម្ពុទ្ធនៃយើង បុរសដែលរៀបចំទេយ្យធម៌ក្នុងពុទ្ធសម័យព្រះពុទ្ធផុស្សៈ បានមកកើតជាព្រះឥន្ទ្រ ហើយត្រឡប់មកកើតជាបុត្ររបស់រដ្ឋបាលសេដ្ឋី ក្នុងថុល្លកោដ្ឋិតនិគម គឺនិគមដែលមានជង្រុកស្រូវបរិបូណ៌នៅក្នុងដែនកុរុ មានឈ្មោះថា **រដ្ឋបាល** ។ សម្រាប់ការសិក្សាខាងដើម រដ្ឋបាលកុលបុត្របានទទួលការសិក្សាក្នុងលទ្ធិរបស់ព្រាហ្មណ៍ ជាការដើរតាមស្នាមវង្សត្រកូល ។

មូលហេតុការចេញបួស និងផលល្អរបស់លោក មានរឿងប្រាកដនៅក្នុង **បាលីរដ្ឋបាលសូត្រ** ក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានជោគ ទ្រង់ស្តេចយាងទៅក្នុងដែនកុរុ ព្រម

ដោយភិក្ខុសង្ឃជាច្រើន បានទៅដល់ថុល្លកោដ្ឋិតនិគម របស់អ្នកដែនកុរុទាំងឡាយ ។ ពួកព្រាហ្មណ៍ និងពួកគហបតី ជាអ្នកស្រុកថុល្លកោដ្ឋិតៈ បានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្រ ទ្រង់ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ឥឡូវនេះ ទ្រង់ពុទ្ធដំណើរមកក្នុងដែនកុរុជាមួយនឹងពួកភិក្ខុសង្ឃច្រើនអង្គ មកដល់ថុល្លកោដ្ឋិតនិគមហើយ កិត្តិស័ព្ទដ៏ល្អនៃព្រះគោតមដ៏ចម្រើននោះឯង ឮខ្ទ័រខ្ចាយយ៉ាងនេះថា ព្រះសម្ពុទ្ធអង្គនោះទ្រង់ជាព្រះអរហន្ត ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគតជាក់ច្បាស់នូវត្រៃលោក ព្រះអង្គជាបុគ្គលប្រសើរបំផុត ព្រះអង្គជាសារថីទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គភ្ញាក់រឭកហើយ ទ្រង់ចែកនូវធម៌ទាំងពួង ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងទេវតា និងមនុស្សដ៏សេស ដោយប្រាជ្ញាដ៏ក្រៃលែង ដោយព្រះអង្គឯង ហើយទ្រង់ប្រកាសនូវសេចក្តីនោះ ទ្រង់សម្តែងធម៌មានលំអបទដើម បទកណ្តាល និងបទចុងទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏បរិបូណ៌បរិសុទ្ធ ក៏ការបានឃើញព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនេះ ជាការប្រពៃពេក ។

**គ្រានោះ ពួកព្រាហ្មណ៍ និងគហបតី អ្នកថុល្លកោដ្ឋិតនិគម ម្នាក់ៗ**

មានការកោតសរសើរព្រះមានព្រះភាគជាម្ចាស់ នាំគ្នាចូលទៅគាល់ព្រះអង្គ ហើយសម្តែងនូវអាការផ្សេងៗ គ្នា គឺ ៖

ពួកខ្លះក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយចុះ ពួកខ្លះលើកដៃប្រណម្យចំពោះព្រះអង្គហើយ ទើបអង្គុយចុះ ពួកខ្លះប្រកាសឈ្មោះ និងគោត្ររបស់ខ្លួន ក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបអង្គុយចុះ និងពួកខ្លះទៀត មិនសម្តែងអាការណាៗ ទេ កាលដល់ទីគាល់ហើយ ក៏អង្គុយចុះក្នុងទីដ៏សមគួរប៉ុណ្ណោះ ។ ក្នុងគ្រានោះ មានកុលបុត្រម្នាក់ ឈ្មោះថារដ្ឋបាល ជាបុត្រនៃសេដ្ឋីនៅក្នុងថុល្លកោដ្ឋិតនិគមនោះ ក៏បានចូលទៅអង្គុយក្នុងទីនោះដែរ ។ កាលបើពួកជន អង្គុយស្ងប់ស្ងៀមល្អហើយ ព្រះមានព្រះភាគ ក៏សម្តែងធម៌ទេសនា ។

រដ្ឋបាលកុលបុត្រ ស្តាប់ព្រះធម៌ទេសនានោះហើយ មានសេចក្តីជ្រះថ្លា ក៏គិតថា ធម៌ដែលព្រះមានព្រះភាគសម្តែងហើយនេះ អ្នកដែលគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តឲ្យបរិបូណ៌បរិសុទ្ធល្អ ដូចជាស័ង្ខដែលគេខាត់ល្អហើយនោះទេ យើងគួរតែកោរសក់ កោរពុកមាត់ និងស្លៀកសំពត់កាសាវពស្ត្រ ហើយចេញបួស ។ ពេលពួកព្រាហ្មណ៍ និងគហបតីអ្នកថុល្លកោដ្ឋិតនិគម ថ្វាយបង្គំលាព្រះមានព្រះភាគត្រឡប់ទៅវិញ រដ្ឋបាលបានចូលទៅក្រាបទូលព្រះមានព្រះភាគថា ព្រះធម៌ដែលព្រះអង្គសម្តែងហើយ យកវាសដូចខ្ញុំព្រះអង្គ មិនងាយនឹងប្រព្រឹត្តឲ្យបរិសុទ្ធល្អ ដូចជា

ស័ទ្ធដែលគេខាត់ហើយនោះទេ ខ្ញុំព្រះអង្គមានបំណងនឹងកោរសក់ ពុក មាត់ ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាវៈ ចេញបព្វជ្ជា សូម ព្រះអង្គមេត្តាបំបួសខ្ញុំព្រះអង្គ ក្នុងសម្នាក់របស់ព្រះអង្គផង ។

ព្រះមានព្រះភាគ ទ្រង់មានមហាករុណាទិគុណ ត្រាស់សួរថា ម្នាលរដ្ឋបាល មាតាបិតាអនុញ្ញាតឲ្យអ្នកបួសហើយឬ ? រដ្ឋបាលកុល-បុត្រក្រាបទូលថា មិនទាន់ទេព្រះអង្គ ព្រះមានព្រះភាគត្រាស់ប្រាប់ថា ម្នាលរដ្ឋបាល តថាគត មិនបំបួសកុលបុត្រណា ដែលមាតាបិតាមិនបាន អនុញ្ញាតនោះទេ ។ រដ្ឋបាលក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះ អង្គនឹងអង្វរមាតាបិតា តាមដែលអាចបួសបាន ។ កាលរដ្ឋបាលក្រាបទូល ដូច្នេះហើយ ក៏ថ្វាយបង្គំលាព្រះអង្គត្រឡប់ទៅវិញ ហើយសូមអនុញ្ញាត ពីមាតាបិតាថា បពិត្រលោកឪពុក អ្នកម្តាយ ខ្ញុំបានស្តាប់ធម៌ព្រះមាន ព្រះភាគ មានសេចក្តីជ្រះថ្លា ចង់បួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ សូមលោកឪពុកអ្នកម្តាយ អនុញ្ញាតឲ្យខ្ញុំបានបួសផង ។ មាតាបិតាឮពាក្យ របស់រដ្ឋបាលហើយ ក៏និយាយហាមឃាត់ថា នែកូនជាទីស្រឡាញ់ អ្នក ជាបុត្រតែម្នាក់ ដែលមាតាបិតាពេញចិត្តក្រៃលែង, កូនជាអ្នកឋិតនៅក្នុង សេចក្តីសុខ មានអ្នកថែរក្សា មិនធ្លាប់ស្គាល់សេចក្តីទុក្ខណាមួយឡើយ ចូរកូននៅគ្រប់គ្រងផ្ទះ ប្រើប្រាស់ទ្រព្យសម្បត្តិ ហើយធ្វើបុណ្យទានចុះ ឪពុកម្តាយមិនអាចឲ្យកូនទៅបួសបានទេ ។

រដ្ឋបាលកុលបុត្រ បានស្តាប់ពាក្យបដិសេធរបស់មាតាបិតាហើយ ក៏នៅតែអង្វរ២-៣ដងទៀត ប៉ុន្តែគាត់នៅតែមិនអនុញ្ញាតឲ្យបួស ។ កាលបើរដ្ឋបាលគិតថា អញនឹងមិនបានទទួលយល់ព្រមពីមាតាបិតាជាប្រាកដ ទើបសម្រេចថា បើមាតាបិតាមិនឲ្យអញបួស អញនឹងដេកឲ្យស្លាប់នៅទីនេះ ឬនឹងបានទទួលការអនុញ្ញាតចេញបួសនៅទីនេះឯង កាលបើសម្រេចចិត្តយ៉ាងនេះហើយ រដ្ឋបាលក៏ចូលទៅដេកនៅក្នុងបន្ទប់របស់ខ្លួន មិនព្រមបរិភោគអាហាររហូត ៧ ថ្ងៃ ។ គ្រានោះ មាតាបិតា លុះបើដឹងថា រដ្ឋបាលមិនព្រមបរិភោគអាហារ ព្រោះការតូចចិត្តមិនបានចេញបួស ក៏បានចូលទៅអង្វររដ្ឋបាលឲ្យបរិភោគអាហារដោយសម្តី ដែលធ្លាប់និយាយបបួលឲ្យនៅជាយរាវាសនោះ ប៉ុន្តែរដ្ឋបាលនៅស្ងៀម មិនព្រមធ្វើតាមពាក្យលួងលោមរបស់មាតាបិតាឡើយ ។

មាតាបិតាពិចារណាឃើញថា រដ្ឋបាលមិនព្រមស្តាប់ពាក្យរបស់យើងទេ ក៏នាំគ្នាទៅរកពួកសម្លាញ់របស់រដ្ឋបាលឲ្យជួយនិយាយ ។ ពួកសម្លាញ់របស់រដ្ឋបាល ក៏នាំគ្នាទៅអង្វររដ្ឋបាលឲ្យនៅគ្រប់គ្រងផ្ទះ ដូចពាក្យដែលមាតាបិតាធ្លាប់និយាយលួងលោមអង្វររួចមកហើយ រដ្ឋបាលក៏មិនព្រម ទើបនាំគ្នាគិតថា បើរដ្ឋបាលមិនបានបួសទេ រដ្ឋបាលនឹងស្លាប់ តែបើរដ្ឋបាលបានបួសវិញ ពួកយើងទាំងអស់គ្នា នឹងបានឃើញក្នុងពេលខាងក្រោយ ទើបនាំគ្នាទៅរកមាតាបិតារបស់រដ្ឋបាល ប្រាប់ហេតុផលថា

លោកទាំងពីរ រដ្ឋបាលសម្រេចចិត្តថា បើមិនបានបួសទេ អញនឹងដេកស្លាប់ក្នុងទីនេះ ដូច្នេះ លោកទាំងពីរមិនបានឃើញគេជាពិតប្រាកដ បើអនុញ្ញាតឲ្យគេបព្វជ្ជា នឹងបានឱកាសឃើញគេមានសេចក្ដីសុខទុក្ខយ៉ាងណាក្នុងពេលក្រោយ សូមលោកទាំងពីរអនុញ្ញាតឲ្យរដ្ឋបាលបួសចុះ ។

មាតាបិតារបស់រដ្ឋបាល ស្ដាប់សម្ដីរបស់ពួកសម្លាញ់នោះហើយ ទើបសម្រេចចិត្តឲ្យរដ្ឋបាលចេញបួស តែស្នើសូមថា កាលបើបានបួសហើយ មេត្តាត្រឡប់មកឲ្យមាតាបិតាឃើញមុខផង ។ ពួកសម្លាញ់ស្ដាប់ពាក្យអនុញ្ញាតនោះហើយ ក៏នាំគ្នាទៅរករដ្ឋបាល ហើយប្រាប់ថា ឥឡូវនេះ លោកឪពុក អ្នកម្ដាយ ព្រមអនុញ្ញាតឲ្យអ្នកបួសហើយ ប៉ុន្តែគាត់ស្នើសូមថា បើបានបួសហើយ សូមត្រឡប់មកឲ្យពួកគាត់បានឃើញមុខផង ។ រដ្ឋបាលដឹងថា មាតាបិតាអនុញ្ញាតហើយ សប្បាយចិត្ត ក្រោកឡើង ជូតខ្លួន បរិភោគអាហារ ហើយក្រាបថ្វាយបង្គំលាមាតាបិតា ទៅគាល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មាតាបិតាអនុញ្ញាតហើយ សូមទ្រង់ប្រោសប្រទានបព្វជ្ជាដល់ខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគ ទ្រង់ឲ្យរដ្ឋបាលបព្វជ្ជាឧបសម្បទាជាភិក្ខុ ក្នុងព្រះសាសនាតាមសទ្ធាដ៏ខ្លាំងក្លារបស់គេនោះ ។

( ក្នុងគម្ពីរមនោរថបូរណីពោលថា រដ្ឋបាលបានបួសក្នុងសម្នាក់របស់ព្រះថេរៈមួយរូប តាមតម្រាស់របស់ព្រះមានព្រះភាគ ) ។

ចាប់ផ្ដើមពីរដ្ឋបាលចេញបួសហើយ លោកសេដ្ឋីដែលជាបិតា ក៏នៅតែមានសេចក្ដីចង្អៀតចង្អល់ ពេលបានឃើញភិក្ខុសង្ឃត្រូវកាត់ស្រុករបស់គាត់ៗ បានជេរពាល់ជង ព្រមទាំងពោលថា យើងមិនត្រូវការឃើញលោកម្ចាស់ទាំងឡាយទេ ព្រោះថា យើងមានកូនប្រុសតែម្នាក់ប៉ុណ្ណោះ យើងចង់ឃើញតែកូនយើង លោកម្ចាស់ទាំងឡាយនាំគ្នាមកធ្វើអ្វី ក្នុងទីនេះ ។ កាលរដ្ឋបាលបួសហើយបានកន្លះខែ ក៏បាននិមន្តទៅតាមព្រះមានព្រះភាគទៅកាន់ក្រុងសាវត្ថី ហើយទ្រង់ចូលទៅសម្រាកនៅវត្តជេតពន ។ ចំណែករដ្ឋបាលជាអ្នកមិនប្រមាទ បានគេចចេញចាកពួកគណៈមកនៅតែម្នាក់ឯង មិនជាប់ជំពាក់នឹងនរណាមួយ តាំងចិត្តបំពេញសមណធម៌ មានសេចក្ដីព្យាយាម ដុតកម្ដៅកិលេស មានខ្លួនបញ្ជូនទៅដើម្បីធម៌វិសេស មិនឃ្លាតត្រឹមតែមួយពេល មិនយូរប៉ុន្មាន ក៏សម្រេចកិច្ចនៃព្រហ្មចរិយធម៌ ជាព្រះអរហន្ត ជាអ្នកទ្រទ្រង់នូវគុណថ្នាក់ខ្ពស់បំផុត ដោយដឹងយ៉ាងជាក់ច្បាស់ថា ការវិលកើតវិលស្លាប់ក្នុងវដ្ដសង្សាររបស់ខ្លួនអស់ហើយ មិនមានវត្ថុដទៃ ដែលនឹងធ្វើដើម្បីមានសភាពយ៉ាងនេះទៀតឡើយ ។ ក្រោយពីលោកបានជាព្រះអរហន្តហើយ ចូលគាល់ព្រះបរមលោកនាថ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានបំណងនឹងទៅសួរសុខទុក្ខញោមប្រុសស្រី នៅថុល្លកោដ្ឋិតនិគម ដែនកុរុ ។

ព្រះសុគត ទ្រង់ជ្រាបវារៈចិត្តរបស់ព្រះរដ្ឋបាលត្ថេរថា រដ្ឋបាល

នឹងមិនលាចាកសិក្ខាបទ ត្រឡប់ទៅកាន់ភេទជាឃរាវាសវិញទេ ទើបត្រាស់អនុញ្ញាតថា ម្នាលរដ្ឋបាល ចូរអ្នកទៅចុះ ។ ព្រះថេរៈបានទទួលពុទ្ធានុញ្ញាតហើយ ក្រោកឡើងក្រាបថ្វាយបង្គំលា ធ្វើប្រទក្សិណព្រះភគវាហើយត្រឡប់មករៀបចំគ្រឿងបរិក្ខារ មានបាត្រចីវរជាដើមនិមន្តទៅកាន់ថុល្លកោដ្ឋិតនិគម ដែនកុរុ ហើយចូលទៅស្នាក់អាស្រ័យនៅក្នុងមិគាចីរៈដែលជាព្រះរាជឧទ្យានរបស់ព្រះបាទកោរព្យ ដែលស្ថិតនៅជិតនឹងកោដ្ឋិ-តនិគមនោះ ។ ព្រឹកឡើង ព្រះរដ្ឋបាលត្ថេរ គ្រងចីវរជាបរិមណ្ឌល កាន់យកបាត្រចេញទៅបិណ្ឌបាតក្នុងនិគមនោះ កាលបើនិមន្តទៅដោយលំដាប់ក៏បានទៅដល់ផ្ទះរបស់លោក ។ ពេលនោះ ញោមប្រុសរបស់លោកកំពុងឲ្យជាងកាត់សក់ កាលក្រឡេកឃើញព្រះរដ្ឋបាលត្ថេរនិមន្តមកអំពីចម្ងាយ ក៏ចាំមិនបាន ទើបស្រែកថា ពួកសមណៈក្បាលត្រងោលទាំងនេះបានឲ្យបព្វជ្ជាដល់បុត្រ ដែលជាទីស្រឡាញ់តែម្នាក់របស់យើង លោកម្ចាស់ទាំងឡាយមកក្នុងទីនេះធ្វើអ្វីទៀត ។ ព្រះរដ្ឋបាលត្ថេរ បិណ្ឌបាតក្នុងថ្ងៃនេះ មិនបានអាហារយ៉ាងណានីមួយ ពីផ្ទះញោមប្រុសរបស់លោកឡើយ សូម្បីតែសម្ដីដែលនឹងប្រាប់ថា សូមនិមន្តទៅមុខចុះ ក៏មិនបានឮត្រឡប់ឮតែពាក្យជេរប៉ុណ្ណោះ។ ( រឿងការត្រឡប់មកផ្ទះរបស់ព្រះរដ្ឋបាលក្នុងអដ្ឋកថាបបញ្ចសូទនីពោលថា ក្រោយពីព្រះថេរៈបួសបាន ១២ វស្សាទើបត្រឡប់មកសួរសុខទុក្ខញោមប្រុសស្រីរបស់លោក ដូច្នេះ ទើបញោម

ប្រុសស្រីចាំលោកមិនបាន នេះជាការសមហេតុផល ) ក្នុងពេលដែលញោមបណ្តេញចេញ ព្រះរដ្ឋបាលត្រូវញោមប្រុសដេរ ជាពេលដែលនាងទាសីរបស់ព្រះថេរៈកំពុងនាំយករបស់ដែលនៅសល់ពីល្ងាច (ទំផ្អូម) យកទៅចោល ។ ព្រះរដ្ឋបាលត្ថេរបានក្រឡេកឃើញ ទើបប្រាប់នាងទាសីនោះថា ប្រសិនបើនំនេះ ជារបស់ដែលគេត្រូវចាក់ចោលហើយ ចូរដាក់ក្នុងបាត្ររបស់អាត្មាមកចុះ ។ ចំណែកទាសី បានយកនំផ្អូមនោះទៅដាក់ក្នុងបាត្រព្រះថេរៈ ប៉ុន្តែក្នុងពេលដែលនាងចូលទៅជិត យកនំទៅដាក់ក្នុងបាត្រ នាងក៏ស្គាល់ស្លាកស្នាមនៅដៃ-ជើង ទាំងសំឡេងរបស់ព្រះថេរៈបាន ទើបប្រញាប់ចូលទៅប្រាប់ញោមប្រុសស្រី របស់ព្រះរដ្ឋបាលត្ថេរថា បពិត្រអ្នកម៉ែម្ចាស់ ឥឡូវនេះ ព្រះរដ្ឋបាលបាននិមន្តមកដល់ទីនេះហើយចា៎ស ។

ញោមស្រី កាលបានស្តាប់នាងទាសីពោលប្រាប់ដូច្នេះហើយ ទើបសប្បាយចិត្តថា ប្រសិនបើនាងនិយាយពាក្យពិត យើងនឹងឲ្យនាងរួចពីភាពជាទាសី កាលនិយាយរួចហើយ ក៏ប្រញាប់ប្រញាល់ទៅរកលោកសេដ្ឋី ឲ្យលោកដឹងថា ខណៈនេះ រដ្ឋបាលមកដល់ទីនេះហើយ ។ ក្នុងពេលនោះ ព្រះរដ្ឋបាលត្ថេរ កំពុងគង់ឆាន់នំដែលសល់ពីល្ងាចនៅក្បែរជញ្ជាំងសាលាមួយ ញោមប្រុសតាមមកទាន់ ក្រឡេកឃើញព្រះថេរៈគង់ឆាន់នំនោះ ទើបនិយាយឡើងដោយមិនបានគោរពកោតក្រែងថា នែរដ្ឋ-

បាលកូន មានដែរឬ លោកមកចាន់នំកុម្មាសផ្អូមទៅវិញ វដ្ឍបាលកូនគួរតែទៅឯផ្ទះរបស់យើងវិញ ។ ព្រះវដ្ឍបាលត្ថេរពោលថា គហបតី អាត្មាគ្មានផ្ទះទេ អាត្មាបានទៅផ្ទះរបស់គហបតីហើយ តែមិនបានអ្វីសោះ បានត្រឹមតែពាក្យជេរប៉ុណ្ណោះ លោកសេដ្ឋីបបួលថា វដ្ឍបាលចូរទៅផ្ទះរបស់យើងវិញ ។ ព្រះថេរៈបដិសេធថា កុំគហបតី ថ្ងៃនេះអាត្មាចាន់រួចហើយ លោកសេដ្ឋីក៏និមន្តព្រះវដ្ឍបាលទុកថា បើដូច្នោះ សូមនិមន្តចាន់ក្នុងថ្ងៃស្អែកចុះ ។ ព្រះវដ្ឍបាលត្ថេរ ទទួលនិមន្តរបស់ញោមដោយអាការៈនៅស្ងៀមតាមទំនៀមរបស់សាវកក្នុងព្រះសាសនា ។ ចំណែកញោម ជ្រាបថា ព្រះវដ្ឍបាលត្ថេរទទួលនិមន្តហើយ ក៏ត្រឡប់ទៅផ្ទះវិញ ហើយប្រើមនុស្សឲ្យលាបផ្ទះដោយទឹកដោះស្រស់ ព្រមទាំងឲ្យនាំយកមាសប្រាក់មកគរជាគំនរធំៗ ។

គំនរប្រាក់ និងមាសនោះ លិចក្បាលបុរស ហើយយកកន្ទេលមកបិទ តម្កល់អាសនៈទុកត្រង់កណ្ដាលគំនរប្រាក់ និងមាសនោះ និងព័ទ្ធវាំងននជុំវិញ ។ បន្ទាប់មក លោកសេដ្ឋីបង្គាប់ទៅអតីតកិរិយារបស់វដ្ឍបាល ដែលជាកូនប្រសាររបស់ខ្លួនថា នែកូនជាទីស្រឡាញ់របស់ឪពុក កូនចូរតាក់តែងខ្លួនឲ្យស្អាតជាទីបំផុត ដោយគ្រឿងអលង្ការផ្សេងៗ ។ លោកសេដ្ឋីប្រើឲ្យមនុស្សចាត់ចែងអាហារដ៏ប្រណីត លុះដល់ព្រឹកឡើង ឲ្យគេទៅនិមន្តព្រះថេរៈថា បពិត្រលោកម្ចាស់ កត្តកាលដល់ហើយ ។ ព្រះ

រដ្ឋបាលត្ថេរ ក៏និមន្តចូលទៅកាន់ផ្ទះរបស់ញោម ហើយគង់លើអាសនៈដែលគេរៀបចំទុក ។ ចំណែកញោមឃើញថា ជាឱកាសល្អហើយ ក៏ឲ្យពួកមនុស្សបើកកន្ទេល ដែលបិទបាំងគំនរមាសប្រាក់នោះចេញ ហើយពោលនឹងព្រះថេរៈថា នែរដ្ឋបាល នេះជាទ្រព្យមត៌ករបស់មាតាកូន នេះជាទ្រព្យមត៌ករបស់បិតាកូន នេះជាទ្រព្យមត៌ករបស់ជីតាកូន សូមកូនសឹកមកនៅគ្រប់គ្រងផ្ទះ ហើយប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ ធ្វើបុណ្យទានតាមសប្បាយចុះ ។ ព្រះរដ្ឋបាលតបថា ញោម បើញោមធ្វើតាមពាក្យរបស់អាត្មា សូមញោមប្រើឲ្យមនុស្សទាំងឡាយ ជញ្ជូនមាស និងប្រាក់នេះដោយរទេះ ហើយយកទៅចាក់ចោលក្នុងស្ទឹងគង្គាចុះ ព្រោះថា ការខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្ដីក្ដៅក្រហាយចង្អៀតចង្អល់ចិត្ត មិនមានដល់ញោម ដែលមានមាសប្រាក់នោះជាដើមហេតុ ។

គ្រានោះ មានស្ត្រីពីនាក់ ដែលធ្លាប់ផ្គងជាភរិយារបស់ព្រះរដ្ឋបាល បានចូលមកចាប់ជើងទាំងពីរ របស់ព្រះថេរៈម្នាក់ម្ខាង ហើយនិយាយថា បពិត្រលោកម្ចាស់ ពួកនាងអប្សរល្អស្អាតដូចម្ដេចទៅ ដែលធ្វើឲ្យលោកម្ចាស់បួសចោលខ្ញុំយ៉ាងនេះ ។ ព្រះថេរៈតបថា នែប្អូនស្រី អាត្មាមិនបានបួសព្រោះនាងទេពអប្សរទេ ។ ស្រីទាំងពីរនាក់នោះ កាលឮព្រះថេរៈហៅថា ប្អូនស្រីដូច្នេះ ក៏ដួលសន្លប់ក្នុងទីនោះ ។ ព្រះរដ្ឋបាលពោលនឹងញោមថា ញោម កុំធ្វើឲ្យអាត្មាលំបាកឡើយ ចូរប្រគេនចង្ហាន់បិណ្ឌបាត

មកដល់អាត្មាចុះ ។ លោកសេដ្ឋី បានរៀបចំអាហារដ៏ប្រណីតច្រើនយ៉ាង ប្រគេនដល់ព្រះថេរៈ ហើយនិយាយថា នៃរដ្ឋបាល ចូរកូនឆាន់ចង្ហាន់ចុះ ។ លំដាប់នោះ ព្រះរដ្ឋបាលដ៏មានអាយុ ឆាន់រួចលាងដៃហើយ ឈរសម្ដែងគាថាទាំងឡាយនេះថា ញោមចូរមើលនូវអត្តភាព ដែលសង្ខារធ្វើឲ្យវិចិត្រហើយ ជាទីប្រជុំនៃដំបៅ ផ្គុំឡើង ( ដោយឆ្អឹង ៣០០ កំណាត់ ) ក្តៅរោលរាល ដែលជនច្រើនគ្នាតែងត្រូវការ ជាកាយមិនទៀងទាត់ស្ថិតស្ថេរឡើយ ញោមចូរមើលរូប ដែលសង្ខារវិចិត្រហើយ ( ប្រកប ) ដោយកុណ្ឌលមណី ដែលរួបរឹតហើយ ដោយឆ្អឹង និងស្បែក ល្អដោយសារតែសំពត់ ជើងទាំងឡាយវិចិត្រហើយដោយទឹកល័ខ មុខមាត់លាបហើយដោយគ្រឿងលំអិត អាចឲ្យមនុស្សពាលវង្វេងបាន តែមិនអាចបំភាន់ដល់អ្នកស្វែងរកត្រើយ គឺព្រះនិព្វានបានឡើយ សក់ទាំងឡាយ ដែលវិចិត្រហើយឲ្យមានសណ្ឋាន ដូចជាក្រឡាចត្រង្គ ភ្នែកទាំងឡាយ លាបហើយដោយថ្នាំសម្រាប់បន្តក់ ល្មមឲ្យបុគ្គលពាលភាន់ភាំងបាន តែមិនអាចបំភាន់អ្នកស្វែងរកត្រើយបានឡើយ កាយស្អុយ ដែលបានប្រដាប់ហើយ ដូចជាបំពង់ថ្នាំដាក់ភ្នែកយ៉ាងថ្មីដ៏វិចិត្រ អាចបំភាន់បុគ្គលពាលបាន តែមិនអាចបំភាន់អ្នកស្វែងរកត្រើយបានឡើយ ព្រានម្រឹគដាក់នូវបង្កាត់ជាអន្ទាក់ តែម្រឹគមិនជាប់បង្កាត់ កាលបើព្រានអ្នកចងម្រឹគ កំពុងកន្ទក់កន្ទេញ អាត្មាបរិភោគបន្ទែរួចហើយ ត្រឡប់ទៅវិញ ។

កាលបើព្រះរដ្ឋបាលត្រេះឈរពោលគាថាដូច្នេះហើយ ទើបនិមន្ត ទៅកាន់ឧទ្យានឈ្មោះមិគាចីរៈ របស់ព្រះបាទកោរព្យៈ លុះចូលទៅដល់ ហើយ ក៏អង្គុយសម្រាកនៅក្នុងវេលាថ្ងៃ ក្បែរគល់ឈើមួយដើម ។ គ្រា នោះ ព្រះរាជាកោរព្យៈត្រាស់ហៅឧទ្យានបាលឈ្មោះ **មិគវៈ** ថា ម្នាលមិគវៈ ឯងចូររៀបចំឧទ្យានកូមិឈ្មោះមិគាចីរៈ យើងនឹងទៅមើលទីដ៏សប្បាយ ។ ឧទ្យានបាលឈ្មោះមិគវៈ ទទួលព្រះរាជឱង្ការព្រះបាទកោរព្យរាជថា ព្រះ ករុណាថ្លៃវិសេស រួចហើយក៏រៀបចំឧទ្យានមិគាចីរៈ បានឃើញព្រះរដ្ឋបាល ដ៏មានអាយុ កំពុងគង់សម្រាកក្នុងវេលាថ្ងៃ ក្បែរគល់ឈើមួយដើម លុះ ឃើញហើយ ក៏ចូលទៅគាល់ព្រះបាទកោរព្យៈ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ឧទ្យានមិគាចីរៈរបស់ ព្រះអង្គស្អាតបាតហើយ ប៉ុន្តែក្នុងទីនោះមានកុលបុត្រឈ្មោះរដ្ឋបាលជាកូន របស់ត្រកូលដ៏ប្រសើរ ក្នុងថុល្លកោដ្ឋិតនិគមនេះឯង ដែលព្រះអង្គតែង ទ្រង់សរសើរដល់រឿយៗ នោះ ឥឡូវនេះ លោកគង់សម្រាកក្នុងវេលា ថ្ងៃ ក្បែរគល់ឈើមួយដើម ។ ព្រះបាទកោរព្យៈត្រាស់ថា ម្នាលមិគវៈ សម្លាញ់ ណ្ហើយចុះ ដំណើរទៅលេងទីឧទ្យានថ្ងៃនេះ ឥឡូវនេះ ចូរឈប់ សិនចុះ យើងនឹងទៅអង្គុយជិតព្រះរដ្ឋបាលដ៏ចម្រើននោះវិញ ។ ទើបព្រះ បាទកោរព្យៈត្រាស់ថា ចូរអ្នកទាំងឡាយចំណាយខាទនីយភោជនីយាហារ ដែលបានតាក់តែងហើយទាំងអស់នោះ ហើយព្រះអង្គឲ្យទឹមយានដ៏ល្អៗ

ឡើងកាន់យានល្អ បររចេញពីចុល្លកោដ្ឋិតនិគមដោយយានល្អៗ ដោយ អានុភាពនៃស្ដេចជាធំ ដើម្បីទ្រង់ទតព្រះរដ្ឋបាលមានអាយុ ។ ទីដែលយាន ទៅបានត្រឹមណា ក៏ទ្រង់យាងទៅដោយយានត្រឹមនោះ ហើយទ្រង់ចុះពី យាន យាងដោយព្រះបាតទទេ ដោយបរិស័ទអឺងកង ចូលសំដៅទៅរក ព្រះរដ្ឋបាលមានអាយុ លុះចូលទៅដល់ហើយ ក៏ទ្រង់រាក់ទាក់ជាមួយនឹង ព្រះរដ្ឋបាលមានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យដែល គួររឭកហើយ ទើបឈរក្នុងទីដ៏សមគួរ ។ លុះព្រះបាទកោរព្យៈទ្រង់ឋិត ក្នុងទីដ៏សមគួរហើយ ទ្រង់មានព្រះរាជឱង្ការ នឹងព្រះរដ្ឋបាលមានអាយុ យ៉ាងនេះថា ព្រះរដ្ឋបាលដ៏ចម្រើន និមន្តគង់លើកម្រាលផ្កានេះចុះ ។ ព្រះ រដ្ឋបាលថ្វាយព្រះពរថា ណ្ហើយមហារាជ សូមព្រះអង្គទ្រង់គង់ចុះ អាត្មា ភាពអង្គុយលើអាសនៈជារបស់ខ្លួនហើយ ។ ព្រះបាទកោរព្យៈ ក៏ទ្រង់ គង់លើអាសនៈ ដែលក្រាលថ្វាយហើយ ។

លុះព្រះបាទកោរព្យៈ ទ្រង់គង់ស្ងប់ហើយ ក៏មានព្រះរាជឱង្ការនេះ នឹងព្រះរដ្ឋបាលមានអាយុថា បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្ដីសាប សូន្យ ៤ យ៉ាងនេះ ដែលពួកមនុស្សខ្លះ ក្នុងលោកនេះជួបប្រទះហើយ តែងកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈចេញចាក ផ្ទះចូលទៅកាន់ផ្នួស ។ សេចក្ដីសាបសូន្យ ៤ យ៉ាង តើដូចម្ដេច ? គឺ សេចក្ដីសាបសូន្យព្រោះជរា ១ សេចក្ដីសាបសូន្យព្រោះព្យាធិ ១ សេចក្ដី

សាបសូន្យព្រោះភោគៈ ១ សេចក្ដីសាបសូន្យព្រោះញាតិ ១ ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្ដីសាបសូន្យព្រោះជរា តើដូចម្ដេច ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មនុស្សពួកខ្លះក្នុងលោកនេះ ជាមនុស្សជរា ចម្រើនហើយដោយវ័យ មានអាយុច្រើន ដល់នូវសេចក្ដីថមថយដោយលំដាប់ ។ មនុស្សនោះពិចារណាឃើញច្បាស់ថា ឥឡូវនេះ អាត្មាអញគ្រាំគ្រា ចម្រើនដោយវ័យចាស់ មានអាយុច្រើន ដល់នូវសេចក្ដីថមថយដោយលំដាប់ អាត្មាអញមិនងាយនឹងធ្វើឲ្យបានភោគៈ ដែលមិនទាន់បានផង មិនអាចនឹងធ្វើភោគៈ ដែលរកបានហើយ ឲ្យចម្រើនឡើងផង បើដូច្នោះគួរតែអាត្មាអញកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស ។ មនុស្សនោះ ជួបប្រទះសេចក្ដីសាបសូន្យព្រោះជរានោះហើយ ទើបបានកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចម្រើន នេះហៅថាសេចក្ដីសាបសូន្យព្រោះជរា ។ ដូចយ៉ាងព្រះរដ្ឋបាលដ៏ចម្រើន ឥឡូវនេះនៅក្មេងកំលោះ មានសក់ខ្មៅរលើប កំពុងប្រកបដោយវ័យដ៏ចម្រើនដែលជាបឋមវ័យ ព្រះរដ្ឋបាលដ៏ចម្រើន មិនឈ្មោះថាមានសេចក្ដីសាបសូន្យព្រោះជរានោះទេ ។ ព្រះរដ្ឋបាលដ៏ចម្រើន តើលោកម្ចាស់ដឹងដូចម្ដេចឃើញដូចម្ដេច ឮដូចម្ដេច បានជាលោកម្ចាស់ចេញចាកផ្ទះទៅបួស ?

បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្ដីសាបសូន្យព្រោះព្យាធិ តើ

ដូចម្ដេច ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មនុស្សខ្លះក្នុងលោកនេះ ជាអ្នកមានអាពាធ ដល់នូវសេចក្ដីទុក្ខឈឺធ្ងន់ ។ មនុស្សនោះពិចារណាឃើញច្បាស់ថា ឥឡូវនេះ អាត្មាអញមានអាពាធ ដល់នូវសេចក្ដីទុក្ខឈឺធ្ងន់ ថែមទាំងអាត្មាអញមិនងាយនឹងធ្វើភោគៈ ដែលមិនទាន់បានឲ្យបានផង មិនអាចនឹងធ្វើភោគៈដែលបានហើយ ឲ្យបានចម្រើនឡើងផង បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស ។ មនុស្សនោះ ជួបប្រទះនូវសេចក្ដីសាបសូន្យព្រោះព្យាធិនោះហើយ ទើបចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចម្រើន នេះហៅថា សេចក្ដីសាបសូន្យព្រោះព្យាធិ ។ ចំណែកខាងព្រះរដ្ឋបាលដ៏ចម្រើន ឥឡូវនេះ គ្មានអាពាធ ឥតទុក្ខ ប្រកបដោយគហណីធាតុ គឺកម្មជតេជោធាតុកំពុងឲ្យផលស្មើ គឺមិនត្រជាក់ពេក មិនក្ដៅពេក ព្រះរដ្ឋបាលដ៏ចម្រើន មិនមានសេចក្ដីសាបសូន្យព្រោះព្យាធិនោះទេ ។ ព្រះរដ្ឋបាលដ៏ចម្រើន តើលោកម្ចាស់ដឹងដូចម្ដេច ឃើញដូចម្ដេច ឮដូចម្ដេច បានជាលោកម្ចាស់ ចេញចាកផ្ទះទៅបួស ?

បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្ដីសាបសូន្យព្រោះភោគៈ តើដូចម្ដេច ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មនុស្សខ្លះក្នុងលោកនេះ ជាមនុស្សស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន តែភោគៈទាំងអស់របស់អ្នកនោះ ក៏ដល់នូវការអស់រលីងទៅដោយលំដាប់ ។ អ្នកនោះពិចារណា

ឃើញថា អាត្មាអញធ្លាប់ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មកពីមុនហើយ តែភោគៈទាំងនោះរបស់អាត្មាអញនោះ បានដល់នូវការអស់រលីងទៅដោយលំដាប់ហើយ ថែមទាំងអាត្មាអញ មិនអាចនឹងធ្វើភោគៈដែលមិនទាន់បាន ឲ្យបានដោយងាយផង មិនអាចនឹងធ្វើភោគៈដែលបានហើយ ឲ្យចម្រើនឡើងបានផង បើដូច្នោះ គួរតែអាត្មាអញទៅបួស ។ អ្នកនោះជួបប្រទះនូវសេចក្តីសាបសូន្យព្រោះភោគៈនោះហើយ ក៏កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចម្រើន នេះហៅថា សេចក្តីសាបសូន្យព្រោះភោគៈ ។ ចំណែកព្រះរដ្ឋបាលវិញ ជាកូនអ្នកមានត្រកូលដ៏ប្រសើរ ក្នុងថុល្លកោដ្ឋិតនិគមនេះឯង ព្រះរដ្ឋបាលដ៏ចម្រើន មិនឈ្មោះថា មានសេចក្តីសាបសូន្យព្រោះភោគៈទេ ។ ព្រះរដ្ឋបាលដ៏ចម្រើន តើលោកម្ចាស់ដឹងដូចម្តេច ឃើញដូចម្តេច ឮដូចម្តេច បានជាលោកម្ចាស់ចេញចាកផ្ទះទៅបួស ?

បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីសាបសូន្យព្រោះញាតិ តើដូចម្តេច ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មនុស្សខ្លះក្នុងលោកនេះ មានពួកមិត្រ អាមាត្យ ញាតិសាលោហិតច្រើន ជនជាញាតិទាំងនោះ របស់អ្នកនោះ ក៏ដល់នូវសេចក្តីព្រាត់ប្រាសទៅដោយលំដាប់ ។ អ្នកនោះពិចារណាឃើញច្បាស់ថា ពីដើម អាត្មាអញមានពួកមិត្រ អាមាត្យ ញាតិសា-

លោហិតច្រើន តែពួកជនជាញាតិទាំងនោះ របស់អាត្មាអញនោះ ក៏ដល់នូវសេចក្តីព្រាត់ប្រាសទៅដោយលំដាប់ ថែមទាំងអាត្មាអញ មិនងាយនឹងធ្វើមិត្រ អាមាត្យ ញាតិសាលោហិត ដែលមិនទាន់បានឲ្យបានផង មិនអាចនឹងធ្វើមិត្រ អាមាត្យ ញាតិសាលោហិត ដែលបានហើយ ឲ្យចម្រើនឡើងបានផង បើដូច្នោះ គួរតែអាត្មាអញទៅបួស ។ អ្នកនោះជួបប្រទះសេចក្តីសាបសូន្យនោះ ក៏កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចម្រើន នេះហៅថាសេចក្តីសាបសូន្យព្រោះញាតិ ។ ចំណែកលោកវិញ មានពួកមិត្រ និងអាមាត្យ ញាតិសាលោហិតច្រើនក្នុងថុល្លកោដ្ឋិតនិគមនេះឯង ព្រះរដ្ឋបាលដ៏ចម្រើន មិនឈ្មោះថា មានសេចក្តីសាបសូន្យព្រោះញាតិទេ ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន តើលោកម្ចាស់ដឹងដូចម្តេច ឃើញដូចម្តេច ឮដូចម្តេច បានជាលោកម្ចាស់ចេញចាកផ្ទះទៅបួស ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីសាបសូន្យទាំង ៤ យ៉ាងនេះ ជាហេតុឲ្យមនុស្សក្នុងលោកនេះ ដែលជួបប្រទះហើយតែងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈចេញទៅបួស ។ ព្រះរដ្ឋបាលដ៏ចម្រើន មិនមានសេចក្តីសាបសូន្យទាំងនោះទេ ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន តើលោកម្ចាស់ ដឹងដូចម្តេច ឃើញដូចម្តេច ឮដូចម្តេច បានជាលោកម្ចាស់ចេញចាកផ្ទះទៅបួស ?

ព្រះរដ្ឋបាលថ្វាយព្រះពរថា បពិត្រមហារាជ មានធម្មុទ្ទេស ៤ ប្រការ ដែលព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយ ដែលអាត្មាភាព បានដឹងផង ឃើញផង ឮហើយផង ទើបចេញចាកផ្ទះទៅបួស ។ ធម្មុទ្ទេស ៤ យ៉ាង តើដូចម្តេច ? បពិត្រមហារាជ ធម្មុទ្ទេសទី ១ ព្រះសម្ពុទ្ធព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយថា សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅរកមរណៈ ដូច្នេះ ដែលអាត្មាភាព បានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស ។ បពិត្រមហារាជ ធម្មុទ្ទេសទី ២ ព្រះលោកនាថអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយថា សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹងឡើយ ដូច្នេះ ដែលអាត្មាភាព បានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស ។ បពិត្រមហារាជ ធម្មុទ្ទេសទី ៣ ព្រះមានបុណ្យអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយថា សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួង ដូច្នេះ ដែលអាត្មាភាព បានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស ។ បពិត្រមហារាជ ធម្មុទ្ទេសទី ៤ ព្រះមានជោគព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយថា សត្វលោកមានតែសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំនៃតណ្ហា ដូច្នេះ ដែលអាត្មា

ភាព បានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស ។ បពិត្រមហារាជ ធម្មទេសទាំង ៤ យ៉ាងនេះឯង ដែលព្រះសក្យមុនី ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយ ជាធម៌ដែលអាត្មាភាព បានដឹង បានឃើញ បានស្តាប់ ហើយចេញចាកផ្ទះទៅកាន់ផ្នួស ។

ព្រះបាទកោរព្យៈត្រាស់សួរថា ព្រះរដ្ឋបាលដ៏ចម្រើន សំដែងថា សត្វលោកមិនទៀង ត្រូវជរានាំចូលទៅរកមរណៈ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្តេច ? ថ្វាយព្រះពរមហារាជ កាលដែលមហាបពិត្រមានព្រះជន្មចូលក្នុងវ៉ាង ២០ ឆ្នាំផង គ្រប់ ២០ ឆ្នាំហើយផង បានស្ទាត់ខាងវិជ្ជាដំរីផង ស្ទាត់ខាងវិជ្ជាសេះផង ស្ទាត់ខាងវិជ្ជារថផង ស្ទាត់ខាងវិជ្ជាធ្នូផង ស្ទាត់ខាងវិជ្ជាដងដាវផង បរិបូណ៌ដោយកម្លាំង ព្រះឩរូ ( ភ្លៅ ) បរិបូណ៌ដោយកម្លាំងព្រះពាហុ ( ដើមដៃ ) អង់អាច ចុះសង្គ្រាមបាន តើព្រះអង្គសម្គាល់សេចក្តីក្នុងពេលនោះ ថាដូចម្តេច ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន កាលដែលខ្ញុំមានអាយុចូលក្នុងវ៉ាង ២០ ឆ្នាំផង គ្រប់ ២០ ឆ្នាំហើយផង បានស្ទាត់ខាងវិជ្ជាដំរី ស្ទាត់ខាងវិជ្ជាសេះផង ស្ទាត់ខាងវិជ្ជារថផង ស្ទាត់ខាងវិជ្ជាធ្នូផង ស្ទាត់ខាងវិជ្ជាដងដាវផង មានកម្លាំងភ្លៅ មានកម្លាំងដៃ អង់អាច ចុះសង្គ្រាមបាន បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ជួនណាខ្ញុំសម្គាល់ហាក់ដូច

ជាអ្នកមានឫទ្ធិ មិនសម្គាល់ឃើញអ្នកណាថា ស្មើដោយកម្លាំងរបស់ខ្លួនបាន ។ មហាបពិត្រ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច ឥឡូវនេះ ព្រះអង្គបរិបូណ៌ដោយកម្លាំងព្រះឱរូ បរិបូណ៌ដោយកម្លាំងព្រះពាហុ អង់អាចចុះសង្គ្រាមបាន ដូចកាលពីដើមយ៉ាងនោះដែរឬ ? បពិត្រព្រះរដ្ឋ-បាលដ៏ចម្រើន ហេតុនោះមិនដូច្នោះទេ ឥឡូវនេះ ខ្ញុំជរាហើយ ចម្រើនដោយវ័យចាស់ មានអាយុច្រើន ដល់នូវសេចក្តីថមថយ ដោយលំដាប់វ័យខ្ញុំដល់ ៨០ ឆ្នាំថ្វាយហើយ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ជួនកាលខ្ញុំគិតថា នឹងជាន់ត្រង់នេះ ខ្ញុំត្រឡប់ជាជាន់កន្លែងឯទៀតវិញ ។ បពិត្រមហារាជ ពាក្យថា សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ ( រកមរណៈ ) នេះឯង ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ត្រាស់សំដៅដល់ហេតុនោះ ដែលអាត្មាភាពបានដឹង បានឃើញ បានឮ ហើយចេញចាកផ្ទះទៅបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ហេតុដែលមិនធ្លាប់កើត ស្រាប់តែកើតបានពាក្យថា សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ ( រកមរណៈ ) ដែលព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ត្រាស់ហើយនេះ ប្រាកដជាទ្រង់សម្តែងត្រូវពិតហើយ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ ( រកមរណៈ ) ពិតមែន បពិត្រ

ព្រះរដ្ឋបាលដ៏ចម្រើន តែក្នុងរាជត្រកូលនេះ មានពួកពលដំរីផង ពួកពលសេះផង ពួកពលរថផង ពួកពលថ្មើរជើងផង ចាំការពារសេចក្តីអន្តរាយដល់ខ្ញុំដែរ ។

ព្រះរដ្ឋបាលដ៏ចម្រើនសម្តែងថា សត្វលោកមិនមានគ្រឿងការពារមិនមានទីពឹង បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្តេច ? បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច ព្រះអង្គធ្លាប់មានអាពាធ ទាល់តែផ្ទំដាបលើទីបន្ទំខ្លះដែរឬ ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំធ្លាប់មានអាពាធទាល់តែដាបនៅលើបន្ទំដែរ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ជួនណាពួកមិត្រ អាមាត្យ ញាតិសាលោហិតឈរចោមរោមខ្ញុំនិយាយថា ព្រះបាទកោរព្យ: ទ្រង់នឹងសោយទិវង្គតឥឡូវនេះ ព្រះបាទកោរព្យ: ទ្រង់នឹងសោយទិវង្គតឥឡូវនេះ ។ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច ព្រះអង្គបានពួក មិត្រ អាមាត្យ ញាតិសាលោហិតទាំងនោះ ដោយការអង្វរឲ្យជួយថា ពួកមិត្រ អាមាត្យ ញាតិសាលោហិតដ៏ចម្រើនរបស់អញ ចូរនាំគ្នាមក សូមឲ្យអ្នកទាំងអស់គ្នារំលែកយកវេទនានោះ ដែលជាហេតុឲ្យខ្ញុំសោយវេទនាបានស្រាលបន្តិចដូច្នេះដែរឬ ឬក៏ព្រះអង្គសោយវេទនាតែមួយព្រះអង្គឯងទេ ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំមិនបានពួកមិត្រ អាមាត្យ ញាតិសាលោហិតទាំងនោះ ដោយសេចក្តីអង្វរថា សូមឲ្យអ្នកទាំងអស់

គ្មានវែលែកយកវេទនានេះ ដែលជាហេតុឲ្យខ្ញុំបានសោយវេទនាស្រាលបន្តិច ដូច្នេះទេ មានតែខ្ញុំត្រូវសោយវេទនានោះ តែម្នាក់ឯងប៉ុណ្ណោះ ។ បពិត្រមហារាជ ត្រង់ពាក្យថា សត្វលោកឥតមានគ្រឿងការពារ ឥតទីពឹង នេះឯងដែលព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដៅយកហេតុនោះ ដែលអាត្មាភាពបានដឹងបានឃើញ បានឮហើយ ចេញចាកផ្ទះទៅបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ហេតុដែលមិនធ្លាប់កើត ស្រាប់តែកើតមាន ពាក្យថា សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹង ដែលព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយនេះ ពិតជាសុភាសិតដែលត្រឹមត្រូវ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ព្រោះថា សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹងពិតមែន បពិត្រព្រះរដ្ឋបាលដ៏ចម្រើន តែក្នុងរាជត្រកូលនេះ មានមាសប្រាក់ច្រើន តាំងនៅលើផែនដីខ្លះ តាំងនៅលើធ្នើរខ្លះដែរ ។ ព្រះរដ្ឋបាលដ៏ចម្រើនសម្តែងថា សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួងទៅ ដូច្នេះ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្តេច ? បពិត្រព្រះរាជសម្ភារ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច ? ឥឡូវនេះ ព្រះអង្គបានឆ្អែតស្កប់ស្កល់ សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង ៥

យ៉ាងណា តទៅលោកខាងមុខទៀត ព្រះអង្គនឹងបានដូចបំណងថា អាត្មាអញគង់បានផ្អែតស្កប់ស្កល់ សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង៥ នេះឯង យ៉ាងនោះទៀតដែរឬ ឬក៏ពួកជនដទៃនឹងគ្រប់គ្រងភោគសម្បត្តិនេះ ( ជំនួស ) ចំណែកព្រះអង្គនឹងទ្រង់ស្តេចទៅតាមយថាកម្ម ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ឥឡូវខ្ញុំបានផ្អែតស្កប់ស្កល់សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង ៥ យ៉ាងណា ដល់ទៅខាងមុខ ខ្ញុំនឹងមិនបានដូចបំណងថា ខ្ញុំគង់បានផ្អែតស្កប់ស្កល់សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង ៥ នេះឯង យ៉ាងនោះទៀតទេ តាមពិតពួកជនដទៃគ្រប់គ្រងភោគសម្បត្តិ ( ជំនួស ) ចំណែកខាងខ្ញុំនឹងទៅតាមយថាកម្ម បពិត្រមហារាជត្រង់ពាក្យថា សត្វលោកសុទ្ធតែគ្មានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងអស់ នេះឯង ដែលព្រះមានបុណ្យ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សំដៅយកហេតុនោះ ដែលអាត្មាភាពបានដឹងផង បានឃើញផង បានឮផង ហើយចេញចាកផ្ទះទៅបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ហេតុដែលមិនធ្លាប់កើត ស្រាប់តែកើតមាន ពាក្យថា សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន សុទ្ធតែលះបង់នូវរបស់ទាំងពួងហើយទៅ ដែលព្រះមានបុណ្យ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយនេះ ពិតជាសុភាសិតដែលត្រឹម

ត្រូវ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ព្រោះថា សត្វលោកស៊ុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់នូវរបស់ទាំងពួងហើយទៅមែន ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ដែលលោកម្ចាស់សម្ដែងថា សត្វលោកស៊ុទ្ធតែមានសេចក្ដីខ្វះខាត មិនចេះឆ្អែត ជាខ្ញុំនៃតណ្ហា បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្ដីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្ដេច? បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះថាដូចម្ដេច ព្រះអង្គគ្រប់គ្រងដែនកុរុ ដែលជាដែនស្តុកស្តម្ភហើយឬ ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំគ្រប់គ្រងដែនកុរុ ដែលជាដែនស្តុកស្តម្ភមែន ។ បពិត្រមហារាជ ព្រះអង្គ សម្គាល់សេចក្ដីនោះដូចម្ដេច បុរសរបស់ព្រះអង្គក្នុងទីនេះ ដែលគួរជឿពាក្យ គួរទទួលស្ដាប់ពាក្យបាន មកអំពីទិសខាងកើត ។ បុរសនោះ ចូលមកគាល់ព្រះអង្គ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គជ្រាប ខ្ញុំព្រះអង្គទើបនឹងមកអំពីទិសខាងកើត បានឃើញជនបទធំក្នុងជនបទនោះ ជាជនបទមាំមួន ស្តុកស្តម្ភ មានជនច្រើន មានមនុស្សកុះករ ក្នុងជនបទនោះ មានពួកពលដំរី ពលសេះ ពលរថ និងពលថ្មើរជើងជាច្រើន ក្នុងជនបទនោះមានភ្លុក និងស្បែកជាច្រើន ក្នុងជនបទនោះ មានមាសប្រាក់ដែលគេមិនទាន់ធ្វើខ្លះ ធ្វើរួចហើយខ្លះជាច្រើន ក្នុងជនបទនោះ មានបរិវារស្ត្រីជាច្រើន ព្រះអង្គអាចនឹងច្បាំងយកបាន ដោយកម្លាំងពលត្រឹមប៉ុណ្ណោះ បពិត្រមហារាជ សូមព្រះអង្គ

ច្បាំងយក តើព្រះអង្គនឹងធ្វើជនបទនោះដូចម្តេច ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំត្រូវតែច្បាំងដណ្តើមយកជនបទនោះ មកគ្រប់គ្រងឲ្យបាន ។ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច បុរសរបស់ព្រះអង្គក្នុងទីនេះ ដែលគួរជឿពាក្យ គួរស្តាប់ពាក្យ បានមកអំពីទិសខាងលិច... អំពីទិសខាងជើង... អំពីទិសខាងត្បូង... អំពីប្រទេសខាងនាយសមុទ្ទ ។ បុរសនោះ ចូលមកគាល់ព្រះអង្គហើយ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គទ្រង់ជ្រាប ខ្ញុំព្រះអង្គទើបនឹងមកអំពីប្រទេសខាងនាយសមុទ្ទ បានឃើញជនបទធំនៅក្បែរសមុទ្ទនោះ ជាជនបទស្តុកស្តម្ភមាំមួន មានជនច្រើន មានមនុស្សកុះករ ក្នុងជនបទនោះ មានពលដំរី ពលសេះ ពលរថ និងពលថ្មើរជើងច្រើន ក្នុងជនបទនោះ មានភ្លុក និងស្បែកច្រើន ក្នុងជនបទនោះ មានមាសប្រាក់ដែលគេរចនាហើយខ្លះ មិនទាន់រចនាខ្លះជាច្រើន ក្នុងជនបទនោះ មានបរិវារស្ត្រីច្រើន ព្រះអង្គអាចច្បាំងយកដោយពលត្រឹមប៉ុណ្ណោះ បពិត្រមហារាជ សូមព្រះអង្គច្បាំងយក តើព្រះអង្គនឹងធ្វើជនបទនោះដូចម្តេច ? បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំត្រូវតែច្បាំងដណ្តើមយកជនបទនោះគ្រប់គ្រងឲ្យបាន ។ ព្រះរដ្ឋបាលថ្វាយព្រះពរថា បពិត្រមហារាជ ពាក្យថា សត្វលោកសុទ្ធតែខ្វះខាត មិនចេះឆ្អែត ជាខ្ញុំនៃតណ្ហា នេះឯងដែលព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញ

ច្បាស់ ទ្រង់ត្រាស់សំដៅយកហេតុនោះ ដែលអាត្មាភាពបានដឹង បាន ឃើញ បានឮ ហើយចេញចាកផ្ទះមកបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មិនដែលមានឡើយ ពាក្យ ដែលថា សត្វលោកសុទ្ធតែមានសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំ នៃតណ្ហា ដែលព្រះមានបុណ្យ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយនេះ ពិតជាសុភាសិតដែល ត្រឹមត្រូវ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ព្រោះថា សត្វលោកសុទ្ធតែមាន សេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំនៃតណ្ហាពិតមែន ។

បន្ទាប់អំពីការសន្ទនាជាមួយនឹងព្រះបាទកោរព្យៈហើយ ព្រះរដ្ឋ-បាលត្ថេរ បានសម្តែងធម្មកថាតទៅទៀត ដូចមានក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ រដ្ឋបាលសូត្រ** និងក្នុង**គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថា ៖

អ្នកចូរមើលនូវអត្តភាព ដែលធ្វើឲ្យវិចិត្រ ជាទីប្រជុំនៃដំបៅ ដែល តាំងឡើងព្រមហើយ ( ដោយឆ្អឹងបីរយកំណាត់ ) ជាអត្តភាពក្តៅក្រហាយ ដែលជនពាលត្រិះរិះដោយច្រើន ជាអត្តភាពមិនទៀងទាត់ស្ថិតស្ថេរ ។ អ្នក ចូរមើលនូវរូប ដែលធ្វើឲ្យវិចិត្រដោយកែវមណី និងកុណ្ឌល ដែលឆ្អឹង និងស្បែករួបរឹតហើយ ( រូបនោះ ) រមែងល្អដោយសារសំពត់ទាំង ឡាយ ។ ជើងទាំងឡាយលាបដោយល័ខស្រស់ មុខលាបដោយគ្រឿង លំអិត អាចញុំាងជនពាលឲ្យវង្វេង តែមិនអាចញុំាងបុគ្គលអ្នកស្វែងរក

នូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានទេ ។ សក់ទាំងឡាយ ដែលគេរចនាដូចជាក្រឡាចត្រង្គ ភ្នែកទាំងឡាយ លាបដោយថ្នាំសម្រាប់បន្តក់ភ្នែក អាចញ៉ាំងជនពាលឲ្យវង្វេង តែមិនអាចញ៉ាំងបុគ្គល អ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានឡើយ ។ កាយស្អុយ ដែលគេតាក់តែងហើយ ដូចជាទាឡិសម្រាប់ដាក់ថ្នាំបន្តក់ ដែលគេវិចិត្រហើយថ្មីៗ អាចញ៉ាំងជនពាលឲ្យវង្វេង តែមិនអាចញ៉ាំងបុគ្គលអ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានឡើយ ។ ព្រានម្រឹគដាក់នូវអន្ទាក់ ម្រឹគក៏មិនបានប៉ះពាល់នូវអន្ទាក់ ហើយស៊ីនូវចំណី កាលដែលព្រានម្រឹគកំពុងកន្ទក់កន្ទេញ ( ក៏បោលចេញទៅ យ៉ាងណាមិញ ) ពួកយើងក៏ដើរចេញទៅ ( យ៉ាងនោះដែរ ) ។ អន្ទាក់របស់ព្រានម្រឹគដាច់ហើយ ម្រឹគក៏មិនប៉ះពាល់នូវអន្ទាក់ ហើយស៊ីនូវចំណី កាលព្រានម្រឹគកំពុងសោកស្តាយ ( ក៏បោលចេញទៅ យ៉ាងណាមិញ ) ពួកយើងក៏ដើរចេញទៅ ( យ៉ាងនោះដែរ ) ។ អាត្មាបានឃើញនូវមនុស្សទាំងឡាយ បរិបូណ៌ដោយទ្រព្យសម្បត្តិក្នុងលោក ( ពួកមនុស្សទាំងនោះ ) លុះបានទ្រព្យគាប់ចិត្តហើយ មិនឲ្យ ( ដល់បុគ្គលណាមួយឡើយ ) ព្រោះតែសេចក្តីវង្វេង ។ ពួកមនុស្សបានទ្រព្យហើយ ក៏ធ្វើនូវការសន្សំទុក ទាំងប្រាថ្នាក្នុងកាមដ៏លើសលប់ ។

ព្រះរាជាឈ្នះនូវផែនដី ដែលព្រះអង្គរឹបជាន់បានហើយ នៅគ្រប់គ្រងផែនដី មានសាគរជាទីបំផុត មានសភាពមិនឆ្អែតនឹងត្រើយសមុទ្រ

ខាងអាយ ក៏ប្រាថ្នានូវត្រើយសមុទ្រខាងនាយ ។ ព្រះរាជាក្តី ពួកមនុស្សដទៃច្រើននាក់ក្តី មិនទាន់ប្រាសចាកតណ្ហា រមែងដល់នូវសេចក្តីស្លាប់ គឺថាជាអ្នកមានសេចក្តីខ្វះខាត លះបង់រាងកាយ ព្រោះថាសេចក្តីឆ្អែតដោយកាមទាំងឡាយ ក្នុងលោកមិនមានឡើយ ។ ពួកញាតិរំសាយសក់កន្ទក់កន្ទេញចំពោះបុគ្គលដែលស្លាប់ហើយនោះ ទាំងបាននិយាយថា ធ្វើម្តេចហ្ន៎ ញាតិរបស់យើងទាំងឡាយ កុំស្លាប់វិញ ក៏នាំខ្មោចដែលរុំដោយសំពត់នោះទៅកាន់ជើងថ្ករ ប្រជុំគ្នាដុតក្នុងទីនោះ ។ បុគ្គលដែលស្លាប់ទៅហើយនោះ ត្រូវពួកអ្នកដុតចាក់ដោយឈើស្លុលដុត បុគ្គលនោះលះបង់នូវភោគៈទាំងឡាយ មានតែសំពត់មួយស្លាប់ទៅ ញាតិទាំងឡាយក្តី មិត្រទាំងឡាយក្តី ឬសម្លាញ់ទាំងឡាយក្តី ជាទីពឹងមិនមានទេ ។ ពួកទាយាទ ( អ្នកត្រូវទទួលមត៌ក ) រមែងនាំទៅនូវទ្រព្យរបស់សត្វដែលស្លាប់នោះ ចំណែកសត្វដែលស្លាប់នោះ ក៏ទៅតាមយថាកម្ម ទ្រព្យតិចតួច កូនប្រពន្ធ មាសប្រាក់ និងដែន ក៏មិនមែនជាប់ទៅតាមសត្វដែលស្លាប់នោះទេ ។ បុគ្គលមិនមែនបាននូវអាយុវែង ដោយសារទ្រព្យទេ ទាំងមិនមែនកម្ចាត់បង់នូវជរាដោយសារទ្រព្យបានដែរ ព្រោះអ្នកប្រាជ្ញទាំងឡាយបានពោលនូវជីវិតនោះថា តិច មិនទៀង មានការប្រែប្រួលទៅជាធម្មតា ។ ជនទាំងឡាយអ្នកស្តុកស្តម្ភ និងអ្នកទ័លក្រ រមែងប៉ះពាល់នូវផស្សៈ ( មិនជាទីប្រាថ្នា ) បុគ្គលពាល និងអ្នកប្រាជ្ញ រមែងប៉ះពាល់ដូចគ្នា ប៉ុន្តែបុគ្គលពាល បើមាន

សេចក្តីទុក្ខបៀតបៀនហើយ រមែងដេក ( សោកស្តាយ ) ព្រោះភាពនៃខ្លួនពាល ឯអ្នកប្រាជ្ញ បើទុកជាប៉ះពាល់នូវផស្សៈ ក៏មិនបានញាប់ញ័រ ។ ព្រោះហេតុនោះ បុគ្គលបាននូវព្រះនិព្វាន ជាទីបំផុតនៃភព ក្នុងលោកនេះ ដោយបញ្ញាណា បញ្ញានោះ ជាធម្មជាតិប្រសើរជាងទ្រព្យ ត្បិតបុគ្គលទាំងឡាយមិនទាន់បានសម្រេចប្រយោជន៍ រមែងធ្វើនូវបាបកម្មទាំងឡាយក្នុងភពតូច និងភពធំ ព្រោះតែមោហៈ ។ បុគ្គលណា ( បានធ្វើបាបកម្ម ) ក៏ដល់នូវការអន្ទោលទៅមក រមែងចូលទៅកាន់គភ៌ និងបរលោក បុគ្គលអ្នកអប្បប្រាជ្ញា ( ឯទៀត ) កាលបើជឿបុគ្គលអ្នកធ្វើបាបកម្មនោះ ក៏ទៅកាន់គភ៌ និងបរលោក ។

ចោរអ្នកមានធម៌ដ៏លាមក ដែលគេចាប់បានត្រង់មុខតំណ ( នៃផ្ទះ ) រមែងក្តៅក្រហាយ ដោយកម្មរបស់ខ្លួន យ៉ាងណាមិញ សត្វអ្នកមានធម៌ដ៏លាមក លុះស្លាប់ទៅ រមែងក្តៅក្រហាយ ក្នុងកាលខាងមុខ ដោយកម្មរបស់ខ្លួន ក៏យ៉ាងនោះដែរ ។ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីរីករាយនៃចិត្ត តែងញាំញីចិត្តដោយសភាពផ្សេងៗ បពិត្រមហារាជ ហេតុនោះ អាត្មាភាពឃើញទោសក្នុងកាមគុណទាំងឡាយ ទើបចេញទៅបួស ។ សត្វទាំងឡាយ ទោះក្មេងក្តី ចាស់ក្តី តែងបែកធ្លាយនូវសរីរៈ ដូចជាផ្លែឈើជ្រុះ (ចាកដើម ) បពិត្រមហារាជ អាត្មាភាពបានឃើញនូវរបស់មិនទៀងនេះឯង បានជាចេញបួស ភាពជាសមណៈ មិនស្ងួវខុសក្លាត់

ជារបស់ប្រសើរលើសលប់ ។ អាត្មាភាពបួសដោយសទ្ធា បានប្រកប សេចក្តីប្រតិបត្តិក្នុងសាសនានៃព្រះជិនស្រី បព្វជ្ជារបស់អាត្មាភាព មិន មានទោស អាត្មាភាពបរិភោគភោជន មិនមានបំណុលទេ ។ អាត្មាភាព ឃើញនូវកាមទាំងឡាយ ហាក់ដូចជាភ្លើងឆេះសព្វហើយ ឃើញជាតរូប ហាក់ដូចជាគ្រឿងសស្ត្រាវុធ ឃើញហេតុនាំមកនូវទុក្ខ តាំងតែអំពីការចុះ ចាប់បដិសន្ធិក្នុងគភ៌ ឃើញនូវភ័យធំ ក្នុងនរកទាំងឡាយ ។ អាត្មាភាព ឃើញនូវទោសនេះឯង ក៏បាននូវសេចក្តីសង្វេគ ក្នុងកាលនោះ អាត្មា ភាពហ្នឹងឯង ជាអ្នកត្រូវសរមុតហើយក្នុងកាលនោះ ( ឥឡូវនេះ ) បាន ដល់ហើយនូវការអស់ទៅនៃអាសវៈ ។ ព្រះសាស្តា អាត្មាភាពបានបម្រើ ហើយ ព្រះពុទ្ធសាសនា អាត្មាភាពក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ អាត្មា ភាពបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព អាត្មាភាពបាន ដកចោលហើយ ។ កុលបុត្របានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ដើម្បី ប្រយោជន៍ណា ប្រយោជន៍នោះ គឺការអស់ទៅនៃសំយោជនៈទាំងពួង អាត្មាភាពក៏បានដល់ហើយ ។

ក្រោយពីព្រះរដ្ឋបាលត្ថេរ បានពោលគាថានេះហើយ ក៏បានស្នាក់ អាស្រ័យនៅក្នុងថុល្លកោដ្ឋិតនិគម ក្នុងកាលដ៏សមគួរហើយ បានត្រឡប់ ទៅរកព្រះមហាមុនីទៀត ដោយអាស្រ័យគុណ គឺសេចក្តីល្អរបស់លោក ដែលជាអ្នកបួសដោយសទ្ធា ទាំងជាអ្នកធ្លាប់បានថ្វាយមហាទាន តាំងចិត្ត

អធិដ្ឋានយ៉ាងក្រៃលែង ទុកក្នុងទីចំពោះព្រះភក្ត្រនៃព្រះបទុមុត្តរៈ ។

លំដាប់នោះ ព្រះភគវាទ្រង់គង់ប្រថាប់នៅកណ្តាលព្រះអរិយសង្ឃសាវ័ក ទើបទ្រង់តែងតាំងព្រះរដ្ឋបាលត្ថេរ ទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយ អ្នកបួសដោយសទ្ធា ក្នុងព្រះពុទ្ធសាសនានេះ ។

ចំណែកគុណ គឺសេចក្តីល្អក្នុងអតីតជាតិ របស់ព្រះរដ្ឋបាលត្ថេរនោះ មានទៀត ដែលមានប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ថា ៖

ព្រះថេរៈបានតំណាលជីវប្រវត្តិរបស់លោក ក្រោយពីបានជាព្រះអរហន្តហើយ មានសេចក្តីថា ខ្ញុំបានថ្វាយដំរីដ៏ប្រសើរ មានភ្លុក.ងដូចចន្ទោល មានគ្រឿងដ៏មាំមួន ដល់ព្រះលោកនាថ ព្រះនាមបទុមុត្តរៈ ដ៏ឆ្នើមក្នុងលោក ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ។ ដំរីនោះមានស្វេតច្ឆ័ត្រសម្រាប់ប្រដាប់ មានពេទ្យសម្រាប់ព្យាបាល មានបុរសសម្រាប់រក្សា ខ្ញុំកាត់ថ្លៃរបស់ទាំងនោះ ( លក់ចំណាយ ) ធ្វើអារាមរបស់សង្ឃ ។ ខ្ញុំបានធ្វើប្រាសាទ អស់ប្រាក់ ៥៤ ពាន់ ធ្វើទានដូចជាទឹកជំនន់ដ៏ធំ ហើយវេរថ្វាយព្រះមហាមុនី ។ ព្រះសយម្ភូ មានព្យាយាមធំ ជាបុគ្គលប្រសើរទ្រង់អនុមោទនា ញុំាងជនទាំងពួងឲ្យរីករាយ សម្តែងនូវអមតនិព្វាន ។ ព្រះពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ គង់នៅកណ្តាលភិក្ខុសង្ឃ ទ្រង់ព្យាករទានរបស់ខ្ញុំនោះ ហើយសម្តែងគាថាទាំងឡាយនេះថា

កុលបុត្រនេះ បានធ្វើប្រាសាទ អស់ប្រាក់ ៥៤ ពាន់ ( ថ្វាយ

តថាគត ) តថាគតនឹងសម្តែង នូវផលនៃទាន ( របស់កុលបុត្រនោះ ) អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ ផ្ទះមានកំពូលចំនួន ១៨ ពាន់ នឹងកើតឡើងសម្រាប់កុលបុត្រនោះ ផ្ទះមានកំពូលទាំងនោះ សុទ្ធតែជាវិការៈនៃមាសទាំងអស់ កើតឡើងក្នុងវិមានដ៏ឧត្តម ។ កុលបុត្រនេះ នឹងសោយជាទេវរាជ ធំជាងទេវតា អស់ ៥០ ដង និងបានជាស្តេចចក្រពត្តិ អស់ ៥៨ ដង ។ ក្នុងកប្បទីមួយសែន ព្រះសាស្តា ព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ ខណៈនោះ កុលបុត្រនេះ នឹងចុតិចាកទេវលោក ត្រូវកុសលមូលដាស់តឿន នឹងកើតក្នុងត្រកូលស្តុកស្តម្ភ មានភោគៈច្រើន ។ កុលបុត្រនោះឈ្មោះ រដ្ឋបាល លុះកើតជាខាងក្រោយមក ក៏ចេញបួស ត្រូវកុសលមូលដាស់តឿន នឹងបានជាសាវក នៃព្រះសាស្តាព្រះនាមគោតមនោះ ។ កុលបុត្រនោះឯង មានចិត្តបញ្ជូនទៅកាន់សេចក្តីព្យាយាម ជាអ្នកមានចិត្តស្ងប់ មិនមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ ខ្ញុំក្រោកទៅសាងផ្នួស លះបោលភោគសម្បត្តិ ខ្ញុំមិនមានសេចក្តីស្រឡាញ់ភោគសម្បត្តិ ទុកដូចជាដុំទឹកមាត់ ។ សេចក្តីព្យាយាមរបស់ខ្ញុំ គួរនាំទៅនូវធុរៈ ជាទីនាំមកនូវធម៌ដ៏ក្សេមចាកយោគៈ ឥឡូវនេះ ខ្ញុំទ្រទ្រង់រាងកាយ ដែលជាទីបំផុតក្នុងសាសនា របស់ព្រះសម្មាសម្ពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់

ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំបានបដិបត្តិហើយ ។

នេះជាផល គឺសេចក្ដីល្អរបស់ព្រះរដ្ឋបាលត្ថេរ ដែលលោកបាន សន្សំទុកអំពីអតីតជាតិ ទើបធ្វើឲ្យលោកបានសម្រេចតំណែងដ៏ប្រសើរ ជាងភិក្ខុទាំងឡាយ ជាអ្នកចេញបួសដោយសទ្ធា ក្នុងព្រះសាសនានេះ ។

កាលបើលោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ ក៏រំលត់ខន្ធបរិនិព្វានទៅ ។ល។

( ជីវប្រវត្តិរបស់ព្រះរដ្ឋបាលត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះរាហុលត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងអ្នកស្រឡាញ់សិក្ខា "

*ព្រះរាហុលត្ថេរ ជាព្រះអរហន្តសាវ័កមួយរូប កើតនៅក្នុងវណ្ណៈខ្ពស់ មានការសិក្សាដ៏ប្រសើរ ថែមទាំងមានការបដិបត្តិដ៏ល្អសមគួរ ដែលនឹងនាំមកជាឧទាហរណ៍ ទាំងលោកក៏ចាត់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក និងបានទទួលការលើកតម្កើងពីព្រះលោកនាថថា ជាអ្នកប្រសើរជាងគេក្នុងផ្នែកខាងអ្នកស្រឡាញ់សិក្ខា តែហេតុផលទាំងនោះដែលប្រាកដដល់លោក ក៏ព្រោះបុណ្យបារមីធ្លាប់សន្សំក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិនេះ ។*

*ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះរាហុលត្ថេរ មានសម្តែងប្រាកដនៅក្នុង* ***អដ្ឋកថាមនោរថបូរណី*** *ដូចមានសេចក្តីថា ៖*

*ព្រះរាហុត្ថេរ លោកធ្លាប់កើតជាបុត្រគហបតីមហាសាល គឺជាត្រកូលដែលមានទ្រព្យសម្បត្តិច្រើន រួមជាមួយនឹងព្រះរដ្ឋបាលត្ថេរ នៅក្នុងក្រុងពារាណសី នៅក្នុងពុទ្ធកាលនៃព្រះបទុមុត្តរៈ ដោយរាប់ប្រមាណពេលបានមួយសែនកប្បកន្លងមកហើយ ។ កាលបើគហបតីបុត្រទាំងពីរនាក់ចម្រើនវ័យធំហើយ បិតាបានធ្វើកាលកិរិយាទៅ បានទទួលនាទីជាអ្នកគ្រប់គ្រងមត៌កជំនួសបិតា តែបុគ្គលទាំងពីរនាក់នោះ កាលបើមាន*

សិទ្ធិក្នុងទ្រព្យសម្បត្តិទាំងអស់នោះហើយ ទើបឲ្យអ្នកមានមុខនាទីចាំឃ្លាំងទ្រព្យសម្បត្តិ បើកឃ្លាំងទ្រព្យសម្បត្តិមើល ក៏ដឹងថា ទ្រព្យសម្បត្តិរបស់បុព្វបុរសរបស់យើងមាននៅសល់ច្រើន រាប់ប្រមាណមិនអស់ ទើបត្រិះរិះគិតថា ទ្រព្យសម្បត្តិមានចំនួនច្រើននេះ ពពួកញាតិរបស់យើងទាំងឡាយ មានជីតា និងបិតាជាដើម មិនអាចនឹងយកជាប់ទៅតាមខ្លួនបាន ត្រូវតែលះបង់របស់ទាំងអស់នោះហើយទៅ ដូច្នេះ ឥឡូវនេះ យើងទាំងពីរនាក់គួរតែរកឧបាយយ៉ាងណាមួយ ដើម្បីធ្វើឲ្យទ្រព្យសម្បត្តិទាំងនោះជាប់ទៅតាមខ្លួនក្នុងអនាគតកាល កាលបើគហបតីបុត្រទាំងពីរនាក់ គិតរកវិធីឃើញហើយ ទើបឲ្យសាងរោងទាន នៅត្រង់ទ្វារស្រុកទាំង ៤ កន្លែង តាំងចិត្តបរិច្ចាគមហាទាន ដល់មនុស្សក្រីសត់ទុគ៌ត និងអ្នកធ្វើដំណើរផ្លូវឆ្ងាយជាដើម ។ ការបរិច្ចាគមហាទាន របស់គហបតីបុត្រទាំងពីរនាក់ មានការផ្សេងគ្នាក្នុងពេលឲ្យទាន ម្យ៉ាងម្នាក់ៗ ។ ម្នាក់មុននឹងឲ្យទានអ្វី ត្រូវសួរអ្នកមកសុំជាមុនថា ត្រូវការវត្ថុណា ហើយក៏រៀបចំវត្ថុនោះឲ្យ ទើបបាននាមថា **អាគតវាចកៈ** អ្នកសាកសួរអ្នកដែលមកសុំ ។

ចំណែកម្នាក់ទៀត មិនសាកសួរអ្នកដែលមកសុំឡើយ កាលបើមានអ្នកមកសុំ ក៏រៀបចំវត្ថុដាក់ចុះក្នុងភាជនៈរបស់អ្នកសុំមួយរំពេច ហើយឲ្យទៅ ទើបមាននាមថា **អនាគតវាចកៈ** អ្នកមិនបានសាកសួរអ្នកដែលមកសុំ ។ ថ្ងៃមួយ គហបតីបុត្រទាំងពីរនាក់ បានបបួលគ្នាចេញទៅខាង

ក្រៅផ្ទះពីព្រឹកព្រលឹម ដើម្បីទៅលុបមុខ និងជម្រះកាយ ។ ខណៈពេលនោះ មានតាបសពីររូបមានឫទ្ធិច្រើន ហោះមកពីព្រៃហិមពាន្ត ដើម្បីប្រាថ្នាស្វែងរកកិក្ខាចារ មកចុះក្នុងទីជិតគហបតីបុត្រទាំងពីរ នាក់ដែលស្នាក់នៅហើយឈរជិតនោះ ។ តាបសទាំងពីររូបនោះក៏រៀបចំគ្រឿងបរិក្ខារ មានភាជនៈសម្បកឃ្មោកជាដើម ត្រៀមនឹងចូលទៅកាន់ស្រុកដើម្បីភិក្ខាចារ ។ គហបតីបុត្រទាំងពីរនាក់ ឃើញតាបសពីររូបនោះហើយ ទើបនមស្ការដោយសេចក្តីគោរពយ៉ាងពេញចិត្ត តាបសទាំងពីរនាក់សួរឡើងមុនថា នែគហបតីទាំងពីរនាក់ អ្នកមានបុណ្យច្រើន លោកទាំងពីរនាក់មកទីនេះតាំងពីពេលណា ? គហបតីបុត្រទាំងពីរនោះតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមកដល់អម្បាញ់មិញនេះឯង ពោលតបហើយ បានទទួលយកសម្បកឃ្មោកពីដៃរបស់តាបសទាំងពីររូបនោះ ហើយនាំតាបសម្នាក់មួយរូប ត្រឡប់ចូលទៅកាន់ផ្ទះរបស់ខ្លួន ។ ក្រោយពីថ្វាយអាហារ ដល់តាបសទាំងពីររូបនោះឆាន់រួចជាស្រេចហើយ ម្នាក់ៗ ក៏និមន្តឲ្យលោកទាំងពីររូបមកឆាន់នៅក្នុងផ្ទះរបស់ខ្លួនជារៀងរាល់ថ្ងៃ ។ តាបសទាំងពីររូបនោះ ម្នាក់មានការទៅសម្រាកពេលថ្ងៃ នៅក្នុងពិភពនាគ ខាងក្រោមមហាសមុទ្រដោយអំណាចនៃឫទ្ធិ ពេលដែលតាបសនោះ មកឆាន់ភត្តាហារនៅផ្ទះឧបដ្ឋាករបស់លោក តែងអនុមោទនាដោយពោលថា សូមឲ្យលោកបានសម្បត្តិដូចគ្នានឹងស្តេចបវរិនធរនាគរាជនោះចុះ នេះជាពាក្យ

អនុមោទនាទាន ដែលតាបសពោលជារៀងរាល់ថ្ងៃ ។ ថ្ងៃមួយ កុដុម្ពិក ដែលជាឧបដ្ឋាក ទើបសួរដល់តាបសនោះថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលបើលោកអនុមោទនាទាន លោកតែងតែពោលថា សូមឲ្យខ្ញុំបាន សម្បត្តិដូចស្តេចបឋវិនធរនាគរាជចុះ ដូច្នេះ ខ្ញុំមិនយល់សេចក្តីនៃការ អនុមោទនាទាននោះឡើយ ។ តាបសនោះពោលតបថា នៃកុដុម្ពិក ពាក្យ អនុមោទនានោះ មានសេចក្តីថា សូមឲ្យលោកបានសម្បត្តិដូចគ្នានឹងស្តេច នាគនោះ ។ ចាប់ផ្តើមពីពេលនោះមក កុដុម្ពិកយល់សេចក្តីនោះហើយ ទើបតាំងចិត្តទុករាល់ដង ក្នុងពេលថ្វាយទាន ប្រាថ្នាឲ្យបានសម្បត្តិដូច ស្តេចនាគនោះ ។

ចំណែកតាបសម្នាក់ទៀត ទៅសម្រាកពេលថ្ងៃនៅឋានតាវត្តិង្ស ក្នុងវិមានដែលទំនេរពីទេវបុត្រ និងទេវធីតា បានឃើញទិព្វសម្បត្តិរបស់ សក្កទេវរាជ ទាំងពេលទៅ ទាំងពេលមក ដូច្នេះហើយ កាលអនុមោទនា ទានដល់ឧបដ្ឋាករបស់ខ្លួន ក៏ពោលថា សូមឲ្យអ្នកបានសម្បត្តិដូចសក្ក- ទេវរាជចុះ ។ ចំណែកកុដុម្ពិកនោះឆ្ងល់ ហើយសួរតាបសថា ហេតុអ្វី បានលោកម្ចាស់ពោលយ៉ាងនេះ? តាបសឆ្លើយថា អាត្មាបានទៅសម្រាក នៅឋានតាវត្តិង្ស បានឃើញសម្បត្តិរបស់សក្កទេវរាជ, កាលជ្រាបសេចក្តី នោះហើយ កុដុម្ពិកក៏តាំងចិត្តប្រាថ្នាឲ្យបានសម្បត្តិដូចសក្កទេវរាជ ។ លុះ គហបតីបុត្រទាំងពីរនាក់ស្លាប់ទៅហើយ បានកើតក្នុងទីដែលខ្លួនប្រាថ្នា ។

កុដុម្ពិកម្នាក់ដែលប្រាថ្នាឲ្យបានសម្បត្តិក្នុងពិភពនាគ ក៏ទៅកើតជាស្តេចនាគ ឈ្មោះថា **បបវិនធរៈ** តែក្នុងអដ្ឋកថា នៃគម្ពីរបបញ្ចសូទនី មានឈ្មោះប្រាកដថា **បាលិតៈ** ចំណែកឈ្មោះថាបបវិនធរៈនោះ ហៅតាមឈ្មោះស្តេចនាគមុន ។ ស្តេចនាគនោះ កាលកើតក្នុងនាគពិភពហើយ ក៏កើតការអន់ចិត្ត ព្រោះកំណើតរបស់នាគនេះ ត្រូវទៅណាមកណាដោយពោះ ទើបគិតថា តាបសដែលយើងឧបដ្ឋាកនោះ ពណ៌នាគុណរបស់ទីដែលមិនចម្រើនដល់យើង ប្រហែលជាមិនដឹងទីឯទៀតទេ ។ ក្នុងខណៈនោះ ពួកនាងនាគកញ្ញា ដែលប្រដាប់តាក់តែងយ៉ាងស្អាត ម្នាក់ៗ កាន់យកគ្រឿងតូរ្យតន្ត្រីទិព្វ មកប្រគំប្រៀងបំពេរឡើងក្នុងទិសទាំងពួង ខណៈនោះ ស្តេចនាគនោះ ក៏ក្លាយមកជាមាណពកំលោះភ្លាម ។

មែនពិត រាងកាយរបស់នាគ ដែលក្លាយមកជាមនុស្សនោះ នឹងត្រូវត្រឡប់ទៅជានាគដូចដើមវិញ ដោយហេតុ ៥ យ៉ាង ដែលមានពោលក្នុង **វិន័យបិដក គម្ពីរមហាវគ្គ** និង **អដ្ឋកថាតតិយសមន្តប្បាសាទិកា** ថា ៖

១- **ក្នុងការចុះចាប់បដិសន្ធិ ។**

២- **ក្នុងពេលសក ។**

៣- **ក្នុងពេលដេកលក់ ។**

៤- **ក្នុងពេលសេពមេថុនធម្មជាមួយនឹងនាងនាគ ។**

៥- **ក្នុងពេលចុតិ ។**

មានច្បាប់ម្យ៉ាង ដែលមហារាជទាំង ៤ ត្រូវឡើងទៅគាល់ព្រះឥន្ទ្ររាល់កន្លះខែក្នុងឋានតាវត្តិង្ស ស្តេចនាគនោះ ត្រូវជាបរិវាររបស់ព្រះបាទវិរូបក្ខមហារាជ ព្រោះហេតុនោះ ទើបឡើងទៅគាល់ព្រះឥន្ទ្រជាមួយនឹងស្តេចវិរូបក្ខៈ ។ ចំណែកព្រះឥន្ទ្រទតឃើញស្តេចនាគពីចម្ងាយ ទ្រង់ក៏ចាំបាន ពេលដែលស្តេចនាគនោះចូលមកជិតក៏សួរថា នែសម្លាញ់ អ្នកបានទៅកើតក្នុងទីណា ? ស្តេចនាគក្រាបទូលថា បពិត្រមហាទេវរាជ សូមព្រះអង្គកុំត្រាស់សួរខ្ញុំព្រះអង្គ ព្រោះថាខ្ញុំព្រះអង្គទៅកើតក្នុងកំណើតសត្វដែលលូនទៅដោយពោះ ចំណែកព្រះអង្គជាអ្នកមានកល្យាណមិត្តល្អ ទើបបានមកកើតក្នុងស្ថាននេះ ។ ព្រះឥន្ទ្រទ្រង់លួងលោមស្តេចនាគថា នែសម្លាញ់ លោកកុំតូចចិត្តឡើយ ឥឡូវនេះ ព្រះបទុមុត្តរៈ ទ្រង់កើតឡើងក្នុងលោកហើយ ចូរសម្លាញ់ទៅធ្វើបុណ្យកុសល ក្នុងសម្នាក់ព្រះពុទ្ធបទុមុត្តរៈចុះ ហើយតាំងសេចក្តីប្រាថ្នា ឲ្យបានមកកើតក្នុងទីនេះ យើងទាំងពីរនាក់ នឹងសោយទិព្វសម្បត្តិជាមួយគ្នា ។ ស្តេចនាគក្រាបទូលថា ខ្ញុំព្រះអង្គនឹងធ្វើតាមពាក្យទាំងនោះ ស្តេចនាគក៏ក្រាបទូលលាត្រឡប់ទៅកាន់ពិភពនាគវិញ តែមុននឹងទៅកាន់ពិភពនាគនោះ បានចៀងចូលទៅគាល់ក្រាបទូលអារាធនាព្រះបទុមុត្តរៈ ដើម្បីឲ្យទ្រង់យាងទៅទទួលចង្ហាន់នៅក្នុងពិភពនាគរបស់ខ្លួន ។ កាលបើដឹងថា ព្រះអង្គទទួលការនិមន្តហើយ ទើបត្រឡប់មកកាន់ពិភពនាគវិញ រៀបចំចាត់ចែងគ្រឿង

សក្ការបូជា ជាមួយនឹងបរិវារហូតអស់មួយយប់ ។ លុះព្រឹកឡើង ព្រះបទុមុត្តរៈត្រាស់ជាមួយនឹងសុមនត្ថេរ ដែលជាឧបដ្ឋាក របស់ព្រះអង្គថា សុមនៈ ថ្ងៃនេះតថាគតនឹងទៅទទួលចង្ហាន់បិណ្ឌបាតទីឆ្ងាយ ចូរអ្នកប្រាប់ភិក្ខុសង្ឃដែលមានជំនាញក្នុងព្រះត្រៃបិដក ថែមទាំងបានសម្រេចអភិញ្ញា ៦ ។ ព្រះសុមនត្ថេរទទួលព្រះពុទ្ធដីកាហើយ និមន្តទៅប្រាប់ដល់ភិក្ខុសង្ឃទាំងឡាយ ឲ្យជ្រាបតាមព្រះពុទ្ធបំណង ។ ភិក្ខុសង្ឃទាំងអស់មួយសែនរូប បាននិមន្តទៅតាមព្រះមានជោគ ទៅកាន់ពិភពនាគ ។ ស្តេចនាគបឋវិនធរៈ ព្រមទាំងបរិវារនាំគ្នាចេញមកទទួលព្រះបទុមុត្តរៈ ព្រមទាំងភិក្ខុសង្ឃ និងបានសម្លឹងមើលពួកភិក្ខុសង្ឃហែហមព្រះវិជិតមារ រហូតតាំងពីដើមមកដល់ឃើញឧបរេវតសាមណេរ ដែលជាព្រះឱរសរបស់ព្រះបទុមុត្តរៈ ថែមទាំងជាអ្នកមានព្រះជន្មតិចជាងគេទៀតផង កាលបើឃើញឧបរេវតសាមណេរ ហើយពិចារណាឃើញសរីរៈប្រាកដស្រដៀងគ្នានឹងព្រះសយម្ភូ ក៏កើតសេចក្តីជ្រះថ្លា ប៉ុន្តែចំពោះឥទ្ធានុភាពរបស់សាវ័កដទៃទៀតមានច្រើន ក៏មិនគួរឲ្យអស្ចារ្យទេ ចំណែកឥទ្ធានុភាពរបស់សាមណេរតូចនេះវិញ គួរឲ្យអស្ចារ្យក្រៃពេក ។ កាលបើព្រះបទុមុត្តរៈ ទ្រង់គង់លើពុទ្ធាសនៈរៀបរយហើយ ភិក្ខុសង្ឃទាំងឡាយក៏អង្គុយចុះជាលំដាប់មក ។ អាសនៈរបស់ឧបរេវតសាមណេរ នៅត្រង់ព្រះភក្រ្តរបស់ព្រះមុនីស្តេចនាគ ខណៈថ្វាយយាគូ និងបង្អែម បានក្រឡេកមើលព្រះសុគតផង

ក្រឡេកមើលឧបវេតសាមណេរផង កាលបើមើលទៅឧបវេតសាមណេរ ឃើញមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងរាងកាយសាមណេរនេះ ស្រដៀងគ្នានឹងមហាបុរិសលក្ខណៈ ក្នុងព្រះវរកាយរបស់ព្រះបទុមុត្តរៈ ទើបនឹកក្នុងចិត្តថា សាមណេរតូចរូបនេះស្រដៀងគ្នានឹងព្រះភគវា តើ សាមណេរនេះជាអ្វីជាមួយនឹងព្រះសយម្ភូ ហើយទើបសួរភិក្ខុមួយរូបដែល អង្គុយជិតនោះថា សាមណេររូបនេះ ត្រូវជាអ្វីជាមួយនឹងព្រះសាស្តាដែរ ?

ភិក្ខុនោះតបថា សាមណេររូបនេះ ជាពុទ្ធឱរសរបស់ព្រះសម្ពុទ្ធ ស្តេចនាគទើបត្រិះរិះគិតថា យើងគួរឲ្យបានភាពដ៏ប្រសើរដូចសាមណេរ រូបនេះ ក្នុងកាលជាអនាគត គិតដូច្នេះហើយ ទើបថ្វាយមហាទានរហូត អស់ ៧ ថ្ងៃ ។ កាលបើគ្រប់ ៧ ថ្ងៃហើយ ទើបតាំងសេចក្តីប្រាថ្នាចំពោះ ព្រះភក្ត្រនៃព្រះបទុមុត្តរៈថា សូមឲ្យខ្ញុំព្រះអង្គ បានជាព្រះឱរសរបស់ព្រះ ពុទ្ធមួយព្រះអង្គក្នុងកាលជាអនាគត ដូចសាមណេរឧបវេតៈនេះដោយ អានុភាពនៃបុណ្យកុសលទាំងនេះ ។ ព្រះបទុមុត្តរៈ ទ្រង់ពិចារណាឃើញ ថា មិនមានអន្តរាយ ទើបទ្រង់ព្យាករថា អ្នកនឹងបានជាព្រះឱរសរបស់ ព្រះសមណគោតមក្នុងកាលជាអនាគត សមតាមសេចក្តីប្រាថ្នា កាលបើ ទ្រង់ព្យាករហើយ ព្រះអង្គព្រមទាំងភិក្ខុសង្ឃ ក៏បាននិមន្តត្រឡប់មកវិញ ។ ស្តេចនាគ កាលដល់កំណត់កន្ទះរំខហើយ បានឡើងទៅគាល់សក្កទេវរាជ ព្រមជាមួយនឹងវិរូបក្ខៈនៅឋានតាវត្តិង្សតាមប្រក្រតី ។ សក្កទេវរាជ បាន

ត្រាស់សួរស្តេចនាគនោះថា នៃសម្លាញ់ លោកធ្វើបុណ្យហើយតាំងសេចក្តីប្រាថ្នាឲ្យមកកើតក្នុងទេវលោកនេះពិតមែនឬ? ខ្ញុំព្រះអង្គធ្វើបុណ្យរួចហើយពិតមែន ប៉ុន្តែមិនបានប្រាថ្នាឲ្យបានមកកើតក្នុងទេវលោកនេះទេ ។ តើលោកឃើញទោសយ៉ាងណា ទើបមិនប្រាថ្នាឲ្យមកកើតក្នុងទីនេះ ខ្ញុំព្រះអង្គមិនបានឃើញទោសអ្វីយ៉ាងណាទីមួយទេ ប៉ុន្តែបានឃើញឧបរេវតសាមណេរ ដែលជាព្រះឱរសរបស់ព្រះបទុមុត្តរៈ ហើយក៏កើតការពេញចិត្ត ទើបតាំងសេចក្តីប្រាថ្នា ឲ្យបានជាព្រះឱរសរបស់ព្រះពុទ្ធអង្គណាមួយ ក្នុងកាលជាអនាគត ស្តេចនាគក្រាបទូលឲ្យជ្រាបបំណងរបស់ខ្លួនដល់សក្កទេវរាជហើយ ថែមទាំងក្រាបទូលបបួលថា បពិត្រព្រះអង្គទ្រង់ប្រសើរជាងទេវតាទាំងឡាយ ខ្ញុំព្រះអង្គមានបំណងឲ្យព្រះអង្គតាំងសេចក្តីប្រាថ្នាយ៉ាងណាទីមួយ ដើម្បីឲ្យយើងទាំងពីរនាក់ បានកើតមកជួបគ្នាទៀត មិនព្រាត់ប្រាសគ្នា ។ សក្កទេវរាជ ទ្រង់ស្តាប់ពាក្យរបស់ស្តេចនាគហើយ កាលតមក ទ្រង់ឃើញភិក្ខុមួយរូបមានអានុភាពច្រើន ទើបទ្រង់ពិចារណាថា កុលបុត្រនេះ ជាអ្នកចេញចាកត្រកូលបួសដោយសទ្ធា ក៏ទ្រង់ជ្រាបទៀតថា កុលបុត្រនេះ ជាអ្នកមានធនធានច្រើន ថែមទាំងរួបរួមនូវស្រុកដែលបែកបាក់គ្នា ឲ្យវិលមកជាប្រក្រតីដូចដើមវិញបាន កុលបុត្រនេះ ជាអ្នកមានសទ្ធា ព្រមទាំងអត់អាហារដល់ ១៤ ថ្ងៃហើយ ទើបមាតាបិតាអនុញ្ញាតឲ្យចេញបព្វជ្ជា ក្នុងព្រះសាសនានេះ ។

*កាលបើសក្កទេវរាជជ្រាបហើយ ធ្វើហាក់បីដូចជានៅមិនទាន់ជ្រាប ទើបក្រាបទូលសួរព្រះបទុមុត្តរៈថា ភិក្ខុរូបនេះជាអ្វី ថែមទាំងបានធ្វើសក្ការបូជាព្រះមានព្រះភាគរហូតអស់ ៧ ថ្ងៃ ហើយតាំងសេចក្ដីប្រាថ្នាថា ដោយអំណាចបុណ្យកុសលនេះ សូមឲ្យខ្ញុំព្រះអង្គបានជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងចេញបួសដោយសទ្ធា ក្នុងសាសនាព្រះពុទ្ធអង្គណាមួយ ក្នុងកាលជាអនាគត ដូចគ្នានឹងភិក្ខុរូបនេះ ។ ព្រះបទុមុត្តរៈទ្រង់ពិចារណាឃើញថា សេចក្ដីប្រាថ្នារបស់សក្កទេវរាជនឹងបានសម្រេចតាមបំណង ។ ទើបទ្រង់ព្យាករថា បពិត្រមហារាជ អ្នកនឹងបានប្រសើរជាងភិក្ខុទាំងឡាយ អ្នកចេញបួសដោយសទ្ធា ក្នុងសាសនារបស់ព្រះសមណគោតម ក្នុងកាលជាអនាគតនោះមិនខាន ។ ចំណែកសក្កទេវរាជកាលមកដល់សាសនារបស់ព្រះផុស្សសម្មាសម្ពុទ្ធ ក្នុងកប្បទី ៩២ ដែលរាប់ត្រឡប់ថយក្រោយពីភទ្ទកប្បនេះ បានមកកើតជាអ្នកទទួលនាទីចាត់ចែងទេយ្យធម៌ថ្វាយដល់ភិក្ខុសង្ឃ ដោយចាំបម្រើព្រះរាជឱរសរបស់ព្រះមហិន្ទរាជា ថ្ងៃមួយ ព្រះរាជឱរសទាំងបីអង្គ ទ្រង់បានរួមគ្នាសមាទានសីល ១០ ថែមទាំងបរិច្ចាគទានផង ។ លុះមកដល់ជាតិចុងក្រោយនេះ សក្កទេវរាជបានមកកើតជាកូនសេដ្ឋី មានឈ្មោះថា* ***រដ្ឋបាល*** *បានចេញបួសសម្រេចជាព្រះអរហន្ត ទាំងបានទទួលការលើកតម្កើងជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងចេញបួសដោយសទ្ធា ឲ្យបានសម្រេចតាម*

សេចក្តីប្រាថ្នានោះ ។ ចំណែកស្តេចនាគបឋវិនធរៈ ត្រឡប់បានមកកើតជាព្រះរាជឱរសច្បងរបស់ព្រះបាទកឹកិស្សរាជ ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធកស្សបៈ ទ្រង់ព្រះនាមថា **បឋវិនធររាជកុមារ** មានព្រះកនិដ្ឋភគិនី ៧ អង្គ ។ ព្រះកនិដ្ឋភគិនីទាំង ៧ អង្គនោះ ទ្រង់នាំគ្នាកសាងបរិវេណវិហារ ៧ កន្លែង ថ្វាយដល់ព្រះកស្សបៈ ។

កាលតមក ព្រះបឋវិនធររាជកុមារនោះ បានទទួលតំណែងជាឧបរាជ ទើបត្រាស់សូមបរិវេណវិហារ ជាមួយនឹងព្រះកនិដ្ឋភគិនីទាំង ៧ អង្គនោះថា នែប្អូនស្រីទាំងឡាយ បរិវេណទាំង ៧ កន្លែង ដែលប្អូនស្រីបានកសាងទុកនោះ សូមបែងចែកបរិវេណមួយចំណែកឲ្យបងផង ។ ព្រះកនិដ្ឋភគិនីទាំង ៧ អង្គ មួយអង្គៗ តបថា បពិត្រព្រះជេស្ឋាធិរាជៗ បានប្រទានដល់ពួកខ្ញុំហើយ ប៉ុន្តែ បែរត្រឡប់ជាមកសុំអំពីពួកខ្ញុំទៅវិញ ម្ចាស់បងបានជាឥស្សរជនហើយ សូមកសាងបរិវេណវិហារឡើងជាថ្មីចុះ ។ ព្រះបាទបឋវិនធរឧបរាជ ទ្រង់សណ្តាប់ព្រះបន្ទូលរបស់ព្រះកនិដ្ឋភគិនីទាំង ៧ អង្គហើយ ទើបទ្រង់មានព្រះឧស្សាហ៍កសាងវិហារថ្មីឡើង មានកុដិ ៥០០ ខ្នង ទ្រង់ធ្វើបុណ្យកុសលរហូតអស់ព្រះជន្មាយុ ហើយបានទៅកើតក្នុងទេវលោក ដោយអំណាចបុណ្យកុសលផ្សេងៗ ដែលទ្រង់បានបំពេញហើយ ។ មកដល់ពុទ្ធកាលនេះ ព្រះបាទបឋវិនធរឧបរាជនោះ បានមកកើតជាព្រះឱរសរបស់ព្រះបាទសិទ្ធត្ថៈ និងព្រះនាងពិម្ពា នៅក្នុងក្រុង

កបិលពស្តុ ក្នុងថ្ងៃដែលប្រសូតចាកព្រះគភ៌មាតា ជាថ្ងៃដែលព្រះបាទសិទ្ធត្ថៈ ស្តេចចេញសាងព្រះផ្នួស ទ្រង់មាននាមថា **រាហុល** ប្រែថា អន្ទាក់ដែលមាននាមដូច្នេះ ព្រោះអាស្រ័យឧទានរបស់ព្រះសិទ្ធត្ថៈ ក្នុងពេលដែលព្រះរាជឱរសប្រសូតថា អន្ទាក់កើតឡើងហើយ គ្រឿងចាក់ស្រែះកើតហើយ ។ ម្យ៉ាងទៀត ពាក្យថា រាហុល មិនបានសំដៅដល់អន្ទាក់តែជាពាក្យដែលមកអំពីពាក្យថា **រាហូ** អ្នកជាទេព អ្នកមានឫទ្ធិរបស់ពួកព្រាហ្មណ៍ ដែលចាប់ព្រះអាទិត្យ និងព្រះច័ន្ទ ដែលហៅថា សូរ្យគ្រាស ឬចន្ទ្រគ្រាស ។ ក្នុងថ្ងៃដែលព្រះរាហុលប្រសូតនោះ ជាថ្ងៃកើតមានសូរ្យគ្រាស ទើបកាន់ហេតុទាំងនោះ ក៏ដាក់ព្រះនាមឲ្យថា **រាហុល** ។

ការទ្រទ្រង់ព្រះផ្នួសរបស់ព្រះរាហុលកុមារ មានរឿងប្រាកដក្នុង **ព្រះបាលីមហាខន្ធកៈ គម្ពីរមហាវគ្គ ព្រះវិន័យបិដក និងអដ្ឋកថាធម្មបទនៃយមកវគ្គ** ក្នុងរឿង **ព្រះអានន្ទត្ថេរ** ដូចមានសេចក្ដីថា ៖

កាលព្រះអង្គត្រាស់ដឹងហើយ ស្តេចយាងទៅប្រោសពពួកញាតិនៅក្នុងក្រុងកបិលពស្តុ ទ្រង់គង់ប្រថាប់នៅនិគ្រោធារាម ។ ថ្ងៃមួយ ព្រះវិជិតមារ ស្តេចយាងទៅកាន់រាជនិវេសន៍របស់ព្រះនាងពិម្ពា ដែលជាអគ្គមហេសីចាស់របស់ព្រះអង្គ ជាថ្ងៃទី ៧ ដែលព្រះលោកនាថ ស្តេចនិមន្តមកកាន់ក្រុងកបិលពស្តុនេះ ។ ព្រះនាងពិម្ពារាហុលមាតា បានចាត់ចែងរៀបចំខ្លួនឲ្យព្រះរាហុលចូលទៅគាល់ព្រះសម្ពុទ្ធ ដោយប្រាប់ថា កូន ចូរ

កូនមើលសមណៈនោះចុះ សមណៈនោះឯង ជាបិតារបស់កូន ក្នុងពេលដែលព្រះបិតារបស់កូនប្រសូត មានរណ្តៅកំណប់ទ្រព្យធំៗ ប្រាកដឡើងចាប់ពីបិតារបស់កូន ស្តេចយាងទៅបួសហើយ រណ្តៅកំណប់ទ្រព្យធំៗទាំងនោះក៏បាត់អស់ទៅ ចូរកូនទៅក្រាបទូលសូមកំណប់ទ្រព្យទាំងនោះដោយពាក្យថា បពិត្រព្រះបិតា ទូលព្រះបង្គំជាកុមារ ពេលទូលព្រះបង្គំបានអភិសេកហើយ នឹងបានជាស្តេចចក្រពត្តិ ទូលព្រះបង្គំត្រូវការទ្រព្យសូមព្រះបិតាប្រទានទ្រព្យដល់ទូលព្រះបង្គំផង ព្រោះថា បុត្រ រមែងជាម្ចាស់ទ្រព្យសម្បត្តិដែលជារបស់បិតា ដូច្នេះឯង ។ ព្រះរាហុលកុមារចូលទៅគាល់ព្រះសុគតសាស្តា តាមព្រះរាជសវនីយ៍របស់ព្រះមាតា កាលបើព្រះរាហុលទៅដល់ទីកន្លែង ដែលព្រះអង្គគង់ប្រថាប់ហើយ ទើបទ្រង់ថ្វាយបង្គំដោយព្រះទ័យនឹកស្រឡាញ់ ដូចបុត្រស្រឡាញ់បិតា មានចិត្តរីករាយត្រេកអរក្រាបទូលថា បពិត្រព្រះសមណៈ ម្លប់របស់ព្រះបិតាជាសុខ ហើយប្រថាប់ឈរក្រាបទូលដោយពាក្យដទៃៗ ទៀត តាមសមគួរដែលគប្បីក្រាបទូល ។

ព្រះមានជោគ ទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយ ទើបទ្រង់ធ្វើការអនុមោទនាទាន ហើយស្តេចក្រោកចាកទីគង់ប្រថាប់ ត្រឡប់ទៅកាន់វិហារវិញ ។ ចំណែកព្រះរាហុលកុមារ ទើបក្រាបបង្គំទូលសូមថា បពិត្រព្រះសមណៈ សូមព្រះអង្គព្រះរាជទានមត៌កឲ្យដល់ខ្ញុំព្រះអង្គ ដូច្នេះជា

រឿយៗ ហើយស្តេចយាងទៅតាមព្រះមានព្រះភាគ ។ សូម្បីព្រះភគវា ក៏ទ្រង់មិនព្រមឲ្យព្រះរាហុលកុមារស្តេចយាងត្រឡប់មកវិញ ។ ពពួកបរិវារមិនអាចនឹងទូលឲ្យព្រះរាហុលកុមារត្រឡប់មកវិញបាន ដោយស្តេចកំពុងយាងទៅតាមព្រះមានព្រះភាគនោះ ។ ព្រះរាហុលកុមារ បានទៅតាមព្រះមានព្រះភាគរហូតដល់អារាម ដែលព្រះអង្គគង់ប្រថាប់ ។ ព្រះសុគតទ្រង់ត្រិះរិះដល់ព្រះរាហុលកុមារថា កុមារនេះត្រូវការទ្រព្យដែលជាសម្បត្តិរបស់បិតា ទ្រព្យនោះរមែងប្រព្រឹត្តទៅក្នុងវដ្តៈ ជាទ្រព្យខាងក្រៅ ធ្វើឲ្យកើតសេចក្តីក្តៅក្រហាយជារឿយៗ តថាគតមិនព្រមឲ្យទ្រព្យបែបនេះដល់កុមារនេះឡើយ ប៉ុន្តែ តថាគតគួរឲ្យអរិយទ្រព្យ ដែលតថាគតបាននៅក្រោមដើមពោធិ៍ឲ្យដល់រាហុល ឲ្យជាម្ចាស់នៃមត៌កដែលជាលោកុត្តរ-សម្បត្តិ ជាទ្រព្យដែលជួយឲ្យឆ្លងផុតចាកលោក ដែលជាទ្រព្យខាងក្នុង ។

ចំណែកសេចក្តីក្នុង **ព្រះបាលីមហាខន្ធកៈ គម្ពីរមហាវគ្គ ព្រះវិន័យបិដក** ដែលពោលទាក់ទងដល់ការបព្វជ្ជារបស់ **ព្រះរាហុលកុមារ** ថា ៖

គ្រានោះ ព្រះរាហុលកុមារទ្រង់នៅវ័យក្មេង មានព្រះជន្មមិនទាន់គ្រប់ដើម្បីនឹងឧបសម្បទា ទើបព្រះសារីបុត្រក្រាបទូលសូមព្រះមហាមុនីថា បពិត្រព្រះអង្គដ៏ចម្រើន តើគប្បីឲ្យព្រះរាហុលកុមារបួសដោយវិធីយ៉ាងណា ? ព្រះសក្យមុនី ទ្រង់សម្តែងធម្មីកថា ដោយទ្រង់ប្រារព្ធរឿងនេះឲ្យជាហេតុដំបូង ហើយត្រាស់អនុញ្ញាតដល់ភិក្ខុទាំងឡាយថា ម្នាល

ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការបំបួសកុលបុត្រជាសាមណេរដោយ ត្រៃសរណគមន៍បាន ។ ជាខាងដើម ឲ្យអ្នកបួសកោរសក់ ពុកមាត់ ពុកចង្កា ឲ្យស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ដោយដណ្តប់សំពត់ឆៀងស្មាម្ខាង ឲ្យថ្វាយបង្គំភិក្ខុទាំងឡាយ ឲ្យអង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយប្រាប់ដល់កុលបុត្រនោះថា **ឯវំ វទេហិ** ប្រែថា ចូរថាយ៉ាងនេះ តពីនោះមក ទើបឲ្យត្រៃសរណគមន៍ថា **ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ** រហូតដល់ទុតិយម្បិ តតិយម្បិ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបំបួសកុលបុត្រជាសាមណេរ ដោយឲ្យត្រៃសរណគមន៍យ៉ាងនេះឯង ។ គ្រានោះ ទើបព្រះសារីបុត្រឲ្យព្រះរាហុលកុមារបព្វជ្ជាដោយវិធីនេះឯង ( វិធីបំបួសកុលបុត្រអ្នកមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ នៅមិនទាន់អាចឧបសម្បទាបាន ក៏គប្បីឲ្យបព្វជ្ជាជាសាមណេរ ដោយវិធីឲ្យទទួលត្រៃសរណគមន៍ ការបព្វជ្ជាជាសាមណេរដោយឲ្យត្រៃសរណគមន៍ មុនគេបង្អស់ក្នុងព្រះសាសនានេះ គឺឲ្យដល់ព្រះរាហុល ) ។ ក្រោយពីព្រះរាហុលបព្វជ្ជាជាសាមណេរហើយ បានកើតពុទ្ធប្បញ្ញត្តិឡើង ដោយសារព្រះបាទសុទ្ធោទនមហារាជពុទ្ធបិតា ទ្រង់មិនសព្វព្រះហឫទ័យ កាលបើដឹងដំណឹងថា ព្រះរាហុលបព្វជ្ជាជាសាមណេរ ទាំងទ្រង់សង្ឃឹមទុកថា ព្រះរាហុលកុមារជាអ្នកបន្តវង្ស ពេលនេះក៏ទ្រង់អស់សង្ឃឹមទៅ ព្រោះធ្លាប់សង្ឃឹមព្រះនន្ទត្ថេរព្រះរាជឱរស ក៏បានខក

បំណាំងម្ដងមកហើយ ទើបទ្រង់ស្ដេចយាងទៅគាល់ព្រះលោកនាយក ទ្រង់ថ្វាយបង្គំហើយ ប្រថាប់គង់ក្នុងទីដ៏សមគួរ ទើបទ្រង់ក្រាបទូលសូមពរថា សូមព្រះអង្គកុំអនុញ្ញាតបំបួសដល់កុលបុត្រ ដែលមាតាបិតាមិនទាន់បានអនុញ្ញាតជាមុនទេ ។

ព្រះសយម្ភូ ក្រោយពីព្រះបាទសុទ្ធោទនមហារាជ ស្ដេចយាងត្រឡប់ទៅវិញហើយ ព្រះអង្គទើបត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីបំបួសកុលបុត្រ ដែលមាតាបិតាមិនទាន់បានអនុញ្ញាតទេ ភិក្ខុណាបំបួសត្រូវអាបត្តិទុក្កដ ។

ក្នុងសម័យកាលរាហុលសាមណេរមានអាយុត្រឹមតែ ៧ ខួប ព្រះបរមសាស្ដាទ្រង់សម្ដែង **រាហុលសូត្រ** ដែលពោលអំពីការមិនមើលងាយអ្នកប្រាជ្ញ មានសម្ដែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** មានន័យថា ៖

ព្រះសាស្ដាត្រាស់សួរថា អ្នកមិនមើលងាយអ្នកប្រាជ្ញ ព្រោះតែនៅរួមគ្នារឿយៗ ទេឬ បុគ្គលអ្នកទ្រោលគប់ភ្លើងបំភ្លឺដល់ពួកមនុស្ស អ្នកគោរពក្រែងដែរឬ ? ព្រះរាហុលដ៏មានអាយុក្រាបទូលថា ខ្ញុំព្រះអង្គមិនមើលងាយអ្នកប្រាជ្ញ ព្រោះនៅរួមគ្នារឿយៗ ទេ បុគ្គលអ្នកទ្រោលគប់ភ្លើងបំភ្លឺដល់ពួកមនុស្ស ខ្ញុំព្រះអង្គគោរពក្រែងជានិច្ច ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា អ្នកចូរលះបង់នូវកាមគុណ ៥ មានសភាពជាទីស្រឡាញ់ ជាទីត្រេកអរនៃចិត្ត ចេញចាកផ្ទះមកបួសដោយសទ្ធា ហើយធ្វើនូវទីបំផុត

ទុក្ខចុះ ។ អ្នកចូរគប់រកនូវកល្យាណមិត្ត និងទីដេក ទីអង្គុយ ដ៏ធ្ងាយ ស្ងប់ស្ងាត់ មិនមានសំឡេងគឹកកង ចូរជាអ្នកស្គាល់ប្រមាណក្នុងភោជន ។ អ្នកកុំធ្វើបំណងក្នុងបច្ច័យទាំងនេះ គឺចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ច័យឡើយ កុំត្រឡប់មកកាន់លោកទៀតឡើយ ។ អ្នកចូរសង្រួមក្នុងបាដិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង ចូរមានស្មារតីប្រព្រឹត្តទៅក្នុងកាយ ចូរជាបុគ្គលច្រើនដោយសេចក្តីនឿយណាយ ។ អ្នកចូរលះបង់នូវសុភនិមិត្តដែលប្រកបដោយរាគៈ ចូរចម្រើនចិត្តដោយអសុភៈ ឲ្យជាចិត្តមូលតែមួយ តាំងមាំដោយប្រពៃ មួយទៀត ចូរចម្រើននូវអនិមិត្តវិបស្សនា ចូរលះនូវអនុស័យ គឺមានះ លំដាប់តពីនោះ អ្នកនឹងប្រព្រឹត្តស្ងប់រំងាប់ ព្រោះលះបង់មានះ ។ ព្រះមានព្រះភាគ ទ្រង់ទូន្មានព្រះរាហុលដ៏មានអាយុជារឿយៗ ដោយគាថាទាំងនេះ កាលបើរាហុលបានបដិបត្តិតាម ក៏បានសម្រេចជាព្រះអរហន្ត ជាអ្នកអស់ទៅនូវឧបធិ ។

ព្រះរាហុលត្ថេរ បានស្តាប់ព្រះសូត្រដែលមានសារគតិធម៌ ឈ្មោះថា **ចូឡរាហុលោវាទសូត្រ** វគ្គដែលពោលដល់ព្រះភគវា ទ្រង់ទូន្មានព្រះរាហុល ដែលមានសម្តែងនៅក្នុងគម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ នៃភិក្ខុវគ្គ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសក្យមុនី ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង ព្រះរាហុលមានអាយុ

គង់នៅក្នុងអម្ពលដ្ឋិកាវ័ន ។ គ្រានោះឯង ព្រះពុទ្ធមានជោគ ទ្រង់ចេញចាកផលសមាបត្តិ ក្នុងវេលាសាយណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរចូលទៅឯអម្ពលដ្ឋិកាវ័ន សំដៅទៅត្រង់កន្លែងដែលព្រះរាហុលមានអាយុនៅ ។ ព្រះរាហុលមានអាយុ ក៏បានឃើញព្រះភគវា ទ្រង់ពុទ្ធដំណើរមកអំពីចម្ងាយ លុះឃើញហើយ ក៏រៀបចំអាសនៈ និងទឹកសម្រាប់លាងព្រះបាទ ។ ព្រះសាស្តា ទ្រង់គង់លើអាសនៈដែលព្រះរាហុលក្រាលបម្រុងទុក លុះគង់ហើយ ទើបលាងព្រះបាទា ។ ចំណែកខាងព្រះរាហុលមានអាយុ ក៏ក្រាបថ្វាយបង្គំព្រះលោកនាថ ហើយក៏គង់ក្នុងទីដ៏សមគួរ ។

លំដាប់នោះឯង ព្រះមហាមុនី ទ្រង់បន្សល់ទឹកបន្តិចក្នុងផ្តិលទឹក ហើយទ្រង់ត្រាស់សួរព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញទឹកសល់បន្តិច ដែលតថាគតបន្សល់ទុកក្នុងផ្តិលទឹកនេះឬទេ ? ព្រះរាហុលក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ឃើញ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុដែលមិនមានការអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចទឹកមានប្រមាណតិច យ៉ាងនេះឯង ។ បន្ទាប់អំពីនោះ ព្រះមុនី ទ្រង់ចាក់ទឹកដែលសល់បន្តិចនោះចោល ហើយសួរបញ្ជាក់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញទឹកសល់បន្តិចដែលតថាគតចាក់ចោលហើយនេះឬទេ ? ព្រះករុណាព្រះអង្គ ឃើញ ។ ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុដែលមិនមាន

សេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចទឹកដែលតថាគតចាក់ចោល ហើយយ៉ាងនេះឯង ។ ទើបព្រះមានព្រះភាគ ទ្រង់ផ្កាប់ផ្តិលទឹកនោះ ហើយត្រាស់សួរបញ្ជាក់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញផ្តិលទឹក ដែលតថាគតផ្កាប់ហើយនេះឬទេ ? ព្រះករុណាព្រះអង្គឃើញ ។ ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចផ្តិលទឹកដែលតថាគតផ្កាប់ យ៉ាងនេះឯង ។ តអំពីនោះមកទៀត ព្រះសុគត ទ្រង់ផ្ងារផ្តិលនោះ ត្រាស់សួរបញ្ជាក់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញផ្តិលទឹកដែលទទេរលីងធេងនេះឬទេ ? ព្រះករុណាព្រះអង្គ ឃើញ ។ ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចផ្តិលទឹកដែលទទេរលីងធេង យ៉ាងនេះឯង ។

ម្នាលរាហុល ដូចជាដំរីរបស់ស្តេច ដែលមានភ្លុក.ង.ទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ដំរីនោះ កាលបើចូលទៅកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ធ្វើការដោយជើងក្រោយខ្លះ ធ្វើការដោយកាយខាងមុខខ្លះ ធ្វើការដោយកាយខាងក្រោយខ្លះ ធ្វើការដោយក្បាលខ្លះ ធ្វើការដោយត្រចៀកខ្លះ ធ្វើការដោយភ្លុកខ្លះ ធ្វើការដោយកន្ទុយខ្លះ រក្សាទុកតែប្រមោយប៉ុណ្ណោះ ។ ឯហ្មដំរី មានសេចក្តីត្រិះរិះក្នុងដំណើរដែលដំរីរក្សាប្រមោយទុកនោះ យ៉ាងនេះថា ដំរីរបស់ស្តេចនេះ

ឯង មានភ្លុក.ង.ទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ទោះបីចូលទៅកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ជើងក្រោយខ្លះ ដោយកាយខាងមុខខ្លះ កាយខាងក្រោយខ្លះ ដោយក្បាលខ្លះ ដោយស្លឹកត្រចៀកខ្លះ ដោយភ្លុកខ្លះ ដោយកន្ទុយខ្លះ រក្សាទុកតែប្រមោយប៉ុណ្ណោះ ដំរីរបស់ស្តេចនេះ ឈ្មោះថា មិនទាន់ប្រថុយជីវិតឡើយ ។ ម្នាលរាហុល កាលដែលដំរីរបស់ស្តេច មានភ្លុក.ង.ទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ទោះបីចូលទៅកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ជើងក្រោយខ្លះ ។ បេ ។ ធ្វើការដោយកន្ទុយខ្លះ ធ្វើការដោយប្រមោយខ្លះ ។ ហ្មដំរី មានសេចក្តីត្រិះរិះក្នុងដំណើរនោះយ៉ាងនេះថា ដំរីរបស់ស្តេចនេះឯង មានភ្លុក.ង.ទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ទោះបីចូលទៅកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ជើងក្រោយខ្លះ កាយខាងមុខខ្លះ កាយខាងក្រោយខ្លះ ក្បាលខ្លះ ស្លឹកត្រចៀកខ្លះ ភ្លុកខ្លះ កន្ទុយខ្លះ ដោយប្រមោយខ្លះ ដំរីរបស់ស្តេចនេះ ទើបឈ្មោះថា ប្រថុយលះបង់ជីវិតហើយ ឥឡូវនេះ អំពើណាមួយដែលដំរីរបស់ស្តេច ឈ្មោះថា មិនទាន់ធ្វើ មិនមានឡើយ សេចក្តីនេះ មានឧបមាយ៉ាងណា ។ ម្នាលរាហុល មានឧបមេយ្យដូចភិក្ខុរូបខ្លះ ដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ តថាគតមិនពោលថា ភិក្ខុនោះមិនធ្វើបាបកម្មបន្តិចបន្តួចដូច្នេះទេ ។ ម្នាល

រាហុល ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគួរសិក្សាថា អាត្មាអញនឹងមិនពោលពាក្យកុហក សូម្បីដើម្បីសើចលេង ម្នាលរាហុល អ្នកត្រូវសិក្សា យ៉ាងនេះចុះ ។

ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច កញ្ចក់មានប្រយោជន៍ដូចម្តេច ? បពិត្រព្រះអង្គដ៏ចម្រើន កញ្ចក់មានប្រយោជន៍ខាងការឆ្លុះមើលមុខ ។ ម្នាលរាហុល យ៉ាងនោះពិតមែនហើយ អ្នកគប្បីពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយកាយ វាចា ចិត្ត ។ ម្នាលរាហុល បើអ្នកចង់ធ្វើអំពើណាមួយ ដោយកាយ វាចា ឬក៏ដោយចិត្ត ត្រូវពិចារណាមើលកាយកម្ម វចីកម្ម មនោកម្មនោះសិនថា អាត្មាអញចង់ធ្វើអំពើណា ដោយកាយ វាចា ចិត្ត តើកាយកម្ម វចីកម្ម មនោកម្មរបស់អាត្មាអញនេះឯង ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែក គឺខ្លួនឯង និងអ្នកដទៃផង កាយកម្ម វចីកម្ម មនោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល បើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ ចង់ធ្វើអំពើណាដោយកាយ វាចា ចិត្ត កាយកម្ម វចីកម្ម មនោកម្មរបស់អាត្មាអញនោះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងផង បុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្ម វចីកម្ម មនោកម្ម

នេះជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកមិនត្រូវធ្វើអំពើដោយកាយ វាចា ចិត្តដែលមានទំនងយ៉ាងនេះជាដាច់ខាត ។ ម្នាលរាហុល ប្រសិនបើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញ ចង់ធ្វើអំពើណាដោយកាយ វាចា ចិត្ត កាយកម្ម វចីកម្ម មនោកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងផង បុគ្គលដទៃផង ឬបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្ម វចីកម្ម មនោកម្មនេះ ជាកុសល ចម្រើនតែខាងសេចក្ដីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើអំពើដោយកាយ វាចា ចិត្ត យ៉ាងនេះចុះ។ ម្នាលរាហុល បើទុកជាអ្នកកំពុងធ្វើអំពើដោយកាយ វាចា ចិត្ត អ្នកត្រូវតែពិចារណាមើលនូវកាយកម្ម វចីកម្ម មនោកម្មនោះឯងថា អាត្មាអញកំពុងធ្វើអំពើណាដោយកាយ វាចា ចិត្ត តើកាយកម្ម វចីកម្ម មនោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងផង បុគ្គលដទៃផង បៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្ម វចីកម្ម មនោកម្មនេះ ជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញកំពុងធ្វើអំពើណា ដោយកាយ វាចា ចិត្ត កាយកម្ម វចីកម្ម មនោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងផង បុគ្គលដទៃផង បៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្ម វចីកម្ម មនោកម្មនេះ

ជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវលះបង់កាយកម្ម វចីកម្ម មនោកម្ម ដែលមានទំនងយ៉ាងនេះចេញ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញកំពុងធ្វើអំពើណា ដោយកាយ វាចា ចិត្ត កាយកម្ម វចីកម្ម មនោកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងផង បុគ្គលដទៃផង បុគ្គលទាំងពីរចំណែកផង កាយកម្ម វចីកម្ម មនោកម្មនេះ ជាកុសល ចម្រើនតែខាងសេចក្ដីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើឲ្យរឿយៗ នូវកាយកម្ម វចីកម្ម មនោកម្មដែលមានទំនងយ៉ាងនេះចុះ ។ ម្នាលរាហុល បើអ្នកបានធ្វើអំពើណាដោយកាយ វាចា ចិត្តរួចហើយ អ្នកត្រូវពិចារណាមើលនូវកាយកម្ម វចីកម្ម មនោកម្មនោះថា អាត្មាអញ បានធ្វើអំពើណាដោយកាយ វាចា ចិត្ត តើកាយកម្ម វចីកម្ម មនោកម្មរបស់អាត្មាអញនោះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងផង បុគ្គលដទៃផង បុគ្គលទាំងពីរចំណែកផង កាយកម្ម វចីកម្ម មនោកម្មនោះ ជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញបានធ្វើកាយកម្ម វចីកម្ម មនោកម្មណា កាយកម្ម វចីកម្ម មនោកម្មនោះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងផង បុគ្គលដទៃផង បុគ្គលទាំងពីរចំណែកផង កាយកម្ម វចីកម្ម មនោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ

មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវសម្តែងបើកបង្ហាញប្រាប់នូវកាយកម្ម វចីកម្ម មនោកម្ម ដែលមានទំនងយ៉ាងនេះចំពោះគ្រូ ឬចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ជាអ្នកប្រាជ្ញ លុះអ្នកសម្តែង បើកបង្ហាញប្រាប់រួចហើយ អ្នកគប្បីដល់នូវការសង្រួមតទៅ ។ ម្នាលរាហុល ប្រសិនបើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញធ្វើអំពើណាដោយកាយ វាចា ចិត្ត កាយកម្ម វចីកម្ម មនោកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងផង បុគ្គលដទៃផង បុគ្គលទាំងពីរចំណែកផង កាយកម្ម វចីកម្ម មនោកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវចំសិក្សាទាំងយប់ទាំងថ្ងៃ ក្នុងធម៌ទាំងឡាយជាកុសល ហើយនៅដោយបីតិ និងបាមោជ្ជនុ៎ះឯង ។

ម្នាលរាហុល ព្រោះថា សមណៈ ឬព្រាហ្មណ៍ណាមួយ ក្នុងកាលដែលកន្លងទៅហើយ បានជម្រះកាយកម្ម ជម្រះវចីកម្ម ជម្រះមនោកម្ម ពួកសមណព្រាហ្មណ៍ទាំងអស់នោះ សុទ្ធតែបានពិចារណា ត្រិះរិះមើលសព្វយ៉ាងនេះហើយ ទើបជម្រះកាយកម្ម វចីកម្ម ពិចារណា ត្រិះរិះមើលសព្វយ៉ាងនេះហើយ ទើបជម្រះមនោកម្មដែរ ។ ម្នាលរាហុល សមណៈ ឬព្រាហ្មណ៍ណាមួយ ក្នុងកាលដែលនឹងមានមក នឹងជម្រះកាយកម្ម វចីកម្ម មនោកម្ម ក៏ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ នឹងពិចារណា

ត្រិះរិះមើលសព្វយ៉ាងនេះហើយ ទើបជម្រះកាយកម្ម វចីកម្ម ពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះមនោកម្មដែរ ។ ម្នាលរាហុល សមណៈ ឬព្រាហ្មណ៍ណាមួយ ក្នុងកាលឥឡូវនេះ ជម្រះកាយកម្ម វចីកម្ម មនោកម្ម ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ តែងពិចារណាមើលសព្វយ៉ាងនេះហើយ ទើបជម្រះកាយកម្ម វចីកម្ម ពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះមនោកម្មផងដែរ ។ ម្នាលរាហុល ព្រោះដូច្នោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាថា អាត្មាអញ នឹងពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះកាយកម្ម វចីកម្ម អាត្មាអញ នឹងពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះមនោកម្ម ដូច្នេះ ម្នាលរាហុល អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ កាលបើព្រះលោកនាថ ទ្រង់ត្រាស់សម្តែងព្រះសូត្រនេះចប់ហើយ ព្រះរាហុលត្ថេរ មានចិត្តត្រេកអរចំពោះភាសិតនេះ ។

ក្រោយពីព្រះរាហុល បានស្តាប់ចូឡរាហុលោវាទសូត្រហើយ ថែមទាំងបានស្តាប់ **មហារាហុលោវាទសូត្រ** ទៀត ដែលមានប្រាកដក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ** នៃ **ភិក្ខុវគ្គ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះវិជិតមារទ្រង់ស្បង់ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ។ ចំណែកខាងព្រះរាហុលមានអាយុ ក៏

ស្លៀកស្បង់ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយនិមន្តតាមក្រោយៗ ព្រះមានព្រះភាគ ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ឆ្មៀងព្រះកត្រ្គ ត្រាស់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល រូបណាមួយ ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ប្រណីតក្តី ឬរូបណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដែលជាអតីត អនាគត បច្ចុប្បន្ន រូបទាំងអស់នោះ ក៏គ្រាន់តែជារូប ( ប៉ុណ្ណោះឯង ) អ្នកគួរយល់ឃើញនូវរូបនោះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ ព្រះរាហុលក្រាបបង្គំសួរថា បពិត្រព្រះមានព្រះភាគ ( សេចក្តីនេះ ) មានតែរូបម្យ៉ាងទេឬ បពិត្រព្រះសុគត ( សេចក្តីនេះ ) មានតែរូបម្យ៉ាងទេឬ ? ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលរាហុល រូបក៏មាន វេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏មាន ។

គ្រានោះឯង ព្រះរាហុលគិតថា បាននរណាហ្ន៎ជាវិញ្ញូបណ្ឌិត ដែលព្រះមានព្រះភាគទូន្មានហើយ ដោយដំបូន្មានផ្ទាល់ព្រះឱស្ឋ នឹងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ក្នុងថ្ងៃនេះទៅអេះ ដូច្នេះហើយ លោកក៏ត្រឡប់ថយចេញ អំពីសម្នាក់ព្រះមានព្រះភាគនោះ ហើយទៅអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងស្មារតីឲ្យមានមុខឆ្ពោះទៅរកព្រះកម្មដ្ឋាន ទៀបគល់ឈើមួយដើម ។ គាប់ជួនជាព្រះសារីបុត្រ បានឃើញព្រះរាហុល

កំពុងអង្គុយទៀបគល់ឈើមួយដើម លុះឃើញហើយ ក៏ប្រាប់ព្រះរាហុលថា ម្នាលរាហុល អ្នកចូរចម្រើនអានាបានស្សតិភាវនាចុះ ត្បិតអានាបានស្សតិភាវនា ដែលបានអប់រំហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ លុះដល់ថ្ងៃរសៀល ព្រះរាហុលក្រោកពីសិង ហើយចូលទៅកាន់ទីដែលព្រះមានព្រះភាគទ្រង់គង់ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាហុលគង់ក្នុងទីសមគួរហើយ ក៏ទូលចំពោះព្រះភគវាថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអានាបានស្សតិ ត្រូវចម្រើនដោយប្រការដូចម្តេច ទើបមានផលច្រើន មានអានិសង្សច្រើន ?

ព្រះមានព្រះភាគត្រាស់តបថា ម្នាលរាហុល រូបណាមួយ ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន ជារូបគ្រោតគ្រាត ជារូបរឹង ជារូបដែលវិញ្ញាណគ្រប់គ្រង គឺសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ពុំនោះសោត រូបណាមួយក្រៅពីនេះ ហៅថា បឋវីធាតុខាងក្នុង ។ មួយទៀត បឋវីធាតុណាខាងក្នុងក្តី ខាងក្រៅក្តី ធាតុទាំងនោះឈ្មោះថា បឋវីធាតុដូចគ្នា ។ បុគ្គលគួរឃើញបឋវីធាតុនោះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់

អញឡើយ ។ បុគ្គលលុះឃើញបឋវីធាតុនោះ ដោយប្រាជ្ញាដ៏ប្រពៃតាមសេចក្តីពិតយ៉ាងនេះហើយ រមែងនឿយណាយចាកបឋវីធាតុ ធ្វើចិត្តឲ្យប្រាសចេញពីបឋវីធាតុ ។

ម្នាលរាហុល ចុះអាបោធាតុ តើដូចម្តេចខ្លះ អាបោធាតុនោះ ខាងក្នុងក៏មាន ខាងក្រៅក៏មាន ម្នាលរាហុល ចុះអាបោធាតុខាងក្នុងដូចម្តេច ? រូបណាដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន មានសភាពជាទឹក ដល់នូវភាពជាទឹក ដែលវិញ្ញាណចូលទៅគ្រប់គ្រង គឺប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ពុំនោះសោត រូបណាមួយក្រៅពីនេះ ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន មានសភាពជាទឹក ដល់នូវភាពជាទឹក ដែលវិញ្ញាណចូលទៅគ្រប់គ្រង ម្នាលរាហុល នេះហៅថា អាបោធាតុខាងក្នុង ។ ម្យ៉ាងទៀត អាបោធាតុណា ខាងក្នុងក្តី ក្រៅក្តី ធាតុទាំងនោះហៅថា អាបោធាតុដូចគ្នា ។ បុគ្គលគួរឃើញអាបោធាតុនោះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ បុគ្គលលុះឃើញអាបោធាតុនោះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះហើយ រមែងនឿយណាយចាកអាបោធាតុ ធ្វើចិត្តឲ្យប្រាសចាកពីអាបោធាតុ ។

ម្នាលរាហុល ចុះតេជោធាតុ តើដូចម្តេចខ្លះ ? តេជោធាតុនោះ

ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល ចុះតេជោធាតុខាងក្នុងដូចម្ដេច ? រូបណាដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន ជារបស់ក្ដៅដល់នូវភាពជារបស់ក្ដៅ ដែលវិញ្ញាណចូលទៅគ្រប់គ្រង គឺភ្លើងដែលអប់ឧណ្ហកាយ ១ ភ្លើងដែលធ្វើកាយឲ្យទ្រុឌទ្រោម ១ ភ្លើងដែលធ្វើកាយឲ្យក្ដៅរោលរាល ១ ភ្លើងដែលធ្វើនូវអាហារដែលបានស៊ីផឹកទំពា លិទ្ធភក្សហើយ ឲ្យទ្រុឌទ្រោមរលួយទៅដោយស្រួល ១ ពុំនោះសោត រូបណាមួយក្រៅអំពីនេះ ដែលជារូបខាងក្នុង ជារបស់ក្ដៅ ម្នាលរាហុល នេះហៅថា តេជោធាតុខាងក្នុង ។ មួយវិញទៀត តេជោធាតុណាខាងក្នុងក្ដី ក្រៅក្ដី ធាតុទាំងនោះ ហៅថា តេជោធាតុដូចគ្នា ។ បុគ្គលគួរឃើញនូវតេជោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្ដីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ បុគ្គលលុះឃើញតេជោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្ដីពិតយ៉ាងនេះហើយ រមែងនឿយណាយចាកតេជោធាតុ ធ្វើចិត្តឲ្យប្រាសចាកពីតេជោធាតុ ។

ម្នាលរាហុល ចុះវាយោធាតុ តើដូចម្ដេច ? វាយោធាតុនុ៎ះ ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល រូបណា ដែលជាខាងក្នុង ជារូបដែលអាស្រ័យនូវខ្លួន មានសភាពជាខ្យល់ ដល់នូវសភាពជាខ្យល់ ដែលវិញ្ញាណចូលទៅគ្រប់គ្រង គឺខ្យល់បក់ឡើងទៅខាងលើ ១ ខ្យល់បក់ចុះមកខាងក្រោម ១ ខ្យល់បក់ក្រៅពោះវៀន ១ ខ្យល់បក់ក្នុងពោះ

វៀន ១ ខ្យល់បក់សព្វអវយវៈតូចធំ ១ ខ្យល់ដង្ហើមចេញចូល ១ ពុំនោះសោត រូបណាមួយក្រៅអំពីនេះ ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន មានសភាពជាខ្យល់ ដល់នូវសភាពជាខ្យល់ ដែលវិញ្ញាណចូលទៅគ្រប់គ្រង ម្នាលរាហុល នេះហៅថា វាយោធាតុខាងក្នុង ។ មួយទៀត វាយោធាតុណាជាខាងក្នុងក្តី ខាងក្រៅក្តី ធាតុទាំងនុ៎ះ ហៅថា វាយោធាតុដូចគ្នា ។ បុគ្គលគួរឃើញវាយោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ បុគ្គល លុះឃើញវាយោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះហើយ រមែងនឿយណាយចាកវាយោធាតុ ធ្វើចិត្តឲ្យប្រាសចាកពីវាយោធាតុ ។

ម្នាលរាហុល អាកាសធាតុ តើដូចម្តេចខ្លះ ? អាកាសធាតុនុ៎ះ ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល អាកាសធាតុខាងក្នុង តើដូចម្តេច ? រូបណា ជារូបខាងក្នុង ដែលជារូបអាស្រ័យនូវខ្លួន មានសភាពជាទីវាល ដល់នូវសភាពជាទីទំនេរ ដែលវិញ្ញាណចូលទៅគ្រប់គ្រង គឺរន្ធត្រចៀក រន្ធច្រមុះ ទ្វារមាត់ បុគ្គលលេបចូលនូវអាហារដែលស៊ីផឹកទំពាលិទ្ធភក្សហើយតាមទ្វារណាក្តី ភោជនដែលបុគ្គលស៊ីផឹកទំពាលិទ្ធភក្សហើយ ឋិតនៅខាងក្នុងទ្វារណាក្តី ភោជនដែលបុគ្គលស៊ីផឹកទំពាលិទ្ធភក្សហើយ តែងចេញមកតាមចំណែកខាងក្រោម ដោយទ្វារណាក្តី ពុំ

នោះសោត រូបណាមួយក្រៅអំពីនេះ ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន មានសភាពជាវាល ដល់នូវភាពជាទីទំនេរ ជាទីទទេ ដល់នូវភាពទទេ ជាចន្លោះ ដល់នូវទីជាចន្លោះ ដែលសាច់ និងឈាមប៉ះពាល់គ្នា ដែលវិញ្ញាណចូលទៅគ្រប់គ្រង ម្នាលរាហុល នេះហៅថា អាកាសធាតុខាងក្នុង ។ មួយទៀត អាកាសធាតុណាជាខាងក្នុងក្តី ខាងក្រៅក្តី ធាតុទាំងនោះ ហៅថា អាកាសធាតុដូចគ្នា ។ បុគ្គលគួរឃើញអាកាសធាតុនោះដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ បុគ្គលលុះឃើញអាកាសធាតុនោះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះហើយ រមែងនឿយណាយចាកអាកាសធាតុ ធ្វើចិត្តឲ្យប្រាសចាកពីអាកាសធាតុ ។

ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាផែនដី ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាផែនដីហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្តដែលកើតហើយ រមែងមិនគ្របសង្កត់នូវចិត្តអ្នក ។ ម្នាលរាហុល ជនទាំងឡាយដាក់វត្ថុស្អាតក្តី ដាក់វត្ថុមិនស្អាតក្តី បន្ទោបង់នូវលាមកក្តី បន្ទោបង់នូវទឹកមូត្រក្តី ដាក់ចុះនូវទឹកមាត់ក្តី ដាក់ចុះនូវខ្ទុះក្តី សម្រក់ឈាមដាក់ក្តី លើផែនដី ផែនដីក៏មិនថ្នាំងថ្នាក់ ឬធុញទ្រាន់ ឬក៏ខ្ពើមរអើមដោយវត្ថុទាំងនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាផែនដីយ៉ាងនោះឯង ព្រោះថា កាលបើអ្នកចម្រើន

ការនាឲ្យដូចជាផែនដីហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្តដែល កើតហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

ម្នាលរាហុល អ្នកចូរចម្រើនការនា ឲ្យដូចជាទឹក ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនការនា ឲ្យដូចជាទឹកហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់នូវចិត្ត ។ ម្នាលរាហុល ជនទាំងឡាយ លាងវត្ថុស្អាតក្តី លាងវត្ថុមិនស្អាតក្តី លាងលាមកក្តី លាងទឹកមូត្រក្តី លាងទឹកមាត់ក្តី លាងខ្ទុះក្តី លាងឈាមក្តី ក្នុងទឹក ទឹកក៏មិនបានថ្នាំងថ្នាក់ ឬធុញទ្រាន់ ឬក៏ខ្ពើមរអើម ដោយវត្ថុទាំងនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនការនាឲ្យដូចជាទឹកយ៉ាងនោះឯង ព្រោះថា កាលបើអ្នកចម្រើនការនាឲ្យដូចជាទឹកហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

ម្នាលរាហុល អ្នកចូរចម្រើនការនាឲ្យដូចជាភ្លើង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនការនាឲ្យដូចជាភ្លើងហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។ ម្នាលរាហុល ភ្លើងឆេះនូវវត្ថុស្អាតក្តី ឆេះវត្ថុមិនស្អាតក្តី ឆេះលាមកក្តី ឆេះទឹកមូត្រក្តី ឆេះទឹកមាត់ក្តី ឆេះខ្ទុះក្តី ឆេះឈាមក្តី ភ្លើងក៏មិនថ្នាំងថ្នាក់ ឬធុញទ្រាន់ ឬក៏ខ្ពើមរអើម ចំពោះវត្ថុទាំងនោះឡើយ យ៉ាងណាមិញ

ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាភ្លើង យ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាភ្លើងហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាខ្យល់ ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាខ្យល់ហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្តដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។ ម្នាលរាហុល ខ្យល់បក់នូវវត្ថុស្អាតក្តី បក់នូវវត្ថុមិនស្អាតក្តី បក់ត្រូវលាមកក្តី បក់ត្រូវទឹកមូត្រក្តី បក់ត្រូវទឹកមាត់ក្តី បក់ត្រូវខ្ទុះក្តី បក់ត្រូវឈាមក្តី ខ្យល់ក៏មិនថ្នាំងថ្នាក់ ឬធុញទ្រាន់ ឬក៏ខ្ពើមរអើមចំពោះវត្ថុទាំងនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាខ្យល់ យ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាខ្យល់ហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាអាកាស ព្រោះថា កាលបើអ្នកចម្រើនភាវនា ឲ្យដូចជាអាកាសហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។ ម្នាលរាហុល ស្នាមគំនូសមិនមាននៅក្នុងអាកាស យ៉ាងណាមិញ ម្នាលរាហុល

អ្នកចូរចម្រើនភាវនាឲ្យដូចជាអាកាស យ៉ាងនោះឯង ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាអាកាសហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

ម្នាលរាហុល អ្នកចូរចម្រើននូវមេត្តាភាវនា ព្រោះថា កាលបើអ្នកចម្រើនមេត្តាភាវនាហើយ វិហិង្សានឹងវិនាសសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនករុណាភាវនា ព្រោះថា កាលបើអ្នកចម្រើនករុណាភាវនាហើយ វិហិង្សា គឺការបៀតបៀន នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនមុទិតាភាវនា ព្រោះថា កាលបើអ្នកចម្រើនមុទិតាភាវនាហើយ អរតិ គឺសេចក្តីមិនត្រេកអរ នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនឧបេក្ខាភាវនា ព្រោះថា កាលបើអ្នកចម្រើនឧបេក្ខាភាវនាហើយ បដិឃៈ គឺការថ្នាំងថ្នាក់ចិត្ត នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនអសុភភាវនា ព្រោះថា កាលបើអ្នកចម្រើនអសុភភាវនាហើយ រាគៈ គឺតម្រេកក្នុងកាមគុណ នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនអនិច្ចសញ្ញាភាវនា ព្រោះថា កាលបើអ្នកចម្រើនអនិច្ចសញ្ញាភាវនាហើយ អស្មិមានះ គឺការប្រកាន់ខ្លួន នឹងសាបសូន្យទៅ ។

ម្នាលរាហុល អ្នកចូរចម្រើននូវអានាបានស្សតិភាវនា ម្នាលរាហុល អានាបានស្សតិភាវនាដែលអ្នកបានចម្រើនហើយ បានធ្វើឲ្យរឿយៗហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលរាហុល ចុះ

អានាបានស្សតិការនាដែលចម្រើនហើយ តើដូចម្ដេច ដែលធ្វើឲ្យរឿយៗ ហើយ តើដូចម្ដេច ទើបជាគុណជាតិមានផលច្រើន មានអានិសង្ស ច្រើន ? ម្នាលរាហុល ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្ដី នៅទៀបគល់ ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី អង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តម្កល់ ស្មារតី ឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ហើយភិក្ខុនោះ មានស្មារតីដក ដង្ហើមចេញ ដកដង្ហើមចូល ។ កាលដកដង្ហើមចេញវែង ចូលវែង ក៏ ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ចូលវែង ។ កាលដកដង្ហើម ចេញខ្លី ចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ចូលខ្លី ។ ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកាយ គឺការដកដង្ហើមទាំងពួង ហើយ ដកដង្ហើមចេញ-ចូល ។ ភិក្ខុសិក្សាថា អាត្មាអញ នឹងរំងាប់នូវកាយ សង្ខារ គឺដង្ហើមចេញ និងដង្ហើមចូល ហើយដកដង្ហើមចេញ-ចូល ។ ភិក្ខុ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវសេចក្ដីសុខហើយ ដកដង្ហើមចេញ- ចូល ។ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្តសង្ខារ គឺវេទនាខន្ធ និង សញ្ញាខន្ធ ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញនឹងរំងាប់ នូវចិត្តសង្ខារ ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញ នឹង រំងាប់នូវចិត្ត ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញ នឹង ធ្វើចិត្តឲ្យរីករាយ ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញ

នឹងតម្កល់ចិត្តឲ្យស្មើ ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញ នឹងដកចិត្តឲ្យផុតស្រឡះចាកនីវរណៈ ជាដើម ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណានូវបញ្ចក្ខន្ធថាមិនទៀង ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណាធម៌ជាគ្រឿងធ្វើឲ្យចិត្តប្រាសចាកតម្រេក ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញនឹងពិចារណានូវសេចក្ដីរលត់នៃកងទុក្ខ ហើយដកដង្ហើមចេញ-ចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណាធម៌ជាគ្រឿងធ្វើចិត្តឲ្យលះបង់នូវកិលេស ព្រមទាំងខន្ធ និងអភិសង្ខារ ហើយដកដង្ហើមចេញ-ចូល ។ ម្នាលរាហុល អានាបានស្សតិ ដែលបុគ្គលបានចម្រើនហើយយ៉ាងនេះ ធ្វើឲ្យរឿយៗ ហើយ យ៉ាងនេះឯង ទើបជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ម្នាលរាហុល កាលបើអានាបានស្សតិដែលបុគ្គលចម្រើនហើយយ៉ាងនេះ ធ្វើឲ្យរឿយៗ ហើយយ៉ាងនេះ ដកដង្ហើមចេញ និងដកដង្ហើមចូលទាំងឡាយណា ដែលមានក្នុងកាលជាខាងក្រោយ ដកដង្ហើមចេញ និងដកដង្ហើមចូលទាំងនោះ នឹងរលត់ទៅវិញជាពិតប្រាកដ មិនមែនមិនរលត់ទៅវិញនោះទេ ។

លុះព្រះសាស្ដា ត្រាស់សម្ដែងសូត្រនេះចប់ហើយ ព្រះរាហុលក៏មានចិត្តរីករាយត្រេកអរចំពោះភាសិតនេះ ។ ម្យ៉ាងទៀត ព្រះរាហុលជាអ្នកស្រឡាញ់ពេញចិត្តក្នុងការសិក្សា ពីព្រោះពេលដែលលោកភ្ញាក់

ឡើងពីព្រលឹម លោកតែងតែក្តាប់ដីខ្សាច់មួយក្តាប់ ហើយពោលថា ថ្ងៃនេះយើងនឹងទទួលស្តាប់ឱវាទ ឲ្យស្មើគ្នានឹងគ្រាប់ខ្សាច់ក្នុងដៃរបស់យើង អំពីព្រះសាស្តា ឬពីព្រះឧបជ្ឈាយាចារ្យរបស់យើង ក្រៅពីនេះ លោកជាអ្នកទូន្មានបានងាយទៀតផង ។

មានរឿងដែលទាក់ទងជាមួយព្រះរាហុល ដែលមានការសិងនៅរួមជាមួយនឹងភិក្ខុ មានប្រាកដក្នុង **គម្ពីរមហាវិភង្គ ព្រះវិន័យបិដក** នៃ **មុសាវាទវគ្គ** និងក្នុង**អដ្ឋកថាខុទ្ទកនិកាយ មហានិបាតជាតក នៃតិបល្លត្ថមិគជាតក** ដូចមានសេចក្តីថា ៖

សម័យនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ កាលគង់នៅអគាឡវចេតិយ ជិតក្រុងអាឡវី ។ សម័យនោះឯង ពួកឧបាសកតែងមកកាន់អារាមដើម្បីស្តាប់ធម៌ ។ កាលបើធម្មកថិកសម្តែងធម៌ចប់ហើយ ពួកភិក្ខុជាថេរៈក៏ទៅកាន់ទីដែលខ្លួននៅ ។ ភិក្ខុបួសថ្មីទាំងឡាយ ក៏ភ្លេចសតិមិនដឹងខ្លួន ជាអ្នកអាក្រាតកាយ ថ្ងូរស្រមុកដេកលក់ជាមួយនឹងឧបាសកទាំងឡាយ ក្នុងសាលាសម្រាប់ធ្វើបុណ្យនោះឯង ។ ឧបាសកទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនទំនងជាមនុស្សភ្លេចសតិ មិនដឹងខ្លួន ជាអ្នកអាក្រាតកាយថ្ងូរស្រមុកសិងលក់ឡើយ ។ ភិក្ខុទាំងឡាយ ក៏បានឮពាក្យរបស់ឧបាសកទាំងនោះពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តី

ប្រាជ្ញាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុទាំងឡាយសិងជាមួយនឹងអនុបសម្បន្នឡើយ ។ គ្រានោះឯង ភិក្ខុទាំងនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះមហាមុនី ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុទៅសិងជាមួយនឹងអនុបសម្បន្ន ( រឿងនេះ ) ពិតឬ ? ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការណ៍នុ៎ះពិតមែន ។ ព្រះមានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនទំនងដេកជាមួយនឹងអនុបសម្បន្នសោះ ម្នាលភិក្ខុទាំងឡាយ កម្មនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយដេកជាមួយនឹងអនុបសម្បន្នត្រូវ **អាបត្តិបាចិត្តិយៈ** ។

គ្រានោះឯង ព្រះសុគតកាលគង់នៅក្នុងក្រុងអាឡវី សមគួរហើយ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកនាក្រុងកោសម្ពី ទ្រង់យាងដោយលំដាប់ទៅក៏បានដល់ក្រុងកោសម្ពីនោះឯង ។ បានឮថា ព្រះលោកនាថទ្រង់សម្រេចឥរិយាបថនៅពុទ្ធិការាម ជិតក្រុងកោសម្ពីនោះ ។ ភិក្ខុទាំងឡាយបានពោលពាក្យនេះនឹងរាហុលដ៏មានអាយុថា ម្នាលរាហុល សិក្ខាបទព្រះភគវាទ្រង់ត្រាស់បញ្ញត្តិដូច្នេះថា ភិក្ខុមិនត្រូវដេកជាមួយនឹងអនុបសម្បន្នទេ ម្នាលរាហុល ( ជាសាមណេរ ) អ្នកចូរដឹងនូវទីសិងចុះ ។ គ្រានោះ

រាហុលរកទីសិងមិនបាន ក៏ទៅសិងក្នុងវច្ចកុដិ ( បង្គន់ ) ។ ខណៈនោះ ព្រះសាស្តាទ្រង់តើនអំពីយប់ ក្នុងវេលាបច្ចូសសម័យនៃរាត្រីហើយ យាង ចូលទៅទីវច្ចកុដិ លុះយាងចូលទៅដល់ហើយ ទ្រង់ឲ្យនូវព្រះសូរសៀង ( គឺគ្រហែមតាមទំនៀមវច្ចកុដិវត្ត ) ។ ឯរាហុលក៏គ្រហែមត ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា នរណានៅក្នុងវច្ចកុដិនេះ ។ រាហុលក៏ក្រាបទូលថា បពិត្រព្រះមានជោគ ខ្ញុំព្រះអង្គឈ្មោះរាហុល ។ ព្រះអង្គទ្រង់ត្រាស់សួរ ថា ម្នាលរាហុល ហេតុអ្វីបានជាអ្នកមកសិងក្នុងវច្ចកុដិនេះ ។ គ្រានោះ រាហុលក៏ក្រាបទូលរឿងនោះ ចំពោះព្រះសក្យមុនី ។ ព្រោះរឿងនេះដំណើរ នេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ សម្តែងថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យអ្នកទាំងឡាយ សម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្នពីរយប់ ឬបីយប់បាន ។ ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះ ថា ភិក្ខុណាមួយ សម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្ន លើសជាង ពីរយប់ ឬបីយប់ឡើងទៅ ភិក្ខុនោះត្រូវ **អាបត្តិបាចិត្តិយៈ** ។

ថ្ងៃមួយ ភិក្ខុទាំងឡាយ ប្រជុំសន្ទនាគ្នាសរសើរអំពីព្រះរាហុល ក្នុងសាលាធម្មសភាថា ព្រះរាហុលជាអ្នកពេញចិត្តក្នុងការសិក្សា ជាអ្នក ទូន្មានបានងាយ ប្រាប់ត្រឹមតែពាក្យមួយម៉ាត់ប៉ុណ្ណោះ ក៏បានទៅសិងនៅ ក្នុងវច្ចកុដិ ។ ពេលនោះ ព្រះសម្ពុទ្ធស្តេចយាងមកដល់ ទើបត្រាស់សួរ

ថា ម្នាលភិក្ខុទាំងឡាយ អ្នកសន្ទនាគ្នាពីរឿងអ្វី ? ភិក្ខុទាំងនោះក្រាបទូលសេចក្តីនោះ ចំពោះព្រះមានព្រះភាគឲ្យទ្រង់ជ្រាប ព្រះអង្គក៏ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនត្រឹមតែជាតិនេះទេ សូម្បីក្នុងអតីតជាតិ រាហុលក៏ដូចគ្នាដែរ ។

មានសម្តែងនៅក្នុង **អដ្ឋកថាគម្ពីរខុទ្ទកនិកាយ មិគជាតក** គឺជាតិដែលកើតជាសត្វម្រឹគ មានសេចក្តីថា ៖

ក្នុងអតីតជាតិ នៅក្នុងនគររាជគ្រឹះ មានម្រឹគមួយហ្វូងធំនៅក្នុងព្រៃមួយកន្លែង ព្រះមានព្រះភាគកើតជាមេហ្វូងម្រឹគ និងជាបងរបស់ព្រះនាងឧប្បលវណ្ណា នាងកើតជាមេម្រឹគ ព្រះរាហុលកើតជាកូនម្រឹគ មេម្រឹគតែងតែមានសេចក្តីស្រឡាញ់ ភ័យព្រួយចំពោះកូនណាស់ ទើបនាំកូនទៅផ្ញើនឹងបងឲ្យជួយទូន្មាន ម្រឹគជាបងទទួលយល់ព្រម ជួយទូន្មានកូនម្រឹគគ្រប់យ៉ាង ។ ថ្ងៃមួយ កូនម្រឹគបានដើរចូលទៅជាប់អន្ទាក់នាយព្រាន ហើយយំស្រែកសំឡេងឡើងយ៉ាងខ្លាំង ពួកម្រឹគបានឮសំឡេងដូច្នោះហើយ ក៏នាំគ្នារត់ទៅមើល ។ មេម្រឹគបានឮសំឡេងកូនយំក៏ចាំបាន ទើបចូលទៅរកសត្វម្រឹគជាបង និងសាកសួរថា តើបងបានទូន្មានកូនរបស់ខ្ញុំបានល្អហើយឬ ? ព្រះបរមពោធិសត្វតបថា អ្នកកុំភ័យព្រួយក្នុងរឿងនេះឡើយ កូនរបស់អ្នកជាអ្នកឈ្លាសវៃ អាចនឹងការពារខ្លួនបាន ព្រោះខ្ញុំបានទូន្មានឲ្យចេះបញ្ឆោតនាយព្រានដោយឧបាយកល ៦ យ៉ាងគឺ

ឲ្យសណ្ដូកជើងទាំង ៤ ចេញ ហើយដេកផ្អៀង ១ ឲ្យកកាយស្មោ និងធូលី ដោយក្រចកជើង ១ ឲ្យលៀនអណ្ដាតសំយុងចុះ ១ ឲ្យធ្វើពោះប៉ោងឡើងធំ ១ ឲ្យបន្ទោបង់មូត្រលាមកចេញមក ១ ឲ្យអត់ដកដង្ហើម ១ ។ ម្យ៉ាងទៀត បោសធូលី និងដីខ្សាច់មកគរទុកខាងមុខខ្លះ រុញចេញទៅខ្លះ ធ្វើអាការបម្រះនទៀលទៅមកខ្លះ បំប៉ោងពោះឡើង និងផតពោះចុះខ្លះ កូនម្រឹគនេះនឹងបញ្ឆោតព្រានឲ្យវង្វេង ជឿបានដោយឧបាយកលយ៉ាងនេះ ។ កាលបើនាយព្រានបានឃើញកូនម្រឹគនោះហើយ យល់ថា វាស្លាប់ទៅហើយ ទើបស្រាយអន្ទាក់ចេញ និងដើរទៅកាប់មែកឈើ ស្លឹកឈើមកដើម្បីយកមកក្រាលដាក់ពន្លះសាច់ម្រឹគនេះ ។ កូនម្រឹគនោះឃើញឱកាសល្អហើយ ទើបប្រញាប់ក្រោកឡើង រត់គេចចេញទៅរកមាតា ។

អាស្រ័យហេតុផលក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិនេះ ដែលព្រះរាហុលធ្លាប់បានសន្សំបុណ្យបារមីមកយូរអង្វែងណាស់មកហើយ ក៏បានទទួលការលើកតម្កើងអំពីព្រះវិជិតមារ ដោយព្រះអង្គប្រកាសតែងតាំងព្រះរាហុលក្នុងកណ្ដាលជំនុំព្រះអរិយសង្ឃ ទុកនៅក្នុងតំណែងជាឯតទគ្គៈ ឲ្យប្រសើរជាងភិក្ខុទាំងឡាយ អ្នកស្រឡាញ់ក្នុងការសិក្ខា ។ ដូចមានប្រាកដក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖

***ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សិក្ខាកាមានំ យទិទំ រាហុលោ*** ម្នាលភិក្ខុទាំងឡាយ រាហុលជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ

ផ្នែកខាងជាអ្នកស្រឡាញ់សិក្ខា ។

ទើបរាប់ថា តំណែងជាឯតទគ្គៈនេះ សមរម្យបំផុតសម្រាប់ព្រះរាហុលត្ថេរ ពីព្រោះលោកធ្លាប់បានបំពេញសេចក្ដីល្អ ជាច្រើនណាស់មកហើយ ។ ក្នុងពេលដែលលោកបានសម្រេចជាព្រះអរហន្តហើយ បានពោលគាថា ដែលចាត់ថា មានសារប្រយោជន៍ច្រើន ដែលមានសម្ដែងក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** នៃ **ចតុក្កនិបាត** ដូចមានសេចក្ដីថា ៖

សព្រហ្មចារីបុគ្គលទាំងឡាយ ស្គាល់ច្បាស់នូវអាត្មាអញថារាហុលដ៏ចម្រើន ជាអ្នកប្រកបដោយគុណទាំងពីរ គឺជាតិ និងប្រតិបត្តិ ព្រោះអាត្មាអញជាកូននៃព្រះពុទ្ធផង ជាអ្នកមានបញ្ញាចក្ខុក្នុងធម៌ទាំងឡាយផង អាសវៈរបស់អាត្មាអញអស់ហើយផង ភពថ្មីទៀតអាត្មាអញមិនមានផង អាត្មាអញជាព្រះអរហន្ត គួរដល់ទក្ខិណា មានវិជ្ជា ៣ ឃើញព្រះនិព្វានឈ្មោះអមតៈ ។ សត្វទាំងឡាយ ជាអ្នកងងឹតព្រោះកាម ត្រូវបណ្ដាញរួបរឹតហើយ ត្រូវដំបូល គឺតណ្ហាបិទបាំងហើយ ត្រូវមារចងហើយ ដូចត្រីជាប់នៅក្នុងមាត់លប ដូច្នោះ ។ អាត្មាអញលះបង់កាមនោះហើយ បានកាត់នូវចំណងនៃមារ ដកតណ្ហា ព្រមទាំងឫសគល់នៃតណ្ហាចេញហើយ ជាអ្នកមានសេចក្ដីត្រជាក់កើតហើយ មានទុក្ខរលត់ហើយ ។

សេចក្ដីល្អរបស់ព្រះរាហុលត្ថេរ នៅមានទៀត ដែលមានសម្ដែងនៅក្នុង **អដ្ឋកថាគម្ពីរខុទ្ទកនិកាយជាតក នៃអព្ភន្តរវគ្គ** ដូចមានសេចក្ដីថា ៖

កាលព្រះនាងពិម្ពា ទ្រង់ពិចារណាថា ព្រះសម្ពុទ្ធជាកស្វាមី និងជាបិតារបស់ព្រះរាហុល ឥឡូវនេះ បួសអស់ហើយ ចំណែកយើងនៅក្នុងរាជវាំង តើមានប្រយោជន៍អ្វី យើងគួរតែទៅបួសជាភិក្ខុនី នៅក្នុងក្រុងសាវត្ថី ទើបជាការល្អ ដើម្បីបានឱកាសឃើញទាំងព្រះស្វាមី និងបុត្ររបស់យើងជានិច្ចផង ។ កាលបើព្រះនាងត្រិះរិះដូច្នេះហើយ ទើបស្តេចយាងទៅសូមបព្វជ្ជានៅក្នុងសម្នាក់ភិក្ខុនី ។ ថ្ងៃមួយ ព្រះនាងពិម្ពាថេរីបានកើតរោគអាពាធ ដោយរោគខ្យល់ចាក់សៀតក្នុងព្រះឧទរ ជារោគអាពាធដែលធ្លាប់កើតមានកាលនៅជាគ្រហស្ថ ។ ចំណែកព្រះរាហុល មានបំណងនឹងទៅសួរសុខទុក្ខម្តាយ តើមានសេចក្តីសុខទុក្ខយ៉ាងណា ក្នុងការរស់នៅនោះ ប៉ុន្តែព្រះនាងពិម្ពាថេរី ទ្រង់ជ្រាបថា កូនប្រុសរបស់ខ្លួនមកសួរសុខទុក្ខ ទើបក្រោកឡើង ប៉ុន្តែមិនអាចក្រោកបាន ។ ភិក្ខុនីទាំងឡាយ បានប្រាប់រឿងហ្នឹងឲ្យដល់ព្រះរាហុលបានជ្រាបថា ព្រះនាងពិម្ពាថេរីទ្រង់មានអាពាធ ពុំអាចក្រោកមកបានទេ ។ កាលបើលោកដឹងថា មាតារបស់ខ្លួនអាពាធហើយ ទើបប្រញាប់ចូលទៅរកមាតា ហើយទូលសួរថា តើរោគរបស់មាតាដាក់ថ្នាំអ្វីបាត់ សូមប្រាប់កូនមកចុះ ។ រាហុលកូនប្រុសកាលមាតានៅជាគ្រហស្ថ ធ្លាប់បានសោយទឹកផ្លែស្វាយផ្សំជាមួយនឹងស្ករត្នោត ទើបរោគខ្យល់នេះជាសះស្បើយ តែឥឡូវនេះ មិនដឹងទៅរកឯណាបាន ។ ព្រះនាងពិម្ពាថេរី និយាយប្រាប់ដោយអាការៈអស់កម្លាំង ព្រះ

រាហុលមានការត្រិះរិះថា នឹងទៅរកយកមកប្រគេនមាតា ដើម្បីបំបាត់រោគនេះ ។ មាតាកុំព្រួយអី កូននឹងទៅរកយកមកប្រគេន ទូលដូច្នេះហើយក៏ប្រញាប់លាត្រឡប់ទៅវិញ ។ ព្រះរាហុលទើបរំពឹងថា មានតែចូលទៅរកព្រះសារីបុត្រ ព្រះមហាមោគ្គល្លាន ព្រះអានន្ទ និងព្រះសម្មាសម្ពុទ្ធទេ ។ កាលរំពឹងដូច្នេះហើយ ព្រះរាហុល ក៏បានចូលទៅរកព្រះសារីបុត្រមុនគេ ដល់ពេលជួបព្រះសារីបុត្រហើយ សម្តែងអាការៈដូចមានទុក្ខកង្វល់ ។ ព្រះសារីបុត្រឃើញដូច្នេះហើយ ទើបសួរថា រាហុល តើអ្នកមានបញ្ហាអ្វី ? បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាមានបញ្ហា ពីព្រោះមាតារបស់ខ្ញុំកើតរោគខ្យល់ចាក់សៀតក្នុងព្រះឧទរ ។ រាហុល តើអ្នកត្រូវការអ្វី ចូរប្រាប់យើងមកចុះ ខ្ញុំព្រះករុណាត្រូវការទឹកផ្លៃស្វាយ លាយនឹងស្ករត្នោតដើម្បីនាំទៅប្រគេនមាតា ។ រឿងនេះមិនជាអ្វីទេ រាហុល អ្នករង់ចាំថ្ងៃស្អែកសិនចុះ ព្រះសារីបុត្រនិយាយលួងលោមព្រះរាហុល កុំឲ្យកើតការព្រួយបារម្ភខ្លាំងពេក ។ លុះព្រឹកឡើង ព្រះសារីបុត្រ ទើបនាំព្រះរាហុលចូលទៅកាន់ក្រុងសាវត្ថី ហើយឲ្យព្រះរាហុលគង់ចាំនៅសាលាឆាន់ ចំណែកលោកក៏ចូលទៅក្នុងរាជវាំង ។

ព្រះបាទបសេនទិកោសល ទ្រង់ទតឃើញព្រះសារីបុត្រនិមន្តមកទើបអារាធនាឲ្យគង់នៅលើអាសនៈដ៏សមគួរ ។ ប៉ុន្តែមិនទាន់បានត្រាស់សន្ទនាផង ក្នុងខណៈពេលនោះ នាយឧទ្យានបាននាំផ្លែស្វាយទុំមកថ្វាយ

ចំពោះព្រះរាជា ទ្រង់បានបកសំបកផ្លែស្វាយនោះចេញ ប្របាច់លាយជាមួយនឹងស្ករគ្រាត ហើយទ្រង់ដាក់នៅក្នុងភាជនៈដ៏ស្អាតដោយព្រះអង្គឯង ។ កាលបើធ្វើរួចស្រេចហើយ ទើបនាំយកទៅដាក់ក្នុងបាត្ររបស់ព្រះសារីបុត្រៗ កាលបានទទួលហើយ ក៏នាំយកមកឲ្យរាហុល ហើយប្រាប់ថា រាហុល ចូរអ្នកនាំយកទឹកផ្លែស្វាយ និងស្ករគ្រាតនេះទៅប្រគេនដល់មាតារបស់អ្នកចុះ ។ ចំណែកព្រះរាហុល កាលបើបានទឹកផ្លែស្វាយនិងស្ករគ្រាតហើយ ក៏ប្រញាប់យកទៅប្រគេនដល់មាតាឆាន់ ព្រះនាងពិម្ពាកាលបើបានឆាន់រួចហើយ រោគខ្យល់ចាក់សៀតក្នុងឧទរក៏បាត់ទៅ ។

នៅមានរឿងរបស់ព្រះរាហុល ដែលប្រយុទ្ធជាមួយនឹងមារ មានសម្តែងនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **តណ្ហាវគ្គ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានជោគគង់ប្រថាប់នៅក្នុងវត្តជេតពន នាក្រុងសាវត្ថី ត្រាស់ទេសនាប្រារព្ធដល់ព្រះរាហុល ដែលបានប្រយុទ្ធជាមួយនឹងមារថា ថ្ងៃមួយ ក្នុងពេលវិកាល ព្រះថេរៈជាច្រើនបាននាំគ្នាចូលទៅកាន់វត្តជេតពន បានចូលទៅដល់កុដិរបស់ព្រះរាហុល ហើយប្រាប់ឲ្យព្រះរាហុលក្រោកឡើងទៅរកកន្លែងសិងក្នុងទីដទៃវិញ ។ ព្រះរាហុល បានក្រោកចេញអំពីទីកន្លែងនោះ ទៅរកទីកន្លែងដទៃសិងមិនមាន កាលបើរកទីកន្លែងមិនបានហើយ ទើបទៅសិងនៅមុខព្រះគន្ធកុដិនៃព្រះបរមសាស្តា ។ ពេលនោះ ព្រះរាហុល បានសម្រេចជាព្រះអរហន្តហើយ ។ គ្រានោះឯង

វសវត្តីមារ បានក្រឡេកឃើញព្រះរាហុលសិងនៅមុខព្រះគន្ធកុដិនៃព្រះមហាមុនី ទើបគិតថា ព្រះរាហុលនេះដូចជាថ្លើមប្រមាត់នៃព្រះសមណគោតមដែរ កាលបើយើងបៀតបៀនព្រះរាហុលបាន ក៏ដូចជាបៀតបៀនព្រះអង្គផងដែរ ។ កាលបើមារគិតដូច្នេះហើយ ទើបប្រែកាឡាជាដំរីធំយកប្រមោយរឹតព្រះរាហុល ថែមទាំងបានបញ្ចេញសំឡេងស្រែកគ្រហឹមឈាន់ឮដូចជាសំឡេងសត្វក្រៀល ។ ព្រះលោកនាថ ទ្រង់ជ្រាបរឿងនោះថា ដំរីនេះពុំមែនជាដំរីធម្មតាទេ តែជាវសវត្តីមារ ពេលនោះ ទើបព្រះអង្គត្រាស់ថា នៃមារ សូម្បីអ្នកមានគ្នាមួយសែននាក់ក៏ដោយ ក៏មិនអាចដើម្បីនឹងធ្វើឲ្យព្រះរាហុលដែលជាបុត្រតថាគតមានការភ័យខ្លាចបានដែរ ព្រោះថា ជាអ្នកមិនមានតណ្ហា ថែមទាំងជាអ្នកមានបញ្ញាច្រើនទៀតផង ទើបព្រះអង្គទ្រង់ត្រាស់សម្តែងព្រះគាថាទាំងនោះថា

អ្នកណាបានសម្រេចហើយ មិនមានសេចក្តីភ័យខ្លាច ប្រាសចាកតណ្ហា មិនមានគ្រឿងចង គឺឧបក្កិលេស បានផ្តាច់ចោលនូវសរ គឺតណ្ហាដែលតែងតែនាំសត្វទៅកាន់ភពជារឿយៗ នោះ មិនប្រកាន់មាំ ជាអ្នកឈ្លាសនៅក្នុងបដិសម្ភិទា បុគ្គលនោះតថាគតហៅថា ជាអ្នកមានបញ្ញាច្រើន ថែមទាំងជាមហាបុរសទៀតផង ។ លុះព្រះអង្គត្រាស់ទេសនានេះចប់ ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ចំណែកវសវត្តីមារមានចិត្តបាបគិតថា ព្រះសមណគោតម

ស្គាល់ខ្លួនហើយ ក៏បាត់អំពីទីនោះទៅ ។ ពាក្យថា មហាបុរសនៅក្នុងព្រះពុទ្ធសាសនា សំដៅដល់អ្នកមានចិត្តផុតស្រឡះចាកកិលេស ឬសេចក្តីទុក្ខហើយ ដូចព្រះអង្គទ្រង់ត្រាស់សម្តែងថា ម្នាលសារីបុត្រ តថាគតហៅអ្នកដែលមានចិត្តផុតស្រឡះហើយ ចាកកិលេសទាំងឡាយ ឬសេចក្តីទុក្ខនោះ ថាជាមហាបុរស ។ ម្យ៉ាងទៀត ដែលព្រះរាហុលមិនភ័យខ្លាចនោះ ពីព្រោះលោកបានជាព្រះអរហន្តហើយ ព្រោះថា ព្រះអរហន្តលោកមិនខ្លាចស្លាប់ មិនស្រឡាញ់ជីវិត តែលោកខ្លាចសេចក្តីអាក្រក់ ជាអ្នកស្រឡាញ់ភាពបរិសុទ្ធិនៃជីវិត ។

ព្រះរាហុល បានពោលសរសើរសេចក្តីល្អរបស់ខ្លួន មានប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្តីថា ៖

ខ្ញុំបានក្រាលកញ្ចក់ក្នុងប្រាសាទ ៧ ជាន់ ថ្វាយដល់ព្រះបទុមុត្តរៈជាចម្បងក្នុងលោក ទ្រង់ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីជាធំជាងសត្វជើងពីរ ព្រះអង្គប្រសើរជាងនរជន មានពួកព្រះខីណាស្រពមួយពាន់អង្គចោមរោម ស្តេចចូលទៅកាន់ព្រះគន្ធកុដិ ។ ព្រះសាស្តាជាទេវតាប្រសើរជាងទេវតា ព្រះអង្គប្រសើរជាងនរជន ទ្រង់ញុំាងព្រះគន្ធកុដិឲ្យរុងរឿង ស្ថិតនៅក្នុងកណ្តាលភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនោះថា

ទីសេយ្យាសន៍នេះ ដែលបុគ្គលណា ធ្វើឲ្យរុងរឿងហើយ ដូចកញ្ចក់ដែលគេក្រាលដោយល្អល្អះ តថាគតនឹងសម្តែងសរសើរបុគ្គល

នោះ អ្នកទាំងឡាយ ចូរស្ដាប់តថាគតសម្ដែងចុះ ។ ប្រាសាទណាមួយ ជាទីស្រឡាញ់ពេញចិត្ត ប្រាសាទទាំងនោះ សុទ្ធតែជាវិការៈនៃមាស ទាំងជាវិការៈនៃកែវពៃទូរ្យ នឹងកើតឡើងសម្រាប់បុគ្គលនេះ ។ បុគ្គលនោះនឹងសោយរាជ្យ ជាធំជាងទេវតាអស់ ៦៤ ដង ក្នុងជាតិជាលំដាប់មក នឹងបានជាស្ដេចចក្រពត្តិអស់មួយពាន់ដង ក្នុងកប្បទី ២១ នឹងបានជាស្ដេចចក្រពត្តិព្រះនាម **វិមលៈ** ។ ជាឥស្សរៈលើផែនដី មានសមុទ្ទទាំង ៤ ព័ទ្ធជុំវិញ ជាស្ដេចឈ្នះសង្គ្រាម ។ ទីក្រុងរបស់ព្រះបាទវិមលៈនោះ ឈ្មោះរេណុវតី ដែលគេស្ថាបនាដោយឥដ្ឋ មានបណ្ដោយបីរយយោជន៍ ប្រកបដោយជ្រុង ៤ ។ ប្រាសាទឈ្មោះ **សុទស្សនៈ** ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ ស្អិតស្អាងដោយកែវ ៧ ប្រការ ដែលវិស្វករបានសាងថ្វាយ ។ ទីក្រុងនោះ ស្ងប់ស្ងាត់ចាកសំឡេងទាំង ១០ ដ៏ដេរដាសដោយពួកវិជ្ជាធរ ដូចជាទីក្រុងឈ្មោះសុទស្សនៈរបស់ទេវតាទាំងឡាយដែរ ។ កាលព្រះអាទិត្យរះឡើង ពន្លឺរបស់ក្រុងនោះ នឹងរុងរឿងជានិច្ចដោយជុំវិញ អស់ចម្ងាយ ៨ យោជន៍ ។ ក្នុងកប្បទីមួយសែន ព្រះសាស្ដាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ កុលបុត្រនោះ នឹងចុតិចាកស្ថានតុសិតនោះមកវិញ ត្រូវកុសលមូលដាស់តឿនបានមកកើតជាព្រះរាជឱរសរបស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ កុលបុត្រនោះ ប្រសិនបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្ដេចចក្រពត្តិ តែ

មិនមានហេតុដែលឲ្យកុលបុត្រជាតាទិបុគ្គលនោះ បានដល់នូវសេចក្តីត្រេកអរក្នុងផ្ទះឡើយ កុលបុត្រនោះ នឹងចេញចាកផ្ទះទៅបួស ជាអ្នកមានវត្តល្អ នឹងបានជាព្រះអរហន្ត ឈ្មោះរាហុល ។

ព្រះមហាមុនី ព្រះអង្គមានប្រាជ្ញាចាស់ បរិបូណ៌ដោយសីល ទ្រង់រក្សាខ្ញុំ ថែទាំខ្ញុំ ដូចជាមេបក្សីត្រដេវវិចរក្សាស៊ុត ពុំនោះសោត ដូចជាមេចាមរីរក្សារោម ។ ខ្ញុំបានដឹងធម៌របស់ព្រះគោតមសម្ពុទ្ធនោះ ត្រេកអរក្នុងសាសនា ហើយកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ការបរិនិព្វានរបស់ព្រះរាហុលត្ថេរ មានសម្តែងនៅក្នុង **អដ្ឋកថាគម្ពីរសុមង្គលវិលាសិនី** បានពោលទុកថា ៖

ព្រះរាហុលទៅបរិនិព្វានក្នុងស្ថានតាវត្តិង្ស រឿងនេះអាចដឹងបាននោះ ពីព្រោះ ព្រះសារីបុត្រមុននឹងបរិនិព្វាន លោកបានពិចារណាដល់ស្ថានទីដែលគួរទៅបរិនិព្វានថា យើងគួរទៅបរិនិព្វានក្នុងទីណាហ្ន៎ ទាំងបានពិចារណាដល់ព្រះអញ្ញាកោណ្ឌញ្ញៈថា លោកបរិនិព្វាននៅស្រះឆទ្ទន្តចំណែកព្រះរាហុលត្ថេរ លោកទៅបរិនិព្វានក្នុងស្ថានតាវត្តិង្សជាដើម ។ ហេតុផលនេះ ក៏ល្មមឲ្យដឹងបានថា ការបរិនិព្វានរបស់ព្រះរាហុលនៅស្ថានតាវត្តិង្ស រឿងទាំងអស់នេះ មើលទៅមិនមែនជារបស់គួរឲ្យអស្ចារ្យ

ទេ សម្រាប់លោកអ្នកជាព្រះអរហន្ត បានសម្រេចអភិញ្ញា លោកធ្វើអ្វីសមហេតុផល ។

**ទស្សនគតិទាក់ទងនឹងព្រះរាហុលត្ថេរនេះ មានឧទាហរណ៍ជាច្រើនពីព្រោះលោកជាអ្នកប្រកបដោយបទដ្ឋានដូច្នេះ គឺ ៖**

១- ជាអ្នកមានការសិក្សាដោយល្អ ២- ជាអ្នកមានភាពអង់អាច ៣- ជាអ្នកប្រព្រឹត្តដោយល្អ ។ បុគ្គលអ្នកមានលក្ខណៈទាំង ៣ នេះ បានទទួលនាមថា **បណ្ឌិត** គឺអ្នកមានចំណេះដឹងជាគ្រឿងថែរក្សាខ្លួន ឲ្យរួចផុតចាកទុក្ខបាន ។ល៚

( ជីវប្រវត្តិរបស់ព្រះរាហុលត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះអានន្ទត្ថេរ ✍

**" ដែលជាឯតទគ្គៈផ្នែកខាងពហុស្សុត ១ មានសតិ ១**

**មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១ "**

*ព្រះអានន្ទត្ថេរ លោកជាឃ្លាំងព្រះធម៌ផង ថែមទាំងជាអ្នកបានទទួលតំណែងជាឯតទគ្គៈ ៥ ទៀតផង និងជាមហាសាវកមួយរូបដ៏ឆ្នើមក្នុងចំណោមព្រះអសីតិមហាសាវក ៨០ រូប ទាំងការបរិនិព្វានរបស់លោកនោះ ក៏ប្លែកអំពីសាវកអង្គដទៃទៀតដែរ ទាំងនេះបញ្ជាក់ឲ្យឃើញបានថាជីវប្រវត្តិរបស់លោក គួរឲ្យយើងជ្រះថ្លាយ៉ាងក្រៃលែងណាស់ ។*

*ជីវប្រវត្តិអតីតជាតិរបស់ព្រះអានន្ទត្ថេរ មានសម្តែងនៅក្នុង **អដ្ឋកថាមនោរថបូរណី** និង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីក្នុង**ព្រះបាលីអានន្ទថេរគាថា និងគម្ពីរខុទ្ទកនិកាយ ថេរគាថា** សម្តែងឲ្យឃើញថា ការសន្សំបុណ្យបារមីគ្រប់យ៉ាង ក៏ដើម្បីឲ្យបានភាពប្រសើរជាងសាវកទាំងឡាយ រហូតទៅដល់ ៥ ប្រការ ដូចមានសេចក្តីថា ៖*

*ក្នុងអតីតជាតិ បានឮថា ក្នុងកប្បទីមួយសែន រាប់ត្រឡប់ថយក្រោយ ពីភទ្ទកប្បនេះទៅ មានព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ ឧប្បត្តិឡើងក្នុងលោក ពុទ្ធបិតាព្រះនាមថា **សុនន្ទរាជ** ពុទ្ធមាតាព្រះនាមថា **សុជាតា***

ទ្រង់គ្រប់គ្រងរាជសម្បត្តិនៅក្នុងនគរហង្សវតី ។ ព្រះពោធិសត្វព្រះនាមថា **ឧត្តរកុមារ** កាលនៅជាយាវ៉ាស ឧត្តរកុមារមានអគ្គមហេសី និងព្រះរាជឱរសមុនពេលដែលស្ដេចយាងចេញទៅសាងព្រះផ្នួសម៉្វះ ក្នុងថ្ងៃដែលព្រះអង្គចេញសាងព្រះផ្នួស ជាថ្ងៃដែលព្រះឱរសប្រសូត ហើយទ្រង់មានសេចក្ដីព្យាយាមរហូតបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ទើបទ្រង់បន្លឺព្រះពុទ្ធឧទានថា **អនេកជាតិសង្សារំ** ជាដើម ទ្រង់គង់ប្រថាប់នៅពោធិបល្ល័ង្កអស់ ៧ ថ្ងៃ ហើយទ្រង់ឈានព្រះបាទចុះចាកពោធិបល្ល័ង្កនោះ មានផ្កាឈូកធំផុសឡើងមកទ្រព្រះបាទរបស់ព្រះអង្គ ទើបមានព្រះនាមថា ព្រះ-បទុមុត្តរៈ ។ ព្រះអង្គមានអគ្គសាវ័កព្រះនាមថា **ព្រះទេវិលត្ថេរ** និង **ព្រះចុឡ្យជាតត្ថេរ** ព្រះអង្គមានអគ្គសាវិកាព្រះនាមថា **អមិត្តាថេរី** និងព្រះនាមថា **អសមាថេរី** មានពុទ្ធុប្បដ្ឋាកព្រះនាមថា **សុមនត្ថេរ** ទ្រង់មានភិក្ខុសង្ឃមួយសែនរូបជាបរិវារ ទ្រង់គង់ប្រថាប់នៅក្នុងក្រុងហង្សវតី ចំណែកព្រះកនិដ្ឋភាតារបស់ព្រះអង្គព្រះនាមថា **សុមនរាជកុមារ** ព្រះរាជបិតានន្ទរាជ បានព្រះរាជទានស្រុកសួយ ១២០ យោជន៍ ( កន្លែងខ្លះថាពីរពាន់យោជន៍ ) ដោយរាប់តាំងអំពីក្រុងហង្សវតីទៅ ឲ្យដល់សុមនរាជកុមារនោះ ឲ្យជាអ្នកគ្រប់គ្រងស្រុកទាំងអស់នោះ ចំណែកសុមនរាជកុមារនោះស្ដេចយាងមកគាល់ព្រះរាជបិតា និងព្រះសាស្ដាម្ដងម្កាល ។

ថ្ងៃមួយ ជនបទកើតចលាចល សុមនកុមារ ទើបបញ្ជូនដំណឹង

ទៅថ្វាយព្រះរាជា។ ទ្រង់តបទៅវិញថា បិតាបានតែងតាំងអ្នកឲ្យជាអ្នកមើលការខុសត្រូវចំពោះជនបទទាំងនោះ ដូច្នេះ ចូរអ្នកចាត់ចែងនូវកិច្ចការទាំងនោះចុះ សុមនរាជកុមារនោះ ក៏បានធ្វើជនបទទាំងនោះឲ្យស្ងប់រំងាប់ទៅវិញ ហើយបញ្ជូនដំណឹងទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះទេវៈ ជនបទបានស្ងប់រំងាប់ហើយ ព្រះរាជាទ្រង់ត្រេកអរត្រាស់ថា បុត្រចូរប្រញាប់មក សុមនរាជកុមារ ព្រមទាំងអាមាត្យមួយពាន់នាក់ ទ្រង់បានប្រឹក្សាជាមួយនឹងអាមាត្យទាំងនោះក្នុងរវាងផ្លូវថា ព្រះរាជបិតារបស់ខ្ញុំទ្រង់ត្រេកអរណាស់ ប្រសិនបើព្រះរាជទានពរដល់ខ្ញុំ តើខ្ញុំគប្បីទទួលយកពរអ្វី ពួកអាមាត្យខ្លះ ក្រាបទូលដល់ព្រះរាជកុមារថា សូមទ្រង់ទទួលយកដំរី សេះ ជនបទ រតនៈ ៧ ប្រការ ។ អាមាត្យមួយ ពួកទៀតទូលថា ព្រះអង្គជាព្រះរាជឱរសរបស់ស្តេចផែនដី ចំពោះទ្រព្យសម្បត្តិព្រះអង្គរមែងមិនលំបាកទេ តែទ្រព្យទាំងអស់នោះ បើព្រះអង្គបានហើយ ត្រូវលះបោលទៅវិញទាំងអស់ មានតែបុណ្យទេទើបព្រះអង្គអាចនាំយកទៅបាន ព្រោះដូច្នោះ ប្រសិនបើព្រះសម្មតិទេពព្រះរាជទានពរ សូមព្រះអង្គទទួលពរគឺធ្វើការឧបដ្ឋាកព្រះបទុមុត្តរៈរហូតអស់មួយត្រៃមាសចុះ ទើបប្រសើរ ។

ព្រះរាជកុមារត្រាស់ថា ពួកលោកជាកល្យាណមិត្តរបស់ខ្ញុំ ពួកលោកមានគំនិតយ៉ាងនេះ ខ្ញុំនឹងធ្វើតាម ហើយស្តេចចូលទៅថ្វាយបង្គំព្រះរាជបិតា។ ត្រាស់ថា បុត្រ បិតានឹងប្រទានពរឲ្យដល់បុត្រ ដូច្នេះ

ហើយ ទើបក្រាបទូលថា បពិត្រព្រះរាជបិតា ទូលព្រះបង្គំមិនចង់បានអ្វីទេ ប៉ុន្តែចង់បានជាអ្នកទំនុកបម្រុងព្រះបទុមុត្តរៈ ដោយបច្ច័យទាំងឡាយ ៤ រហូតអស់មួយត្រៃមាស ដើម្បីញ៉ាំងជីវិតឲ្យបានទទួលនូវប្រយោជន៍ ។ ព្រះរាជបិតាត្រាស់ថា បិតាមិនអាចប្រទានពរនេះឲ្យដល់បុត្របានទេ សុមនរាជកុមារក្រាបទូលថា បពិត្របិតា ធម្មតាក្សត្រមិនត្រាស់ព្រះបន្ទូលជាលើកទីពីរឡើយ ។ សូមព្រះរាជបិតា ព្រះរាជទានពរនេះឲ្យដល់ទូលព្រះបង្គំផងចុះ ពរដទៃទូលព្រះបង្គំមិនត្រូវការទេ ។ ព្រះរាជាត្រាស់ថា ធម្មតាថា ព្រះទ័យនៃព្រះសម្មាសម្ពុទ្ធដឹងបានដោយលំបាក ប្រសិនបើព្រះភគវាទ្រង់មិនប្រាថ្នា កាលបើបិតាប្រទានពរនេះ ដល់បុត្រហើយ នឹងមានរឿងអ្វីៗ តើគិតយ៉ាងម៉េច ព្រះរាជកុមារក្រាបទូលថា ល្អហើយ ព្រះបិតា ទូលព្រះបង្គំនឹងជ្រាបព្រះទ័យនៃព្រះលោកនាថ ពោលដូច្នេះហើយ ទើបស្តេចយាងចូលទៅកាន់វិហារ ។

សម័យនោះ ព្រះបទុមុត្តរៈទទួលភត្តរួចជាស្រេចហើយ ស្តេចយាងចូលទៅក្នុងព្រះគន្ធកុដិ ព្រះរាជកុមារបានចូលទៅរកភិក្ខុទាំងឡាយដែលប្រជុំគ្នានៅក្នុងសាលាធម្មសភា ភិក្ខុទាំងនោះទូលសួរព្រះរាជកុមារថា តើព្រះរាជបុត្រស្តេចយាងមកមានការអ្វី ព្រះរាជកុមារត្រាស់ថា មកដើម្បីចូលគាល់ព្រះមហាមុនី សូមលោកម្ចាស់ទូលដល់ព្រះសុគតសាស្តាឲ្យខ្ញុំព្រះករុណាផង ភិក្ខុទាំងនោះទូលថា ព្រះរាជកុមារ ពេលនេះមិន

អាចនឹងទៅជួបព្រះសយម្ភូបានទេ ទើបត្រាស់សួរទៀតថា តើមានអ្នកណាអាចចូលទៅគាល់ព្រះអង្គបានដែរឬ ភិក្ខុទាំងនោះទូលតបថា មាន ព្រះរាជបុត្រ គឺសុមនត្ថេរ ព្រះរាជកុមារសួរថា តើព្រះថេរៈនោះគង់នៅក្នុងទីណា ខ្ញុំព្រះករុណាប្រាថ្នានឹងចូលទៅគាល់ព្រះមានព្រះភាគ សូមឲ្យលោកម្ចាស់អង្គនោះទូលព្រះភគវាឲ្យខ្ញុំព្រះករុណាផង គ្រានោះ ព្រះថេរៈក៏ចូលអាបោកសិណ ហើយអធិដ្ឋានផែនដីឲ្យដូចជាទឹក មុជចុះទៅក្នុងផែនដីទៅប្រាកដត្រង់ព្រះគន្ធកុដិរបស់ព្រះសាស្តា ។

គ្រានោះ ព្រះសម្ពុទ្ធត្រាស់ជាមួយនឹងសុមនត្ថេរថា សុមនៈ អ្នកមកមានការអ្វី ព្រះថេរៈទូលថា ព្រះរាជបុត្រស្តេចយាងមក មានបំណងនឹងចូលគាល់ព្រះអង្គ ។ ប្រសិនបើយ៉ាងនោះ ចូរអ្នកទៅរៀបចំអាសនៈចុះ ។ កាលព្រះរាជកុមារកំពុងទតឃើញនោះឯង ព្រះថេរៈកាន់យកពុទ្ធាសនៈ មុជចុះក្នុងព្រះគន្ធកុដិ ទៅប្រាកដខាងក្រៅបរិវេណព្រះគន្ធកុដិវិញ រៀបចំក្រាលអាសនៈ ព្រះរាជកុមារទ្រង់ទតឃើញហេតុដ៏អស្ចារ្យទាំងពីរនោះហើយ ទ្រង់ត្រិះរិះថា ភិក្ខុរូបនេះជាធំហ្ន៎ សូម្បីព្រះលោកនាថក៏ស្តេចចេញអំពីព្រះគន្ធកុដិមកដែរ ហើយទ្រង់គង់ប្រថាប់លើអាសនៈដែលរៀបចំទុក ព្រះមានព្រះភាគត្រាស់សួរថា តើព្រះរាជបុត្រយាងមកដល់ពេលណា ? ព្រះរាជកុមារទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងពេលព្រះអង្គស្តេចយាងចូលទៅព្រះគន្ធកុដិ តែភិក្ខុទាំងឡាយប្រាប់ថា ពេល

នេះមិនអាចចូលទៅគាល់ព្រះអង្គបានទេ ហើយប្រាប់ខ្ញុំព្រះអង្គឲ្យទៅរក ព្រះថេរៈរូបនោះ ដែលជាទីស្និទ្ធស្នាលរបស់ព្រះអង្គ ព្រះបទុមុត្តរៈទ្រង់ត្រាស់ថា ពិតមែនហើយ ភិក្ខុរូបនោះជាទីស្និទ្ធស្នាលរបស់តថាគត ព្រះរាជកុមារទូលថា ភិក្ខុរូបនេះ ធ្វើអ្វីទើបជាទីស្និទ្ធស្នាលរបស់ព្រះអង្គ ? ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ជាអ្នកបានថ្វាយទាន រក្សាឧបោសថ និងបំពេញសេចក្តីល្អដទៃទៀត ទើបបានសម្រេចនូវសេចក្តីប្រាថ្នានេះបាន ។ ព្រះរាជកុមារទូលថា បពិត្រព្រះភគវា ខ្ញុំព្រះអង្គប្រាថ្នាឲ្យបានភាពស្និទ្ធស្នាលដូចព្រះថេរៈរូបនេះដែរ ថ្ងៃស្អែកនេះ សូមព្រះអង្គអារាធនាទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ព្រះសម្ពុទ្ធទទួលដោយតុណ្ហីភាព ។

ព្រះរាជកុមារ ស្តេចយាងត្រឡប់ទៅកាន់ទីគង់ប្រថាប់ របស់ព្រះអង្គវិញ រៀបចំគ្រឿងសក្ការៈរហូតអស់មួយយប់ទល់ភ្លឺ បានថ្វាយខន្ធ-វារភត្ត ( ភិក្ខាដែលថ្វាយព្រះសាស្តាក្នុងចន្លោះពេលដែលជំរំស្នាក់នៅ ) ។ ថ្ងៃទី ៧ ថ្វាយបង្គំព្រះសាស្តាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលពរ ដើម្បីបានជាឧបដ្ឋាកទំនុកបម្រុងព្រះអង្គ រហូតអស់ត្រៃមាសក្នុងវស្សានរដូវនេះ ពីព្រះរាជបិតា សូមព្រះអង្គទ្រង់គង់ចាំព្រះវស្សាក្នុងទីនេះចុះ ដើម្បីប្រយោជន៍ដល់ខ្ញុំព្រះអង្គផង ព្រះបរមសាស្តា ទ្រង់ពិចារណាមើលថា អត្ថប្រយោជន៍ដោយសេចក្តីល្អនេះ មានឬទេហ្ន៎ ក៏ទ្រង់ឃើញថាមាន ទើបត្រាស់ថា នែព្រះរាជកុមារ ព្រះតថាគតទាំងឡាយ រមែង

ត្រេកអរក្នុងទីស្ងាត់ ព្រះរាជកុមារត្រាស់ថា បពិត្រព្រះសុគត ខ្ញុំព្រះអង្គ ដឹងហើយៗ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឲ្យគេកសាង វិហារថ្វាយដល់ព្រះអង្គ ព្រមដោយភិក្ខុសង្ឃមួយសែនរូប ពេលនោះ ព្រះមានព្រះភាគទទួលការនិមន្ត ហើយស្តេចយាងទៅកាន់សម្នាក់ព្រះ រាជបិតាក្រាបទូលថា បពិត្រព្រះរាជបិតា ព្រះភគវាព្រមទទួលការនិមន្ត របស់ទូលព្រះបង្គំហើយ ទើបថ្វាយបង្គំលាព្រះរាជបិតា ត្រឡប់ទៅវិញ ព្រះអង្គឲ្យគេចាត់ចែងកសាងវិហារក្នុងរយៈផ្លូវ មួយយោជន៍មួយកន្លែងៗ ស្តេចយាងទៅអស់ចម្ងាយផ្លូវពីរពាន់យោជន៍ ។

កាលស្តេចយាងទៅដល់ហើយ ទ្រង់ជ្រើសរើសទីកន្លែងកសាង វិហារក្នុងនគររបស់ព្រះអង្គ ទ្រង់ឃើញឧទ្យានរបស់កុដុម្ពិកឈ្មោះសោភៈ ទ្រង់ទិញដីនោះដោយតម្លៃមួយសែនកហាបណៈ កសាងវិហារអស់តម្លៃ មួយសែនកហាបណៈ ថែមទាំងឲ្យកសាងព្រះគន្ធកុដិសម្រាប់ព្រះភគវា ទៀតផង និងកសាងសេនាសនៈ មណ្ឌប សម្រាប់សម្រាកពេលថ្ងៃ និង ពេលយប់សម្រាប់ភិក្ខុទាំងឡាយ ក្រៅអំពីនោះ ឲ្យគេចាត់ចែងធ្វើកំផែង ព័ទ្ធជុំវិញ និងខ្លោងទ្វាររួចជាស្រេចហើយ ទើបបញ្ជូនរាជបុរសទៅកាន់ សម្នាក់ព្រះរាជបិតា ក្រាបទូលថា ការកសាងវិហាររួចជាស្រេចហើយ សូមព្រះបិតាអារាធនានិមន្តព្រះសាស្តាផង ។ កាលបើព្រះរាជបិតា បាន ថ្វាយចង្ហាន់បិណ្ឌបាតចំពោះព្រះសម្ពុទ្ធ ឲ្យទ្រង់សោយរួចជាស្រេចហើយ

ទូលថា បពិត្រព្រះសុគត កិច្ចរបស់សុមនរាជកុមារធ្វើរួចស្រេចអស់ហើយ គេរង់ចាំការនិមន្តន៍ទៅរបស់ព្រះអង្គ ព្រះមានព្រះភាគ មានភិក្ខុសង្ឃមួយសែនរូបហែហមជាបរិវារ កាលស្តេចយាងទៅ ក៏ប្រថាប់ក្នុងវិហារទាំងឡាយ អស់រយៈផ្លូវមួយយោជន៍ ព្រះរាជកុមារទ្រង់ជ្រាបថា ព្រះសាស្តាកំពុងយាងមក ក៏ចេញទៅទទួលអស់រយៈផ្លូវមួយយោជន៍ បានបូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើមរួចហើយ ក៏ចូលទៅកាន់ព្រះវិហារ ដើម្បីវេរថ្វាយព្រះសម្មាសម្ពុទ្ធ ។

ក្នុងថ្ងៃចូលព្រះវស្សា ព្រះរាជកុមារថ្វាយទានរួចហើយ ក៏ហៅបុត្រភរិយារបស់ខ្លួន និងពួកអាមាត្យមកហើយ ប្រាប់ថា ព្រះសាស្តាយាងមកកាន់សម្នាក់របស់ពួកយើងដោយផ្លូវឆ្ងាយ ព្រះពុទ្ធជាម្ចាស់របស់យើង ទ្រង់ធ្ងន់ក្នុងធម៌ មិនឃើញតែអាមិស ព្រោះដូច្នោះ យើងនឹងស្លៀកសំពត់តែពីរផ្ទាំងរហូតអស់ត្រៃមាសនេះ សមាទានសីល ១០ ជានិច្ចក្នុងទីនេះឯង ពួកលោកចូរថ្វាយទានដល់ព្រះមានព្រះភាគ និងព្រះខីណាស្រពមួយសែនរូប ។ សុមនរាជកុមារ ប្រថាប់នៅជិតនឹងទីនៅរបស់ព្រះសុមនៈ ឃើញកិច្ចកម្មគ្រប់យ៉ាង ដែលព្រះថេរៈធ្វើវត្តដល់ព្រះមានព្រះភាគ ហើយត្រិះរិះថា ព្រះថេរៈរូបនេះស្និទ្ធស្នាលនឹងព្រះភគវាណាស់ យើងគួរឲ្យបាននូវតំណែងដូចព្រះថេរៈនេះ ។ កាលជិតចេញវស្សា ស្តេចចូលទៅកាន់តំណាក់ថ្វាយមហាទាន ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់ដាក់ចីវរទៀបបាទារបស់

ភិក្ខុមួយសែនរូប ហើយថ្វាយបង្គំព្រះលោកនាថ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុណ្យដែលខ្ញុំព្រះអង្គបានធ្វើ តាំងពីការថ្វាយទានត្រង់ទីសម្រាកតាមផ្លូវមក ៧ ថ្ងៃនោះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាសម្បត្តិសួគ៌ សម្បត្តិព្រហ្មទេ ខ្ញុំព្រះអង្គប្រាថ្នាឲ្យបានជាឧបដ្ឋាករបស់ព្រះពុទ្ធជាម្ចាស់ ដូចជាព្រះសុមនត្ថេរនេះប៉ុណ្ណោះ ។ ព្រះមហាមុនី ទ្រង់មិនឃើញអន្តរាយក្នុងការប្រាថ្នានេះ ទើបទ្រង់ព្យាករថា ព្រះរាជកុមារនឹងបានសម្រេចតាមសេចក្ដីប្រាថ្នា ហើយស្ដេចត្រឡប់ទៅ ។ ព្រះរាជកុមារបានស្ដាប់ហើយត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនត្រាស់ពាក្យជាលើកទីពីរ ។ ក្នុងថ្ងៃទី ២ ក៏បានកាន់បាត្រ និងចីវរតាមស្ដេចទៅ ហាក់បីដូចបាត្រ និងចីវររបស់ព្រះគោតមជាម្ចាស់ ។ លុះស្លាប់ពីមនុស្សលោកនេះទៅ ក៏កើតក្នុងស្ថានសួគ៌រាប់សែនឆ្នាំ ។

ក្នុងសាសនាព្រះពុទ្ធកស្សបៈ បានថ្វាយសំពត់ដណ្ដប់ដើម្បីទ្រាប់បាត្រដល់ព្រះថេរៈដែលនិមន្តទៅបិណ្ឌបាត បន្ទាប់ពីស្លាប់ទៅ ក៏កើតក្នុងស្ថានសួគ៌ទៀត ចុតិចាកទេវលោកហើយ កើតជាស្ដេចនៅក្នុងក្រុងពារាណសី កាលស្ដេចយាងឡើងលើប្រាសាទជាន់ខាងលើ ក៏បានទតឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ ដែលនិមន្តមកពីភ្នំគន្ធមាទន៍ ហើយក៏បានឲ្យគេនិមន្តព្រះបច្ចេកពុទ្ធទាំងនោះមកដើម្បីថ្វាយចង្ហាន់ ទ្រង់ឲ្យគេកសាងបណ្ណសាលា ៨ ខ្នង សម្រាប់ព្រះបច្ចេកពុទ្ធ ក្នុងឧទ្យានរបស់ព្រះអង្គ

ទ្រង់តាក់តែងធ្វើដោយរតនៈសុទ្ធ ត្រៃ និងស្បែកជើងធ្វើដោយកែវមណី ធ្វើការទំនុកបម្រុងអស់ម៉ឺនឆ្នាំ ។ លោកថ្វាយទានអស់សែនកប្ប កើតក្នុងស្ថានតុសិតជាមួយនឹងព្រះពោធិសត្វ ចុតិចាកស្ថានតុសិតនោះហើយ កើតក្នុងប្រាសាទរបស់អមិតោទនរាជ លោកកើតហើយ ធ្វើឲ្យព្រះញាតិទាំងអស់ត្រេកអររីករាយ ដូច្នេះ ទើបពួកញាតិថ្វាយព្រះនាមថា អានន្ទ ។ កាលព្រះទសពលជាម្ចាស់ ស្ដេចត្រាស់ដឹងហើយ ទ្រង់និមន្តមកក្រុងកបិលពស្តុជាគ្រាដំបូង កាលពួកព្រះរាជកុមារបព្វជ្ជាដើម្បីជាបរិវាររបស់ព្រះមានព្រះភាគ អានន្ទរាជកុមារ ក៏ចេញបួសក្នុងសម្នាក់ព្រះសាស្ដា ព្រមជាមួយពួកសក្យៈ មានព្រះភទ្ទិយៈ អនុរុទ្ធ ភគ្គុ កិម្ពិលៈ ទេវទត្ត និងនាយឧបាលិ ។ មិនយូរប៉ុន្មាន លោកបានស្ដាប់ធម្មកថារបស់ព្រះ-បុណ្ណមន្តានីបុត្រ ក៏បានសម្រេចសោតាបត្តិផល ។

ព្រះសុគតសាស្ដាជាម្ចាស់ ទ្រង់មានភិក្ខុឧបដ្ឋាកមិនច្បាស់លាស់ អស់ ២០ ឆ្នាំ ក្នុងបឋមពោធិកាល គ្រាខ្លះព្រះនាគសមាលៈ គ្រាខ្លះក៏ព្រះនាគិតៈ គ្រាខ្លះក៏ព្រះឧបវាណៈ គ្រាខ្លះក៏ព្រះសុនក្ខត្តៈ គ្រាខ្លះក៏ព្រះចុន្ទៈ គ្រាខ្លះក៏ព្រះសាគតៈ គ្រាខ្លះក៏ព្រះរាធៈ គ្រាខ្លះក៏ព្រះមេឃិយៈ ។ ថ្ងៃមួយ ព្រះមានព្រះភាគ ស្ដេចពុទ្ធដំណើរទៅផ្លូវឆ្ងាយជាមួយនឹងព្រះនាគសមាលត្ថេរ ដល់ផ្លូវបែកជាពីរក៏ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅផ្លូវនេះ ព្រះមានព្រះភាគត្រាស់ថា មកភិក្ខុ តថាគតនឹង

ទៅតាមផ្លូវនេះជាមួយអ្នក ព្រះថេរៈក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ទៅតាមផ្លូវព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងទៅតាមផ្លូវនេះ ហើយក៏ដាក់បាត្រ ចីវរទុកលើផែនដី ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកចូរហុចបាត្រ និងចីវរមកតថាគត កាលព្រះសុគតបានទទួលបាត្រ និងចីវរហើយ ក៏ស្តេចយាងទៅ ។ ពេលដែលព្រះថេរៈនិមន្តបែកពីព្រះសម្ពុទ្ធ ទៅតាមផ្លូវតែម្នាក់ឯងនោះ ក៏បានជួបនឹងពួកចោរៗ ក៏ជណ្តើមយកបាត្រចីវររបស់លោក ថែមទាំងវាយព្រះថេរៈរហូតដល់បែកព្រះសីសៈ គ្រានោះ លោកគិតថា ឥឡូវនេះ មានតែព្រះមានព្រះភាគជាម្ចាស់ទេ ជាទីពឹងរបស់អាត្មាអញ ហើយក៏មកកាន់សម្នាក់ព្រះមានព្រះភាគ ទាំងដែលមានឈាមហូរ ។ កាលព្រះមានព្រះភាគត្រាស់សួរថា មានរឿងអ្វីភិក្ខុ ? លោកក៏ឆ្លើយថា ពួកចោរបៀតបៀនខ្ញុំព្រះអង្គ ទ្រង់លួងលោមថា អ្នកកុំគិតអ្វីឡើយ តថាគតបបួលអ្នកមកជាមួយ ក៏ព្រោះតែហេតុទាំងនោះឯង ។

គ្រាមួយ ព្រះសាស្តា ស្តេចយាងទៅកាន់ស្រុកជន្តុគ្រាម ជិតបាចីនវង្សមិគទាយវ័នជាមួយព្រះមេឃិយត្ថេរ ក្នុងទីនោះព្រះមេឃិយត្ថេរត្រាច់ទៅបិណ្ឌបាតក្នុងជន្តុគ្រាម ជួបនឹងចម្ការស្វាយគួរជាទីរីករាយ នៅក្បែរច្រាំងនៃស្ទឹង ក៏ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់យកបាត្រ និងចីវររបស់ព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងធ្វើសមណធម៌ក្នុងព្រៃស្វាយនោះ សូម្បីព្រះទសពលទ្រង់ហាមបីដង ក៏នៅតែទៅ កាលអកុសលវិតក្កចូល

គ្របសង្កត់ ក៏ត្រឡប់មកទូលរឿងរ៉ាវថ្វាយព្រះមានព្រះភាគ ព្រះអង្គត្រាស់ថា តថាគតហាមឃាត់ព្រោះតែរឿងអ៊ីចឹងឯង ហើយស្តេចចារិកទៅកាន់ក្រុងសាវត្ថីតាមលំដាប់ ។ កាលព្រះមានព្រះភាគ ប្រថាប់នៅក្រុងសាវត្ថីនោះ ទ្រង់គង់លើពុទ្ធាសនៈ ដែលគេចាត់ចែងទុកត្រង់បរិវេណព្រះគន្ធកុដិ ហើយត្រាស់ហៅភិក្ខុទាំងឡាយមកប្រាប់ថា ម្នាលភិក្ខុទាំងឡាយឥឡូវនេះ តថាគតចាស់ហើយ ភិក្ខុខ្លះពោលថា ខ្ញុំព្រះអង្គនឹងទៅផ្លូវនេះហើយក៏គេចចេញទៅ ភិក្ខុខ្លះក៏ដាក់បាត្រ ចីវររបស់តថាគតលើផ្ទៃដី ពួកអ្នកចូរជ្រើសរើសភិក្ខុ ជាឧបដ្ឋាកពិតប្រាកដដល់តថាគតផង ភិក្ខុទាំងឡាយមានសេចក្តីសង្វេគ នឹកស្មានមិនដល់ ។ ខណៈនោះ ព្រះសារីបុត្រក្រោកចាកអាសនៈថ្វាយបង្គំក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រាថ្នាជួបព្រះអង្គ ទើបបំពេញបារមីទាំងឡាយ អស់មួយអសង្ខេយ្យកម្រៃមួយសែនកប្ប បុគ្គលមានបញ្ញាច្រើនដូចខ្ញុំព្រះអង្គ សមគួរជាឧបដ្ឋាក ឬខ្ញុំព្រះអង្គសូមជាឧបដ្ឋាក ព្រះមានព្រះភាគត្រាស់ហាមថា កុំឡើយសារីបុត្រ អ្នកនៅទិសណាក៏មិនទំនេរ ឱវាទរបស់អ្នកក៏ដូចជាឱវាទរបស់តថាគត កិច្ចដែលអ្នកត្រូវឧបដ្ឋាកតថាគតមិនមានទេ ព្រះអសីតិមហាសាវកតាំងពីព្រះមហាមោគ្គល្លានជាលំដាប់មក ក៏ក្រោកឡើង ក្រាបទូលដូចគ្នានឹងព្រះសារីបុត្រដែរ តែព្រះបរមសាស្តាទ្រង់ត្រាស់ហាមឃាត់ទាំងអស់ ចំណែកឯព្រះអានន្ទគង់នៅស្ងៀម លំដាប់នោះ ភិក្ខុទាំងឡាយពោល

នឹងព្រះអានន្ទថា អានន្ទ ភិក្ខុសង្ឃទូលសូមតំណែងឧបដ្ឋាក លោកក៏គួរទូលសូមដែរ ព្រះអានន្ទពោលថា លោកដ៏មានអាយុទាំងឡាយ តើប្រយោជន៍អ្វីដោយតំណែងដែលខ្ញុំព្រះករុណាទូលសូម ព្រះមានព្រះភាគមិនឃើញខ្ញុំឬ ប្រសិនបើព្រះសាស្តាទ្រង់សព្វព្រះទ័យ ក៏នឹងត្រាស់ថា អានន្ទ ចូរជាឧបដ្ឋាកតថាគតដូច្នេះ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទមិនចាំបាច់មានបុគ្គលដទៃបបួលឲ្យក្រោកឡើងទូលសូមទេ នឹងដឹងខ្លួនឯង ហើយឧបដ្ឋាកតថាគត ពេលនោះ ភិក្ខុទាំងឡាយពោលថា ក្រោកឡើងអានន្ទ លោកចូរក្រាបទូលសូមតំណែងជាឧបដ្ឋាកនឹងព្រះសម្មាសម្ពុទ្ធចុះ ។ គ្រានោះ ព្រះអានន្ទក្រោកឡើងក្រាបទូលសូមពរ ៨ ប្រការ អំពីព្រះទសពលដើម្បីធានាខ្លួនធ្វើជាឧបដ្ឋាក គឺ ១ សូមព្រះអង្គកុំឲ្យចីវរដែលគហបតីថ្វាយដល់ព្រះអង្គ ដល់ខ្ញុំព្រះអង្គឡើយ ២ សូមព្រះអង្គកុំប្រទានបិណ្ឌបាតដ៏ប្រណីតដល់ខ្ញុំព្រះអង្គ ៣ សូមព្រះអង្គកុំឲ្យខ្ញុំព្រះអង្គនៅក្នុងព្រះគន្ធកុដិរួមជាមួយ ៤ សូមព្រះអង្គកុំនាំខ្ញុំព្រះអង្គទៅក្នុងទីដែលគេនិមន្ត ៥ សូមព្រះអង្គស្តេចទៅកាន់ទីដែលខ្ញុំព្រះអង្គនិមន្តទុកហើយ ៦ សូមមេត្តាឲ្យខ្ញុំព្រះអង្គនាំពួកពុទ្ធបរិស័ទ ដែលមកពីទិសផ្សេងៗ ចូលគាល់បានគ្រប់កាល ៧ បើខ្ញុំព្រះអង្គមានសេចក្តីសង្ស័យក្នុងកាលណា សូមព្រះអង្គឲ្យខ្ញុំព្រះអង្គចូលគាល់សួរបានក្នុងកាលនោះ ៨ បើព្រះអង្គសម្តែងធម៌ក្នុងទីណា ដែលខ្ញុំព្រះអង្គមិនបានស្តាប់ សូមព្រះអង្គ

សម្តែងធម៌នោះដល់ខ្ញុំព្រះអង្គម្តងទៀត ។ ចំណែកពរ ៤ ខាងដើម សូមហាម ពរ ៤ ខាងចុងសូមសំណូមពរ ។

ព្រះពុទ្ធត្រាស់សួរថា អានន្ទ តើអ្នកឃើញទោសយ៉ាងណា ទើបហាមពរ ៤ ខាងដើម ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើខ្ញុំព្រះអង្គនឹងបាននូវវត្ថុបំណាងទាំងនោះ នឹងមានអ្នកដទៃពោលថា អានន្ទប្រើប្រាស់ចីវរ បានបិណ្ឌបាត ថែមទាំងនៅក្នុងព្រះគន្ធកុដិជាមួយព្រះអង្គ និងមានការនិមន្តទៅទីណា ក៏ជាមួយនឹងព្រះភគវាដែរ លាភទាំងអស់នេះកើតឡើង មកអំពីព្រះអានន្ទជានាខ្ជួនធ្វើជាឧបដ្ឋាក របស់ព្រះមហាមុនី បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញទោសយ៉ាងនេះឯង ទើបសូមហាមពរទាំង ៤ នេះអំពីព្រះអង្គ ។ ចុះចំពោះសំណូមពរ ៤ ខាងចុងនោះ តើមានប្រយោជន៍យ៉ាងណា ព្រះអានន្ទទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកពុទ្ធបរិស័ទដែលមានសទ្ធាក្នុងលោកនេះ កាលបើមិនបានឱកាសចូលគាល់ព្រះបរមសាស្តាហើយ ទើបពោលជាមួយខ្ញុំព្រះអង្គយ៉ាងនេះថា លោកម្ចាស់អានន្ទ ថ្ងៃស្អែកនេះ សូមលោកម្ចាស់ជាមួយនឹងព្រះសក្យមុនីទទួលភត្តាហារក្នុងផ្ទះរបស់ខ្ញុំ ប្រសិនបើព្រះអង្គមិនទទួលនិមន្តទៅទេនោះ ខ្ញុំព្រះអង្គមិនបានឱកាសឲ្យពុទ្ធបរិស័ទចូលគាល់តាមសេចក្តីប្រាថ្នាបាន បើខ្ញុំព្រះអង្គមានសេចក្តីសង្ស័យ ពួកគេនឹងពោលថា អានន្ទ អ្នកធ្វើជាឧបដ្ឋាករបស់ព្រះទសពលបានប្រយោជន៍អ្វី

សូម្បីតែព្រះអង្គក៏មិនអនុគ្រោះដល់អ្នកផង នឹងមានគេសួរដល់ខ្ញុំព្រះអង្គថា គាថានេះ ព្រះសូត្រនេះ ព្រះអង្គទ្រង់សម្ដែងនៅក្នុងទីណា ប្រសិនបើខ្ញុំព្រះអង្គមិនដឹងទេនោះ ពួកគេនឹងពោលថា អានន្ទសូម្បីត្រឹមតែប៉ុណ្ណោះមិនដឹងទៅហើយ តើមានប្រយោជន៍អ្វី ក្នុងការនៅរួមជាមួយព្រះមានព្រះភាគនោះ ខ្ញុំព្រះអង្គឃើញប្រយោជន៍ដូច្នេះឯង ទើបសូមពរទាំងនេះ កាលបើព្រះអង្គទ្រង់សណ្ដាប់ នូវការសូមពរទាំងអស់នោះហើយ ក៏ព្រះអង្គត្រាស់ថា អានន្ទ តថាគតប្រទានពរឲ្យដល់អ្នក ឲ្យសមតាមបំណងដែលអ្នកសុំពរចុះ ពេលនោះ ព្រះអានន្ទ បានទទួលពរទាំងនោះហើយ ទើបបានជានាខ្លួនធ្វើជាឧបដ្ឋាកព្រះសុគតតរហូតមក ។

ការសន្សំបុណ្យបារមីទាំងឡាយ ដែលបានបំពេញរហូតមួយសែនកប្បមកហើយ ក៏បានធ្វើឲ្យព្រះអានន្ទសម្រេចតាមសេចក្ដីប្រាថ្នា ចំពោះតំណែងជាពុទ្ធុបដ្ឋាកនោះ តាំងពីថ្ងៃដែលបានទទួលតំណែងជាពុទ្ធុបដ្ឋាកមក អានន្ទតែងតែឧបដ្ឋាកព្រះទសពលដោយកិច្ចទាំងឡាយយ៉ាងនេះ ជាដើម គឺដោយការរៀបចំទឹកសម្រាប់ប្រើប្រាស់ និងទឹកសម្រាប់ឆាន់ ឬឈើស្ទន់ ទាំងបានប្រេបាច់ព្រះហស្ត និងព្រះបាទ ថែមទាំងបានបោសសម្អាតបរិវេណព្រះគន្ធកុដិ ដោយគិតថា ព្រះសាស្ដាគួរធ្វើកិច្ចនេះក្នុងវេលានេះ ហើយមានការទ្រោលប្រទីបបំភ្លឺជុំវិញព្រះគន្ធកុដិ ។ នៅពេលអធ្រាត្រ ព្រះអានន្ទ តែងដើរពិនិត្យមើលជុំវិញបរិវេណព្រះគន្ធកុដិ មួយ

យប់ ៩ ដង លោកមានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើយើងទៅសិង ព្រះសាស្តាត្រាស់ហៅយើងក៏មិនបានឮ ព្រោះដូច្នោះហើយ ទើបទ្រោលប្រទីបដើរជុំវិញព្រះគន្ធកុដិ ។ កាលជាខាងក្រោយមក ព្រះភគវាទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់សរសើរព្រះអានន្ទថា ជាឃ្លាំងធម៌ដោយអនេកប្បរិយាយ ទើបស្ថាបនាព្រះអានន្ទទុកក្នុងតំណែងជាឯតទគ្គៈប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកខាងពហូសូតមានសតិ មានគតិ មានធិតិ និងពុទ្ធុប្បដ្ឋាក ក្នុងព្រះសាសនានេះ ។

សម័យមួយ ព្រះអានន្ទ អាស្រ័យនៅជងព្រៃមួយកន្លែង ក្នុងដែនកោសល លោកជាអ្នកច្រើនទៅដោយ ការទទួលពុទ្ធបរិស័ទហួសកាលវេលា ។ គ្រានោះ មានទេវតាដែលអាស្រ័យនឹងដូរព្រៃនោះ មានការអាណិតប្រាថ្នាប្រយោជន៍ឲ្យដល់ព្រះអានន្ទ ដើម្បីឲ្យលោកមានសេចក្តីសង្វេគ ទើបចូលទៅរកដល់ទីកន្លែង ហើយពោលជាមួយព្រះអានន្ទថា

លោកម្ចាស់អានន្ទ សូមចូលទៅកាន់ផ្ទះ គឺគល់ឈើ សូមបង្អោនចិត្តទៅកាន់ព្រះនិព្វាន ។ លោកម្ចាស់ចូរសម្ញឹងឈាន កុំមានសេចក្តីប្រមាទការជួបសន្ទនារវាងគ្រហស្ថ មានប្រយោជន៍អ្វីដល់លោកម្ចាស់ ។

គ្រានោះ ព្រះអានន្ទ ត្រូវទេវតាពោលដាស់តឿន ក៏កើតសេចក្តីសង្វេគក្នុងចិត្តឡើង ។

សម័យមួយ ព្រះមហាកស្សបត្ថេរ ប្រាប់ដល់ភិក្ខុទាំងឡាយថា

អាវុសោទាំងឡាយ គ្រាមួយ ខ្ញុំចេញចាកក្រុងបាវា ធ្វើដំណើរទៅកាន់ក្រុងកុសិនារារួមជាមួយភិក្ខុសង្ឃប្រមាណ ៥០០ រូប ខ្ញុំបានគេចចេញអំពីផ្លូវ ទៅអង្គុយសម្រាកនៅក្រោមម្លប់ឈើមួយដើម មានអាជីវកម្នាក់កាន់ផ្កាមន្ទារវៈចេញពីក្រុងកុសិនារា ទៅកាន់ក្រុងបាវា ខ្ញុំបានឃើញអាជីវកនោះមកអំពីចម្ងាយ ទើបសួរទៅកាន់អាជីវកថា អ្នកជ្រាបដំណឹងព្រះសាស្ដារបស់យើងដែរឬទេ ? អាជីវកឆ្លើយថា ខ្ញុំម្ចាស់ជ្រាបទេតើ ព្រះសមណគោតមបានបរិនិព្វានទៅ ៧ ថ្ងៃហើយ ផ្កាមន្ទារវៈនេះ ខ្ញុំករុណាបានកាន់មកអំពីទី ដែលព្រះអង្គបរិនិព្វាននោះឯង ។ បណ្ដាភិក្ខុទាំងនោះភិក្ខុពួកខ្លះដែលមិនទាន់ប្រាសចាករាគៈ ក៏យំសោក ខ្សឹកខ្សួល កន្ទក់កន្ទេញ ដួលដេកលើផែនដី បម្រះនទៀលយំរៀបរាប់ថា ព្រះសាស្ដាស្ដេចបរិនិព្វានឆាប់ពេកណាស់ ព្រះសុគតស្ដេចបរិនិព្វានឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ទ្រង់បាត់ទៅឆាប់ពេកណាស់ ឯពួកភិក្ខុដែលប្រាសចាករាគៈហើយ មានសតិសម្បជញ្ញៈ អត់សង្កត់ចិត្ត ដោយគិតថា សង្ខារទាំងឡាយមិនទៀង ។ គ្រានោះ ខ្ញុំបានពោលជាមួយនឹងភិក្ខុទាំងនោះថា ណ្ហើយចុះអ្នកទាំងឡាយ កុំសោកសៅ ខ្សឹកខ្សួលឡើយ ព្រះលោកនាថទ្រង់ត្រាស់ប្រាប់អ្នកហើយមិនមែនឬថា សង្ខារទាំងឡាយមិនទៀង មានការកើតឡើងហើយ ក៏ត្រូវតែមានការបែកធ្លាយជាធម្មតា ទោះតែអ្នកប្រាថ្នាថា កុំឲ្យព្រាត់ប្រាសយ៉ាងនេះយ៉ាងនោះ មិនមែនជា

ឋាន:ឡើយ ។ លំដាប់នោះ មានភិក្ខុបួសចាស់ឈ្មោះសុភទ្ទ អង្គុយនៅកណ្ដាលបរិស័ទនោះ ហើយពោលនឹងភិក្ខុទាំងឡាយនោះថា អ្នកទាំងឡាយ កុំសោកសៅ ខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចផុតស្រឡះអំពីអាជ្ញារបស់ព្រះសមណគោតមហើយ កាលបើពួកយើងធ្វើអ្វីនីមួយតែងតែពោលថា អំពើនេះអ្នកគួរធ្វើ អំពើនេះអ្នកមិនគួរធ្វើទៅវិញ ឥឡូវនេះ ពួកអ្នកប្រាថ្នាធ្វើនូវអំពើណា ចូរធ្វើនូវអំពើនោះចុះ បើមិនប្រាថ្នាធ្វើអំពើណាទេ ក៏កុំធ្វើអី ។ ភិក្ខុទាំងឡាយ កាលបើបានស្ដាប់សុភទ្ទពោលដូច្នោះហើយ ទើបពោលឡើងថា

ណ្ហើយចុះ អ្នកទាំងឡាយ ពួកយើងនឹងសង្គាយនាព្រះធម៌ ព្រះវិន័យ ព្រោះថា ខាងមុខសភាពដែលមិនមែនជាធម៌នឹងរុងរឿង ធម៌រមែងអន់ថយ ខាងមុខសភាពមិនមែនជាវិន័យនឹងរុងរឿង វិន័យនឹងមានការសាបសូន្យទៅ ខាងមុខអធម្មវាទីនឹងមានកម្លាំង ធម្មវាទីនឹងថយកម្លាំង អវិនយវាទីនឹងមានកម្លាំង វិនយវាទីនឹងថយកម្លាំង ។ ភិក្ខុទាំងឡាយពោលថា ប្រសិនបើដូច្នោះ សូមព្រះថេរៈជ្រើសរើសភិក្ខុទាំងឡាយចុះដើម្បីសង្គាយនា ។ គ្រានោះ ព្រះមហាកស្សបៈ ក៏បានជ្រើសរើសនូវព្រះអរហន្តបាន ៤៩៩ រូប ភិក្ខុទាំងនោះពោលនឹងព្រះមហាកស្សបៈថា បពិត្រលោកម្ចាស់ ព្រះអានន្ទនៅជាសេក្ខបុគ្គល ( គឺសោតាបន្ន ) ពិតមែនតែលោកមិនអាចលុះដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិ

លោកបានរៀនព្រះធម៌ ព្រះវិន័យយ៉ាងច្រើន ក្នុងសម្នាក់ព្រះវិជិតមារ ព្រោះហេតុនោះ សូមព្រះថេរៈជ្រើសរើសយកព្រះអានន្ទផង ។ ទើបព្រះមហាកស្សបៈ ជ្រើសរើសយកព្រះអានន្ទបញ្ចូលផង ហើយប្រឹក្សាគ្នាថា នឹងធ្វើសង្គាយនាព្រះធម៌ ព្រះវិន័យនៅទីឯណាហ្ន៎ បន្ទាប់មក ក៏ព្រមគ្នាធ្វើសង្គាយនានៅនគររាជគ្រឹះ ដែលមានទីគោចរក៏ច្រើន មានសេនាសនៈក៏ច្រើន សមគួរដល់ពួកយើងនឹងទៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីសង្គាយនាព្រះធម៌ ព្រះវិន័យ ឯភិក្ខុពួកដទៃកុំគប្បីចូលទៅនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ ។ លំដាប់នោះ ព្រះថេរៈទាំងឡាយបានទៅកាន់នគររាជគ្រឹះ ដើម្បីសង្គាយនាព្រះធម៌ព្រះវិន័យ ហើយប្រឹក្សាគ្នាថា បពិត្រព្រះករុណាម្ចាស់ទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សរសើរការជួសជុលសេនាសនៈដែលវិនាសទ្រុឌទ្រោម ប្រសិនបើដូច្នោះ ពួកយើងនឹងជួសជុលសេនាសនៈ ដែលវិនាសទ្រុឌទ្រោមក្នុងខែដំបូងសិនហើយ នឹងប្រជុំសង្គាយនាព្រះធម៌ព្រះវិន័យក្នុងកណ្តាលខែ គ្រានោះ ព្រះថេរៈបានជួសជុលសេនាសនៈ ដែលវិនាសទ្រុឌទ្រោមក្នុងដើមខែ ។

ពួកភិក្ខុបានពោលនឹងព្រះអានន្ទថា អាវុសោ ការប្រជុំនឹងមានក្នុងថ្ងៃស្អែកនេះ តែលោកនៅជាសេក្ខបុគ្គលនៅឡើយ ព្រោះហេតុនោះ លោកមិនគួរទៅកាន់ទីប្រជុំ សូមលោកចូរជាអ្នកមិនប្រមាទចុះ ដូច្នេះ ។ ព្រះអានន្ទត្រិះរិះថា ការប្រជុំនឹងមានក្នុងថ្ងៃស្អែកនេះ ក៏កិច្ចដែលយើងនៅ

ជាសេក្ខបុគ្គលនឹងគប្បីទៅកាន់ទីប្រជុំនោះ មិនសមគួរដល់យើងពិតមែនហើយ ក៏បានចម្រើនកាយគតាសតិ ដែលចម្រើនជាប់រហូតរាត្រី ក្នុងពេលបច្ចូសសម័យនៃរាត្រី ( ជិតភ្លឺ ) ចុះចាកទីចង្រ្កមហើយ ចូលទៅកាន់វិហារគិតថា នឹងចូលទៅសិង ក៏ទម្រេតកាយ ព្រះបាទទាំងពីរទើបតែផុតអំពីផែនដី តែព្រះសិរសាមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនេះ ព្រះទ័យក៏រួចស្រឡះចាកអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ការពិតណាស់ ព្រះអានន្ទនេះ នៅសម្រាកខាងក្រៅដោយការចង្រ្កម ។ កាលមិនអាចនឹងញ៉ាំងនូវគុណវិសេសឲ្យកើតឡើងបាន ទើបគិតថា ព្រះមានជោគបានត្រាស់ពាក្យនេះដល់អាត្មាអញមិនមែនឬថា អានន្ទ អ្នកជាអ្នកដែលបានធ្វើបុណ្យទុកមកហើយ ចូរប្រឹងប្រែងប្រកបនូវសេចក្តីព្យាយាម នឹងជាអ្នកគ្មានអាសវៈដោយឆាប់រហ័ស ធម្មតា ទោសនៃព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយរមែងមិនមាន អាត្មាអញប្រារព្ធសេចក្តីព្យាយាមច្រើនហួសទៅ ព្រោះហេតុនេះ ចិត្តរបស់អាត្មាអញ ទើបប្រព្រឹត្តទៅដើម្បីភាពរាយមាយ ណ្ហើយចុះ អាត្មានឹងប្រកបនូវសេចក្តីព្យាយាមឲ្យស្មើ នឹងសម្រាកបន្តិច ទើបទម្រេតកាយលើគ្រែ ជើងទាំងពីរទើបតែផុតអំពីផែនដី ក្បាលនៅមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនោះ ចិត្តក៏រួចស្រឡះចាកអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ភាពជាព្រះអរហន្តរបស់ព្រះថេរៈរូបនេះ វៀរចាកឥរិយាបថទាំង ៤ ។ ព្រោះដូច្នោះ កាល

បើមានអ្នកសួរថា ក្នុងព្រះសាសនានេះ ភិក្ខុរូបណា មិនសិង មិនគង់ មិនឈរ មិនចង្ក្រម បានសម្រេចព្រះអរហន្ត គប្បីឆ្លើយតបថា គឺព្រះអានន្ទត្ថេរ ។

ក្នុងថ្ងៃទី ២ ព្រះថេរៈទាំងឡាយ ធ្វើភត្តកិច្ចស្រេចហើយ ទុកបាត្រនិងចីវរ ហើយទៅទីប្រជុំគ្នានៅសាលាធម្មសភា ។ ឯព្រះអានន្ទត្ថេរ មានបំណងនឹងឲ្យអ្នកដទៃ ដឹងការសម្រេចភាពជាព្រះអរហន្តរបស់ខ្លួន មិននិមន្តទៅព្រមជាមួយនឹងភិក្ខុទាំងឡាយទេ ភិក្ខុទាំងឡាយកាលនឹងគង់លើអាសនៈរបស់ខ្លួនតាមលំដាប់វស្សា បានគង់វៀរអាសនៈទុកសម្រាប់ព្រះអានន្ទត្ថេរ ។ កាលបើភិក្ខុពួកខ្លះ ក្នុងសាលាធម្មសភានោះសួរថា ទុំះជាអាសនៈលោកម្ចាស់ណា ក្នុងសម័យនោះឯង ព្រះថេរៈគិតថា ឥឡូវនេះជាពេលដែលអាត្មាអញនឹងនិមន្តទៅ ។ កាលនឹងសម្ដែងអានុភាពរបស់ខ្លួន ទើបជ្រែកចូលទៅក្នុងដី ហើយបង្ហាញខ្លួនលើអាសនៈរបស់ខ្លួននោះឯង ។ អាចារ្យមួយពួកពោលថា និមន្តមកតាមផ្លូវអាកាស ហើយមកគង់លើអាសនៈក៏មាន ។ គ្រានោះ ព្រះមហាកស្សបៈប្រកាសឲ្យសង្ឃដឹង ដោយញត្តិកម្មវាចាដូច្នេះថា

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ បើកម្មនេះមានកាលសមគួរដល់សង្ឃហើយ ខ្ញុំនឹងគប្បីសួរព្រះវិន័យជាមួយព្រះឧបាលិ ។

ព្រះឧបាលិប្រកាសឲ្យសង្ឃដឹង ដោយញត្តិកម្មវាចាដូច្នេះថា :

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មនេះមានកាលសមគួរដល់សង្ឃហើយ ខ្ញុំកាលបើព្រះមហាកស្សបៈសួរវិន័យហើយ ខ្ញុំគប្បីវិសជ្ជនា ។ លំដាប់នោះ ព្រះមហាកស្សបៈសួរព្រះឧបាលិថា ឧបាលិ បឋមបារាជិកសិក្ខាបទ ព្រះសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ?

ឧបាលិ. ក្នុងនគរវេសាលី ។

មហាកស្សបៈ. ទ្រង់ប្រារព្ធបុគ្គលណា ?

ឧបាលិ. ទ្រង់ប្រារព្ធសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី ។

មហាកស្សបៈ. ព្រោះរឿងអ្វី ?

ឧបាលិ. ព្រោះរឿងប្រព្រឹត្តអសទ្ធម្ម ។

បន្ទាប់អំពីនោះ ព្រះមហាកស្សបៈ សួរដល់វត្ថុ និទាន បុគ្គល បញ្ញត្តិ អនុប្បញ្ញត្តិ អាបត្តិ អនាបត្តិ នៃបឋមបារាជិកសិក្ខាបទចំពោះព្រះឧបាលិ ហើយសួរទៅទៀតថា ទុតិយបារាជិក ព្រះមានព្រះភាគបញ្ញត្តក្នុងទីណា ?

ឧបាលិ. ក្នុងនគររាជគ្រឹះ លោកម្ចាស់ ។

មហាកស្សបៈ. ទ្រង់ប្រារព្ធបុគ្គលណា ?

ឧបាលិ. ទ្រង់ប្រារព្ធភិក្ខុធនិយៈ ជាកូនស្មូនឆ្នាំង ។

មហាកស្សបៈ. ព្រោះរឿងអ្វី ?

ឧបាលិ. ព្រោះអទិន្នាទាន ។

បន្ទាប់ពីនោះ ព្រះមហាកស្សបៈ សួរវត្ថុ និទាន បញ្ញត្តិ អនុ-ប្បញ្ញត្តិ អាបត្តិ អនាបត្តិ ចំពោះព្រះឧបាលិហើយ សួរតទៅទៀតថា តតិយបារាជិក ទ្រង់បញ្ញត្តក្នុងទីណា ?

ឧបាលិ. ក្នុងនគរវេសាលី លោកម្ចាស់ ។

មហាកស្សបៈ. ទ្រង់ប្រារព្ធបុគ្គលណា ?

ឧបាលិ. ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប ។

មហាកស្សបៈ. ព្រោះរឿងអ្វី ?

ឧបាលិ. ព្រោះមនុស្សវិគ្គហៈ គឺធ្វើរាងកាយនៃមនុស្សឲ្យធ្លាក់ចុះចាកជីវិត ។

បន្ទាប់ពីនោះ ព្រះមហាកស្សបៈ សួរវត្ថុ និទាន បុគ្គល បញ្ញត្តិ អនុប្បញ្ញត្តិ អាបត្តិ អនាបត្តិ ចំពោះព្រះឧបាលិ ហើយសួរតទៅទៀតថា ចតុត្ថបារាជិកសិក្ខាបទ ទ្រង់បញ្ញត្តក្នុងទីណា ?

ឧបាលិ. ក្នុងនគរវេសាលី លោកម្ចាស់ ។

មហាកស្សបៈ. ទ្រង់ប្រារព្ធបុគ្គលណា ?

ឧបាលិ. ទ្រង់ប្រារព្ធភិក្ខុដែលចាំវស្សា ក្បែរស្ទឹងវគ្គុមុទា ។

មហាកស្សបៈ. ព្រោះរឿងអ្វី ?

ឧបាលិ. ព្រោះឧត្តរិមនុស្សធម៌ ។

បន្ទាប់ពីនោះ ព្រះមហាកស្សបៈ សួរដល់វត្ថុ និទាន បុគ្គល

បញ្ញត្តិ អនុប្បញ្ញត្តិ អាបត្តិ អនាបត្តិ នៃចតុត្ថបារាជិកសិក្ខាបទចំពោះព្រះឧបាលិ ហើយសួរឧភតោវិន័យដោយរបៀបនេះឯង ឯព្រះឧបាលិ ក៏ឆ្លើយតាមដែលព្រះមហាកស្សបៈសួរហើយ ។ ក្នុងកាលនោះ ព្រះមហាកស្សបៈប្រកាសសង្ឃឲ្យដឹងដោយញត្តិកម្មវាចាថា :

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ បើកម្មនេះមានកាលសមគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរព្រះសូត្រចំពោះអានន្ទ ។ ឯព្រះអានន្ទក៏ប្រកាសសង្ឃឲ្យដឹងដោយញត្តិកម្មវាចាថា

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ បើកម្មនេះមានកាលសមគួរដល់សង្ឃហើយ ព្រះមហាកស្សបៈសួរព្រះសូត្រចំពោះខ្ញុំៗគប្បីដោះស្រាយក្នុងកាលឥឡូវនេះ ។ លំដាប់នោះ ព្រះមហាកស្សបៈសួរចំពោះព្រះអានន្ទថា ព្រហ្មជាលសូត្រ ទ្រង់សម្ដែងក្នុងទីណា ?

អានន្ទ. សម្ដែងក្នុងឧទ្យានអម្ពលដ្ឋិកា ចន្លោះក្រុងរាជគ្រឹះ និងក្រុងនាលន្ទា លោកម្ចាស់ ។

មហាកស្សបៈ. ទ្រង់ប្រារព្ធបុគ្គលណា ?

អានន្ទ. ទ្រង់ប្រារព្ធសុប្បិយបរិព្វាជក និងព្រហ្មទត្តមាណព ។

លំដាប់នោះ ព្រះមហាកស្សបៈ សួរនិទាន និងបុគ្គលនៃព្រហ្មជាលសូត្រចំពោះព្រះអានន្ទ ហើយសួរតទៅទៀតថា សាមញ្ញផលសូត្រ ទ្រង់សម្ដែងក្នុងទីណា ?

អានន្ទ. ក្នុងវិហារជីវកម្ពវ័ន ក្បែរក្រុងរាជគ្រឹះ លោកម្ចាស់ ។

មហាកស្សបៈ. សម្ដែងនឹងបុគ្គលណា ?

អានន្ទ. សម្ដែងនឹងព្រះបាទអជាតសត្តុវេទេហីបុត្រ ។

លំដាប់នោះ ព្រះមហាកស្សបៈ សួរនិទាន និងបុគ្គលនៃសាមញ្ញផលសូត្រចំពោះអានន្ទ ហើយសួរនិកាយទាំង ៥ ដោយទំនងនេះឯង ។ ព្រះអានន្ទក៏វិសជ្ជនា តាមដែលព្រះមហាកស្សបៈសួរហើយ ។ លំដាប់នោះ ព្រះអានន្ទ បានពន្យល់ប្រាប់ព្រះថេរៈទាំងឡាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលព្រះមានព្រះភាគជិតបរិនិព្វាន ទ្រង់មានបន្ទូលថា នែអានន្ទ លុះអំណឹះតតពីតថាគតទៅ បើសង្ឃប្រាថ្នាដកនូវសិក្ខាបទតូចៗ ចេញខ្លះក៏បាន ។ ព្រះថេរៈទាំងឡាយសួរថា នែអានន្ទ ចុះលោកបានទូលសួរព្រះមានព្រះភាគឬទេថា សិក្ខាបទណាតូចៗ ។ ព្រះអានន្ទឆ្លើយថា ខ្ញុំព្រះករុណាមិនបានទូលសួរព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន សិក្ខាបទពួកណា ជាសិក្ខាបទតូចៗ ទេ ។ ព្រះថេរៈពួកខ្លះពោលយ៉ាងនេះថា ក្រៅពីបារាជិក ៤ ជាសិក្ខាបទតូចៗ ។ ព្រះថេរៈពួកខ្លះពោលថា វៀរបារាជិក ៤ សង្ឃាទិសេស ១៣ ជាសិក្ខាបទតូចៗ ។ ព្រះថេរៈខ្លះទៀតពោលថា វៀរបារាជិក ៤ សង្ឃាទិសេស ១៣ អនិយតៈ ២ និស្សគ្គិយបាចិត្តិយៈ ៣០ សុទ្ធិកបាចិត្តិយៈ ៩២ បាដិទេសនីយៈ ៤ ជាសិក្ខាបទតូចៗ ។ គ្រានោះឯង ព្រះមហាកស្សបត្ថេរ ប្រកាសសង្ឃ

ឲ្យដឹងដោយទុតិយកម្មវាចាថា :

ម្នាលអាវុសោទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើង បានផ្សព្វផ្សាយដល់ពួកគ្រហស្ថ ពួកគេក៏ដឹងថា អំពើនេះគួរ អំពើនេះមិនគួរដល់សមណសក្យបុត្រ ។ បើយើងទាំងឡាយដកសិក្ខាបទតូចៗ ចេញ ពួកគ្រហស្ថនឹងពោលថា ព្រះសមណគោតមបញ្ញត្តសិក្ខាបទដល់សាវ័កទាំងឡាយ បានត្រឹមតែមួយរយៈកាល ។ សាវ័កពួកនេះសិក្សាសិក្ខាបទទាំងឡាយ តែក្នុងកាលព្រះសាស្តាគង់នៅ កាលបើព្រះសាស្តាបរិនិព្វានទៅហើយ ក៏មិនសិក្សាក្នុងសិក្ខាបទនោះ បើការព្រមព្រៀងមានកាលគួរដល់សង្ឃហើយ សង្ឃមិនគប្បីបញ្ញត្តសិក្ខាបទថែម មិនគប្បីដកនូវសិក្ខាបទ ដែលព្រះមានព្រះភាគបញ្ញត្តទុកហើយ គប្បីសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយ ដែលទ្រង់បញ្ញត្តរួចហើយចុះ នេះជាញត្តិ ។ ម្នាលអាវុសោទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ សិក្ខាបទរបស់ពួកយើងទាំងឡាយ ក៏មានទូទៅដល់គ្រហស្ថដែរ ។ សូម្បីពួកគ្រហស្ថក៏ដឹងថា អំពើនេះគួរដល់សមណសក្យបុត្ត អំពើនេះមិនគួរ បើយើងទាំងឡាយដកនូវសិក្ខាបទនោះចេញ ប្រាកដជាមានពាក្យពោលថា ព្រះសមណគោតមបញ្ញត្តសិក្ខាបទដល់សាវ័កទាំងឡាយ បានត្រឹមតែមួយរយៈកាលប៉ុណ្ណោះ ពួកសាវ័កនេះ សិក្សាសិក្ខាបទទាំងឡាយតែក្នុងកាលព្រះសក្យមុនីគង់នៅ កាលបើព្រះភគវាបរិនិព្វានទៅហើយ ព្រះសមណៈ

ទាំងនោះ មិនបានសិក្សាក្នុងសិក្ខាបទទាំងឡាយ ឥឡូវនេះ សង្ឃក៏កុំគប្បីបញ្ញត្តនូវសិក្ខាបទ ដែលទ្រង់មិនបានបញ្ញត្ត មិនគប្បីដកនូវសិក្ខាបទដែលទ្រង់បានបញ្ញត្តរួចហើយ នាំគ្នាសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយ តាមដែលព្រះអង្គបញ្ញត្តទុករួចហើយ បើគាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវនៅស្ងៀម ខ្ញុំសូមចាំទុកដោយអាការនៅស្ងៀមយ៉ាងនេះឯង ។

គ្រានោះឯង ព្រះថេរៈទាំងឡាយ បានពោលជាមួយព្រះអានន្ទថា នៃអាវុសោអានន្ទ ទោសដែលលោកមិនបានទូលសួរ ព្រះលោកនាថថា បពិត្រព្រះអង្គដ៏ចម្រើន តើសិក្ខាបទណាជាសិក្ខាបទតូចៗ នេះជាអាបត្តិទុក្កដសម្រាប់អ្នក ចូរលោកសម្តែងអាបត្តិទុក្កដនោះចេញ ។ ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះខ្ញុំព្រះករុណាភ្លេចមិនបានដែលមិនបានទូលសួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន សិក្ខាបទណាជាសិក្ខាបទតូចៗ ខ្ញុំមិនឃើញហេតុដែលមិនបានទូលសួរនោះថាជាអាបត្តិទុក្កដ តែព្រោះការជឿលោកមានអាយុទាំងឡាយ ខ្ញុំព្រមសម្តែងអាបត្តិទុក្កដនោះចេញ ។ ព្រះថេរៈទាំងឡាយពោលតទៅទៀតថា នៃអាវុសោអានន្ទ អំពើអាក្រក់ ដែលលោកជាន់ដេរសំពត់វស្សិកសាដករបស់ព្រះមានជោគ សូម្បីទាំងនេះក៏ជាអាបត្តិទុក្កដដល់អ្នក ចូរលោកសម្តែងអាបត្តិទុក្កដនោះ ។ ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះ

ករុណាជាន់ដេរសំពត់វស្សិកសាដករបស់ព្រះសាស្តា មិនមែនធ្វើដោយសេចក្តីមិនគោរពទេ ខ្ញុំព្រះករុណាមិនបានឃើញហេតុដែលជាន់ដេរនោះថាជាអាបត្តិទុក្កដ តែព្រោះការជឿលោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណាព្រមសម្តែងនូវអាបត្តិទុក្កដនោះចេញ ។ ព្រះថេរៈទាំងឡាយ ពោលតទៅទៀតថា នែអាវុសោអានន្ទ អំពើអាក្រក់ដែលលោកឲ្យមាតុគ្រាមថ្វាយបង្គំព្រះសរីរៈរបស់ព្រះសក្យមុនីមុនគេ ព្រះសរីរៈរបស់ព្រះសុគតប្រឡាក់ដោយទឹកភ្នែក របស់ពួកមាតុគ្រាមទាំងអស់ដែលយំនោះ នេះក៏ជាអាបត្តិទុក្កដដែរ ។ ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាគិតថា មាតុគ្រាមទាំងនេះកុំឲ្យនៅយូរដល់ពេលព្រលប់ ទើបឲ្យពួកមាតុគ្រាមថ្វាយបង្គំព្រះសរីរៈរបស់ព្រះសម្ពុទ្ធមុន ខ្ញុំព្រះករុណាមិនឃើញហេតុដែលឲ្យមាតុគ្រាមថ្វាយបង្គំព្រះសរីរៈ របស់ព្រះអង្គថាជាអាបត្តិទុក្កដ តែខ្ញុំជឿតាមលោកម្ចាស់ទាំងឡាយ ព្រមសម្តែងនូវអាបត្តិទុក្កដនោះចេញ ។

ព្រះថេរៈទាំងឡាយពោលតទៅទៀតថា នែអាវុសោអានន្ទ នេះជាអំពើអាក្រក់របស់លោកដែរ ព្រោះព្រះមានព្រះភាគទ្រង់ធ្វើនូវនិមិត្តដ៏គ្រោតគ្រាត ទ្រង់ធ្វើឱកាសដ៏គ្រោតគ្រាត នៅតែលោកមិនបានទូលសូមអង្វរព្រះភគវាថា សូមឲ្យព្រះអង្គគង់នៅអស់មួយកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ នេះក៏ជាអាបត្តិទុក្កដដល់អ្នកដែរ ចូរ

លោកសម្តែងអាបត្តិទុក្កដនោះ ។ ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវមារគ្របសង្កត់ចិត្ត ទើបមិនបានទូលសូមអារាធនាព្រះជិនស្រីថា សូមព្រះអង្គទ្រង់គង់នៅអស់មួយកប្ប សូមព្រះសុគតទ្រង់គង់នៅអស់មួយកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើនជាដើម ខ្ញុំព្រះករុណាមិនឃើញហេតុនេះថាជាអាបត្តិទុក្កដទេ ប៉ុន្តែខ្ញុំជឿលោកម្ចាស់ទាំងឡាយ ព្រមសម្តែងអាបត្តិទុក្កដនោះចេញ ។ ព្រះថេរៈទាំងឡាយពោលតទៅទៀតថា នៃអាវុសោអានន្ទ អំពើអាក្រក់ដែលលោកបានជួយខ្នះខ្នែងឲ្យមាតុគ្រាមនៅក្នុងធម្មវិន័យនេះ ដែលព្រះតថាគតទ្រង់ប្រកាសហើយ នេះក៏ជាអាបត្តិទុក្កដដល់អ្នក ចូរលោកសម្តែងអាបត្តិទុក្កដនេះ ។ ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាបានធ្វើការខ្នះខ្នែងឲ្យមាតុគ្រាមបួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ប្រកាសហើយ ដោយគិតថា ព្រះនាងមហាបជាបតិគោតមីជាព្រះមាតុច្ឆា ( ម្តាយមីង ) នៃព្រះវិជិតមារ បានបីបាច់ចិញ្ចឹមរក្សា ទ្រង់ប្រទានខីរធារៈ ( ទឹកដោះ ) ដល់ព្រះភគវា កាលពុទ្ធមាតា ( ព្រះនាងមហាមាយាទេវី ) ជាព្រះមាតាបង្កើតបានសោយទិវង្គតទៅ ព្រះនាងថែមទាំងបានបំបៅដោះព្រះសយម្ភូផង ខ្ញុំព្រះករុណាមិនឃើញហេតុនេះថាជាអាបត្តិទុក្កដ ប៉ុន្តែខ្ញុំជឿលោកម្ចាស់ទាំងឡាយ ព្រមសម្តែងអាបត្តិទុក្កដនេះចេញ ។

សម័យនោះឯង ព្រះរាហុលត្ថេរ ត្រាច់ទៅបិណ្ឌបាតក្នុងទក្ខិណា

គិរីជនបទ ព្រមដោយភិក្ខុសង្ឃមួយពួកធំ ប្រមាណ ៥០០ រូប នាកាល ព្រះថេរៈទាំងឡាយ សង្គាយនាព្រះធម៌ និងព្រះវិន័យ បានសម្រាកនៅក្នុងទក្ខិណាគិរីជនបទ តាមសមគួរដល់អធ្យាស្រ័យហើយ ក៏ចូលទៅរកព្រះថេរៈទាំងឡាយដែលគង់នៅក្នុងវត្តវេឡុវ័ន ក្បែរក្រុងរាជគ្រឹះ ថែមទាំងបានធ្វើការរាក់ទាក់ជាមួយនឹងព្រះថេរៈទាំងនោះ រួចហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ ព្រះថេរៈទាំងឡាយ បានពោលជាមួយនឹងព្រះរាហុលថា នែរាហុល យើងបានសង្គាយនាព្រះធម៌ព្រះវិន័យហើយ ចូរអ្នកទទួលដឹងព្រះធម៌ព្រះវិន័យនោះ ដែលព្រះថេរៈទាំងឡាយបានសង្គាយនារួចហើយ ។ ព្រះរាហុលពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ តើការសង្គាយនារៀបរយហើយឬ តែថាខ្ញុំព្រះករុណាបានស្តាប់ បានទទួលមកក្នុងទីចំពោះព្រះភក្រ្ត នៃព្រះសម្ពុទ្ធដោយប្រការណា ខ្ញុំនឹងទ្រទ្រង់ទុកប្រតិបត្តិដោយប្រការនោះ ។ គ្រានោះឯង ព្រះអានន្ទ បានពោលជាមួយនឹងព្រះថេរៈទាំងឡាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះមុនីកាលទៀបនឹងបរិនិព្វាន ព្រះអង្គទ្រង់មានព្រះបន្ទូលនឹងខ្ញុំព្រះករុណាថា ម្នាលអានន្ទ អំណើះអត់អំពីតថាគតទៅ សង្ឃប្រូវដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុផង ។

ព្រះថេរៈទាំងឡាយសួរថា អាវុសោអានន្ទ លោកបានទូលសួរព្រះសម្ពុទ្ធដែរឬ ព្រះអង្គឲ្យដាក់ព្រហ្មទណ្ឌយ៉ាងណា ? ព្រះអានន្ទតបថា បានទូលសួរដែរ ព្រហ្មទណ្ឌនោះតើដូចម្តេច ព្រះអង្គត្រាស់ថា ម្នាល

អានន្ទ កុំឲ្យភិក្ខុទាំងឡាយនិយាយរក កុំគប្បីប្រដៅទូន្មានឆន្នភិក្ខុឡើយ ។ ព្រះថេរៈទាំងឡាយពោលថា នែអាវុសោអានន្ទ បើដូច្នោះ ចូរលោកដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុចុះ ។ ព្រះអានន្ទ បានប្រឹក្សាគ្នាថា បពិត្រលោកម្ចាស់ តើខ្ញុំព្រះករុណាគប្បីដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុបានយ៉ាងណា ភិក្ខុនេះកាចរឹងរូសណាស់ ។ ព្រះថេរៈទាំងឡាយពោលថា នែអាវុសោអានន្ទ បើដូច្នោះ លោកចូរទៅជាមួយនឹងភិក្ខុច្រើនរូប ។ ព្រះអានន្ទទទួលពាក្យព្រះថេរៈបញ្ជាហើយ ក៏ឡើងជិះទូកព្រមជាមួយនឹងភិក្ខុប្រមាណ ៥០០ រូប ទៅកាន់ក្រុងកោសម្ពី លុះបានឡើងអំពីទូកហើយ បានទៅគង់ក្រោមម្លប់ឈើមួយដើម ជិតព្រះរាជឧទ្យាននៃព្រះបាទឧទេន ។ គ្រានោះ ព្រះបាទឧទេន និងអគ្គមហេសីប្រថាប់នៅក្នុងព្រះរាជឧទ្យាន ព្រមដោយពួករាជបរិវារ ។ អគ្គមហេសីរបស់ព្រះបាទឧទេន ទ្រង់បានជ្រាបដំណឹងថា លោកម្ចាស់អានន្ទ ជាអាចារ្យរបស់ពួកយើង គង់ក្រោមម្លប់ឈើមួយដើមជិតព្រះរាជឧទ្យាន ក៏ទូលសូមព្រះរាជាថា ពួកខ្ញុំម្ចាស់ប្រាថ្នានឹងទៅសួរសុខទុក្ខលោកម្ចាស់អានន្ទ ។ ព្រះបាទឧទេនត្រាស់ថា បើដូច្នោះ ចូរអ្នកទាំងអស់គ្នាទៅសួរសុខទុក្ខព្រះអានន្ទចុះ ។ លំដាប់នោះឯង អគ្គមហេសីរបស់ព្រះបាទឧទេន បានចូលទៅរកព្រះអានន្ទ លុះចូលទៅដល់ហើយ ក៏បានថ្វាយបង្គំព្រះអានន្ទ រួចអង្គុយក្នុងទីដ៏សមគួរ ។ ព្រះអានន្ទ បានពន្យល់ដល់អគ្គមហេសីនៃព្រះបាទឧទេន ឲ្យឃើញច្បាស់ ឲ្យប្រព្រឹត្តតាម ឲ្យ

អាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ អគ្គមហេសីរបស់ព្រះបាទឧទេន កាលបើព្រះអានន្ទបានពន្យល់ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទើបបានថ្វាយសំពត់ឧត្តរាសង្គ: ៥០០ ផ្ទាំងដល់ព្រះអានន្ទ ។ លំដាប់នោះឯង អគ្គមហេសីរបស់ព្រះបាទឧទេន ត្រេកអររីករាយនឹងភាសិតរបស់ព្រះអានន្ទ ទើបក្រោកចាកអាសនៈ ថ្វាយបង្គំលា ធ្វើប្រទក្សិណចៀសចេញទៅ ចូលទៅគាល់ព្រះបាទឧទេន ។ ពេលនោះ ព្រះបាទឧទេន បានទតឃើញអគ្គមហេសីមកអំពីចម្ងាយ មកដល់ហើយបានសួរថា ពួកអ្នកទាំងអស់គ្នា បានសួរសុខទុក្ខព្រះអានន្ទហើយឬ ? អគ្គមហេសីក្រាបទូលថា ពួកខ្ញុំទាំងអស់គ្នា បានសួរសុខទុក្ខលោកម្ចាស់អានន្ទរួចហើយ ។

ឧទេន. ពួកនាង បានថ្វាយអ្វីដល់ព្រះអានន្ទខ្លះដែរឬទេ ?

មហេសី. ពួកខ្ញុំម្ចាស់បានថ្វាយសំពត់ឧត្តរាសង្គ: ៥០០ ផ្ទាំងដល់លោកម្ចាស់អានន្ទដែរ ។ ព្រះបាទឧទេន ក៏ពោលទោសតិះដៀលបន្តុះបន្អាប់ថា មិនសមបើសមណៈឈ្មោះអានន្ទ ទទួលយកចីវរច្រើនដល់ម្ល៉េះទេ សមណៈរូបនេះ ធ្វើនូវជំនួញសំពត់ ឬនឹងតាំងរានលក់សំពត់ ។ ហើយទើបចូលទៅរកព្រះអានន្ទ ទ្រង់ប្រាស្រ័យសំណេះសំណាលជាមួយនឹងព្រះអានន្ទ លុះបញ្ចប់ការប្រាស្រ័យសំណេះសំណាល និងពាក្យដែលគួររឭកដល់គ្នាហើយ បានប្រថាប់គង់នៅក្នុងទីដ៏សមគួរ **ទើបត្រាស់សួរ**

ថា បពិត្រលោកម្ចាស់អានន្ទ ពួកអគ្គមហេសីរបស់ខ្ញុំបានមកឬ ?

អានន្ទ. អគ្គមហេសីរបស់ព្រះអង្គបានមក ។

ឧទេន. ពួកអ្នកទាំងអស់នោះ បានថ្វាយអ្វីដល់លោកម្ចាស់ខ្លះទេ ?

អានន្ទ. បានថ្វាយសំពត់ដល់អាត្មា ៥០០ ផ្ទាំងដែរ ។

ឧទេន. លោកម្ចាស់អានន្ទ នឹងយកចីវរធ្វើអ្វីច្រើនដល់ម្ល៉េះ ?

អានន្ទ. អាត្មានឹងចែកដល់ភិក្ខុទាំងឡាយ ដែលមានចីវរគ្រាំគ្រា ។

ឧទេន. តើលោកម្ចាស់នឹងធ្វើយ៉ាងណាចំពោះចីវរគ្រាំគ្រានោះ ?

អានន្ទ. អាត្មានឹងយកសំពត់ចីវរទាំងនោះទៅធ្វើកម្រាលគ្រែ ។

ឧទេន.លោកម្ចាស់យកធ្វើអ្វីចំពោះសំពត់កម្រាលគ្រែចាស់នោះ?

អានន្ទ. អាត្មានឹងយកសំពត់ទាំងនោះទៅធ្វើស្រោមពូក ។

ឧទេន. លោកម្ចាស់ធ្វើយ៉ាងណាចំពោះស្រោមពូកចាស់នោះ ?

អានន្ទ. អាត្មានឹងយកសំពត់ទាំងនោះទៅធ្វើជាកម្រាលផែនដី ។

ឧទេន. ចុះលោកម្ចាស់នឹងធ្វើយ៉ាងណាចំពោះសំពត់កម្រាលផែនដីចាស់នោះ ?

អានន្ទ. អាត្មានឹងយកសំពត់កម្រាលផែនដីចាស់នោះ ទៅធ្វើជាសំពត់ជូតជើង ។

ឧទេន. ចុះលោកម្ចាស់ធ្វើយ៉ាងណាចំពោះសំពត់ជូតជើងនោះ ?

អានន្ទ. អាត្មានឹងយកសំពត់ជូតជើងចាស់នោះ ទៅធ្វើជាសំពត់

ជូតធូលីវិញ ។

ឧទេន. ចុះលោកម្ចាស់យកសំពត់ជូតធូលីចាស់នោះទៅធ្វើអ្វី ?

អានន្ទ. អាត្មានឹងចិញ្ច្រាំនូវសំពត់ជូតធូលីចាស់នោះ ហើយច្របាច់លាយជាមួយភក់ យកទៅបូកលាបជញ្ជាំង ។

គ្រានោះ ព្រះបាទឧទេនទ្រង់ត្រិះរិះថា សមណសក្យបុត្រទាំងឡាយ យកសំពត់ទៅប្រើប្រាស់ដោយឧបាយនៃប្រាជ្ញា មិនប្រមូលសន្សំសំពត់ទុក ហើយក៏ទ្រង់ប្រគេនសំពត់ ៥០០ ផ្ទាំងទៀតដល់ព្រះអានន្ទពេលនោះ បរិក្ខារ គឺចីវរបានកើតដល់ព្រះអានន្ទជាលើកដំបូង គឺសំពត់មួយពាន់ផ្ទាំង ។ គ្រានោះឯង ព្រះអានន្ទចូលទៅកាន់វត្តឃោសិតារាម គង់លើអាសនៈដែលគេក្រាលទុក ឆន្នភិក្ខុចូលទៅរកព្រះអានន្ទ បានធ្វើអភិវាទន៍រួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ព្រះអានន្ទបានពោលនឹងឆន្នភិក្ខុថា នែអាវុសោឆន្ន សង្ឃបានដាក់ព្រហ្មទណ្ឌដល់លោកហើយ ។

ឆន្ន. លោកម្ចាស់អានន្ទ ក៏ព្រហ្មទណ្ឌនោះ តើដូចម្តេចខ្លះ ?

អានន្ទ. នែអាវុសោ ឆន្ន លោកប្រាថ្នានឹងនិយាយពាក្យណា ក៏និយាយពាក្យនោះចុះ ភិក្ខុទាំងឡាយនឹងមិននិយាយរក មិនប្រដៅទូន្មានដល់លោកទៀតឡើយ ។

ឆន្ន. លោកម្ចាស់អានន្ទ ដោយហេតុត្រឹមតែភិក្ខុទាំងឡាយ មិននិយាយរក មិនដាស់តឿន មិនប្រៀនប្រដៅខ្ញុំ ទាំងនេះឈ្មោះថា សង្ឃ

សម្លាប់ខ្ញុំហើយឬ ហើយក៏ជួលជ្រប់នៅក្នុងទីនោះឯង ។

តមក ឆន្នភិក្ខុលំបាកចិត្តចំពោះព្រហ្មទណ្ឌនោះ ទើបគេចទៅនៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មិនយូរប៉ុន្មាន បានធ្វើឲ្យជាក់ច្បាស់នូវគុណដ៏ប្រសើរបំផុត ជាទីបំផុតនៃព្រហ្មចរិយធម៌ ដែលកុលបុត្រទាំងឡាយចេញចាកផ្ទះបួសដោយប្រពៃ ជាអ្នកមានបំណងស្វែងរកនោះ ដោយប្រាជ្ញាដ៏ប្រពៃ ដោយខ្លួនឯង ក្នុងបច្ចុប្បន្នជាតិនេះចូលទៅដល់ហើយ បានដឹងច្បាស់ហើយថា ជាតិអស់ហើយ ព្រហ្មចរិយធម៌នៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចហើយ កិច្ចដទៃទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ឆន្នភិក្ខុក៏ជាព្រះអរហន្តមួយរូបដែរ លុះពេលដែលឆន្នភិក្ខុបានសម្រេចជាព្រះអរហន្តហើយ បានចូលទៅរកព្រះអានន្ទ ហើយពោលថា បពិត្រលោកម្ចាស់អានន្ទដ៏ចម្រើន សូមលោកម្ចាស់រំងាប់ព្រហ្មទណ្ឌដល់ខ្ញុំឥឡូវនេះចុះ ។ ព្រះអានន្ទពោលថា នែឆន្ន លោកបានធ្វើឲ្យជាក់ច្បាស់ហើយនូវព្រះអរហត្ត ក្នុងកាលជាទីបំផុតណា ឯព្រហ្មទណ្ឌរបស់លោក ក៏រំងាប់ក្នុងកាលជាទីបំផុតនោះដែរ ។ ក្នុងពេលសង្គាយនាព្រះវិន័យ មានភិក្ខុ ៥០០ រូប មិនលើសមិនខ្វះ ។ ព្រោះហេតុនោះ ការសង្គាយនាព្រះវិន័យក្នុងកាលនោះ បណ្ឌិតទើបហៅថា **បញ្ចសតិកាសង្គាយនា** គឺសង្គាយនារបស់ភិក្ខុមានចំនួន ៥០០ រូប

ដូច្នេះឯង ។

ព្រះអានន្ទត្ថេរ លោកបានពិចារណាមើលអាយុសង្ខារ ក្នុងកាល ដែលមានព្រះជន្មបាន ១២០ វស្សា ដឹងថា អាយុអស់ហើយ ទើបប្រាប់ថា ខ្ញុំព្រះករុណានឹងបរិនិព្វានក្នុងថ្ងៃទី ៧ រាប់ពីថ្ងៃនេះតទៅ ។ បណ្តាមហាជន អ្នកនៅឆ្នេរស្ទឹងរោហិណីទាំងពីរខាង ជ្រាបដំណឹងហើយ នាំគ្នាពោលថា

ពួកយើងមានឧបការៈច្រើនដល់ព្រះថេរៈៗ គួរនឹងបរិនិព្វានខាងត្រើយរបស់យើង ព្រះថេរៈបានស្តាប់ពាក្យទាំងនោះហើយ គិតថា ពួកជនទាំងពីរខាង ម្នាក់ៗ ក៏មានឧបការគុណដល់យើងដូចគ្នា យើងមិនអាចពោលថា ត្រើយខាងនេះមិនមានឧបការគុណទេ បើយើងបរិនិព្វានត្រើយខាងនេះ អ្នកត្រើយខាងនោះ ប្រាកដជាមានការឈ្លោះគ្នាជាមួយអ្នកត្រើយខាងនេះ ដើម្បីនឹងចង់បានគ្រប់គ្រង យកអដ្ឋិធាតុរបស់យើង ប្រសិនបើយើងបរិនិព្វានត្រើយនោះ ត្រើយនេះក៏នឹងឈ្លោះគ្នា ការឈ្លោះគ្នានឹងកើតឡើង ក៏ព្រោះតែយើង ព្រះថេរៈទើបពោលប្រាប់ដល់ជនទាំងពីរខាងថា អ្នកទាំងអស់គ្នា ក៏សុទ្ធតែជាអ្នកមានឧបការគុណដូចគ្នា ចូរនាំគ្នាទៅកាន់ត្រើយរបស់ខ្លួនរៀងៗ ខ្លួនចុះ ។ ដល់ថ្ងៃទី ៧ ព្រះអានន្ទគង់ពែនភ្នែនលើអាកាសប្រមាណ ៧ ដូរត្នោតកណ្តាលស្ទឹង ថែមទាំងបានសម្តែងធម៌ដល់មហាជន រួចហើយ លោកបានអធិដ្ឋានថា សូមឲ្យ

សរីរៈរបស់យើងបែកជាពីរចំណែក ។ មួយចំណែក ចូរធ្លាក់នៅត្រើយខាងនេះ មួយចំណែកទៀត ចូរធ្លាក់ត្រើយខាងនោះ ហើយចូលសមាបត្តិមានតេជោធាតុជាអារម្មណ៍ ក៏មានអណ្តាតភ្លើងឆេះឡើង ។ ព្រះអដ្ឋិធាតុបែកជាពីរចំណែក ធ្លាក់ទៅត្រើយខាងនេះផង ខាងនោះផង មហាជនជាច្រើនបានយំសោកខ្សឹកខ្សួល សំឡេងយំដូចជាសំឡេងផែនដីស្រុត ការយំពេលនេះ ច្រើនជាងពេលដែលព្រះបរមសាស្តាបរិនិព្វានទៅទៀត ។

ពួកពុទ្ធបរិស័ទបានយំសោកខ្សឹកខ្សួលអស់ ៤ ខែ ហើយត្អូញត្អែរថា កាលដែលព្រះថេរៈទទួលបាត្រចីវររបស់ព្រះសាស្តា ក៏ហាក់បីដូចជាព្រះសាស្តាទ្រង់គង់ព្រះជន្មនៅឡើយ ឥឡូវនេះ ព្រះសាស្តារបស់យើងមួយអង្គទៀត បានបរិនិព្វានទៅទៀតហើយ ។

ព្រោះថា ព្រះអានន្ទត្ថេរ ត្រូវព្រះបរមសាស្តា ទ្រង់លើកតម្កើងឲ្យប្រសើរជាងភិក្ខុដែលជាសាវ័ករបស់ព្រះអង្គមាន ៥ ប្រការ ថា :

**ឯទតគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ យទិទំ អានន្ទោ ។ សតិមន្តានំ យទិទំ អានន្ទោ ។ គតិមន្តានំ យទិទំ អានន្ទោ ។ ធិតិមន្តានំ យទិទំ អានន្ទោ ។ ឧបដ្ឋាកានំ យទិទំ អានន្ទោ** ម្នាលភិក្ខុទាំងឡាយ អានន្ទជាអ្នកប្រសើរជាងភិក្ខុ ដែលជាសាវ័ករបស់តថាគត ១ ផ្នែកខាងជាពហុសូត ២ ផ្នែកខាងមានសតិ ៣ ផ្នែកខាងមានគតិ ៤ ផ្នែកខាងមានធិតិ និង ៥ ផ្នែកខាងជាអ្នកឧបដ្ឋាក ។

## ពណ៌នាបន្ថែមសេចក្ដីទាក់ទងនឹងព្រះអានន្ទត្ថេរ

១ ព្រះអានន្ទ ជាព្រះអនុជរបស់ព្រះមានព្រះភាគជាម្ចាស់ ។

២/១- ផ្នែកខាងជាពហូសូតនោះ ពីព្រោះលោកបានរៀនព្រះពុទ្ធ-វចនៈពីព្រះសាស្ដា និងភិក្ខុដទៃៗ ទៀតជាច្រើន ថែមទាំងព្រះអានន្ទនេះជាឃ្លាំងធម៌ទៀតផង និងឲ្យឃើញបានថា ការជ្រើសរើសអំពីសម្មាក់សង្ឃ ឲ្យព្រះអានន្ទវិសជ្ជនាព្រះសូត្រ និងព្រះអភិធម្ម ក្នុងការសង្គាយនាលើកទី ១ ដែលមានព្រះមហាកស្សបៈជាប្រធាន ។

២/២- ផ្នែកខាងមានសតិនោះ ពីព្រោះការរៀនសូធ្យនូវព្រះពុទ្ធវចនៈសតិរបស់លោកមានការទ្រទ្រង់ចាំទុក មានកម្លាំងខ្លាំងជាងភិក្ខុដទៃ ។

២/៣- ផ្នែកខាងមានគតិ ពីព្រោះលោកបានឮពាក្យតែមួយបទ ក៏អាចយល់សេចក្ដីបានដល់ ៦ ម៉ឺនបទ ។

២/៤-ផ្នែកខាងមានធិតិ ពីព្រោះលោកមានការព្យាយាមរៀនសូធ្យទន្ទេញ ទ្រទ្រង់ចាំទុក និងព្យាយាមឧបដ្ឋាកព្រះសាស្ដាទៀតផង ។

២/៥-ផ្នែកខាងជាអ្នកឧបដ្ឋាកនោះ ពីព្រោះលោកជាអ្នកឧបដ្ឋាកដ៏យូរ អាចធ្វើឲ្យព្រះទ័យព្រះសាស្ដាទុកចិត្តបាន និងឲ្យឃើញថា ព្រះអង្គជិតនឹងបរិនិព្វាន ព្រះសម្ពុទ្ធបានសរសើរព្រះអានន្ទថា អានន្ទជាបណ្ឌិតតែងដឹងកាល មុននឹងចូលទៅគាល់តថាគត ដឹងថា នេះជាកាលរបស់ភិក្ខុ នេះជាកាលរបស់ពួកភិក្ខុនី នេះជាកាលរបស់ពួកឧបាសក នេះជាកាល

របស់ពួកឧបាសិកា នេះជាកាលរបស់ពួកព្រះរាជា នេះជាកាលរបស់ពួកអាមាត្យ នេះជាកាលរបស់ពួកអន្យតិរ្ថិយ ។ ថែមទាំងជាអ្នកបានក្រាបទូលសួរដល់វិធីបដិបត្តិក្នុងមាតុគ្រាម និងសរីរៈរបស់ព្រះសាស្តា ក្រោយអំពីបរិនិព្វាន ។ ជាអ្នកក្រាបទូលអង្វរព្រះពុទ្ធជាម្ចាស់ សូមទ្រង់អនុញ្ញាតឲ្យស្ត្រីបួសផង ។ មុននឹងព្រះអង្គបរិនិព្វាន ព្រះសាស្តាត្រាស់លួងលោមព្រះអានន្ទ ថែមទាំងឲ្យកម្លាំងចិត្តទំព្យាយាមថា អានន្ទចូរប្រកបនូវសេចក្តីព្យាយាមចុះ អ្នកនឹងជាអ្នកមិនមាននូវអាសវៈដោយឆាប់ហ័ស ។

៣- ព្រះអានន្ទ ជាអ្នកមានគុណដ៏ច្រើនក្នុងការផ្សព្វផ្សាយព្រះធម៌ ដូចជាសម្តែងធម៌ដល់ព្រះបាទឧទេន និងអគ្គមហេសី បានសម្តែងធម៌ដល់ភិក្ខុនីដែលក្លែងធ្វើជាឈឺ និងឆ្លើយបញ្ហាដល់កោកនុទបរិព្វាជកជាដើម ។

៤- ព្រះអានន្ទសួរព្រះសារីបុត្រថា ដោយហេតុត្រឹមប៉ុនណា ទើបភិក្ខុជាអ្នកពិចារណាឃើញបានដោយឆាប់ហ័ស ក្នុងកុសលធម៌ទាំងឡាយ រៀនបានល្អ រៀនបានច្រើន និងរបស់ដែលខ្លួនរៀនរួចហើយ រមែងមិនជាក់ច្បាស់ ព្រះសារីបុត្រពោលថា ពាក្យរបស់ព្រះអានន្ទជាពហុស្សូតសេចក្តីនេះ ចូរជាក់ច្បាស់ដល់លោកចុះ ។ ព្រះអានន្ទពោលថា នែអាវុសោ បើដូច្នោះ ចូរលោកស្តាប់ដោយយកចិត្តទុកដាក់ចុះ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកឈ្លាសវៃក្នុងអត្ថ ក្នុងធម៌ និងព្យញ្ជនៈ ក្នុងនិរុត្តិ និងឈ្លាសវៃខាងដើម និងខាងចុង ដោយហេតុត្រឹមតែប៉ុណ្ណោះឯង ។ ព្រះ

សារីបុត្រពោលថា នែអាវុសោ គួរឲ្យអស្ចារ្យណាស់ មិនធ្លាប់មានមក ដែលព្រះអានន្ទពោលទុកល្អហើយនេះ ទាំងពួកយើងក៏ទ្រទ្រង់ចាំថាព្រះអានន្ទ ជាអ្នកប្រកបដោយធម៌ ៥ ប្រការ គឺជាអ្នកឈ្លាសវៃក្នុងអត្ថ ក្នុងធម៌ ក្នុងព្យញ្ជនៈ ក្នុងនិរុត្តិ ទាំងឈ្លាសវៃក្នុងខាងដើម និងខាងចុង ។

៥- គ្រាមួយ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងធម៌ដល់ភិក្ខុដោយសង្ខេប ភិក្ខុទាំងឡាយចង់បានពិស្តារ ក៏នាំគ្នាទៅសួរព្រះអានន្ទ លោកក៏អធិប្បាយឲ្យភិក្ខុទាំងឡាយយល់ចូលចិត្តដោយពិស្តារ ក្រោយមកភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ល្អហើយៗ ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ជាអ្នកមានបញ្ញាច្រើន ប្រសិនបើអ្នកទាំងឡាយចូលទៅរកតថាគត ហើយសួរនូវសេចក្តីនោះ តថាគតផ្ទាល់ក៏អធិប្បាយសេចក្តីនោះ ដូចព្រះអានន្ទដែរ ។

៦- ក្នុងគ្រាដែលព្រះទេវទត្តធ្វើសង្ឃភេទ ទេវទត្តបានប្រាប់ដល់អានន្ទថា នែអាវុសោអានន្ទ ឥឡូវនេះ ខ្ញុំនឹងធ្វើឧបោសថ និងសង្ឃកម្មបែកពីព្រះមានព្រះភាគ និងភិក្ខុសង្ឃតាំងអំពីថ្ងៃនេះតទៅ អានន្ទក៏ចូលគាល់ព្រះសាស្តា ក្រាបទូលឲ្យទ្រង់ជ្រាបសេចក្តីនោះ ព្រះមានព្រះភាគទ្រង់បន្លឺឧទានថា សេចក្តីល្អមនុស្សល្អធ្វើបានដោយងាយ សេចក្តីល្អមនុស្សអាក្រក់ធ្វើបានដោយលំបាក មនុស្សអាក្រក់ធ្វើអាក្រក់បានដោយងាយ អំពើអាក្រក់ ព្រះអរិយៈជាម្ចាស់ទាំងឡាយធ្វើបានដោយកម្រ ។

៧- ព្រះអានន្ទពោលដោយការបដិបត្តិធម៌ ការរៀនសូត្របង់ចាំ ការឧបដ្ឋាក និងការសម្រេចព្រះអរហត្តទុកថា បណ្ឌិតមិនគួរធ្វើខ្លួនឲ្យជាមិត្តនឹងមនុស្សដែលចូលចិត្តញុះញង់ ចូលចិត្តក្រោធ កំណាញ់ និងជាអ្នកប្រាថ្នាឲ្យអ្នកដទៃវិនាស ព្រោះការសមាគមនឹងមនុស្សអាក្រក់ ជាអំពើលាមក តែបណ្ឌិតគួរធ្វើខ្លួនឲ្យជាមិត្តសម្លាញ់នឹងមនុស្សដែលមានសទ្ធា មានសីលជាទីស្រឡាញ់ មានបញ្ញា និងជាអ្នកបានស្តាប់ បានរៀនសូត្រច្រើន ព្រោះការសមាគមនឹងមនុស្សល្អ រមែងមានតែសេចក្តីចម្រើន ។ ព្រះអានន្ទត្ថេរ បានរៀនសូត្រធម៌ពីព្រះពុទ្ធផ្ទាល់ បាន ៨២.០០០ ព្រះធម្មក្ខន្ធ បានរៀនអំពីសម្នាក់ភិក្ខុ មានព្រះសារីបុត្រជាដើមបាន ២.០០០ ព្រះធម្មក្ខន្ធ រួមទៅជា ៨៤.០០០ ព្រះធម្មក្ខន្ធ ដែលលោកចាំរត់មាត់ ។

អាត្មាអញបានឧបដ្ឋាកព្រះមានព្រះភាគជាម្ចាស់ ដោយមេត្តាកាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្ម ដូចស្រមោលជាប់តាមព្រះកាយព្រះអង្គរហូត ២៥ ឆ្នាំ ។ កាលព្រះអង្គពុទ្ធដំណើរទៅ អាត្មាអញក៏បានដើរតាមក្រោយព្រះអង្គ កាលព្រះអង្គសម្តែងធម៌ ញាណក៏កើតឡើងដល់អាត្មាអញ ជាអ្នកមានកិច្ចត្រូវធ្វើ ជាព្រះសេក្ខៈ មិនទាន់សម្រេចអរហត្ត ។

ព្រះសាស្តាអង្គណា ទ្រង់អនុគ្រោះយើង ព្រះសាស្តាអង្គនោះស្តេចបរិនិព្វានទៅមុនហើយ ។ កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ដល់នូវភាពប្រសើរដោយអាការទាំងពួង ស្តេចបរិនិព្វានហើយ លំដាប់នោះ

ឯង យើងស្ងុតចិត្ត ព្រឺរោមយ៉ាងខ្លាំង ។

យើងមានការស្និទ្ធស្នាលនឹងព្រះសាស្ដា យើងបានធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គរួចស្រេចហើយ មានការៈធ្ងន់ដាក់ចុះហើយ ដកចេញនូវតណ្ហា ដែលជាគ្រឿងនាំទៅកាន់ភពបានហើយ ៕៚

***( ជីវប្រវត្តិរបស់ព្រះអានន្ទត្ថេរ ចប់ )***

# ជីវប្រវត្តិរបស់ព្រះវក្កលិត្ថេរ

**" ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកមានសទ្ធាស៊ប់ "**

*ព្រះមានព្រះភាគ ទ្រង់ប្រារព្ធព្រះវក្កលិត្ថេរ ដែលជាមហាសាវ័កមួយរូប ពីព្រោះលោកធ្លាប់ស្រវឹងនៅក្នុងរូបរបស់ព្រះអង្គ នាកាលដែលទ្រង់គង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ដែលជាវត្តដំបូងក្នុងព្រះពុទ្ធសាសនាកសាងថ្វាយដោយព្រះបាទពិម្ពិសារ ។*

*ជីវប្រវត្តិរបស់ព្រះវក្កលិត្ថេរ ដូចមានសម្ដែងប្រាកដនៅក្នុង **គម្ពីរអដ្ឋកថាមនោរថបូរណី** និង **អដ្ឋកថាធម្មបទ** នៃ **ភិក្ខុវគ្គ** ក្នុងរឿងវក្កលិត្ថេរ ដូចមានសេចក្ដីថា ៖*

*ព្រះវក្កលិត្ថេរ កើតនៅក្នុងត្រកូលព្រាហ្មណ៍ នាក្រុងសាវត្ថី កាលលោកចម្រើនវ័យធំឡើង សមគួរដល់ការសិក្សាចំណេះវិជ្ជា ក៏បានទៅរៀនសូធ្យវិជ្ជាត្រៃវេទក្នុងលទ្ធិព្រាហ្មណ៍ ដែលជាការសិក្សាតាមវង្សនៃបុព្វបុរសរបស់លោក ។ ថ្ងៃមួយ វក្កលិបានក្រឡេកឃើញព្រះសម្ពុទ្ធស្ដេចយាងទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ព្រមទាំងភិក្ខុសង្ឃជាបរិវារ ។ កាលបើគេបានក្រឡេកឃើញ ព្រះវរកាយដែលប្រកបដោយមហាបុរិសលក្ខណៈរបស់ព្រះសាស្ដាហើយ ក៏កើតការពេញចិត្តយ៉ាងក្រៃលែង រហូតមិនអាចទឹងហាមនូវការពេញចិត្ត ដែលកើតឡើងហើយនោះបានឡើយ ។*

ប្រសិនបើនឹងប្រៀបធៀប ក៏ស្រដៀងគ្នានឹងកំលោះដែលវង្វេងស្រឡាញ់ក្នុងភាពល្អស្អាតរបស់ស្រីក្រមុំ ឬស្រីក្រមុំដែលវង្វេងស្រឡាញ់ក្នុងភាពស្អាតរបស់កំលោះ ម្នាក់ៗមានតែទុក្ខព្រួយអន្ទះអន្ទែងតាមផ្លូវចិត្តប៉ុណ្ណោះ ចង់ឃើញចង់ជួបគ្នាជានិច្ច ប្រសិនបើថ្ងៃណាមិនបានឃើញ មិនបានជួបមុខគ្នាទេនោះ ក៏នឹងកើតទុក្ខលំបាកតាមផ្លូវចិត្ត ។ វក្កលិជាប់ជំពាក់ក្នុងរូបសម្បត្តិរបស់ព្រះសក្យមុនី មានការដើរតាមសម្លឹងមើលព្រះអង្គ រហូតទៅដល់វិហារ ។

កាលបើវក្កលិទៅដល់វិហារហើយ បានឈរសម្លឹងមើលព្រះអង្គទ្រង់សម្តែងធម៌ ពេលនោះ ក៏បានកើតសទ្ធាជ្រះថ្លា ទើបគិតថា ប្រសិនបើយើងនៅជាឃរាវាស ប្រាកដជាគ្មានឱកាសបានឃើញព្រះបរមសាស្តាជានិច្ចទេ ។ មិនថាតែវក្កលិទេ សូម្បីអ្នកដទៃទៀតក៏មិនឆ្អែតដោយការមើលសិរីសម្បត្តិរបស់ព្រះសម្ពុទ្ធជាម្ចាស់ដែរ ដូច្នេះហើយ ទើបសម្រេចចិត្តលះបង់កិច្ចការរបស់ឃរាវាស ចេញចាកផ្ទះចូលបួសក្នុងសម្នាក់ព្រះអង្គដោយសង្ឃឹមថា នឹងបានឃើញព្រះមានព្រះភាគជានិច្ចកាល ។ ចាប់តាំងពីព្រះវក្កលិបព្វជ្ជាមក លោកមិនបានធ្វើសមណធម៌ មានស្វាធ្យាយ និងមនសិការៈ គឺការតម្កល់ចិត្តក្នុងព្រះកម្មដ្ឋានជាដើម ។ លោករង់ចាំតែទៅសម្លឹងមើលព្រះមានព្រះភាគគ្រប់ខណៈ សូម្បីពេលឈរ ក៏ត្រូវឈរក្នុងទីណាដែលអាចសម្លឹងឃើញព្រះភគវាបាន វៀរតែពេលឆាន់អាហារប៉ុណ្ណោះ

ព្រះទសពលជាម្ចាស់ ទ្រង់ជ្រាបអំពើរបស់ព្រះវក្កលិគ្រប់ប្រការ តែព្រះអង្គមិនទាន់បានត្រាស់ពាក្យណាមួយនឹងព្រះវក្កលិឡើយ ព្រោះទ្រង់រង់ចាំឲ្យញាណ គឺបញ្ញាត្រាស់ដឹងធម៌របស់លោកចាស់ក្លាសិន ទើបទ្រង់បណ្តោយឲ្យព្រះវក្កលិតាមមើលព្រះវរកាយរបស់ព្រះអង្គ រហូតអស់កាលដ៏យូរ ។ ព្រះភគវា កាលទ្រង់ជ្រាបថា ញាណរបស់ព្រះវក្កលិចាស់ក្លាអាចត្រាស់ដឹងធម៌បានហើយ ទើបត្រាស់ណែនាំអប់រំថា :

ម្នាលវក្កលិ ប្រយោជន៍អ្វីនឹងមានដល់អ្នក ព្រោះការតាមមើលរាងកាយដែលស្អុយនេះ វក្កលិ អ្នកណាឃើញធម៌ អ្នកនោះឈ្មោះថាឃើញតថាគត អ្នកមិនឃើញធម៌ សូម្បីនឹងឃើញរូបកាយរបស់តថាគតក៏ឈ្មោះថាមិនឃើញតថាគតដែរ ។ សូម្បីព្រះវិជិតមារ ទ្រង់ណែនាំយ៉ាងនេះហើយ ព្រះវក្កលិក៏នៅតែមិនអាចដើម្បីលះបង់ការតាមមើលព្រះអង្គបាន ។ ព្រះលោកនាថ ទ្រង់ព្រះតម្រិះថា ប្រសិនបើភិក្ខុនេះមិនកើតការស្លុតចិត្ត ប្រាកដជានឹងមិនបានត្រាស់ដឹងធម៌វិសេសឡើយ ។ ពេលជិតនឹងដល់ថ្ងៃចូលវស្សា ព្រះសាស្តា ស្តេចយាងទៅកាន់នគររាជគ្រឹះ ក្នុងថ្ងៃចូលវស្សា ទ្រង់បានបណ្តេញព្រះវក្កលិដោយពុទ្ធតម្រាស់ថា នែវក្កលិអ្នកចូរចេញទៅឲ្យផុតពីសម្នាក់តថាគត ។ ធម្មតាព្រះពុទ្ធជាម្ចាស់ មានព្រះវាចាពិតប្រាកដ ដែលបុគ្គលព្រមជឿ ព្រោះដូច្នោះ ព្រះវក្កលិបានស្តាប់ព្រះលោកនាយកទ្រង់បណ្តេញឲ្យចេញហើយ ទើបមិនអាចរែងទទឹង

នឹងព្រះអង្គបាន ក៏កើតការខូចចិត្តថា បើយើងមិនអាចនៅក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្តាបាន ព្រោះព្រះអង្គទ្រង់បណ្តេញយើងដូច្នេះ ជីវិតយើងមានប្រយោជន៍អ្វីទៅ យើងនឹងទៅលោតពីលើភ្នំឲ្យស្លាប់ល្អជាង ។ ព្រះវក្កលិគិតដូច្នេះហើយ បានឡើងទៅលើភ្នំគិជ្ឈកូដ ប្រាថ្នានឹងលោតចុះទៅក្នុងជ្រោះ ដើម្បីឲ្យស្លាប់ចាកលោកនេះទៅ ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់ជ្រាបចិត្តទន់ខ្សោយរបស់ព្រះវក្កលិហើយ ទ្រង់ព្រះតម្រិះថា ភិក្ខុនេះ បើមិនបានការលួងលោមពីតថាគតទេ មុខជាទម្លាយឧបនិស្ស័យនៃមគ្គ និងផលឲ្យវិនាសទៅ ដូច្នេះហើយ ទើបទ្រង់បញ្ចេញព្រះរស្មីទៅ ដើម្បីបង្ហាញព្រះអង្គឲ្យព្រះវក្កលិឃើញ ។ចាប់ផ្តើមពីព្រះវក្កលិឃើញព្រះមានព្រះភាគជាថ្មីមក លោកអាចដកកូនសរ គឺការសោកសៅតូចចិត្ត ដែលមាននៅច្រើនសន្ធឹកសន្ធាប់នោះ ឲ្យស្ងប់បាន ។ ព្រះមានបុណ្យជាម្ចាស់ មានព្រះបំណងនឹងជួយព្រះវក្កលិឲ្យមានបីតិ និងបាមោជ្ជដ៏ខ្លាំងក្លា បីដូចបុគ្គលដែលជងទឹកមកចាក់ក្នុងស្រះដែលស្ងួត ទើបត្រាស់ព្រះគាថានេះថា :

**បាមោជ្ជពហុលោ ភិក្ខុ　　បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ　　សង្ខារូបសមំ សុខំ ។**

ភិក្ខុដែលច្រើនដោយបាមោជ្ជ ជ្រះថ្លាហើយក្នុងព្រះពុទ្ធសាសនា គប្បីសម្រេចសន្តិបទ ( ព្រះនិព្វាន ) ជាសុខ ព្រោះជាទីស្ងប់ចាកសង្ខារ ។

កាលដែលព្រះមានព្រះភាគ ត្រាស់ព្រះគាថានេះហើយ ទ្រង់លាត ព្រះហស្តចេញព្រមជាមួយនឹងការត្រាស់ថា មកវក្កលិ អ្នកកុំខ្លាចឡើយ ចូរក្រឡេកមើលតថាគតៗ នឹងលើកអ្នកឡើង ដូចបុគ្គលអ្នកជួយដំរីដែល លិចនៅក្នុងភក់ឡើងមកបានដូច្នេះដែរ មកវក្កលិ អ្នកកុំខ្លាចឡើយ ចូរ ក្រឡេកមើលតថាគតៗ នឹងលើកអ្នកឡើង ដូចបុគ្គលអ្នកជួយព្រះច័ន្ទ ដែលត្រូវរាហូចាប់ដូច្នោះដែរ ។

ព្រះវក្កលិ កើតបីតិយ៉ាងខ្លាំងក្លា ហើយគិតថា យើងបានឃើញ ព្រះសាស្តាហើយ ទាំងព្រះអង្គក៏ហៅយើងថាមកវក្កលិ ទើបធ្វើឲ្យលោក ភ្លេចផ្លូវដែលមកថាមកពីណា ហើយគប្បីទៅតាមផ្លូវណា ។ កាលលោក មិនឃើញផ្លូវដែលត្រូវទៅ ក៏ហោះឡើងទៅឰដ៏អាកាស ឆ្ពោះទៅកាន់ទី ចំពោះព្រះភក្ត្រព្រះបរមគ្រូ ខណៈដែលជើងម្ខាងជាន់នៅលើភ្នំនោះ ចិត្តក៏ នឹកភ្លាមដល់ព្រះគាថា ដែលព្រះអង្គបានត្រាស់សម្តែងរួចហើយ បានសង្កត់ បីតិក្នុងអាកាសនោះឯង ក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ៤ ហើយលើកដៃប្រណម្យថ្វាយបង្គំព្រះបរមសាស្តា ក្នុងពេលដែលចុះ ចាកអាកាសមកឈរក្នុងសម្នាក់ព្រះអង្គហើយ ។

ភាពជាអ្នកប្រសើរដោយសទ្ធាវិមុត្តិ ក្នុងព្រះពុទ្ធសាសនា ដែល ព្រះវក្កលិត្ថេរបានទទួលការលើកតម្កើងកិត្តិយសដ៏ខ្ពង់ខ្ពស់ រាប់ថា មាន លោកមួយក្នុងបណ្តាព្រះមហាសាវកទាំងអស់ មានសេចក្តីប្រាកដក្នុង

**គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖

លុះក្រោយមក ព្រះមានព្រះភាគជាម្ចាស់ ប្រជាប់នៅកណ្តាលពួកអរិយសង្ឃ ទ្រង់តែងតាំងព្រះវក្កលិត្ថេរទុកក្នុងតំណែងជាឯតទគ្គៈ ដូចមានបាលីថា **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សទ្ធាធិមុត្តានំ យទិទំ វក្កលិ** ម្នាលភិក្ខុទាំងឡាយ វក្កលិ ប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងសទ្ធាវិមុត្តិ ( ពីព្រោះលោករួចផុតស្រឡះចាកកិលេសដោយសទ្ធា ) ។

ចំណែកជីវប្រវត្តិអតីតជាតិរបស់ព្រះវក្កលិត្ថេរ ដែលជាមូលដ្ឋានជួយឲ្យលោកបានជួបប្រសព្វ ជាមួយនឹងការអស់ទៅនៃភពជាតិកំណើតបានជាព្រះអរហន្ត ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាផ្នែកខាងសទ្ធាវិមុត្តិនោះ ពីព្រោះលោកធ្លាប់បានសន្សំបុណ្យបារមីផ្សេងៗ ជាច្រើនមកហើយ អស់មួយសែនកប្ប ។

រឿងអតីតជាតិរបស់ព្រះវក្កលិត្ថេរ ដែលលោកពោលផ្ទាល់នូវជីវប្រវត្តិរបស់ខ្លួនឯង ក្រោយពីលោកបានសម្រេចមគ្គផលហើយ ដូចមានសម្តែងប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ថា ៖

ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះនាយក ព្រះនាមបទុមុត្តរៈមានព្រះនាមខ្ពង់ខ្ពស់ មានគុណរាប់មិនបាន ត្រាស់ដឹងហើយក្នុងលោក ។ ព្រះអង្គមានអាការ និងព្រះឱស្ឋដូចផ្កាឈូក មានព្រះឆវីវណ្ណល្អមិនមាន

មន្ទិលដូចផ្កាឈូក មិនជាប់ជំពាក់ដោយលោក ដូចផ្កាឈូកមិនប្រឡាក់ដោយទឹក ។ ព្រះអង្គជាអ្នកប្រាជ្ញ មានព្រះនេត្រដូចត្របកឈូក ជាទីត្រេកអរដូចផ្កាឈូក ទ្រង់មានក្លិនវិសេសដូចផ្កាឈូក ព្រោះហេតុនោះឯង ទើបព្រះអង្គព្រះនាមថា **បទុមុត្តរៈ** ។ ព្រះអង្គជាចម្បងក្នុងលោក ទ្រង់មិនមានមានះ មានឧបមាដូចភ្នែកនៃពួកជនខ្វាក់ ទ្រង់មានភេទស្ងប់រំងាប់ ជាកំណប់នៃគុណ ទ្រង់មានករុណាគុណ និងបញ្ញាគុណដូចសាគរ ។ ជួនកាល ព្រះមហាវីរៈនោះ មានពួកព្រហ្ម ទេវតា និងអសុរបូជា ព្រះអង្គឧត្តមជាងពួកជន ក្នុងកណ្តាលប្រជុំជន ដែលកុះករដោយទេវតា និងមនុស្ស ។ ព្រះមហាវីរៈ ទ្រង់ញុំាងបរិស័ទទាំងពួងឲ្យត្រេកអរ ដោយព្រះឱស្ឋមានក្លិនក្រអូបផង ដោយព្រះសូរសៀងដ៏ពីរោះផង ទ្រង់សរសើរសាវ័ករបស់ព្រះអង្គថា សាវ័កនេះ ជាសទ្ធាធិមុត្តិ មានប្រាជ្ញាល្អ មានអាល័យក្នុងការឃើញតថាគត បុគ្គលដទៃបែបនេះ មិនមានដូចវក្កលិភិក្ខុនេះឡើយ ។ កាលនោះខ្ញុំកើតជាកូនរបស់ព្រាហ្មណ៍ នៅក្នុងក្រុងហង្សវតី លុះបានស្តាប់ព្រះពុទ្ធដីកានោះហើយ ក៏ប្រាថ្នានូវតំណែងនោះ ។ កាលនោះ ខ្ញុំនិមន្តព្រះតថាគត ទ្រង់មិនមានមន្ទិលនោះ ព្រមទាំងសាវ័កឲ្យគង់ឆាន់អស់ ៧ ថ្ងៃ ក្រោមបាំងសំពត់ ។ ខ្ញុំក្រាបចុះដោយសិរសា មុជចុះក្នុងសាគរ គឺអនន្តគុណរបស់ព្រះអង្គ មានបីតិពេញលេញ ទើបពោលពាក្យនេះថា បពិត្រព្រះមហាមុនី ឥសី គឺភិក្ខុអង្គណា ជាសទ្ធាធិមុត្តិក្នុង

សាសនានេះ ដែលព្រះអង្គសរសើរហើយថា ជាចម្បងជាងពួកភិក្ខុអ្នកមានសទ្ធា ខ្ញុំព្រះអង្គសូមបានដូចភិក្ខុនោះ ក្នុងកាលអនាគត ។ លុះខ្ញុំពោលយ៉ាងនេះហើយ ទើបព្រះមហាមុនី ទ្រង់មានព្យាយាមធំ មានការឃើញមិនកំបាំង ទ្រង់បន្លឺឡើងនូវព្រះពុទ្ធដីកានេះ ក្នុងកណ្តាលបរិស័ទ ។

អ្នកទាំងឡាយ ចូរមើលមាណពនេះ ដែលស្លៀកសំពត់សាច់ម៉ដ្ឋ មានសម្បុរលឿង ជាអ្នកមានអវយវៈដូចគ្រឿងបូជា ដែលបិទដោយមាស ជាទីត្រូវភ្នែកត្រូវចិត្តរបស់ជន ។ មាណពនេះ នឹងបានជាសាវ័ករបស់ព្រះគោតមមហេសី ប្រសើរលើសជាងពួកភិក្ខុ ដែលជាសទ្ធាធិមុត្តិក្នុងកាលជាអនាគត ។ មាណពនេះ ទោះកើតជាទេវតា ឬជាមនុស្សជាអ្នកវៀរចាកសេចក្តីក្តៅក្រហាយទាំងពួង បរិបូណ៌ដោយភោគៈទាំងពួង ជាអ្នកអន្ទោលទៅទាំងដែលមានសេចក្តីសុខ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលឱក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ មាណពនេះ នឹងបានជាធម្មទាយាទរបស់ព្រះអង្គ ជាឱរស ជាធម្មនិម្មិត មាននាមថាវក្កលិ ជាសាវ័ករបស់ព្រះភគវា ។

ខ្ញុំលះរាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតនៅនាឋានតាវត្តិង្ស ដោយសេសនៃកម្មនោះឯង ដោយការតាំងទុកនូវចេតនានោះផង ។ ខ្ញុំអន្ទោលទៅក្នុងភពតូចភពធំ ជាអ្នកមានសេចក្តីសុខក្នុងភពទាំងពួង ខ្ញុំមកកើតក្នុងត្រកូលមួយ ក្នុងក្រុងសាវត្ថី ។ មាតាមានភ័យអំពី

បិសាច បៀតបៀននូវខ្ញុំដែលនៅក្មេងខ្ចីដូចទឹកដោះខាប់ កំពុងនៅដេកផ្ងារ នៅក្មេងខ្ចីដូចត្រួយឈើ ។ មាតាផ្ដេកខ្ញុំទៀបបាទមូលរបស់ព្រះមហេសី លុះគាត់មានចិត្តចង់ថ្វាយ ( ទើបពោលថា ) បពិត្រព្រះលោកនាថ ខ្ញុំព្រះអង្គថ្វាយទារកនេះចំពោះព្រះសម្ពុទ្ធ បពិត្រព្រះនាយក ខ្ញុំព្រះអង្គសូមដល់នូវព្រះភគវា ជាទីពឹងទីរឭក ។ គ្រានោះ ព្រះមហាមុនី ដែលជាទីពឹងនៃពួកសត្វអ្នកខ្លាច ទ្រង់ទទួលនូវខ្ញុំដោយព្រះហស្តដ៏ទន់ដូចផ្កា មានក្រឡាប្រទាក់ដូចសំណាញ់ មានជួរស្នាមវិលវង់ដូចចក្រ ។

ចាប់ដើមតាំងពីកាលនោះ ខ្ញុំបានព្រះសម្ពុទ្ធរក្សាហើយ ដោយអំពើមិនគួរគេរក្សាបាន ខ្ញុំរួចស្រឡះចាកព្យាធិទាំងពួង ចម្រើនដោយសេចក្ដីសុខ ។ បើខ្ញុំវៀរចាកព្រះសុគតហើយ ក៏កើតអផ្សុកមួយរំពេច លុះខ្ញុំអាយុ ៧ ឆ្នាំ រាប់អំពីកំណើត ក៏បានចូលទៅកាន់ផ្នួស ។ ខ្ញុំមិនឆ្អែតចិត្តនឹងព្រះសុគត ទ្រង់ពេញលេញដោយបារមីទាំងពួង មានព្រះនេត្រខៀវស្រស់ មានព្រះរូបល្អពេញដោយរបស់ស្អាតទាំងអស់ ។ កាលនោះ ព្រះជិនស្រីទ្រង់ជ្រាបថា ខ្ញុំមានសេចក្ដីត្រេកអរក្នុងរូបរបស់ព្រះពុទ្ធហើយ ក៏ទ្រង់ទូន្មាននូវខ្ញុំថា នែវក្កលិ កុំឡើយ អ្នកត្រេកអរក្នុងរូបដែលជនពាលត្រេកអរហើយ នឹងមានប្រយោជន៍អ្វី ព្រោះថា បុគ្គលណាជាបណ្ឌិត បានឃើញព្រះធម៌ បុគ្គលនោះឈ្មោះថាឃើញតថាគត បុគ្គលណា កាលមិនឃើញព្រះធម៌ សូម្បីឃើញតថាគត បុគ្គលនោះក៏ឈ្មោះថាមិនឃើញដែរ ។

រាងកាយជារបស់មានទោស រកទីបំផុតគ្មាន មានឧបមាដូចដើមឈើមានពិស ជាលំនៅនៃរោគទាំងពួង ជាគំនរនៃកងទុក្ខទាំងអស់ ។ អ្នកគួរនឿយណាយ ចាកកាយនោះ គួរឃើញនូវការកើតឡើង និងការសាបសូន្យនៃខន្ធទាំងឡាយក្នុងរូបចុះ អ្នកនឹងដល់នូវព្រះនិព្វានជាទីបំផុតនៃកិលេសទាំងពួង ដោយសេចក្ដីសុខ ។ លុះព្រះនាយក ទ្រង់ស្វែងរកនូវប្រយោជន៍អង្គនោះ ប្រៀនប្រដៅខ្ញុំយ៉ាងនេះរួចហើយ ខ្ញុំក៏ឡើងភ្នំគិជ្ឈកូដនៅសញ្ចប់សញ្ចឹងត្រង់ច្រកភ្នំ ។ ព្រះជិនស្រីមហាមុនី ទ្រង់ស្ថិតនៅទាជើងភ្នំ ញ៉ាំងខ្ញុំឲ្យត្រេកអរ ទ្រង់ត្រាស់ហៅខ្ញុំថា ម្នាលវក្កលិ ខ្ញុំបានឮព្រះពុទ្ធដីកានោះហើយ ក៏មានចិត្តរីករាយ ។ កាលនោះ ខ្ញុំលោតចូលទៅក្នុងជ្រោះភ្នំ មានជម្រៅច្រើនរយជួរបុរស ក៏ធ្លាក់ទៅដល់ដីដោយស្រួលដោយពុទ្ធានុភាព ។ ព្រះវិជិតមារទ្រង់សម្ដែងធម៌ គឺការកើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយម្ដងទៀត ខ្ញុំបានដឹងនូវធម៌នោះហើយ ក៏បានដល់នូវអរហត្តផល ។

គ្រានោះ ព្រះសម្ពុទ្ធមានប្រាជ្ញាច្រើន ទ្រង់ដល់នូវទីបំផុតនៃចរណៈព្រះអង្គតាំងខ្ញុំជាកំពូលនៃពួកភិក្ខុ ដែលជាសទ្ធាធិមុត្តិ ក្នុងកណ្ដាលបរិស័ទច្រើន ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ

ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានបដិបត្តិហើយ ។

ព្រះវក្កលិត្ថេរ ក្រៅពីបានពោលដល់ជីវប្រវត្តិរបស់លោក ក្នុងរឿងផ្សេងៗ ដូចដែលពោលរួចមកហើយនោះ លោកថែមទាំងបានពោលនូវព្រះគាថា ដែលជាពុទ្ធភាសិត ក្រោយពីលោកបានជាព្រះអរហន្ត មាន ៤ គាថា ដូចមានប្រាកដក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថា ៖

( ព្រះមានព្រះភាគត្រាស់សួរថា ) ម្នាលភិក្ខុ អ្នកត្រូវរោគដែលកើតអំពីខ្យល់គ្របសង្កត់ហើយ នៅក្នុងព្រៃធំ មានគោចរលះបង់ហើយ ( មិនសំបូរបច្ច័យ ) ជាទីសៅហ្មង តើនឹងធ្វើដូចម្តេច ? ព្រះវក្កលិក្រាបបង្គំទូលថា ខ្ញុំព្រះអង្គផ្សាយចិត្តទៅកាន់កាយទាំងមូល ដោយសុខដែលកើតអំពីបីតិដ៏លើសលប់ អត់ទ្រាំនូវបច្ច័យដ៏សៅហ្មង នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គចម្រើនសតិប្បដ្ឋានទាំងឡាយ សម្មប្បធានផង ឥទ្ធិបាទផង ឥន្ទ្រិយផង ពលៈផង ចម្រើនពោជ្ឈង្គផង អដ្ឋង្គិកមគ្គផង នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គឃើញនូវសព្រហ្មចារីបុគ្គលទាំងឡាយ អ្នកមានព្យាយាមតឹងតែងហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានព្យាយាមប្រឹងប្រែង

ដ៏មាំអស់កាលជានិច្ច មានសេចក្ដីព្រមព្រៀងគ្នា ប្រកបដោយភាពជាសមណៈ នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គនឹករឿយៗ នូវព្រះសម្ពុទ្ធ ព្រះអង្គមានខ្លួនទូន្មានបានហើយ មានព្រះទ័យតាំងមាំហើយ មិនខ្ជិលច្រអូសអស់ថ្ងៃ និងយប់ នៅក្នុងព្រៃធំ ។

ថេរវាចា ដែលព្រះវក្កលិនាំមកពោលទាំងនេះ ជាព្រះពុទ្ធដីការបស់ព្រះបរមសាស្ដា ដែលត្រាស់សួរដល់ព្រះវក្កលិត្ថេរ ចំណែកពាក្យខាងក្រោមតមក ជាថេរដីការបស់ព្រះវក្កលិ ។ ចំពោះព្រះពុទ្ធដីកាដែលព្រះមានបុណ្យត្រាស់ថា បុគ្គលណាឃើញព្រះសទ្ធម្ម ( ឃើញធម៌របស់សប្បុរស ) បុគ្គលនោះឈ្មោះថាឃើញតថាគត បុគ្គលមិនឃើញព្រះសទ្ធម្មសូម្បីនឹងឃើញតថាគត ក៏ឈ្មោះថាមិនឃើញដែរ មានពាក្យអធិប្បាយថា ព្រះសទ្ធម្ម បានដល់ មគ្គ ផល និព្វាន និងបានដល់ត្រៃលក្ខណ៍ គឺ **អនិច្ចំ ទុក្ខំ អនត្តា** ។ បុគ្គលណាបានឃើញ អនិច្ចំ ទុក្ខំ អនត្តា សូម្បីបុគ្គលនោះនៅមិនទាន់បានឃើញ មគ្គ ផល និព្វាន ក៏នៅតែរាប់ថា បានឃើញព្រះសទ្ធម្ម ចំណែកបុគ្គលដែលបានឃើញ មគ្គ ផល និព្វាននោះ ចាត់ថា បានឃើញព្រះសទ្ធម្មយ៉ាងជាក់ច្បាស់ ។ កាលបានឃើញព្រះសទ្ធម្ម ក៏ស្មើគ្នាបានឃើញព្រះពុទ្ធ ព្រោះឃើញធម៌ ដែលព្រះពុទ្ធទ្រង់ឃើញហើយ ។

ហេតុផលទាំងនេះ ល្មមប្រៀបធៀបគ្នា នឹងពាក្យនិយាយគ្នាថា

យើងស្គាល់មនុស្សនេះ មនុស្សនោះល្អ ជានិទស្សនឧទាហរណ៍ ។ ពាក្យថា យើងស្គាល់មនុស្សនេះ មនុស្សនោះល្អនោះ មិនមែនសំដៅដល់ការស្គាល់ខ្លួន ឬកេរ្តិ៍ឈ្មោះប៉ុណ្ណោះទេ គប្បីស្គាល់ដល់ចិត្តគំនិតរបស់បុគ្គលនោះ ថែមទាំងការប្រព្រឹត្តរបស់អ្នកនោះទៀតផង ទើបចាត់ថា ស្គាល់បុគ្គលនោះល្អ ។

ព្រះវក្កលិត្ថេរ លោកជាព្រះអរហន្តសាវ័កមួយរូប ចាត់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក ៨០ រូប លោកតាំងចិត្តបំពេញបុណ្យបារមីផ្សេងៗ ទុកជាមូលដ្ឋាន ដោយរាប់ប្រមាណមួយសែនកប្បហើយ ក៏បានសម្រេចតាមសេចក្តីប្រាថ្នារបស់លោកទៅ ។ ព្រះវក្កលិត្ថេរ លោកទ្រទ្រង់នូវអាយុសង្ខារមកដល់កាលដ៏សមគួរហើយ ក៏រំលត់ខន្ធបរិនិព្វានទៅហោង ។ល។

*( ជីវប្រវត្តិរបស់ព្រះវក្កលិត្ថេរ ចប់ )*

22 22 t 22 22

# ✍ ជីវប្រវត្តិរបស់ព្រះវង្គីសត្ថេរ ✍

" ដែលជាឯតទគ្គៈផ្នែកខាងមានបដិភាណ "

*ព្រះវង្គីសត្ថេរ លោកជាអ្នកមានបដិភាណ អាចនឹងចងក្រង ពាក្យពោលសរសើរគុណព្រះសក្យមុនី និងមហាសាវកអង្គដទៃទៀតបាន តាមសេចក្តីប្រាថ្នា ទាំងលោកក៏ចាត់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវក ៨០ រូប ថែមទាំងបានទទួលការលើកតម្កើងឲ្យជាឯតទគ្គៈ បាន ដល់ ភាពប្រសើរខ្ពង់ខ្ពស់ ដែលសម្រេចដោយបុញ្ញឫទ្ធិរបស់លោក ។*

*ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះវង្គីសត្ថេរ មានសម្តែងនៅក្នុង* ***អដ្ឋកថាបរមត្ថទីបនី អដ្ឋកថាធម្មបទ*** *នៃ* ***ព្រាហ្មណវគ្គ*** *និងក្នុង* ***គម្ពីរខុទ្ទកនិកាយ សុត្តនិបាត*** *នៃ* ***វង្គីសសូត្រ*** *និង* ***អដ្ឋកថាមនោរថបូរណី*** *ថា ៖*

*ព្រះវង្គីសៈកើតនៅក្នុងត្រកូលព្រាហ្មណ៍ (តែក្នុង****គម្ពីរខុទ្ទកនិកាយ សុត្តនិបាត នៃវង្គីសសូត្រ*** *បានពោលថា ជាបុត្ររបស់បរិព្វាជក និង មាតាជាបរិព្វាជិកា ) នៅក្នុងក្រុងសាវត្ថី ( ក្នុង****អដ្ឋកថាធម្មបទ*** *ពោលថា នៅក្នុងក្រុងរាជគ្រឹះ ) មានឈ្មោះថា វង្គីសៈ ។ មាតាបិតារបស់ព្រះវង្គីសៈ ឈ្មោះអ្វីៗ ក៏មិនបានឃើញពោលទុកទេ ។ កាលបើវង្គីសមាណព ចម្រើនវ័យធំហើយ បានទៅរៀនវិជ្ជាត្រៃវេទក្នុងលទ្ធិរបស់ព្រាហ្មណ៍រហូត ដល់ចេះចប់ ថែមទាំងបានរៀនមន្តពិសេសមួយបែបទៀត ដែលមាន*

ឈ្មោះថា **ឆវសីសមន្ត** ជាមន្តដែលប្រើពិសោធក្បាលរបស់មនុស្សស្លាប់ សូម្បីស្លាប់ទៅហើយ ៣ ឆ្នាំ កាលយកក្រចកគោះលលាដ៍ក្បាល ក៏បានដឹងដល់គតិរបស់សត្វទាំងឡាយថា ស្លាប់ហើយទៅកើតក្នុងទីណា ដូចដឹងថា អ្នកនេះទៅកើតក្នុងនរក អ្នកនេះទៅកើតជាសត្វតិរច្ឆាន អ្នកនេះទៅកើតជាបេតវិស័យ អ្នកនេះទៅកើតជាមនុស្ស អ្នកនេះទៅកើតជាទេវតា ។ វង្គីសមាណពអាស្រ័យឆវសីសមន្តនោះចិញ្ចឹមជីវិត មន្តនេះ ពួកមហាជនបានស្គាល់ក្នុងពេលដែលលោកសម្តែងសិល្បៈនេះ ជាលើកដំបូងឲ្យដល់ពួកមហាជន នៅក្នុងក្រុងសាវត្ថីបានឃើញ ។

គ្រានោះ មានព្រាហ្មណ៍មួយពួកពិចារណាឃើញថា វង្គីសមាណពល្មមជាទីអាស្រ័យចិញ្ចឹមជីវិតរបស់ខ្លួន ឲ្យនៅយ៉ាងសប្បាយបាន ទើបឲ្យវង្គីសមាណពអង្គុយលើពាហនៈដែលមានគ្រឿងបិទបាំង នាំទៅតាមស្រុក និគម ជនបទ រាជធានីផ្សេងៗ និងចូលសម្រាកតាមទ្វារស្រុក ទ្វារក្រុង ដើម្បីប្រកាសឲ្យបុគ្គលទាំងឡាយបានដឹងទូទៅ ។ កាលពួកព្រាហ្មណ៍ទាំងនោះ មើលឃើញមនុស្សទាំងឡាយ មកប្រជុំគ្នាច្រើន ក៏ឃោសនាដើម្បីកសាងជំនឿថា អ្នកណាបានឃើញវង្គីសៈ អ្នកនោះនឹងបានទ្រព្យ បានយស បានទៅកើតស្ថានសួគ៌ ។ មនុស្សជាច្រើននាក់គ្រាន់តែបានស្តាប់ពាក្យឃោសនាដូច្នេះ ម្នាក់ៗ ក៏ប្រាថ្នាចង់ឃើញ ចង់មើល ទើបឲ្យប្រាក់ដល់ពួកព្រាហ្មណ៍ទាំងនោះ ដើម្បីត្រូវការឲ្យជួយបើកគ្រឿង

បិទបាំងចេញ នឹងបានឃើញវង្គីសៈ ហើយនឹងបានទទួលជោគល្អ ដូចពាក្យឃោសនា ។

ព្រះរាជា និងមហាមាត្យទាំងឡាយ ក៏ចាប់អារម្មណ៍ចូលទៅសួរពួកព្រាហ្មណ៍ទាំងនោះថា អាចារ្យរបស់ពួកលោក មានការដឹងពិសេសក្នុងវិជ្ជាអ្វី ? ពួកព្រាហ្មណ៍ពិចារណាឃើញថា នេះជាឱកាសដើម្បីនឹងឃោសនាគុណវិសេសរបស់វង្គីសមាណព ទើបឆ្លើយថា នែលោកដ៏ចម្រើនទាំងឡាយ ពួកលោកមិនជ្រាបទេឬ អ្នកដទៃដែលឈ្មោះថា ជាបណ្ឌិត ដូចអាចារ្យរបស់ពួកខ្ញុំ មិនឃើញមាននៅក្នុងជម្ពូទ្វីបនេះទេ វិជ្ជាវិសេសរបស់អាចារ្យពួកខ្ញុំមាន សូម្បីបុគ្គលដែលស្លាប់ទៅហើយរហូតដល់ ៣ ឆ្នាំ លោកអាចារ្យរបស់ពួកខ្ញុំ គ្រាន់តែប្រើក្រចកគោះត្រង់លលាដ៍ក្បាលប៉ុណ្ណោះ ក៏អាចដឹងថា ទៅកើតក្នុងទីណា ។ ក្នុងគ្រានោះវង្គីសមាណពចង់ដើម្បីកាត់សេចក្ដីសង្ស័យរបស់ពួកមហាជន ទើបគោះលលាដ៍ក្បាលរបស់មនុស្សដែលស្លាប់ទៅ ហើយប្រាប់ទីកើតរបស់ខ្លួនឲ្យមហាជនមានជំនឿក្នុងមន្តរបស់ខ្លួនយ៉ាងជាប់ចិត្ត ។ ប្រជាជន ពួកខ្លះត្រូវការសួរដល់ទីកើតនៃញាតិរបស់ខ្លួន ទើបឲ្យទ្រព្យតាមឋានៈរបស់ខ្លួនម្នាក់ៗ អ្នកខ្លះឲ្យ ១០ កហាបណៈ ខ្លះ ២០ កហាបណៈ ខ្លះ ១០០ កហាបណៈ ខ្លះឲ្យដល់ ១០០០ កហាបណៈក៏មាន ហើយបានទទួលការឆ្លើយប្រាប់យ៉ាងគាប់ចិត្ត ។

ចំណែកពួកព្រាហ្មណ៍ ដែលអាស្រ័យនៅជាមួយវង្គីសមាណព បាននាំវង្គីសមាណពត្រាច់ធ្វើដំណើរឃើតៗ តាមបំណងរបស់ពួកខ្លួនរហូតដល់ពេលវិលត្រឡប់មកក្រុងសាវត្ថីវិញ ដោយមកសម្រាកនៅទីក្បែរៗវត្តជេតពន ។ ព្រឹកមួយ ពួកព្រាហ្មណ៍ជាបរិវាររបស់វង្គីសមាណព បានក្រឡេកឃើញមហាជនកាន់ផ្កា ទៀន ធូបជាដើម នាំគ្នាសំដៅទៅកាន់វត្តជេតពន ដើម្បីស្តាប់ធម៌ទេសនា ពួកព្រាហ្មណ៍ទាំងនោះមិនដឹង ក៏សួរថា ពួកលោកទាំងឡាយ នាំគ្នាទៅណា ? មហាជនឆ្លើយថា ពួកយើងទៅស្តាប់ធម៌ទេសនានៅជេតវនារាម ។ ពួកព្រាហ្មណ៍ បានពោលជំទាស់ថែមទាំងបានពោលសរសើរគុណសម្បត្តិរបស់វង្គីសព្រាហ្មណ៍ថា នែអ្នកទាំងឡាយដ៏ចម្រើន តើពួកអ្នកទៅទីនោះធ្វើអ្វី ព្រោះថា បុគ្គលឲ្យស្មើគ្នានឹងវង្គីសមាណពរបស់ពួកយើងមិនមានទេ ដោយថា លោកជាអ្នកមានចំណេះចេះដឹងច្រើន ។ មហាជន បានពោលជំទាស់ពាក្យនិយាយរបស់ព្រាហ្មណ៍ទាំងនោះ ហើយក៏បានពោលសរសើរគុណព្រះសម្ពុទ្ធ វង្គីស-មាណពនឹងដឹងអ្វី បុគ្គលដែលមានការដឹង ដូចនឹងព្រះបរមសាស្តារបស់ពួកយើង មិនមានឡើយ ។

ចំណែកព្រាហ្មណ៍ដែលជាបរិវាររបស់វង្គីសៈ ក៏បានពោលអួតអះអាងអាចារ្យរបស់ខ្លួន អ្នកទាំងអស់នោះបានប្រកែកគ្នាមិនចាញ់មិនឈ្នះ ទើបនាំគ្នាទៅកាន់វត្តជេតពន ដើម្បីពិសោធឲ្យដឹងការពិត ។ គ្រានោះ

វង្គីសៈបានស្តាប់ឮពាក្យប្រកែករបស់អ្នកទាំងនោះហើយ កើតការនឹកគិតថា ព្រះសមណគោតមជាបណ្ឌិត យើងគួរនឹងនៅរួមជាមួយពួកព្រាហ្មណ៍ទាំងនេះអស់កាលជានិច្ចឬ ឬថាយើងនឹងគួរទៅរកជួបបណ្ឌិត ហើយក៏សម្រេចចិត្តថា នឹងចូលទៅគាល់ព្រះសម្ពុទ្ធ ទើបប្រាប់ដល់ពួកព្រាហ្មណ៍ទាំងនោះថា នែអ្នកទាំងឡាយ ពួកអ្នកចូរទៅចុះ ខ្ញុំមិនទៅរួមជាមួយនឹងពួកមនុស្សភាគច្រើន ប៉ុន្តែខ្ញុំនឹងចូលទៅមើលព្រះសមណគោតម ដើម្បីពិសោធរកការពិតតែម្នាក់ឯង ។ ពួកព្រាហ្មណ៍ បានពោលហាមឃាត់វង្គីសៈថា នែវង្គីសៈ ពួកខ្ញុំមិនព្រមឲ្យលោកចូលទៅរកព្រះសមណគោតមទេ ព្រោះបុគ្គលណាចូលទៅរកហើយ ព្រះសមណគោតមនោះ តែងតែធ្វើឲ្យបុគ្គលនោះជាប់ចិត្តដោយមាយា គឺការបោកបញ្ឆោត ។ ចំណែកវង្គីសៈ មិនព្រមជឿស្តាប់ពាក្យហាមឃាត់ របស់ពួកព្រាហ្មណ៍ទាំងនោះឡើយ បានចូលទៅគាល់ព្រះវិជិតមារ ហើយបានប្រាស្រ័យចរចាជាមួយព្រះអង្គ រួចហើយក៏អង្គុយចុះក្នុងទីដ៏សមគួរតាមឋានៈរបស់ខ្លួន ។

ព្រះមុនីបានត្រាស់សួរថា នែវង្គីសៈ អ្នកចេះសិល្បវិជ្ជាយ៉ាងណានីមួយដែរឬ ? វង្គីសៈក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គចេះមន្តគោះលលាដ៍ក្បាលមនុស្សដែរ ។ ព្រះអង្គត្រាស់សួរតទៅទៀតថា មន្តនោះអ្នកធ្វើយ៉ាងណាវង្គីសៈ ? វង្គីសៈក្រាបទូលថា ខ្ញុំព្រះអង្គរាយធរសីសមន្ត ហើយប្រើក្រចកគោះលលាដ៍ក្បាលរបស់មនុស្សស្លាប់ សូម្បី

ស្លាប់បីឆ្នាំហើយ ក៏នៅតែអាចដឹងទីកើតរបស់គេបាន ។ ព្រះមុនីត្រាស់ឲ្យគេនាំលលាដ៍ក្បាលមកពីប៉ាឆា ៤ ដែលជាលលាដ៍ក្បាល របស់អ្នកដែលស្លាប់ទៅហើយ តែផ្សេងគ្នាដោយកម្មដែលខ្លួនបានធ្វើទុកហើយ គឺ

**១- លលាដ៍ក្បាលរបស់អ្នកទៅកើតក្នុងនរក ។**

**២- លលាដ៍ក្បាលរបស់អ្នកមកកើតជាមនុស្ស ។**

**៣- លលាដ៍ក្បាលរបស់អ្នកទៅកើតស្ថានសួគ៌ ។**

**៤- លលាដ៍ក្បាលរបស់ព្រះអរហន្ត ។**

ដោយយកលលាដ៍ក្បាលទាំងនោះ មកតាំងរៀបតាមលំដាប់ រួចហើយ ព្រះអង្គត្រាស់ឲ្យវង្គីសមាណពនោះ គោះលលាដ៍ក្បាលទាំងនោះឲ្យមើល ។ វង្គីសៈរាយមន្តគោះក្បាលហើយ ប្រើក្រចកគោះលលាដ៍ក្បាលទី ១ និងក្រាបទូលថា បពិត្រព្រះសមណគោតម **អ្នកនេះទៅកើតក្នុងនរក** ។ ព្រះអង្គត្រាស់ថា ពិតមែនហើយៗ វង្គីសៈ ចូរអ្នកគោះលលាដ៍ក្បាលទី ២ និងទី ៣ ទៀតចុះ ។ វង្គីសៈក៏គោះលលាដ៍ក្បាលទី ២ និងទី ៣ ទៀត រួចហើយ ក៏បានក្រាបទូលព្រះអង្គថា **លលាដ៍ក្បាលទី ២ ទៅកើតជាមនុស្ស ចំណែកលលាដ៍ក្បាលទី ៣ ទៅកើតក្នុងស្ថានសួគ៌** ។ ព្រះសម្ពុទ្ធត្រាស់អះអាងថា ពិតមែនហើយ ចូរអ្នកគោះលលាដ៍ក្បាលទី ៤ ថាគេទៅកើតក្នុងទីណា ? វង្គីសៈ ទើបធ្វើតាមវិធីខាងដើមហើយគោះ**លលាដ៍ក្បាលរបស់ព្រះអរហន្ត ក៏មិនអាចដឹងខាងដើម និង**

ខាងចុងបានឡើយថា គេទៅកើតក្នុងទីណា ព្រោះតែលលាដ៍ក្បាលនេះនៅស្ងៀម ។ ព្រះលោកនាយកត្រាស់សួរឡើងថា ម្នាលវង្គីសៈ អ្នកមិនអាចនឹងដឹងបានមែនឬ ? វង្គីសៈក្រាបទូលថា មិនអាចដឹងទេ តែសូមព្រះអង្គអនុគ្រោះឲ្យដល់ខ្ញុំព្រះអង្គ សាកល្បងម្តងទៀតសិនចុះ កាលបើក្រាបទូលដូច្នេះហើយ ទើបរាយមន្តគោះលលាដ៍ក្បាលនោះម្តងទៀត ក៏នៅតែមិនដឹងអ្នកនេះទៅកើតក្នុងទីណា គេបានធ្វើហើយធ្វើទៀត ក៏នៅតែមិនអាចនឹងដឹងបានឡើយ ។ ព្រោះថា មន្តខាងក្រៅព្រះពុទ្ធសាសនា នឹងនាំមកពិសោធដើម្បីឲ្យដឹងគតិ របស់អ្នកអស់អាសវក្កិលេសបរិនិព្វានទៅហើយ រមែងមិនបានផល ។ ក្នុងខណៈពេលនោះ វង្គីសៈបែកញើសជោកពេញខ្លួន កើតការអៀនខ្មាសជាទីបំផុត បានឈរនៅស្ងៀម ។ ព្រះជិនស្រីទ្រង់ទតឃើញ វង្គីសៈមានអាការលំបាកចិត្ត ទើបត្រាស់សួរថា ម្នាលវង្គីសៈ អ្នកលំបាកចិត្តរឿងអ្វីឬ ? វង្គីសៈក្រាបទូលព្រមចុះចាញ់ទៅតាមសេចក្តីពិតថា ខ្ញុំព្រះអង្គមានការលំបាកចិត្ត ដែលមិនអាចនឹងដឹងដល់ទីទៅកើតនៃម្ចាស់លលាដ៍ក្បាលនេះបាន ។ ព្រះវិជិតមារត្រាស់ថា ម្នាលវង្គីសៈ តថាគតដឹង វង្គីសៈក្រាបទូលសួរថា ព្រះអង្គទ្រង់ដឹងបានដោយសារអ្វី ? ព្រះភគវា ត្រាស់តបថា តថាគតដឹងបានដោយអំណាចកម្លាំងនៃមន្ត ការដឹងនេះមិនមែនជានិស្ស័យរបស់អ្នកដែលអាចដឹងបានទេ តែជានិស្ស័យរបស់តថាគត ផ្សេងដោយឡែក នេះជាលលាដ៍ក្បាលរបស់អ្នកអស់

អាសវក្កិលេសហើយ និងត្រាស់អធិប្បាយតទៅថា :

ព្រៃជាគតិ ( គតិ គឺការដើរ ឬផ្លូវ ) របស់សត្វព្រៃទាំងឡាយ អាកាសជាគតិរបស់សត្វស្លាបទាំងឡាយ ពិភព ( លោក ) ជាគតិរបស់ធម៌ទាំងឡាយ និព្វានជាគតិរបស់ព្រះអរហន្ត ។ វង្គីសៈប្រាថ្នាចង់រៀនមន្តនោះអំពីព្រះមានជោគ ទើបក្រាបទូលសូមបបួលប្តូរមន្តគ្នាថា បពិត្រព្រះគោតម ទ្រង់ប្រសើរក្នុងលោក ការអន់ថយរមែងមិនមានដល់ការប្តូរវិជ្ជាគ្នា ខ្ញុំព្រះអង្គនឹងថ្វាយមន្តរបស់ខ្ញុំដល់ព្រះអង្គ តែសូមព្រះអង្គប្រទានមន្តនេះដល់ខ្ញុំព្រះអង្គវិញ ។ ព្រះមានបុណ្យត្រាស់បដិសេធថា ម្នាលវង្គីសៈ តថាគតមិនប្តូរវិជ្ជា តែតថាគតនឹងឲ្យវិជ្ជារបស់តថាគតដល់អ្នក ។ វង្គីសៈបានក្រាបទូលឡើង ដោយការសប្បាយចិត្តថា ល្អហើយព្រះគោតម សូមព្រះអង្គទ្រង់ប្រទានមន្តនោះ ឲ្យដល់ខ្ញុំព្រះអង្គមកចុះ កាលក្រាបទូលដូច្នេះរួចហើយ អង្គុយប្រណម្យដៃឡើង ដើម្បីត្រៀមទទួលរៀនមន្តអំពីព្រះលោកនាថ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់សួរថា ម្នាលវង្គីសៈ ក្នុងលទ្ធិរបស់អ្នក មិនមានការអប់រំសម្រាប់អ្នកដែលមករៀនមន្តយ៉ាងណាទីមួយជាមុនទេឬ ? វង្គីសៈក្រាបទូលថា មិនមានទេព្រះអង្គ កាលបើអ្នកណាប្រាថ្នាចង់រៀនក៏រៀនចុះ ។ ព្រះភគវាត្រាស់សួរថា អ្នកយល់ថា មន្តរបស់តថាគតមិនមានការអប់រំជាមុន ដូចគ្នានឹងមន្តរបស់ពួកអ្នកដូច្នោះឬ ធម្មតាពួកព្រាហ្មណ៍រមែងមិនឆ្អែតដោយមន្ត ព្រោះដូច្នោះ វង្គីសៈ ទើប

ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើតាមពាក្យដែលព្រះអង្គប្រាប់ ។ ព្រះមានជោគត្រាស់ថា នែវង្គីសៈ តថាគតឲ្យនូវមន្តនេះដល់បុគ្គលអ្នកដែលមានភេទ ជាអ្នកបួសដូចគ្នានឹងតថាគតតែប៉ុណ្ណោះ ។ វង្គីសៈគិតជញ្ជឹងមើលថា យើងធ្វើយ៉ាងណានីមួយក៏ដោយ ឲ្យតែបានមន្តនេះសិនចុះ ហើយទើបត្រឡប់ទៅវិញ គិតដូច្នេះហើយ ទើបប្រាប់ដល់ពួកព្រាហ្មណ៍ដែលមកតាមនៅរង់ចាំថា អ្នកទាំងឡាយ ចូររង់ចាំយើងពីរបីថ្ងៃសិនចុះ យើងនឹងបួសក្នុងសម្នាក់របស់ព្រះសមណគោតម ដើម្បីរៀនមន្ត កាលបើខ្ញុំរៀនមន្តបានហើយ ខ្ញុំនឹងជាអ្នកប្រសើរជាងគេក្នុងជម្ពូទ្វីបនេះ ប្រសិនបើបានសម្រេចដូចសេចក្ដីដែលស្មានទុកនេះ ផលទាំងនេះនឹងមានដល់ពួកលោកផងដែរ ។

កាលបើបានប្រាប់ដល់ពួកព្រាហ្មណ៍ដូច្នេះហើយ ទើបក្រាបទូលសូមបព្វជ្ជាចំពោះព្រះសក្យមុនី ដោយប្រាថ្នាចង់បានមន្តតែប៉ុណ្ណឹងឯង ។ ក្នុងពេលនោះ ព្រះនិគ្រោធកប្បត្ថេរនៅជិតនោះដែរ ព្រះសុគតទើបត្រាស់ថា និគ្រោធកប្បៈ ចូរអ្នកឲ្យវង្គីសៈបព្វជ្ជាចុះ ។ ព្រះនិគ្រោធកប្បត្ថេរទទួលស្ដាប់ព្រះពុទ្ធដីកាហើយ បានចាត់ចែងឲ្យវង្គីសៈបព្វជ្ជាតាមព្រះពុទ្ធបំណាងគ្រប់ប្រការ ។ លុះវង្គីសៈបានឧបសម្បទាហើយ មានឈ្មោះថាព្រះវង្គីសត្ថេរ ព្រះជិនស្រីទ្រង់ប្រទានកម្មដ្ឋាន មានអាការ ៣២ បានដល់សក់ រោម ក្រចក ធ្មេញ ស្បែក ជាដើម ថែមទាំងត្រាស់ឲ្យទន្ទេញ

បរិកម្មនូវមន្ត គឺអាការ ៣២ នេះ ឲ្យឃើញជារបស់មិនស្អាត ។

ក្នុងវគ្គនេះ នឹងសូមនាំរឿងដែលទាក់ទង វាងព្រះវង្គីសត្ថេរជាមួយនឹងព្រះអានន្ទត្ថេរ ដែលមានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលសម្តែងដល់ព្រះវង្គីសៈ ទើបតែបួសបានថ្មីៗ ដូចមានសេចក្តីថា ៖

ថ្ងៃមួយ មានមហាមាត្យម្នាក់ បាននិមន្តព្រះអានន្ទត្ថេរ ជាមួយព្រះវង្គីសត្ថេរទៅឆាន់ក្នុងផ្ទះរបស់ខ្លួន កាលបើព្រះថេរៈទាំងពីររូបបានទៅឆាន់ក្នុងផ្ទះរបស់មហាមាត្យហើយ ក្នុងពេលនោះ មានពួកស្ត្រីប្រដាប់តាក់តែងរាងកាយយ៉ាងល្អស្អាត បានចូលទៅសួរបញ្ហានឹងព្រះអានន្ទត្ថេរ ហើយក៏នាំគ្នាស្តាប់ព្រះធម៌ព្រះអានន្ទត្ថេរ ថែមទាំងអង្គុយជិតព្រះថេរៈទាំងពីររូបនោះទៀត ។ រាគចរិត គឺនិស្ស័យដែលធ្ងន់ក្នុងរាគៈ ( ការត្រេកត្រអាល ) កាលបានឃើញវិសភាគារម្មណ៍ បានដល់អារម្មណ៍ផ្សេងៗ បានកើតឡើងដល់ព្រះវង្គីសត្ថេរ ព្រោះលោកជាអ្នកបួសថ្មី ទើបមិនអាចហាមឃាត់ចិត្តបាន តែលោកជាអ្នកមាននិស្ស័យស្មោះត្រង់ ក៏គិតថា កាលបើតម្រេក គឺសេចក្តីត្រេកត្រអាលនេះចម្រើនឡើងហើយ នឹងទម្លាយនូវប្រយោជន៍ទាំងបច្ចុប្បន្ន និងអនាគតរបស់យើង គិតដូច្នេះហើយ ទើបប្រាប់ដល់ព្រះអានន្ទត្ថេរថា :

ខ្ញុំក្តៅក្រហាយទៅដោយកាមរាគៈ ចិត្តរបស់ខ្ញុំ ត្រូវកាមរាគៈដុតរោល សូមលោកម្ចាស់ប្រាប់នូវធម៌សម្រាប់រំលត់នូវកាមរាគៈនេះ ឲ្យ

ដល់ខ្ញុំព្រះអង្គផងចុះ ។ ព្រះអានន្ទត្ថេរ បានពោលពន្យល់ដោយហេតុផលថា នែអាវុសោ វង្គីសៈ ដោយការយល់ខុស រមែងញ៉ាំងចិត្តរបស់លោកឲ្យក្តៅក្រហាយ ព្រោះដូច្នោះ ចូរលោកលះបង់ការយល់ខុស គឺការយល់ថា ល្អស្អាតនោះចេញ ចូរលោកអប់រំចិត្តឲ្យមានអារម្មណ៍តែមួយ ដែលហៅថា ឯកគ្គតារម្មណ៍ ចូរតាំងសតិឲ្យមាំ ពិចារណារាងកាយ ឲ្យឃើញថា វត្ថុទាំងពួងជារបស់មិនស្អាតមិនល្អ ចូរលោកសម្លឹងមើលដោយប្រការដែលគួរឲ្យនឿយណាយ ចូរលោកចម្រើនអនិមិត្តសមាធិ គឺទឹកដល់វត្ថុដែលមិនមានកិលេសជាគ្រឿងសម្គាល់ ចូរលោកលះបង់កិលេសប្រចាំចិត្ត គឺមានានុស័យ អនុស័យ គឺមានះចេញ កាលបើលោកកម្ចាត់មានះ គឺការប្រកាន់ខ្លួនបានហើយ ចិត្តរបស់អ្នកនឹងស្ងប់ដោយពិត ។

ការជ្រើសមណធម៌របស់ព្រះវង្គីសត្ថេរ រហូតដល់បានសម្រេចមគ្គផលនោះ មានសម្តែងទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **ព្រាហ្មណវគ្គ** និង **អដ្ឋកថាបរមត្ថទីបនី** ដូចមានសេចក្តីថា ៖

ពេលដែលព្រះវង្គីសៈស្វាធ្យាយមន្ត ពួកព្រាហ្មណ៍ដែលជាបរិវាររបស់លោក បាននាំគ្នាចូលទៅសួរលោកថា លោកអាចារ្យរៀនមន្តបានចប់ហើយឬនៅ ? វង្គីសត្ថេរប្រាប់ពន្យាពេលថា ចូរអ្នកទាំងអស់គ្នារង់ចាំសិនចុះ ។ កន្លងទៅបាន ២-៣ ថ្ងៃប៉ុណ្ណោះ វង្គីសត្ថេរជាអ្នកមានបញ្ញាក្នុងពេលដែលលោកស្វាធ្យាយអាការ ៣២ គឺទន្ទេញត្រឡប់ចុះឡើង ក៏

បានឃើញការអស់ទៅ ការវិនាសទៅនៃអាការ ៣២ ទាំងនោះ និងតាំងចិត្តបំពេញវិបស្សនា គឺធ្វើការយល់ច្បាស់ ឲ្យចម្រើនឡើងជាលំដាប់ ហើយក៏បានសម្រេចជាព្រះអរហន្ត កាត់ផ្តាច់នូវកិលេសជាសមុច្ឆេទប្បហាន បានដល់ការលះកិលេសដាច់ជាសមុច្ឆេទ ។ ក្រោយពីលោកបានសម្រេចជាព្រះអរហន្តហើយ ពួកព្រាហ្មណ៍ដែលនៅរង់ចាំ ទើបនាំគ្នាគិតថា ពួកយើងគួរនឹងទៅស្តាប់ដំណឹងរបស់ព្រះវង្គីសត្ថេរថា បានលទ្ធផលយ៉ាងណាខ្លះ ហើយក៏នាំគ្នាចូលទៅរកព្រះវង្គីសត្ថេរ បានសួរថា លោកអាចារ្យបានរៀនមន្ត ក្នុងសម្នាក់ព្រះគោតមចប់ហើយឬ ? ព្រះវង្គីសត្ថេរតបថា នៃអ្នកទាំងឡាយ ខ្ញុំរៀនមន្តបានចប់ហើយ ពួកព្រាហ្មណ៍ទាំងនោះ ទើបពោលបបួលថា ប្រសិនបើដូច្នោះ លោកមករួមគ្នាជាមួយនឹងពួកយើង ហើយទៅជាមួយគ្នា ។ ព្រះថេរៈពោលបដិសេធថា ចូរអ្នកទាំងអស់គ្នាទៅចុះ ខ្ញុំមិនទៅជាមួយពួកលោកទេ ។ ពួកព្រាហ្មណ៍និយាយថា លោកម្ចាស់វង្គីសៈ ពួកយើងធ្លាប់ប្រាប់ដល់លោកតាំងពីមុនដំបូងមកហើយថា កុំចូលទៅគាល់ព្រះសមណគោតម ព្រោះព្រះសមណគោតមរមែងធ្វើចិត្តរបស់មនុស្សទាំងឡាយ ដែលមករកព្រះអង្គឲ្យជាប់ចិត្តដោយកលមាយា ពេលនេះ លោកធ្លាក់នៅក្នុងអំណាចព្រះសមណគោតមហើយ តើពួកយើងនឹងរស់នៅជាមួយនឹងលោកបានយ៉ាងណា កាលបើពោលដូច្នេះហើយ ទើបនាំគ្នាត្រឡប់ទៅវិញដោយការអស់សង្ឃឹម ។

ភិក្ខុទាំងឡាយ កាលបានឮពាក្យដែលព្រះវង្គីសត្ថេរ ពោលជាមួយនឹងពួកព្រាហ្មណ៍ នឹកមិនពេញចិត្ត ដោយយល់ថា ព្រះវង្គីសៈពោលអួតគុណវិសេស ដែលមិនមានក្នុងខ្លួន ទើបនាំគ្នាមកក្រាបទូលព្រះភគវាថា បពិត្រព្រះមានបុណ្យ ព្រះវង្គីសត្ថេរពោលព្យាករនូវព្រះអរហត្តផល ដោយពាក្យដែលមិនពិត ។ ព្រះមហាមុនីត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុំពោលយ៉ាងហ្នឹងឡើយ ឥឡូវនេះ វង្គីសៈ បុត្ររបស់តថាគតឈ្លាសវៃក្នុងចុតិ និងបដិសន្ធិហើយ បន្ទាប់មកព្រះអង្គត្រាស់គាថា ដែលមាននៅក្នុង **ធម្មបទ** នៃ **ព្រាហ្មណវគ្គ** ដូចមានសេចក្តីថា ៖

បុគ្គលណា ដឹងច្បាស់ចុតិ និងបដិសន្ធិរបស់ពួកសត្វ ដោយអាការទាំងពួងបាន តថាគតហៅបុគ្គល ដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្តីប្រតិបត្តិ អ្នកត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។ ទេវតា គន្ធព្វ និងពួកមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះ ថាជាព្រាហ្មណ៍ ។

នាកាលព្រះវង្គីសត្ថេរ បានសម្រេចជាព្រះអរហន្តហើយ ទើបបានពោលពាក្យផ្សេងៗ ដោយប្រារព្ធរឿងរ៉ាវរបស់លោក កាលដែលលោកមិនទាន់បានជាព្រះអរហន្ត ឬបានជាព្រះអរហន្តហើយ ដោយពោលគាថាជាច្រើន ដូចមានប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថា ៖

វិតក្កទាំងនេះ ជាសភាវៈឃ្នើសឃ្នង ព្រោះជារបស់លាមក តែងគ្របសង្កត់អាត្មាអញ ដែលចេញចាកផ្ទះ បួសក្នុងព្រះពុទ្ធសាសនា ដូចពួកខ្មាន់ធ្នូដ៏ប្រសើរ ជាកូនអ្នកខ្ពង់ខ្ពស់ សិក្សាស្ទាត់ហើយ មានធ្នូដ៏មាំគប្បីបាញ់ប្រសាចនូវព្រួញ ទាំងពាន់ជុំវិញខ្លួន សត្រូវមិនឲ្យរត់រួចបាន ។ បើពួកស្រីប៉ុណ្ណោះ ឬលើសជាងនេះនឹងមក ក៏គង់បៀតបៀនអាត្មាអញមិនបាន ព្រោះអាត្មាអញបានតាំងមាំនៅក្នុងធម៌ទាំងឡាយហើយ ។ ព្រះពុទ្ធដីការបស់ព្រះពុទ្ធជាអាទិច្ចពន្ធុ អាត្មាអញបានស្តាប់ម្តងហើយ ចិត្តរបស់អាត្មាអញត្រេកអរ ក្នុងផ្លូវជាទីទៅកាន់ព្រះនិព្វាននោះហើយ ។ ម្នាលមារដ៏លាមក បើអ្នកចូលមកបំបាក់យើង ដែលកំពុងចុះចិត្តស៊ប់ក្នុងវិបស្សនាយ៉ាងនេះ អ្នកមិនបានឃើញផ្លូវរបស់យើងយ៉ាងណា យើងនឹងធ្វើអ្នកឲ្យដល់នូវសេចក្តីស្លាប់ យ៉ាងនោះដែរ បុគ្គលណា លះបង់នូវសេចក្តីអផ្សុក នូវសេចក្តីត្រេកអរ នូវសេចក្តីត្រិះរិះ ដែលអាស្រ័យនូវផ្ទះ ដោយប្រការទាំងពួង មិនធ្វើនូវសេចក្តីប្រាថ្នាក្នុងវត្ថុណាមួយ ជាអ្នកមិនមានសេចក្តីប្រាថ្នា ព្រោះមិនមានសេចក្តីប្រាថ្នា បុគ្គលនោះឈ្មោះថាភិក្ខុ ។ ក្នុងលោកនេះ វត្ថុណាមួយ នៅលើផែនដីក្តី លើអាកាសក្តី ដែលរាប់ចូលក្នុងភព ៣ មានសភាពវិនាសទៅ វត្ថុទាំងអស់នោះ ជារបស់មិនទៀង រមែងទ្រុឌទ្រោមទៅ អ្នកប្រាជ្ញទាំងឡាយ រមែងយល់ច្បាស់យ៉ាងនេះ ។ ពួកជនរមែងជាប់ជំពាក់ក្នុងឧបធិ គឺរូប និងសំឡេង

ដែលឃើញហើយ ឮហើយផង គឺក្លិន រស និងផោដ្ឋព្វៈដែលទង្គិចហើយ ប៉ះពាល់ហើយផង អ្នកចូរជាបុគ្គលមិនមានសេចក្ដីញាប់ញ័រ បន្ទោបង់នូវសេចក្ដីប្រាថ្នា ក្នុងកាមទាំងឡាយនោះចេញ ព្រោះបុគ្គលណាមិនជាប់ក្នុងកាមគុណនោះ ពួកអ្នកប្រាជ្ញ ទើបហៅបុគ្គលនោះ ថាជាមុនី ។ បុគ្គលអន្ធពាលមានវិតក្ក អាស្រ័យនូវទិដ្ឋិ ៦២ រមែងជាអ្នកតាំងមាំហើយក្នុងអធម៌ ព្រោះតែខ្លួនជាបុថុជ្ជន បុគ្គលណា មិនលុះក្នុងពួកនៃមិច្ឆាទិដ្ឋិ ក្នុងវត្ថុណាមួយ ទាំងជាអ្នកមិននិយាយអាក្រក់ បុគ្គលនោះ ឈ្មោះថា ភិក្ខុ ។ អ្នកប្រាជ្ញមានចិត្តតម្កល់មាំ អស់កាលយូរហើយ ជាអ្នកមិនកុហក មានប្រាជ្ញាល្អិត មិនមានតណ្ហា ជាអ្នកបរិបូណ៌ដោយមោនេយ្យធម៌ រំលត់កិលេស ហើយបានសម្រេចនូវសន្តិបទ ព្រោះអាស្រ័យព្រះនិព្វាន រង់ចាំតែបរិនិព្វានកាល ។

ម្នាលអ្នកជាគោត្រនៃព្រះគោតម អ្នកចូរលះបង់នូវមានះផង ចូរលះបង់នូវផ្លូវនៃមានះ កុំឲ្យមានសេសសល់ផង ព្រោះបុគ្គលជាប់នៅក្នុងផ្លូវនៃមានះហើយ រមែងមានសេចក្ដីក្ដៅក្រហាយ អស់កាលយូរ ។ ពួកសត្វ ដែលត្រូវសេចក្ដីលុបគុណគ្របសង្កត់ ត្រូវមានះបៀតបៀនហើយ រមែងធ្លាក់ទៅក្នុងនរក ពួកជនដែលមានះបៀតបៀនហើយ រមែងទៅកើតក្នុងនរក សោកសៅអស់កាលយូរ ។ ភិក្ខុអ្នកឈ្នះកិលេស ដោយមគ្គអ្នកប្រតិបត្តិដោយប្រពៃ រមែងមិនសោកសៅ ក្នុងកាលណាម្ដងឡើយ

ភិក្ខុណា បានទូវកិត្តិយសផង បានទូវសេចក្តីសុខផង ពួកបណ្ឌិតតែង ហៅភិក្ខុនោះ ថាជាអ្នកឃើញធម៌ ដោយពិត ។ ហេតុនោះ ភិក្ខុអ្នកមិន រីងរូស មានព្យាយាមក្នុងសាសនានេះ លះបង់នូវនីវរណៈទាំងឡាយ ជា អ្នកបរិសុទ្ធ លះបង់នូវមានៈ មិនឲ្យមានសេសសល់ រមែងជាអ្នកធ្វើនូវ ទីបំផុតនៃវិជ្ជា ជាអ្នកស្ងប់រំងាប់នូវកិលេស ។

នៅថ្ងៃមួយ ព្រះវង្គីសត្ថេរ ក្រាបទូលកោតសរសើរព្រះសាស្តា ក្នុងទីចំពោះព្រះភក្ត្រព្រះអង្គ ដោយសប្បាយចិត្តតាមពាក្យដែលព្រះពុទ្ធ ទ្រង់សម្តែងទុកក្នុងគម្ពីរខុទ្ទកនិកាយ សុត្តនិបាត ក្នុងសុភាសិតសូត្រថា ៖

បុគ្គល មិនគប្បីញុំាងខ្លួនឲ្យក្តៅក្រហាយ ដោយវាចាណា គប្បី ពោលតែវាចានោះ បុគ្គលមិនគប្បីបៀតបៀន ពួកបុគ្គលដទៃ ដោយវាចា ណា វាចានោះឯងជាសុភាសិត ។ វាចាណា ដែលគេទទួលត្រេកអរ បុគ្គលគប្បីពោលតែវាចាជាទីស្រឡាញ់នោះឯង បុគ្គលកុំកាន់យកពាក្យ អាក្រក់ ពោលតែពាក្យដែលជាទីពេញចិត្តនៃពួកជនដទៃ ។ ពាក្យពិត ជាពាក្យមិនស្លាប់ នេះជាធម៌មានមកពីបុរាណ ពួកសប្បុរស តាំងមាំក្នុង សច្ចៈផង ក្នុងអត្ថៈផង ក្នុងធម្មៈផង ។ ព្រះពុទ្ធទ្រង់ពោលវាចា ជាវាចា ដ៏ក្សេម ដើម្បីដល់នូវព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ វាចានេះឯង ជាវាចាឧត្តមជាងវាចាទាំងឡាយ ។

គ្រាមួយ ព្រះវង្គីសត្ថេរ បានពោលសរសើរព្រះមហាមុនី ដែល

ទ្រង់គង់ប្រថាប់នៅក្នុងកណ្តាលជំនុំភិក្ខុសង្ឃក្នុង ១៥ ថ្ងៃ មានប្រាកដក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ** នៃ **បវារណាសូត្រ** ថា ៖

ពួកភិក្ខុ ៥០០ រូប ជាអ្នកផ្តាច់បង់នូវចំណង គឺសំយោជនៈ ជាអ្នកមិនមានទុក្ខ មានភពថ្មីអស់ហើយ ជាអ្នកស្វែងរកគុណ បានមកជួបជុំគ្នាដើម្បីមកធ្វើវិសុទ្ធិបវារណាក្នុងថ្ងៃ ១៥ ។ ព្រះរាជាចក្រពត្តិ មានអាមាត្យចោមរោម យាងប្រទក្សិណផែនដី ដែលមានសាគរជាទីបំផុតនេះ ដោយជុំវិញ យ៉ាងណា ។ ពួកសាវ័កមានវិជ្ជា ៣ អ្នកបំផ្លាញនូវមច្ចុរាជ រមែងអង្គុយជិតព្រះសាស្តា ព្រះអង្គជាបុគ្គលប្រសើរលើសលប់ ឈ្នះសង្គ្រាម គឺកិលេស អ្នកដឹកនាំនូវពួកក្រុង ក៏យ៉ាងនោះដែរ ។ ពួកសាវ័កទាំងអស់ ជាបុត្រនៃព្រះនាយក សភាពសោះសូន្យក្នុងពួកនោះមិនមានឡើយ ខ្ញុំព្រះករុណា សូមថ្វាយបង្គំចំពោះព្រះសាស្តា ជាផៅពង្សនៃព្រះអាទិត្យ ព្រះអង្គជាអ្នកបំផ្លាញនូវសរ គឺតណ្ហា ។ ពួកភិក្ខុច្រើនជាងពាន់អង្គុយជិតព្រះសុគត ដែលកំពុងសម្តែងធម៌ ជាគ្រឿងប្រាសចាករាគៈ គឺព្រះនិព្វាន ឥតមានភ័យអំពីទីណា ។ ពួកសាវ័កស្តាប់ធម៌ដ៏ធំទូលាយ ដែលព្រះសម្ពុទ្ធទ្រង់សម្តែងហើយ ឱហ្ន៎ ! ព្រះមានជោគ មានភិក្ខុចោមរោមហើយ ល្អណាស់តើ ។ បពិត្រព្រះមានបុណ្យ ព្រះអង្គព្រះនាមថានាគ ជាឥសីគម្រប់ ៧ ( រាប់តាំងពី ព្រះវិបស្សីសម្មាសម្ពុទ្ធឥសីមក ) នៃឥសីទាំងឡាយ ព្រះអង្គជាអ្នកបង្អុរនូវធម៌ស្រោចពួកសាវ័ក មានសភាព

ដូចជាមហាមេឃបង្អុរនូវភ្លៀង ។ បពិត្រព្រះអង្គមានព្យាយាមធំ វង្គីសៈជាសាវ័ក ចេញចាកទីនៅក្នុងវេលាថ្ងៃ ព្រោះមានសេចក្តីប្រាថ្នាចង់គាល់ព្រះមហាវីរៈ ថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ ។

ព្រះភគវា ទ្រង់គ្របសង្កត់ផ្លូវខុស គឺកិលេសមារ បានប្រព្រឹត្តទម្លាយបង្គោល គឺកិលេស អ្នកទាំងឡាយចូរមើលព្រះពុទ្ធនោះ ព្រះអង្គធ្វើឲ្យរួចចាកចំណង មិនអាស្រ័យតណ្ហា ទ្រង់ចែករំលែកធម៌ តាមចំណែក ។ ព្រោះថា ព្រះអង្គបានប្រាប់ផ្លូវច្រើនប្រការ ដើម្បីជាគ្រឿងរលាស់ឱឃៈចោល កាលទ្រង់សម្តែងធម៌ប្រាប់អមតមហានិព្វាននោះហើយ ពួកជនក៏បានឃើញច្បាស់នូវធម៌ តម្កល់នៅនឹង មិនមានអ្នកណាដឹកនាំទៅបាន ។ ព្រះពុទ្ធនោះ អ្នកធ្វើនូវពន្លឺ ទ្រង់ធ្លុះវិញ្ញាណដ្ឋិតិរបស់សត្វទាំងអស់បានត្រាស់ដឹងផង ធ្វើឲ្យជាក់ច្បាស់ផង ទ្រង់យាងកន្លងផ្លូវឆ្ងាយបាន ហើយសម្តែងធម៌ដ៏ប្រសើរដល់ពួកបញ្ចវគ្គិយភិក្ខុ អ្នកមានសទ្ធាត្រាស់ដឹងធម៌មុនគេបង្អស់ ។ កាលបើធម៌ដែលព្រះតថាគត សម្តែងល្អយ៉ាងនេះហើយ សេចក្តីប្រមាទដូចម្តេច នឹងមានដល់ពួកជន ដែលជាអ្នកដឹងច្បាស់នូវធម៌បាន ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកប្រមាទក្នុងសាសនាព្រះមានជោគនោះឡើយ គប្បីនមស្ការសិក្សាតាមសព្វៗ កាល ។

ព្រះវង្គីសត្ថេរ ក្រោយអំពីបានពោលសរសើរគុណ ព្រះពុទ្ធរួចមកហើយ ថែមទាំងបានពោលសរសើរគុណ ព្រះមហាថេរៈមួយរូបទៀត គឺ

ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ដូចដែលមានសម្តែងនៅក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ** នៃ **កោណ្ឌញ្ញសូត្រ** ថា ៖

ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធ មានសេចក្តីព្យាយាមមាំមួន ជាអ្នកបាននូវវិវេក ជាគ្រឿងនៅជាសុខរឿយៗ ។ កិច្ចណាដែលសាវក អ្នកធ្វើតាមសាសនានៃព្រះសាស្តា គប្បីសម្រេចកិច្ចនោះ បានសម្រេចទាំងអស់ហើយ ។ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ មានអានុភាពច្រើន បានសម្រេចវិជ្ជា ៣ ស្ទាត់ក្នុងចេតោបរិយញ្ញាណ ជាពុទ្ធទាយាទ ថ្វាយបង្គំព្រះបាទានៃព្រះលោកនាថ ។

ថ្ងៃមួយ ព្រះវង្គីសត្ថេរ បានពោលសរសើរគុណព្រះសារីបុត្រ ដែលមានប្រាកដក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ នៃសារីបុត្តសូត្រ** ថា ៖

ព្រះសារីបុត្រ ជាបុគ្គលមានប្រាជ្ញាជ្រាលជ្រៅ ជាអ្នកប្រាជ្ញ ដឹងផ្លូវ និងមិនមែនផ្លូវ មានប្រាជ្ញាច្រើន រមែងសម្តែងធម៌ដល់ពួកភិក្ខុ ។ ព្រះសារីបុត្រសម្តែងធម៌ដោយសង្ខេបក៏បាន សម្តែងដោយពិស្តារក៏បាន លោកមានសំឡេងក្រអួនពីរោះ ដូចសំឡេងសាលិកា ទាំងមានបដិភាណផុសផុល ។ កាលព្រះសារីបុត្រកំពុងសម្តែងធម៌នោះ ពួកភិក្ខុកំពុងស្តាប់សំឡេងដ៏ពីរោះ ក៏មានចិត្តអណ្តែតអណ្តូង ត្រេកអរ ផ្ចង់សោតបសាទទៅរកសំឡេងដែលគួរត្រេកអរ គួរចង់ស្តាប់ គួរប្រាថ្នា ។

គ្រាមួយ ព្រះវង្គីសៈបានពោលសរសើរគុណ របស់មហាមោគ្គ-

ល្លានត្ថេរជាមួយនឹងព្រះបរមគ្រូ ដូចមានប្រាកដក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ** នៃ **មោគ្គល្លានសូត្រ** ថា ៖

ចូរមើលចុះ ពួកសាវ័ក បានសម្រេចវិជ្ជា ៣ ជាអ្នកសាបសូន្យចាកមច្ចុរាជ នាំគ្នាអង្គុយជិតព្រះមហាមុនី ព្រះអង្គជាអ្នកដល់នូវត្រើយនៃទុក្ខ ( ដោយចេតោបរិយញ្ញាណ ) ខាងលើភ្នំឥសិគិលិ ។ ព្រះមោគ្គល្លានមានឫទ្ធិច្រើន យកចិត្តទុកដាក់ស្ទះស្វែងរកចិត្តដែលផុតចាកកិលេស ជាចិត្តមិនមានឧបធិរបស់ព្រះខីណាស្រពទាំងឡាយនោះ ។ បពិត្រព្រះគោតម ពួកសាវ័កតែងអង្គុយជិត ព្រះអង្គបរិបូណ៌ដោយអវយវៈគ្រប់យ៉ាង ព្រះអង្គដល់នូវត្រើយនៃទុក្ខ ព្រះអង្គបរិបូណ៌ដោយអាការច្រើនប្រការយ៉ាងនេះ ។

ជីវិតរបស់យើង រមែងជួបជាមួយនឹងវត្ថុដែលជាទីគាប់ចិត្តខ្លះ មិនជាទីគាប់ចិត្តខ្លះ ដូចជាពេលខ្លះយើងធ្វើល្អ តែត្រឡប់ជាអ្នកដទៃមើលទៅឃើញថា មិនល្អទៅវិញ ក៏មានច្រើនសន្ធឹកសន្ធាប់ដែរ ព្រោះថា មនុស្សដែលមានកិលេសក្រាស់ តែងតែត្រូវកិលេសផ្សេងៗ រួបរឹតចិត្តហើយទើបធ្វើឲ្យបុគ្គលនោះ ឃើញល្អថាអាក្រក់ ឃើញអាក្រក់ថាល្អ ដូច្នេះហើយ ក៏និយាយបន្ទុចអ្នកដទៃ ដោយឥតហេតុផល ។

ដូចមានរឿង ដែលជាឧទាហរណ៍នៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្តីថា ៖

ថ្ងៃមួយ ព្រះមានជោគ ទ្រង់សណ្ដាប់ការសន្ទនាភិក្ខុទាំងឡាយថា ព្រះវង្គីសៈមិនតាំងចិត្តរៀនសូត្រ ជាអ្នកនិយាយពាក្យមិនពិតឡើយ ។ ព្រះមហាវីរៈ ទ្រង់ត្រាស់អះអាងសេចក្ដីល្អរបស់ព្រះវង្គីសត្ថេរថា ម្នាលភិក្ខុទាំងឡាយ វង្គីសៈ ( រៀនចប់ហើយ ) បានគ្របសង្កត់នូវពពួកមារបានហើយ ទាំងបានទម្លាយដែកគោល គឺកិលេសបានទៀតផង អ្នកទាំងឡាយចូរមើលវង្គីសៈដោះនូវគ្រឿងចង ជាអ្នកមិនមានតណ្ហា មានះ ទិដ្ឋិ ថែមទាំងជាអ្នកប្រាប់ផ្លូវផ្សេងៗ ដើម្បីឲ្យអ្នកទាំងឡាយបានឆ្លងស្ទឹង គឺសង្សារវដ្ដទៅបាន ។ កាលបើវង្គីសៈប្រាប់ផ្លូវដែលមិនស្លាប់ ភិក្ខុទាំងឡាយណាបានស្ដាប់ ក៏ជាអ្នកឃើញធម៌ ជាបុគ្គលមានការប្រព្រឹត្តមិនដាច់ ។ វង្គីសៈជាអ្នកធ្វើឲ្យកើតពន្លឺ ជាអ្នកចាក់ធ្លុះនូវធម៌ដ៏ប្រសើរទាំងពួង ជាអ្នកឆ្លងផុតអំពីភាពជាអ្នកស្រវឹងហើយ ។ វង្គីសៈសម្ដែងធម៌ដ៏ប្រសើរ ព្រោះខ្លួនឯងដឹងច្បាស់ និងធ្វើឲ្យជាក់ច្បាស់បានផង ។ កាលបើវង្គីសៈសម្ដែងដ៏ល្អយ៉ាងនេះ អ្នកទាំងឡាយមិនគួរប្រមាទចំពោះធម៌ ដែលវង្គីសៈសម្ដែងនោះទេ ។ ព្រោះដូច្នោះ ពួកអ្នកកុំជាអ្នកមានសេចក្ដីប្រមាទក្នុងសាសនារបស់តថាគត ចូរតាំងចិត្តសិក្សាព្រះធម៌វិន័យ ដោយសេចក្ដីគោរពចុះ ។

**គាថា គឺពាក្យនិពន្ធ ដែលព្រះវង្គីសត្ថេរចងក្រង ពោលដើម្បីប្រកាសខ្លួនបដិបត្តិ និងគុណធម៌របស់លោក ព្រមទាំងការពោលសរសើរគុណព្រះបរមគ្រូ ដូចមានសេចក្ដីថា ៖**

កាលពីដើម យើងខ្ញុំពួកកវីរាប់អាន បានដើរចេញពីស្រុកមួយទៅស្រុកមួយ ពីបុរីមួយ ទៅបុរីមួយ វេលានេះ យើងខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះអង្គបានដល់នូវត្រើយនៃធម៌ទាំងពួង ។ ព្រះមុនីនោះ ព្រះអង្គជាអ្នកដល់នូវត្រើយនៃទុក្ខ បានសំដែងធម៌ដល់ខ្ញុំ យើងខ្ញុំលុះបានស្តាប់ធម៌ហើយ ក៏មានចិត្តជ្រះថ្លា មានសទ្ធាកើតឡើង ។ ខ្ញុំបានស្តាប់ព្រះពុទ្ធដីកានៃព្រះមុនីនោះហើយ ក៏បានដឹងច្បាស់ នូវខន្ធ អាយតនៈ និងធាតុទាំងឡាយ ហើយចេញចាកផ្ទះ បួសក្នុងសម្នាក់ នៃបុគ្គលមិនមានផ្ទះ ។ ឱហ្ន៎ ! ព្រះតថាគតទាំងឡាយកើតឡើង ដើម្បីជាប្រយោជន៍ដល់បុរសនិងស្ត្រីដ៏ច្រើន ដែលជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ។ ពួកភិក្ខុ និងពួកភិក្ខុនីណា បានឃើញនូវកំណត់ ដែលគេកត់ទុកហើយ ព្រះមុនីបានត្រាស់ដឹងពោធិញ្ញាណ ដើម្បីប្រយោជន៍ដល់ពួកភិក្ខុ និងពួកភិក្ខុនីទាំងនោះឯង ។ អរិយសច្ចៈទាំង ៤ ប្រការ គឺទុក្ខ ១ ការកើតនៃទុក្ខ ១ ការកន្លងផុតនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរ ជាដំណើរទៅកាន់សេចក្តីរំលត់ទុក្ខ ១ ព្រះពុទ្ធជាវង្សនៃព្រះអាទិត្យ មានចក្ខុ គឺប្រាជ្ញាទ្រង់សំដែងធម៌ទុកល្អហើយ ដើម្បីអនុគ្រោះដល់សត្វទាំងឡាយ ។ ធម៌គឺអរិយសច្ចៈទាំងឡាយនេះ ជាធម៌ពិត ព្រះពុទ្ធទ្រង់សំដែងហើយយ៉ាងនេះ អរិយសច្ចៈទាំងនោះ ខ្ញុំបានឃើញតាមពិត ប្រយោជន៍ខ្លួន ខ្ញុំបានសម្រេចហើយ ទាំងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ កិច្ចណាដ៏ប្រសើរក្នុងធម៌ទាំងឡាយ ដែលព្រះពុទ្ធទ្រង់សម្តែងវែកញែកហើយដោយប្រពៃ ខ្ញុំបានសម្រេចកិច្ចនោះហើយ ។ ខ្ញុំបានសម្រេចអភិញ្ញាបារមី បានជម្រះនូវសោតធាតុ បាននូវវិជ្ជា ៣ បានសម្រេចឫទ្ធិ ជាអ្នកឈ្លាសវៃ ក្នុងចេតោបរិយញ្ញាណ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវង្គីសៈ គាថានេះ អ្នកត្រៀមគិតទុកជាមុន ឬទើបតែគិតឥឡូវនេះ ? ព្រះវង្គីសត្ថេរក្រាបទូលតបថា ខ្ញុំព្រះអង្គទើបតែគិតឡើងអម្បាញ់មិញនេះឯង ។

ព្រះបរមលោកនាថ ទ្រង់អាស្រ័យមូលហេតុ នៃការពោលគាថាទាំងឡាយដ៏ពីរោះរបស់ព្រះវង្គីសត្ថេរ ទើបទ្រង់ប្រកាសតែងតាំង ឲ្យជាឯតទគ្គៈ តាមដែលមានប្រាកដក្នុងគម្ពីរអង្គុត្តរនិកាយ ឯកនិបាត ថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ បដិភាណវន្តានំ យទិទំ វង្គីសោ** ម្នាលភិក្ខុទាំងឡាយ វង្គីសត្ថេរជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងមានបដិភាណ ។

ការព្រួយបារម្ភ ជាឧបនិស្ស័យរបស់អ្នកមានចិត្តកតញ្ញូកតវេទី ដែលព្រះវង្គីសត្ថេរ មានចំពោះព្រះនិគ្រោធកប្បត្ថេរ លោកជាឧបជ្ឈាយ៍ ដូចមានរឿងសម្តែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ថា ៖

សម័យមួយ ព្រះសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅក្នុងអគាឡវចេតិយ

នៅក្បែរក្រុងអាឡវី ។ សម័យនោះឯង ព្រះនិគ្រោធកប្បៈ ជាឧបជ្ឈាយ៍របស់ព្រះវង្គីសត្ថេរ បានរំលត់ខន្ធបរិនិព្វានទៅ នៅមិនទាន់បានយូរប៉ុន្មានដែលនៅក្នុងអគាឡវចេតិយ ។ គ្រានោះ ព្រះវង្គីសៈ បានពួនសំងំនៅក្នុងទីស្ងាត់ ក៏បានកើតសេចក្តីសង្ស័យថា ឧបជ្ឈាយ៍របស់យើង បរិនិព្វានទៅហើយឬ លុះដល់វេលាល្ងាច លោកចេញអំពីទីពួនសំងំ ចូលទៅគាល់ព្រះទសពល ថ្វាយបង្គំរួចហើយ អង្គុយក្នុងទីដ៏សមគួរ ទើបក្រាបទូលសួរថា បពិត្រព្រះមានបុណ្យ សូមប្រទានវរោកាស កាលខ្ញុំព្រះអង្គនៅក្នុងទីពួនសំងំ ខ្ញុំព្រះអង្គបានគិតឡើងថា ឧបជ្ឈាយ៍របស់យើងបរិនិព្វានទៅហើយឬហ្ន៎ កាលបើក្រាបទូលដូច្នេះហើយ ទើបបានគ្រងនូវចីវរ លើកដៃប្រណម្យឡើងក្រាបទូលព្រះសក្យមុនី ដោយពាក្យជាគាថាឡើងថា

ខ្ញុំព្រះអង្គសូមទូលសួរព្រះសាស្តា ជាបុគ្គលមានប្រាជ្ញាមិនថោកថយ ភិក្ខុណា បានផ្តាច់បង់វិចិកិច្ឆាក្នុងអត្តភាពនេះ មានកេរ្តិ៍ឈ្មោះល្បីល្បាញ សម្បូរដោយយស មានចិត្តរំលត់ភាពក្តៅក្រហាយ បានធ្វើកាលកិរិយាក្នុងអគាឡវចេតិយ ។ បពិត្រព្រះលោកនាយក នាមនៃភិក្ខុ ជាព្រាហ្មណ៍នោះ ព្រះអង្គឲ្យឈ្មោះថា និគ្រោធកប្បៈ លោកនោះមានព្យាយាមតឹងតែង ជាអ្នកយល់ឃើញធម៌មុតមាំ ប្រាថ្នានូវព្រះនិព្វាន បានប្រព្រឹត្តនមស្ការចំពោះព្រះអង្គ ។ បពិត្រព្រះអង្គជាសក្កៈ មានចក្ខុជុំវិញ យើងខ្ញុំទាំងអស់គ្នា ប្រាថ្នាចង់ដឹងសាវកនោះ យើងខ្ញុំប្រុងសោតៈដើម្បី

ស្តាប់ ព្រះអង្គជាសាស្តារបស់យើងខ្ញុំ ព្រះអង្គជាបុគ្គលប្រសើរបំផុត ។ សូមព្រះអង្គទ្រង់កាត់សេចក្តីសង្ស័យរបស់យើងខ្ញុំ សូមព្រះអង្គប្រាប់នូវសាវកនោះ បពិត្រព្រះអង្គមានបញ្ញាដូចផែនដី មានចក្ខុជុំវិញ ព្រះអង្គទ្រង់ជ្រាបនូវព្រាហ្មណ៍ដែលបរិនិព្វានហើយ សូមសម្តែងក្នុងកណ្តាលនៃពួកយើងខ្ញុំ ដូចជាសក្កទេវរាជ មានព្រះនេត្រមួយពាន់ ( សម្តែងក្នុងកណ្តាល ) នៃទេវតាទាំងឡាយ ។ គន្ថៈទាំងឡាយ ( មានអភិជ្ឈាកាយគន្ថៈជាដើម ) ណាមួយ ជាផ្លូវនាំឲ្យវង្វេង ជាបក្ខពួកនៃការមិនដឹង ជាទីតាំងនៃសេចក្តីសង្ស័យក្នុងលោកនេះ គន្ថៈទាំងនោះមកប៉ះនឹងព្រះតថាគតហើយ រមែងមិនកើតឡើង ព្រោះបញ្ញាចក្ខុរបស់ព្រះអង្គនោះ ឧត្តមជាងជនទាំងឡាយ ។ ប្រសិនបើបុរស ( ព្រះមានព្រះភាគ ) មិនកម្ចាត់បង់នូវកិលេសទាំងឡាយ ដូចជាខ្យល់កម្ចាត់នូវដុំនៃពពកទេ លោកទាំងមូលដែលអវិជ្ជារួបរឹតហើយ សមនឹងងងឹតដោយពិត សូម្បីអ្នកមានពន្លឺ គឺបញ្ញា ក៏មិនអាចបំភ្លឺបាន ។

អ្នកប្រាជ្ញទាំងឡាយ ជាអ្នកធ្វើពន្លឺ ខ្ញុំព្រះអង្គសម្គាល់ព្រះអង្គនោះថា ជាអ្នកប្រាជ្ញយ៉ាងនោះដែរ យើងខ្ញុំដឹង ( នូវធម៌ទាំងអស់ ) របស់ជនអ្នកចេះដឹងទាំងឡាយ ទើបបានចូលមកជិត សូមព្រះអង្គសម្តែងប្រាប់នូវនិគ្រោធកប្បត្ថេរ ( ជាឧបជ្ឈាយ៍ ) ឲ្យច្បាស់លាស់ ដល់យើងខ្ញុំក្នុងកណ្តាលបរិស័ទ ។ បពិត្រព្រះអង្គមានព្រះសូរសៀងដ៏ពីរោះ សូមព្រះអង្គ

បញ្ចេញចាប់ៗ នូវព្រះពុទ្ធដីកាដ៏ពីរោះ ដោយព្រះសូរសៀងមូល ដែលបច្ច័យតាក់តែងល្អហើយ ដូចហង្សដក.ក.ហើយស្រែកតិចៗ ពួកយើងខ្ញុំទាំងអស់គ្នានោះ មានចិត្តត្រង់ ប្រុងចាំស្តាប់ព្រះតថាគត ។ តថាគតបានផ្ចាញ់ផ្ចាល់នូវជាតិ និងមរណៈឲ្យសាបសូន្យ មិនឲ្យមានសេសសល់ និងសម្តែងនូវធម៌ ជាគ្រឿងកម្ចាត់បង់នូវបាប មែនពិត បុថុជ្ជនទាំងឡាយមិនមានការធ្វើបានតាមប្រាថ្នាទេ ព្រះតថាគតទាំងឡាយ មានការធ្វើបានតាមបញ្ញា ។ វេយ្យាករណ៍ ដ៏បរិបូណ៌នេះ ព្រះអង្គជាបុគ្គលមានប្រាជ្ញាត្រង់ល្អ ផ្គូផ្គងហើយដោយប្រពៃ ការធ្វើអញ្ជលីជាទីបំផុតនេះ ខ្ញុំព្រះអង្គបានប្រណម្យហើយដោយល្អ បពិត្រព្រះអង្គ ជាបុគ្គលមានប្រាជ្ញាធំទូលាយ កាលបើព្រះអង្គជ្រាប សូមកុំធ្វើឲ្យខ្ញុំព្រះអង្គវង្វេងឡើយ ។ បពិត្រព្រះអង្គ ជាបុគ្គលមានព្យាយាមធំ ព្រះអង្គជ្រាបច្បាស់នូវអរិយធម៌ គឺសច្ចៈទាំង ៤ ដ៏ល្អ ( ដោយអំណាចលោកិយធម៌ ) កាលបើទ្រង់ជ្រាបច្បាស់ហើយ សូមកុំធ្វើឲ្យខ្ញុំព្រះអង្គវង្វេងឡើយ ខ្ញុំព្រះអង្គប្រាថ្នាចង់ស្តាប់ព្រះពុទ្ធដីកា ដូចជាបុគ្គលមានខ្លួនក្តៅអន្ទះអន្ទែង ក្នុងកាលក្តៅ ប្រាថ្នាចង់បានទឹក សូមព្រះអង្គបង្អុរនូវសុតៈ គឺធម្មទេសនា ។ និគ្រោធកប្បត្ថេរ បានប្រព្រឹត្តនូវព្រហ្មចារ្យ ប្រកបដោយប្រយោជន៍ណា ការប្រព្រឹត្តព្រហ្មចារ្យរបស់លោកនោះ មិនសាបសូន្យទេឬ និគ្រោធកប្បត្ថេរនោះនិព្វានហើយដោយអសេក្ខវិមុត្តិ ឬសឧបាទិសេសនិព្វាន យើងខ្ញុំចង់ស្តាប់រឿងនោះ ។

ព្រះសយម្ភូ ទ្រង់ត្រាស់ថា និគ្រោធកប្បភិក្ខុ បានផ្តាច់បង់នូវសេចក្តីប្រាថ្នាក្នុងនាមរូបនេះអស់ហើយ បានផ្តាច់បង់នូវខ្សែនៃសេចក្តីប្រាថ្នា ជាទីដេកនៅរឿយៗ ក្នុងសន្តាន អស់រាត្រីកាលដ៏វែង ទាំងបានឆ្លងចាកជាតិ និងមរណៈ ឥតមានសេសសល់ ។ ព្រះមានជោគប្រសើរដោយឥន្ទ្រិយ ៥ ( មានសទ្ធិន្ទ្រិយជាដើម ) បានត្រាស់ដឹងហើយ យ៉ាងនេះ ។ បពិត្រព្រះអង្គជាឥសីគម្រប់ ៧ ខ្ញុំព្រះអង្គនេះ បានឮព្រះពុទ្ធដីការបស់ព្រះអង្គហើយ ក៏ជ្រះថ្លា ឯកិច្ចការដែលខ្ញុំព្រះអង្គសួរហើយ មិនសោះសូន្យទេ ព្រះទីណាសវព្រាហ្មណ៍ មិនបញ្ឆោតខ្ញុំព្រះអង្គ ។ សាវករបស់ព្រះពុទ្ធពោលយ៉ាងណា ធ្វើយ៉ាងនោះ បានផ្តាច់នូវសំណាញ់ដ៏មាំដែលមច្ចុអ្នកមានមាយាផ្សាយទៅហើយ ។ ព្រះមហាវីរៈ ទ្រង់គួរបានទតឃើញច្បាស់ នូវខាងដើមនៃឧបាទាន កប្បត្ថេរបានកន្លងនូវលំនៅនៃមច្ចុរាជ ដែលគេឆ្លងបានដោយកម្រ ។ បពិត្រព្រះមហាមុនី ព្រះអង្គឧត្តមជាងសត្វជើងពីរ ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំនិគ្រោធកប្បត្ថេរនោះ ជាបុត្ររបស់ព្រះអង្គ ដែលទុកដូចជាទេវតាឧត្តមជាងទេវតា ជាអនុជាតបុត្តមានព្យាយាមធំ ជាបុគ្គលមិនធ្វើបាប ជាឱរសនៃព្រះពុទ្ធនាគ ។

ចំណែកជីវប្រវត្តិអតីតជាតិ របស់ព្រះវង្គីសត្ថេរ ដែលមានប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ឬក្នុង **អដ្ឋកថាមនោរថបូរណី** និង **អដ្ឋកថាគម្ពីរវិសុទ្ធជនវិលាសិនី** ដូចមានសេចក្តីថា ៖

ក្នុងពុទ្ធសម័យព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ព្រះអង្គមានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ជានាយក ទ្រង់កើតឡើងហើយ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ រលកក្នុងសាគរ និងពួកផ្កាយ ក្នុងអាកាស យ៉ាងណាមិញ សាសនារបស់ព្រះពុទ្ធអង្គនោះ ដ៏វិចិត្រហើយ ដោយពួកព្រះអរហន្ត ក៏យ៉ាងនោះដែរ ។ ព្រះវិជិតមារ ដ៏ឧត្តមនោះ មានពួកមនុស្សព្រមទាំងទេវតា អសុរ នាគចោមរោម ក្នុងកណ្តាលប្រជុំជន កុះករដោយសមណៈ និងព្រាហ្មណ៍ ។ ព្រះលោកនាយកនោះ ព្រះអង្គដល់នូវទីបំផុតនៃលោក ក្នុងលោក ទ្រង់ញុំាងឈ្មួក គឺវេនេយ្យសត្វឲ្យពេញចិត្តដោយរស្មីទាំងឡាយ ឲ្យត្រាស់ដឹងដោយពាក្យ ( របស់ព្រះអង្គ ) ។ ព្រះអង្គបរិបូណ៌ដោយវេសារជ្ជធម៌ទាំង ៤ ជាបុរសដ៏ឧត្តម មានភ័យ និងសេចក្តីកោតញញើតលះបង់ហើយ ទ្រង់ដល់នូវទីដ៏ក្សេម ជាអ្នកក្លៀវក្លា ។ ព្រះអង្គជាបុគ្គលប្រសើរក្នុងលោក ទ្រង់ប្តេជ្ញានូវពុទ្ធភូមិដ៏ប្រសើរ ថ្លៃថ្លាបំផុត ព្រះអង្គគ្មានបុគ្គលណាមួយជាស់តឿនឡើយ ។ កាលព្រះអង្គជាតាទិបុគ្គល បន្លឺនូវសីហនាទ ឥតមានញញើត មិនមានទេវតា និងនរជន ឬព្រហ្មពោលតបបានឡើយ ។ ព្រះអង្គកាលសម្តែងធម៌ដ៏ប្រសើរ ញុំាងមនុស្ស ព្រមទាំងទេវតាឲ្យឆ្លង ( នូវវដ្តៈទាំង ៣ ) ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ទ្រង់ជាអ្នកក្លៀវក្លាក្នុងបរិស័ទ ។ ព្រះអង្គប្រកាសនូវគុណដ៏ច្រើននៃសាវកមួយរូប ដ៏ប្រសើរជាងពួកលោកមានបដិភាណ ដែល

គេសន្មតិថា ជាសប្បុរស ហើយតាំងសាវ័កនោះ ទុកជាឯតទគ្គៈ ។

កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ឈ្មោះវឌ្ឍិសៈ នៅក្នុងនគរហង្សវតី ចេះចប់នូវវេទសព្វគ្រប់ គេសន្មតិថា ជាសប្បុរស ជាអ្នកបង្ហូរនូវពាក្យប្រៀនប្រដៅ ។ ខ្ញុំបានចូលទៅជិតព្រះអង្គមានព្យាយាមធំ ហើយស្តាប់ធម៌ទេសនា បាននូវបីតិដ៏ប្រសើរ ក៏ត្រេកអរក្នុងគុណនៃសាវ័ក ។ កាលនោះ ខ្ញុំនិមន្តព្រះសុគត ព្រមទាំងភិក្ខុសង្ឃ ដែលជាអ្នកញុំាំងសត្វលោកឲ្យត្រេកអរ ទទួលចង្ហាន់អស់ ៧ ថ្ងៃ ហើយឲ្យគេបិទបាំងដោយសំពត់ទាំងឡាយ ។ ខ្ញុំបានក្រាបក្បាលទៀបព្រះបាទា ( នៃព្រះអង្គ ) លុះព្រះអង្គបើកឱកាសឲ្យខ្ញុំហើយ ខ្ញុំបានធ្វើនូវអញ្ជលិកម្ម ស្ថិតនៅក្នុងទីដ៏សមគួរ មានចិត្តត្រេកអរ សរសើរនូវព្រះបរមគ្រូដ៏ឧត្តមថា បពិត្រព្រះអង្គ ទ្រង់បង្ហូរនូវពាក្យប្រៀនប្រដៅ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គជាឥសីទី ៧ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គ ជាបុគ្គលប្រសើរជាងសត្វលោកទាំងអស់ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់កម្ចាត់បង់នូវភ័យ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ ។ បពិត្រព្រះអង្គទ្រង់ញាំញីនូវមារ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់បង្ហូរនូវទិដ្ឋិ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់ឲ្យនូវសន្តិសុខ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់ធ្វើនូវទីពឹង ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ ។ ព្រះអង្គដ៏ចម្រើនជាទីពឹងនៃសត្វ ដែលពុំមានទីពឹង ទ្រង់ប្រទាន

នូវអភ័យ ដល់សត្វដែលមានភ័យ ទ្រង់ជាទីស្និទ្ធស្នាលរបស់សត្វទាំងឡាយ ដែលមានភូមិដ៏ស្ងប់ ជាទីពឹងរបស់ពួកជនអ្នកស្វែងរកនូវទីពឹង ។ លុះខ្ញុំសរសើរព្រះសម្ពុទ្ធមានគុណធំ ដោយពាក្យទាំងឡាយ មានយ៉ាងនេះជាដើម រួចបានពោលថា ខ្ញុំសូមដល់នូវគតិភិក្ខុ ដែលជាអ្នកក្លៀវក្លាជាងភិក្ខុអ្នកមានវាទៈក្លៀវក្លា ។

កាលនោះ ព្រះទសពល ព្រះអង្គមានបដិភាណគ្មានទីបំផុត បានត្រាស់ថា បុគ្គលណា បានញុំាងព្រះពុទ្ធ ព្រមទាំងសាវ័ក ឲ្យឆាន់អស់ ៧ ថ្ងៃ ជ្រះថ្លា ( ប្រណម្យ ) ដោយដៃរបស់ខ្លួន សរសើរនូវគុណនៃតថាគត បុគ្គលនោះ ប្រាថ្នានូវតំណែងរបស់ភិក្ខុ អ្នកក្លៀវក្លាក្នុងវាទៈ ។ បុគ្គលនោះ នឹងសោយសម្បត្តិទេវតា និងសម្បត្តិមនុស្សដ៏ច្រើន ហើយបានតំណែងជាទីពេញចិត្តនោះ ក្នុងអនាគតកាល ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានមហាបុរសទ្រង់កើតក្នុងឱក្កាកត្រកូល នឹងបានជាព្រះសាស្តា ទ្រង់ព្រះនាមគោតម ត្រាស់ឡើងក្នុងលោក ។ បុរសនោះជាទាយាទក្នុងធម៌ទាំងឡាយ របស់ព្រះអង្គ ជាឱរស ជាធម្មនិម្មិត ជាសាវ័កនៃព្រះសាស្តាអង្គនោះ មានឈ្មោះថា វង្គីសៈ ។

កាលនោះ ខ្ញុំបានឮនូវពាក្យព្យាករនោះហើយ ក៏ជាបុគ្គលមានចិត្តទន់ មានចិត្តមេត្តា បានបម្រើនូវព្រះជិនស្រីដ៏បវរ ដោយបច្ច័យទាំងឡាយដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការ

តម្កល់ទុកចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ដល់មកក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំបាន មកកើតក្នុងត្រកូលបរិព្វាជក មានអាយុ ៧ ឆ្នាំ រាប់អំពីកំណើត ក៏ចេះ ចប់នូវត្រៃវេទទាំងអស់ ក្លៀវក្លាដោយវាទសាស្ត្រ មានសំឡេងដ៏ពីរោះ មានសម្តីដ៏វិចិត្រ ជាអ្នកញាំញីនូវវាទៈនៃបុគ្គលដទៃ ។ ឯនាមដ៏ប្រសើរ របស់ខ្ញុំ ដែលលោកសន្មតិហើយថា វង្គីសៈ ព្រោះកើតក្នុងវង្គជនបទ ឬ ថា វង្គីសៈ ព្រោះជាឥស្សរៈក្នុងពាក្យ ។ កាលណា ខ្ញុំបានដឹងក្តី ស្ថិត នៅក្នុងបឋមវ័យ កាលនោះ ខ្ញុំបានជួបព្រះសារីបុត្រ ក្នុងក្រុងរាជគ្រឹះ ដែលជាទីរីករាយ ។ ខ្ញុំឃើញព្រះសារីបុត្រនោះ កំពុងត្រាច់ទៅបិណ្ឌបាត មានបាត្រក្នុងដៃ លោកសង្រួមល្អ មានភ្នែកមិនរវើរវាយ និយាយ ល្មមកំណត់ ក្រឡេកមើលត្រឹមមួយជួរនឹម លុះឃើញលោកហើយ មាន សេចក្តីអស្ចារ្យ បានពោលពាក្យគួរសម ជាបទគាថាវិចិត្រ ដូចជាផ្កា កណិកា ដែលគេវិចិត្រហើយ ។

លោកក៏ប្រាប់ខ្ញុំ នូវព្រះសម្ពុទ្ធទ្រង់ជាសាស្តា ជាលោកនាយក កាលនោះ លោកជាបណ្ឌិតមានប្រាជ្ញា បានប្រាប់ខ្ញុំតទៅទៀត ។ ខ្ញុំត្រូវ លោកជាតាទិបុគ្គល ធ្វើពាក្យប្រកបដោយវិរាគៈដ៏ឧត្តម ដែលគេឃើញបាន ដោយកម្រ ឲ្យត្រេកអរ ដោយបដិភាណដ៏វិចិត្រទាំងឡាយ ។ ខ្ញុំក៏ឱន ក្បាលទៀបព្រះបាទា ហើយពោលថា សូមលោកម្ចាស់បំបួសខ្ញុំ លំដាប់

នោះឯង ព្រះសារីបុត្រ មានប្រាជ្ញាច្រើននោះ នាំខ្ញុំចូលទៅរកព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំឱនក្បាលទៀបព្រះបាទា អង្គុយក្នុងសម្នាក់នៃព្រះសាស្តា ឯព្រះសាស្តាប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់មានព្រះពុទ្ធដីកាចំពោះខ្ញុំថា ម្នាលវង្គីសៈ សិប្បៈណាមួយរបស់អ្នក មានពិតឬ ។ ក្បាលមនុស្សដែលស្លាប់ហើយ បើអ្នកអាច (ដឹងក្បាលមនុស្ស) ដែលស្លាប់ទៅកាន់សុគតិ ឬទុគ្គតិ ដោយវិជ្ជាវិសេសរបស់អ្នក អ្នកចូរប្រាប់មកចុះ ។ ខ្ញុំបានទទួលពាក្យប្តេជ្ញាថា ព្រះករុណាព្រះអង្គ ព្រះពុទ្ធទ្រង់បង្ហាញនូវក្បាលបី ខ្ញុំក្រាបទូលចំពោះក្បាល ( មនុស្ស ) ដែលទៅកើតក្នុងនរក និងទេវតា ។ កាលនោះ ព្រះលោកនាយក បង្ហាញនូវក្បាលរបស់ព្រះខីណាស្រព លំដាប់នោះ ខ្ញុំទាល់គំនិត ក៏សូមបព្វជ្ជា ។ លុះខ្ញុំបព្វជ្ជាហើយ ក៏សរសើរព្រះសុគត ទោះក្នុងទីណាៗ ក៏ដោយ លំដាប់នោះ ភិក្ខុទាំងឡាយលើកទោស ថាជាអ្នករីករាយក្នុងកាព្យ ។ លំដាប់នោះ ព្រះពុទ្ធជានាយក ទ្រង់ត្រាស់ដើម្បីល្បងមើលចំពោះខ្ញុំថា លុះតែបុគ្គលទាំងឡាយ ជាអ្នកត្រិះរិះ ទើបពោលគាថាទាំងឡាយ តាមដំណើរបានមែនឬទេ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គមិនមែនជាអ្នកយកចិត្តតិចតួចក្នុងកាព្យទេ តែខ្ញុំព្រះអង្គពោលនូវគាថាទាំងឡាយ តាមដំណើរបាន ។ ម្នាលវង្គីសៈ បើដូច្នោះ ឥឡូវនេះ អ្នកចូរសរសើរតថាគតតាមហេតុ ជាគាថាមកមើល ។

កាលនោះ ខ្ញុំសរសើរព្រះអង្គជាអ្នកប្រាជ្ញ ជាឥសីទី ៧ ដោយគាថាទាំងឡាយ ។ ព្រះជិនស្រីនោះ មានព្រះហឫទ័យត្រេកអរមួយរំពេច ក៏តាំងខ្ញុំក្នុងតំណែងឯតទគ្គៈ ។ ខ្ញុំកន្ទន់បង់នូវបុគ្គលដទៃ ដោយចិត្តដ៏ឈ្លាសវៃបាន ខ្ញុំជាបុគ្គលមានសីលជាទីស្រឡាញ់ មានសេចក្តីសង្វេគដោយបដិភាណ ចិត្តក៏បានដល់នូវអរហត្ត ។

ភិក្ខុដទៃណា ជាបុគ្គលប្រសើរជាងភិក្ខុ អ្នកមានបដិភាណ ដូចជាវង្គីសភិក្ខុនេះ មិនមានទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកយ៉ាងនេះចុះ ។

កម្មដែលខ្ញុំធ្វើហើយ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ក៏ឲ្យផលដល់ខ្ញុំ ក្នុងលោកនេះ ខ្ញុំដកផុតចាកកិលេសហើយ ដូចជាសន្ទុះសរ របូតផុតចាកបំពង់ព្រួយ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់នូវចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធនេះ ខ្ញុំក៏បានប្រតិបត្តិហើយផងដែរ ។៚

**( ជីវប្រវត្តិរបស់ព្រះវង្គីសត្ថេរ ចប់ )**

# ✍ ជីវប្រវត្តិរបស់ព្រះសាគតត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងឈ្លាសវៃក្នុងតេជោធាតុ "

*ព្រះសាគតត្ថេរ លោកជាអ្នកសាងវីរកម្ម ដើម្បីព្រះពុទ្ធសាសនា រហូតបានទទួលការលើកតម្កើង ឲ្យជាអ្នកឈ្លាសវៃក្នុងតេជោកសិណសមាបត្តិ កំពូលជាងព្រះអរហន្តទាំងឡាយ តាមដែលព្រះមុនីទ្រង់ត្រាស់សរសើរដល់លោក ដូចមាននៅក្នុង* ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** *ថា*

***ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ តេជោធាតុកុសលានំ យទិទំ សាគតោ*** *ម្នាលភិក្ខុទាំងឡាយ សាគតៈ ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងជាអ្នកឈ្លាសវៃក្នុងតេជោធាតុ ។*

*ជីវប្រវត្តិរបស់ព្រះសាគតត្ថេរ មានសម្តែងនៅក្នុង****អដ្ឋកថា គម្ពីរមនោរថបូរណី*** *ដូចមានសេចក្តីថា ៖*

*ព្រះសាគតត្ថេរ មកកើតនៅក្នុងត្រកូលព្រាហ្មណ៍ នៅក្នុងនគរហង្សវតី មាតាបិតាដាក់ឈ្មោះឲ្យលោកថា ជាសាគតៈ ។ ចំណែកឈ្មោះរបស់មាតាបិតាលោកវិញ មិនឃើញមានសម្តែងថាមានឈ្មោះអ្វីទេ ។ កាលសាគតមាណពចម្រើនវ័យធំហើយ បានទៅស្តាប់ធម៌ទេសនាក្នុងសម្នាក់ព្រះមានបុណ្យ ហើយក៏កើតសទ្ធាជ្រះថ្លានៅក្នុងព្រះពុទ្ធសាសនា*

ទើបសម្រេចចិត្តបួស ពេលដែលលោកបួសរួចហើយ មានការតាំងចិត្តបំពេញសមណកិច្ច រហូតបានសម្រេចសមាបត្តិ ៨ ដែលជាលោកិយថែមទាំងជាអ្នកមានភាពស្ទាត់ជំនាញ រហ័សរហួនក្នុងសមាបត្តិ ៨ នោះ ។ ថ្ងៃមួយ ព្រះមានព្រះភាគ ស្ដេចយាងទៅដល់កន្លែងមួយក្បែរទីក្រុងកោសម្ពី ដែលមានព្រះសាគតត្ថេរទៅជាមួយផងដែរ ។ គ្រានោះ មនុស្សជាច្រើននាក់បាននាំគ្នាទៅកាន់កំពង់ចម្លងអម្ពៈ ហើយបានទាស់គ្នាជាមួយអ្នកចម្លងនោះ ។ ការឈ្លោះប្រកែកគ្នារវាងអ្នកធ្វើដំណើរ ជាមួយនឹងអ្នកចម្លងយ៉ាងខ្លាំងក្លា រហូតដល់ពួកអ្នកទាំងអស់នោះ នាំគ្នាវាយអ្នកចម្លងនោះទាល់តែអស់ជីវិត ។ ប៉ុន្តែមុនពេលអ្នកចម្លងជិតស្លាប់នោះ ក៏បានតាំងសេចក្ដីប្រាថ្នាទុកដោយចិត្តក្រោធ ចងអាឃាតចំពោះអ្នកទាំងអស់នោះ ហើយស្លាប់ទៅកើតជាស្ដេចនាគ ដែលមានអានុភាពច្រើន នៅនឹងកំពង់ចម្លងនោះឯង ។ ពេលជិតនឹងស្លាប់ ប្រសិនបើបុគ្គលមានចិត្តជាប់ជំពាក់ជាមួយនឹងអ្វី នឹងធ្វើឲ្យបុគ្គលនោះទៅកើតក្នុងភព ឬស្ថាននោះ ។ ឧបមាដូចមនុស្សដែលធ្វើបុណ្យផ្សេងៗ កាលបើគេនឹករឭកនូវសេចក្ដីល្អនោះជារឿយៗ ទើបធ្វើឲ្យគេទៅកើតក្នុងសុគតិភព ដោយអំណាចបុណ្យកុសលដែលគេធ្វើហើយហ្នឹងឯង ។ ចំណែកបុគ្គលធ្វើអាក្រក់វិញ មិនធ្លាប់ធ្វើសេចក្ដីល្អទាល់តែសោះ ការនឹកគិតដល់រឿងអាក្រក់របស់គេនោះក៏ធ្វើឲ្យចិត្តក្ដៅក្រហាយ ចំពោះអំពើអាក្រក់របស់គេ កាលបើសេចក្ដី

ស្លាប់មកដល់ហើយ ធ្វើឲ្យបុគ្គលនោះទៅកើតក្នុងទុគ្គតិ មាននរក ប្រេត តិរច្ឆាន និងអសុរកាយ ឬត្រឡប់មកកើតជាមនុស្សវិញ ជាអ្នកមានរាង កាយពិការពិកិន ក្ររហេមរហាម ថែមទាំងជាអ្នកមានជំងឺតម្កាត់ច្រើន ទៀតផង និងជាមនុស្សអនាថា មិនមានទីពឹងទៀតផង ។

ចំណែកស្តេចនាគនោះ នៅតែមានចិត្តគិតចងអាឃាត ចំពោះអ្នក ទាំងនោះជានិច្ច បានបណ្តាលឲ្យមានភ្លៀងខុសរដូវកាល ដូចជារដូវភ្លៀង ធ្វើមិនឲ្យមានភ្លៀង ដំណាំរបស់កសិករទាំងឡាយ ក៏ដល់នូវការវិនាស ខូចខាតទៅ មិនអាចដុះលូតលាស់បានឡើយ ។ មនុស្សទាំងអស់ក្នុងដែន កាលបើជួបប្រសព្វនឹងភ័យ ដែលមិនមានភ្លៀង ថែមទាំងរាំងស្ងួតហួត ហែង ដូច្នេះហើយ ទើបនាំគ្នាធ្វើពលិកម្មបួងសួងរាល់ៗ ឆ្នាំ ដើម្បីឲ្យមាន ភ្លៀងធ្លាក់ត្រូវកាល ក៏បាននាំគ្នាសង់សាលាមួយខ្នង ឲ្យស្តេចនាគនោះ ។

ការទូន្មានស្តេចនាគ ជាដើមបញ្ញត្តិ ការហាមផឹកសុរាមេរ័យរបស់ ព្រះសាគតត្ថេរ ដូចមានរឿងប្រាកដក្នុង **គម្ពីរមហាវគ្គ ព្រះវិន័យបិដក** នៃ **សុរាបានវគ្គ សិក្ខាបទទី ១** និងនៅក្នុងអដ្ឋកថាដែលអធិប្បាយសេចក្តីនៃ **សុរាបានជាតក** ក្នុង **គម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្តីថា ៖

សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលទ្រង់ពុទ្ធដំណើរទៅកាន់ ចារិក ក្នុងចេតិយជនបទ ហើយយាងចូលទៅកាន់ស្រុក កទ្ទវតិកា ។ ពួកអ្នកឃ្វាលគោ ពួកអ្នកបសុសត្វ ( សត្វសម្រាប់ចិញ្ចឹមជាអាហារ )

ពួកអ្នកស្រែ ពួកអ្នកដើរផ្លូវ បានឃើញព្រះទសពលយាងមកអំពីចម្ងាយ លុះឃើញហើយ ក៏នាំគ្នាក្រាបទូលព្រះសម្ពុទ្ធ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ កុំយាងទៅកាន់កំពង់ឈ្មោះអម្ពៈឡើយ បពិត្រព្រះវិជិតមារដ៏ចម្រើន នាគមានឫទ្ធិជាសត្វអាសិរពិស មានពិសដ៏ក្លៀវក្លា អាស្រ័យនៅក្នុងអាស្រម របស់ជដិលទៀបកំពង់ឈ្មោះអម្ពៈ កុំឲ្យនាគនោះ បៀតបៀនព្រះសក្យមុនីឡើយ ។ កាលបើពួកជនទាំងនោះក្រាបទូលយ៉ាងនេះហើយ ព្រះមានជោគក៏ទ្រង់នៅស្ងៀម ។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកស្រែ អ្នកដើរផ្លូវ បានក្រាបទូលសេចក្ដីនោះចំពោះព្រះជិនស្រី ជាគម្រប់ពីរដងផង ។ បេ ។ បីដងផងថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គកុំយាងទៅកាន់កំពង់ឈ្មោះអម្ពៈនោះឡើយ ព្រោះមាននាគមានឫទ្ធិច្រើន ជាសត្វអាសិរពិស មានពិសដ៏ក្លៀវក្លា អាស្រ័យនៅក្នុងអាស្រមរបស់ជដិល ទៀបកំពង់អម្ពៈ កុំឲ្យនាគនោះបៀតបៀនព្រះមហាវីរៈបានឡើយ ។ ព្រះលោកនាថ ក៏ទ្រង់នៅស្ងៀម ជាគម្រប់បីដង ។ លំដាប់នោះ ព្រះសយម្ភូ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ក៏បានយាងទៅដល់ស្រុកភទ្ទវតិកា ។ មានដំណឹងល្បីទៅថា ព្រះលោកនាយកគង់នៅក្នុងស្រុកភទ្ទវតិកានោះ ។ គ្រានោះឯង ព្រះសាគតៈដ៏មានអាយុ បានចូលទៅកាន់អាស្រម របស់ជដិលទៀបកំពង់អម្ពៈ លុះចូលទៅដល់ហើយ ក៏ដើរចូលទៅក្នុងរោងភ្លើង ក្រាលកម្រាល

ស្មៅ ហើយក៏អន្តរធានស្ដែន តាំងកាយដ៏ត្រង់ តម្កល់សតិផ្ចិតផ្ចង់ ។ ឯនាគនោះ បានឃើញព្រះសាគតៈដ៏មានអាយុចូលមកហើយ លុះឃើញហើយ ក៏កើតទុក្ខទោមនស្សបង្ហុយផ្សែង ( ពិសចំពោះសាគតត្ថេរ ) ។ ចំណែកខាងព្រះសាគតៈដ៏មានអាយុ ក៏បង្ហុយផ្សែងតបទៅវិញ ។ គ្រានោះ នាគនោះទឹងអត់ទ្រាំនូវសេចក្ដីលោកលើនោះមិនបាន ក៏បណ្ដាលឲ្យកើតភ្លើងឡើង ។ ឯព្រះសាគតៈ ក៏បានចូលតេជោធាតុ ហើយបណ្ដាលភ្លើងតបទៅវិញ ។ លំដាប់នោះឯង ព្រះសាគតៈក៏បានគ្របសង្កត់តេជៈរបស់នាគនោះ ដោយតេជៈរបស់លោក ស្ដេចនាគទើបគិតថា ភិក្ខុរូបនេះមានតេជៈច្រើន ជាអ្នកប្រសើរដោយពិត ហើយក៏ព្រមចាញ់ បានចូលទៅរកព្រះថេរៈ ទើបពោលថា

បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់សូមគោរពលោកម្ចាស់ជាសរណៈ ជាទីពឹង ជាទីរឭក គ្រានោះ ព្រះសាគតៈមានថេរវាចាណែនាំស្ដេចនាគដោយប្រការផ្សេងៗ ហើយទើបពោលថា អ្នកកុំយកយើងជាសរណៈអី អ្នកចូរយកព្រះសម្មាសម្ពុទ្ធជាទីពឹងទីរឭកវិញចុះ ។ ក្នុងទីបំផុតស្ដេចនាគព្រមទទួលថា ល្អហើយ និងបានពោលវាចាសូមដល់ព្រះពុទ្ធជាទីពឹង ទីរឭកស្មើដោយជីវិត ។ ការគោរពព្រះរតនត្រៃជាទីពឹងសំដៅដល់មានត្រៃសរណគមន៍ ប្រចាំចិត្តរបស់ស្ដេចនាគនោះ និងមានសញ្ញាលក្ខណៈប្រចាំនៅក្នុងចំណែកផ្សេងៗ របស់រាងកាយ ដែលជា

និមិត្តប្លែកអំពីមនុស្សយើងច្រើន ។ ព្រះត្រៃសរណគមន៍ ដែលស្តេចនាគគោរពនោះ មានព្រះសព្វញ្ញុតញ្ញាណដ៏ប្រសើរ ជាសិរសា មានអារម្មណ៍ដ៏ប្រសើរ គឺព្រះនិព្វាន ជាសក់ មានចតុត្ថជ្ឈានដ៏ប្រសើរ ជាថ្ងាស មានសមាបត្តិដ៏ប្រសើរ ជារោមឧណ្ណាលោម មាននីលកសិណា បីតកសិណាដ៏ប្រសើរ ជាចិញ្ចើមទាំងគូ មានទិព្វចក្ខុ បញ្ញាចក្ខុ សមន្តចក្ខុដ៏ប្រសើរ ជាចក្ខុទាំងពីរខាង មានទិព្វសោតដ៏ប្រសើរ ជាត្រចៀកឆ្វេងស្តាំ មានគោត្រភូញាណដ៏ប្រសើរ ជាច្រមុះ មានមគ្គញ្ញាណ ផលញ្ញាណ វិមុត្តិ-ញ្ញាណដ៏ប្រសើរ ជាកំពូលទាំងពីរខាង មានលោកិយញាណ លោកុត្តរញាណដ៏ប្រសើរ ជាបបូរមាត់ មានពោធិបក្ខិយញាណដ៏ប្រសើរ ៣៧ ប្រការ ជាធ្មេញដ៏ស្អាត មានមគ្គញ្ញាណ ៤ ដ៏ប្រសើរ ជាចង្កូមទាំង ៤ មានសច្ចញ្ញាណទាំង ៤ ដ៏ប្រសើរ ជាអណ្តាត មានញាណដែលមិនមានវត្ថុណាជំទាស់ ជាចង្កា មានញាណជាគ្រឿងសម្រេចវិមោក្ខយ៉ាងខ្ពស់ ជាដើម.ក. មានត្រៃលក្ខណ៍ដ៏ប្រសើរ ជាបំពង់.ក. មានវេសារជ្ជញ្ញាណ ៤ ដ៏ប្រសើរ ជាដៃទាំងពីរ មានអនុស្សតិញ្ញាណ ១០ ប្រការដ៏ប្រសើរ ជាទ្រូង មានអាសយានុសយញ្ញាណដ៏ប្រសើរ ជាដោះទាំងពីរ មានទសពលញ្ញាណដ៏ប្រសើរ ជាជង្ខន មានញាណដែលដឹងនូវបដិច្ចសមុប្បាទធម៌ដ៏ប្រសើរ ជាផ្ចិត មានឥន្ទ្រិយ ៥ ពលៈ ៥ ដ៏ប្រសើរ ជាជង្គង់ មានការព្យាយាមត្រូវ ៥ ប្រការ ជាជើង មានកុសលកម្មបថ ១០ ប្រការ

ជាស្នងជើងទាំងពីរ មានឥទ្ធិបាទ ជាបាទជើងទាំងពីរ មានសីល សមាធិ បញ្ញា ជាសំពត់ស្លៀក មានហិរិឱត្តប្បៈ ជាសំពត់ដណ្តប់ មានអដ្ឋង្គិក-មគ្គញ្ញាណ ជាស្បែក មានសតិប្បដ្ឋាន ៤ ជាវត្ថពន្ធចង្កេះ ។ ចាប់ពីថ្ងៃនេះតទៅ ខ្ញុំព្រះអង្គមិនបៀតបៀននរណាៗ ទៀតឡើយ ខ្ញុំព្រះអង្គនឹងធ្វើឲ្យមានភ្លៀងធ្លាក់ត្រូវរដូវកាលវិញ ។

ក្រោយពីស្តេចនាគ បានទទួលយកព្រះរតនត្រៃជាទីពឹង ទីរឭកហើយ មនុស្សក្នុងដែននោះក៏ប្រកបដំណាំដាំដុះបានដូចដើមវិញ ទាំងនេះកើតឡើងដោយអានុភាពរបស់ស្តេចនាគនោះ ។ ព្រះសាគតត្ថេរ កាលបើទូន្មានស្តេចនាគបានដូច្នេះហើយ ក៏ត្រឡប់ទៅកាន់សម្នាក់ព្រះទសពលដែលគង់ប្រថាប់ក្នុងស្រុកភទ្ទវតិកា ។ កាលដែលព្រះមានបុណ្យគង់នៅក្នុងស្រុកភទ្ទវតិកា តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ឯក្រុងកោសម្ពី ។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពីបានឮគេនិយាយថា លោកម្ចាស់សាគតៈ បានច្បាំងគ្នានឹងនាគឈ្មោះអម្ពតិត្ថកៈ ។ គ្រានោះ ព្រះមានជោគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ហើយទ្រង់សំដៅទៅឯក្រុងកោសម្ពីនោះ ។ គ្រានោះឯង ពួកឧបាសកនៅក្នុងក្រុងកោសម្ពី នាំគ្នាទៅទទួលព្រះភគវា ហើយចូលទៅរកព្រះសាគតៈ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះសាគតៈ ហើយក៏ស្ថិតនៅក្នុងទីដ៏សមគួរ ។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពី លុះស្ថិត

នៅក្នុងទីដ៏សមគួរហើយ ទើបនិយាយពាក្យនេះនឹងព្រះសាគតៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន វត្ថុអ្វីដែលលោកម្ចាស់បានដោយកម្រផង ជាទីគាប់ចិត្តផង ពួកយើងខ្ញុំនឹងតាក់តែងវត្ថុអ្វីប្រគេន លុះឧបាសកទាំងនោះបានពោលពាក្យយ៉ាងនេះហើយ ពួកឆព្វគ្គិយភិក្ខុ បាននិយាយពាក្យនេះនឹងពួកឧបាសកនោះថា ម្នាលអ្នកទាំងឡាយ សុរាថ្លាឈ្មោះកាបោតិកា (មានពណ៌ក្រហមដូចជើងព្រាប) ដែលភិក្ខុទាំងឡាយរកបានដោយកម្រផងជាទីគាប់ចិត្តរបស់ពួកភិក្ខុផង ពួកអ្នកឯងចូរតាក់តែងវត្ថុនោះប្រគេនលោកចុះ ។ លំដាប់នោះឯង ពួកឧបាសកនៅក្នុងក្រុងកោសម្ពី នាំគ្នាតាក់តែងសុរាថ្លាឈ្មោះកាបោតិកាគ្រប់ៗ ផ្ទះ បានឃើញព្រះសាគតៈកំពុងនិមន្តបិណ្ឌបាតហើយ និយាយពាក្យនេះនឹងព្រះសាគតៈថា បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់សាគតៈ និមន្តឆាន់សុរាថ្លាឈ្មោះកាបោតិកាចុះ ។ គ្រានោះ ព្រះសាគតៈដ៏មានអាយុ លុះបានឆាន់សុរាគ្រប់ៗ ផ្ទះហើយ ចេញពីនគរទៅ ក៏ដួលដេកទៀបទ្វារនគរ ។ គ្រានោះ ព្រះសម្ពុទ្ធ កាលចេញចាកនគរជាមួយនឹងភិក្ខុជាច្រើនអង្គ បានទតឃើញព្រះសាគតៈដួលដេក នៅទៀបទ្វារនគរ លុះទ្រង់ឃើញហើយ ក៏ត្រាស់បង្គាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរគ្រាហ៍សាគតភិក្ខុឡើង ។ ភិក្ខុទាំងនោះក៏ទទួលព្រះពុទ្ធដីការបស់ព្រះសក្យមុនី ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយៗ ក៏គ្រាហ៍ព្រះសាគតៈទៅកាន់អារាម ហើយ

ផ្គកបែរក្បាលទៅរកព្រះវិជិតមារ ។

លំដាប់នោះ ព្រះសាគតៈ ប្រែត្រឡប់ដេកដាក់ជើងទៅរកព្រះជិនស្រីវិញ ។ គ្រានោះ ព្រះមហាវីរៈ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពីដើមមកសាគតភិក្ខុ មានសេចក្តីគោរពកោតក្រែងដល់តថាគតពិតមែនឬទេ ? ពួកភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសពិតយ៉ាងហ្នឹងហើយ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះឥឡូវនេះ សាគតភិក្ខុ មានសេចក្តីគោរពកោតក្រែងដល់តថាគតឬទេ ? ពួកភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មិនគោរពទេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា សាគតភិក្ខុបានច្បាំងនឹងអម្ពតិត្ថកនាគពិតមែនឬទេ ? ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះឥឡូវនេះ សាគតភិក្ខុ ( ដែលដួលដេកមិនដឹងខ្លួនយ៉ាងនេះ ) អាចច្បាំងនឹងពស់ទឹកបានឬទេ ? ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស មិនបានទេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រាសចាកសញ្ញា ព្រោះផឹកទឹកណា ទឹកនោះ ភិក្ខុគួរផឹកឬ ? ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស មិនគួរផឹកទេ ។ ព្រះលោកនាថទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កម្មរបស់សាគតភិក្ខុមិនសមគួរ មិនទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើ ម្នាលភិក្ខុទាំងឡាយ សាគត

ភិក្ខុ មិនគួរនឹងផឹកទឹកស្រវឹងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាផឹកសុរា និងមេរ័យត្រូវ **អាបត្តិបាចិត្តិយៈ** ។

រាប់ថា ជាពុទ្ធប្បញ្ញត្តិ គឺការហាម តាំងពីថ្ងៃនោះជាដើមមក ភិក្ខុទាំងឡាយណា ធ្វើដូចជាព្រះសាគតៈមិនបានឡើយ ។ ចំណែកព្រះ-សាគតៈផឹកសុរាហើយ មានអាការស្រវឹងដូច្នោះ រាប់យកថាមុនព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តសិក្ខាបទនេះ ដែលនៅមិនទាន់ចាត់ថាខុសក្នុងសិក្ខាបទដែលទ្រង់បញ្ញត្តនេះ និងបានទទួលការលើកលែងទោស ព្រោះជាដើមបញ្ញត្តិ ។ ជាខាងក្រោយមក ភិក្ខុទាំងឡាយ បានប្រជុំសន្ទនាគ្នាក្នុងសាលាធម្មសភា ដល់ទោសនៃការផឹកសុរាថា ការផឹកសុរាមានទោសច្រើន មើលតួយ៉ាងដូចជាព្រះសាគតៈ ជាអ្នកមានបញ្ញា និងឫទ្ធិ កាលផឹកសុរាចូលទៅហើយ ក៏ដល់នូវការវិនាសសតិ មិនអាចគ្រប់គ្រងខ្លួនបាន សូម្បីព្រះសុគតសាស្តាមានគុណ ក៏មិនអាចដឹងបាន ។ កាលបើព្រះសាស្តាទ្រង់សណ្តាប់ពាក្យសន្ទនា របស់ភិក្ខុទាំងឡាយដោយទិព្វសោតហើយ ទើបស្តេចយាងទៅកាន់សាលាធម្មសភា ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បព្វជិតដែលផឹកសុរាហើយ វិនាសចាកសតិដូច្នេះ មិនមែន

មានតែក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្លាប់មានរឿងមកហើយដែរ ។

កាលត្រាស់ដូច្នេះហើយ ទើបទ្រង់ត្រាស់សម្តែងរឿងអតីតនិទានមានក្នុងអដ្ឋកថា ដែលអធិប្បាយសេចក្តីនៃ **សុរាបានជាតក** ក្នុង **គម្ពីរខុទ្ទកនិកាយ ជាតក** ដូចមានសេចក្តីថា ៖

កាលកន្លងមកហើយ ព្រះបាទព្រហ្មទត្ត គ្រប់គ្រងរាជសម្បត្តិនៅក្នុងក្រុងពារាណសី ។ មានកុលបុត្រម្នាក់ ជាបុត្ររបស់ព្រាហ្មណ៍ ជាអ្នកកើតនៅក្នុងត្រកូលខ្ពង់ខ្ពស់ កាលធំឡើង បានចេញបួសជាឥសី ហើយបានសម្រេចអភិញ្ញាសមាបត្តិ នៅក្នុងព្រៃហិមពាន្ត ថែមទាំងមានកូនសិស្ស ៥០០ នាក់ជាបរិវារ ។ ថ្ងៃមួយ កូនសិស្សទាំង ៥០០ នាក់នោះ បាននាំគ្នាលាអាចារ្យ ដើម្បីទៅចាំវស្សានៅក្នុងក្រុងពារាណសី គ្រានោះ ព្រះបាទពារាណសី ទ្រង់និមន្តឲ្យទៅចាំវស្សានៅក្នុងព្រះរាជឧទ្យាន ហើយទ្រង់អារាធនា ឲ្យទៅឆាន់ក្នុងព្រះរាជវាំងជាប្រចាំ ។ លុះតមកដល់ថ្ងៃនក្ខត្តឫក្ស ព្រះបាទពារាណសី ត្រាស់ឲ្យចាត់ចែងសុរាយ៉ាងល្អថ្វាយដល់ឥសីទាំងនោះ ។ ចំណែកឥសីទាំងនោះ ក៏នាំគ្នាផឹកសុរាទាល់តែស្រវឹង ហើយត្រឡប់ទៅកាន់កន្លែងព្រះរាជឧទ្យានវិញ ដើម្បីសម្រាក ។ កាលបើឥសីទាំងនោះ បានត្រឡប់មកដល់ទីសម្រាកហើយ ឫទ្ធិរបស់សុរាសម្តែងតេជៈ ឥសីខ្លះក្រោកឡើងរាំ ខ្លះច្រៀង ខ្លះកំពុងតែជុនដាប

មានអាការដូចមនុស្សស្រវឹងស្រា ធ្វើបានគ្រប់យ៉ាង មិនមានការអៀនខ្មាសឡើយ ។ កាលឥសីទាំងនោះស្វាងស្រាហើយ ត្រឡប់មានសតិឡើងវិញ ក៏កើតការខូចចិត្ត ថែមទាំងប្រាប់ដល់គ្នានិងគ្នាថា ពួកយើងទាំងអស់គ្នា ចាប់ពីថ្ងៃនេះតទៅឈប់ផឹកសុរាទៀត កាលដែលពួកយើងទៅជួបអាចារ្យវិញ ត្រូវទទួលសារភាពទោសរបស់ខ្លួន ពេលដែលឥសីទាំងនោះទៅជួបហើយ ទើបនាំគ្នាពោលឡើងថា បពិត្រលោកអាចារ្យ ពួកខ្ញុំទាំងឡាយធ្លាប់តែនៅក្នុងព្រៃ កាលបើបានផឹកសុរាហើយ ម្នាក់ៗ នាំគ្នារាំច្រៀង ដោយគ្មានការអៀនខ្មាសឡើយ ។

កាលផឹកសុរាទាល់តែស្រវឹង វិនាសសតិហើយ ត្រឡប់ឃើញល្អជាជាអាក្រក់ និងឃើញអាក្រក់ថាជាល្អ មិនប្រព្រឹត្តប្រតិបត្តិដូចនៅក្នុងសម្នាក់របស់អាចារ្យឡើយ ។ ចំណែកឥសីជាអាចារ្យ បានស្តាប់ពាក្យសារភាពកំហុសនៃសិស្សទាំងឡាយហើយ ទើបពោលប្រៀនប្រដៅថា អ្នកធ្វើនូវអំពើនេះ មិនសមគួរដល់ពួកយើង ជាឥសីនៅក្នុងព្រៃឡើយ ។ ឥសីទាំងនោះ បានជឿស្តាប់ពាក្យប្រៀនប្រដៅរបស់លោកអាចារ្យ ក៏នាំគ្នាតាំងចិត្តប្រតិបត្តិតាមរបៀបនៃឥសីរហូតដល់អស់ជីវិត ក៏បានទៅកើតក្នុងព្រហ្មលោក ។ កាលព្រះបរមគ្រូ ត្រាស់សុរាបានជាតកចប់ ទើបទ្រង់ប្រជុំជាតកថា ឥសីទាំង ៥០០ នាក់នោះ ត្រឡប់មកកើតជាបរិវាររបស់តថាគតក្នុងកាលឥឡូវនេះ ចំណែកឥសីជាអាចារ្យ គឺតថាគតនេះឯង

ជាតកនេះ បង្ហាញឲ្យឃើញទោសរបស់សុរាថា សុរាមេរ័យនេះឲ្យទោស មនុស្សដែលផឹកដោយមិនរើសភេទ ជាតិ ថ្នាក់ វណ្ណៈ ឡើយ ។ លុះព្រឹកឡើង ព្រះសាគតត្ថេរដឹងខ្លួន មានស្មារតី បានស្តាប់នូវហេតុការណ៍ដែលលោកធ្វើរួចហើយ បានកើតការសង្វេគ ទើបចូលទៅសូមខមាទោសចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គក៏អភ័យទោសឲ្យ ។ ការដឹងខ្លួនថាខុសហើយ សូមទោសចេញ ដោយមិនប្រើភាពរឹងរូស ទើបបណ្ឌិតពោលសរសើរបុគ្គលប្រភេទនេះ ដូចមានពាក្យបុរាណថា ខុសហើយ ព្រមទទួលកំហុស ជាបណ្ឌិតដោយពិត ។

ក្រោយពីព្រះសាគតត្ថេរ បានដឹងកំហុសហើយ ទើបកែខ្លួនសាជាថ្មី ដោយតាំងចិត្តព្យាយាមចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចជាព្រះអរហន្ត ។ តមក ព្រះបរមគ្រូ ទ្រង់តែងតាំងព្រះ-សាគតៈទុកក្នុងតំណែងដ៏ប្រសើរ ជាងភិក្ខុសាវកទាំងឡាយ ផ្នែកខាងជាអ្នកឈ្លាសវៃក្នុងតេជោធាតុ មានធាតុភ្លើងជាអារម្មណ៍ ធ្វើឲ្យកើតធាតុភ្លើងឡើងបាន ។ ព្រះសាគតត្ថេរ ធ្លាប់ទទួលនាទីជាឧបដ្ឋាកព្រះមានព្រះភាគមុនព្រះអានន្ទត្ថេរចូលមកទទួលនាទីជាប់លាប់ តែបានជាពុទ្ធុបដ្ឋាកនៅត្រឹមតែមួយខណៈមួយពេលនោះ កាលមិនទាន់មានព្រះសាវកណាមួយទទួលនាទីពុទ្ធុបដ្ឋាកជាប្រចាំ កាលមានព្រះអានន្ទត្ថេរចូលមកទទួលនាទីជាប្រចាំហើយ លោកក៏ឈប់ទៅ ។ ដូចមានរឿងនៅក្នុងគម្ពីរមហាវគ្គ

ព្រះវិន័យបិដក ត្រង់ចម្មក្ខន្ធកៈ ដូចមានសេចក្តីថា ៖

ព្រះសាគតត្ថេរ ធ្លាប់បានបដិបត្តិបម្រើព្រះមានព្រះភាគ ក្នុងកាលដែលព្រះអង្គប្រថាប់នៅភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង មានពួកអ្នកស្រុកទាំង៨ ម៉ឺន បាននាំគ្នាទៅកាន់ភ្នំគិជ្ឈកូដនោះ ដើម្បីចូលគាល់ព្រះមានព្រះភាគតាមព្រះបាទពិម្ពិសារ ។ ក្នុងសម័យនោះ ព្រះសាគតៈបានទទួលនាទីជាអ្នកបម្រើព្រះមានព្រះភាគ ។ វេលានោះ ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះ បានចូលទៅរកព្រះសាគតៈ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងព្រះសាគតៈថា បពិត្រលោកដ៏ចម្រើន ឥឡូវពួកអ្នកស្រុកទាំង ៨ ម៉ឺននេះ បានចូលមកក្នុងទីនេះ ដើម្បីឃើញព្រះសម្ពុទ្ធបពិត្រលោកដ៏ចម្រើន យើងខ្ញុំគួរបានឃើញព្រះភគវា ទើបជាការប្រពៃ ។ ព្រះសាគតកិក្ខុតបទៅវិញថា នែអ្នកដ៏មានអាយុទាំងឡាយ បើដូច្នោះ អ្នករាល់គ្នាឈប់បន្តិចចាំអាត្មានៅទីនេះមួយស្របក់ចុះ ចាំអាត្មាក្រាបទូលព្រះវិជិតមារសិន ។ គ្រានោះឯង កាលបើពួកអ្នកស្រុកទាំង ៨ ម៉ឺននោះកំពុងតែសម្លឹងមើលក្នុងទីចំពោះមុខ ព្រះសាគតៈក៏ជ្រែកចុះចំផែនថ្ម ហើយទៅផុសក្នុងទីចំពោះព្រះភក្ត្រព្រះមហាវីរៈ រួចបានពោលពាក្យនេះនឹងព្រះលោកនាថថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវ មានពួកអ្នកស្រុកទាំង ៨ ម៉ឺននេះ បានចូលមកក្នុងទីនេះដើម្បីឃើញព្រះសយម្ភូ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ រមែងជ្រាបនូវកាលគួរ ជាប្រយោជន៍ក្នុងកាល

ឥឡូវនេះ ។ ព្រះលោកនាយកតបថា នែសាគតៈ បើដូច្នោះ អ្នកចូរទៅរៀបចំក្រាលអាសនៈត្រង់មូប់នៃវិហារចុះ ។ ព្រះសាគតៈដ៏មានអាយុបានទទួលព្រះពុទ្ធដីកាព្រះមានបុណ្យថា ព្រះករុណាព្រះអង្គ ហើយក៏នាំយកតាំង ជ្រែកចុះក្នុងទីចំពោះព្រះភក្ត្រព្រះមានជោគ កាលអ្នកស្រុកទាំង ៨ ម៉ឺននោះ កំពុងសម្លឹងមើលក្នុងទីចំពោះមុខ ក៏ស្រោប់តែទៅផុសត្រង់ថ្ម ហើយក្រាលអាសនៈត្រង់មូប់នៃវិហារ ។ វេលានោះ ព្រះភគវា ទ្រង់យាងចេញពីវិហារទៅគង់នៅលើអាសនៈ ដែលព្រះសាគតត្ថេរបានក្រាលត្រង់មូប់នៃវិហារ ។ លំដាប់នោះឯង ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះ បានចូលទៅគាល់ព្រះសុគត លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះសាស្តា រួបអង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះ ក៏អប់អរពាក់ទាក់ទឹងព្រះសាគតៈទៅវិញ មិនបានអប់អរពាក់ទាក់ទឹងព្រះបរមគ្រូឡើយ ។

វេលានោះឯង ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបនូវបរិវិតក្កក្នុងចិត្តរបស់ពួកអ្នកស្រុកទាំងនោះ ដោយព្រះទ័យនោះហើយ ទើបទ្រង់ត្រាស់ហៅព្រះសាគតៈមកថា នែសាគតៈ បើដូច្នោះ អ្នកចូរសម្តែងឥទ្ធិប្បាដិហារ្យដែលជាធម៌របស់មនុស្សជាន់ខ្ពស់ ឲ្យក្រៃលែងឡើងទៅទៀត ។ ព្រះសាគតៈ បានទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ហោះទៅលើវេហាស៍ ចង្ក្រម គឺដើរខ្វះ ឈរខ្វះ គង់ខ្វះ សិង

ខ្វះ បណ្តាលឲ្យកើតផ្សែងខ្វះ បណ្តាលឲ្យកើតភ្លើងខ្វះ បាត់ខ្លួនទៅខ្វះក្នុងប្រទេសទំនេរ គឺអាកាស ។ ក្នុងឱកាសពេលនោះ ព្រះសាគតៈ លុះបានសម្តែងឥទ្ធិប្បាដិហារ្យ ជាធម៌របស់មនុស្សជាន់ខ្ពស់ មានប្រការច្រើនយ៉ាងនៅលើប្រទេសទំនេរ គឺអាកាសរួចហើយ ក៏មកក្រាបសិរសាទៀបព្រះបាទានៃព្រះទសពល ហើយក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសក្យមុនីជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក បពិត្រព្រះអង្គដ៏ចម្រើន ព្រះវិជិតមារជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។ ខណៈនោះ អ្នកស្រុកទាំង ៨ ម៉ឺននោះ ក៏ពោលថា នៃគ្នាយើងដ៏ចម្រើន អស្ចារ្យពេកណាស់ នៃគ្នាយើងដ៏ចម្រើន ហេតុដែលមិនធ្លាប់កើតៗ ឡើងហើយតើ អម្បាលសាវ័កមានឫទ្ធិដ៏ខ្លាំងក្លា មានអានុភាពច្រើនម៉្លោះទៅហើយ ចំណង់បើគ្រូគង់មានឫទ្ធានុភាពក្រៃលែងជាងនេះពិតប្រាកដ ហើយបែរមកអប់អរពាក់ទាក់នឹងព្រះជិនស្រីវិញ លែងអប់អរពាក់ទាក់នឹងព្រះសាគតៈ ដូច្នោះទៀតឡើយ ។ វេលានោះ ព្រះមុនីទ្រង់ជ្រាបនូវបរិវិតក្កក្នុងចិត្តរបស់អ្នកស្រុកទាំងនោះ ដោយព្រះទ័យហើយ ទើបទ្រង់សម្តែងអនុបុព្វីកថា ឯអនុបុព្វីកថានោះ តើដូចម្តេចខ្វះ គឺព្រះអង្គទ្រង់សម្តែងទានកថា សីលកថា សគ្គកថា សម្តែងពីទោសរបស់កាមដែលជារបស់លាមកសៅហ្មង និងអានិសង្សក្នុងកិរិយាចេញបួស ។ ព្រះលោកនាថទ្រង់បានជ្រាបថា ពួកជនទាំងនោះ មានចិត្តស្រួល មានចិត្ត

ទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងវេលាណាហើយ ក៏ទ្រង់សម្តែងនូវធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយតែងលើកឡើងសម្តែងដោយព្រះអង្គឯង គឺសម្តែងពីកងទុក្ខ ហេតុដែលនាំឲ្យកើតកងទុក្ខ សេចក្តីរំលត់នូវកងទុក្ខ និងផ្លូវដែលដល់នូវសេចក្តីរំលត់កងទុក្ខក្នុងវេលានោះ ។ សំពត់ស្អាត ប្រាសចាកវត្ថុមានពណ៌ខ្មៅ គួរទទួលយកគ្រឿងជ្រលក់ដោយល្អ យ៉ាងណាមិញ ធម្មចក្ខុ ( គឺសោតាបត្តិមគ្គ ) ឥតមានធូលី ឥតមានមន្ទិល ក៏កើតឡើងដល់ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះ នៅហ្នឹងអាសនៈនោះថា ធម្មជាតឯណានីមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ ក៏មានការរលត់ទៅវិញជាធម្មតាយ៉ាងនោះឯង ។ ពួកជនទាំងនោះ ក៏បានយល់នូវអរិយសច្ចធម៌ហើយ បានដល់នូវអរិយសច្ចធម៌ហើយ បានដឹងច្បាស់នូវអរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យប្រាសចេញពីសេចក្តីងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនបានជឿបុគ្គលដទៃ ក្នុងសាសនានៃព្រះសយម្ភូ ក៏បានក្រាបបង្គំទូលពាក្យនេះនឹងព្រះលោកនាថថា បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ណាស់ហើយ ដូចបុគ្គលផ្ងារឡើងនូវភាជនៈដែលគេផ្កាប់ចុះ ឬបើកឡើងនូវវត្ថុដែលកំបាំង ឬប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬទ្រោលបំភ្លឺប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា ពួកជនដែលមានចក្ខុ នឹងបានឃើញនូវរូបទាំងឡាយ យ៉ាងណាមិញ ធម៌

ដែលព្រះសាស្តាបានសម្តែងដោយអនេកបរិយាយ ក៏ដូច្នោះឯង បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយនេះ សូមដល់នូវព្រះមានជោគផង ព្រះធម៌ផង ព្រះសង្ឃផង ថាជាទីរឭក សូមព្រះភគវាចាំទុកនូវយើងខ្ញុំថា ជាឧបាសក បានដល់នូវព្រះរតនត្រៃថាជាទីរឭក ស្មើដោយជីវិតចាប់ផ្តើមតាំងពីថ្ងៃនេះតទៅ ។

ចំណែកជីវប្រវត្តិអតីតជាតិ របស់ព្រះសាគតត្ថេរ មានសម្តែងប្រាកដក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដោយលោកបានឧទាន ដោយខ្លួនឯងផ្ទាល់ អំពីការកសាងបុណ្យបារមីផ្សេងៗ រហូតឲ្យបានជាបច្ច័យធ្វើឲ្យលោកបានសម្រេចជាព្រះអរហន្ត ដូចមានសេចក្តីថា ៖

គ្រានោះ ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះសោភិតៈ មានពួកសិស្សហែហម ដើរទៅកាន់អារាម ។ សម័យនោះ ព្រះភគវា ជាបុរសឧត្តម មានពួកភិក្ខុចោមរោម ស្តេចចេញអំពីទ្វារអារាម ហើយស្ថិតនៅ ។ ខ្ញុំបានឃើញព្រះសុគតអង្គនោះ ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ មានសាវកដែលមានឥន្ទ្រិយទូន្មានហើយដែរ ជាបរិវារ ខ្ញុំក៏ញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយពោលសរសើរព្រះសាស្តាថា ពួកឈើទាំងអស់ណាមួយ ពួកឈើទាំងនោះ រមែងដុះលូតលាស់លើផែនដី យ៉ាងណាមិញ សត្វទាំងឡាយជាអ្នកមានប្រាជ្ញា តែងចម្រើនលូតលាស់ឡើង ក្នុងសាសនារបស់ព្រះបរមគ្រូ ក៏យ៉ាងនោះ ។ ព្រះអង្គជាអ្នកដឹកនាំពួក ជាសព្វញ្ញូ

ស្វែងរកនូវគុណធំ ទ្រង់ស្រោចស្រង់នូវពួកជនជាច្រើនអំពីផ្លូវខុស ហើយប្រាប់ផ្លូវត្រូវ ។ ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ ទាំងមានសាវ័កដែលមានឥន្ទ្រិយទូន្មានហើយចោមរោម ព្រះអង្គមានឈាន មានពួកអ្នកត្រេកអរក្នុងឈាន អ្នកមានព្យាយាម និងអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន អ្នកមានចិត្តស្ងប់រំងាប់ អ្នកមិនញាប់ញ័រដោយលោកធម៌ ចោមរោម ។ ព្រះអង្គប្រដាប់ហើយដោយពួកបរិស័ទ ទ្រង់ល្អដោយបុណ្យនិងញាណ រស្មីរបស់ព្រះអង្គផ្សាយចេញ ដូចព្រះអាទិត្យ ដែលទើបនឹងរះឡើង ។ ព្រះមហេសីជាសាស្តាព្រះនាមបទុមុត្តរៈ ទ្រង់ស្ថិតនៅក្នុងភិក្ខុ-សង្ឃ ឃើញខ្ញុំមានចិត្តជ្រះថ្លាហើយ ត្រាស់នូវគាថាទាំងឡាយនេះថា

ព្រាហ្មណ៍ណា ញុំាងសេចក្តីរីករាយឲ្យកើតឡើងហើយ ពោលសរសើរតថាគត ព្រាហ្មណ៍នោះនឹងរីករាយ ក្នុងទេវលោកអស់សែននៃកប្បទាំងឡាយ ។ ព្រាហ្មណ៍នោះលុះច្យុតចាកឋានតុសិតមក ត្រូវកុសលមូលជាស់តឿន នឹងបួសក្នុងសាសនា របស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ ព្រាហ្មណ៍នោះ បួសក្នុងសាសនាហើយ នឹងបាននូវសេចក្តីត្រេកអររីករាយ មាននាមថាសាគតៈ នឹងបានជាសាវ័ករបស់ព្រះសាស្តានោះ ។ ខ្ញុំលុះបួសរួចហើយ ក៏វៀរចាកបាបកម្ម ដោយកាយ លះបង់នូវវចីទុច្ចរិត ជម្រះសម្អាតនូវអាជីវបារិសុទ្ធិសីល ។ ខ្ញុំកាលនៅយ៉ាងនេះ ជាអ្នកឈ្លាសវៃក្នុងតេជោធាតុ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិន

មានទូវអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

សរុបអំពើល្អក្នុងអតីតជាតិរបស់លោក មានការបំពេញបុណ្យកុសលក្នុងសម្នាក់ព្រះបទុមុត្តរៈ ហើយថែមទាំងមានសេចក្តីជ្រះថ្លា បានពោលសរសើរគុណព្រះបទុមុត្តរៈនោះ ធ្វើឲ្យលោកបានជួបប្រទះ នូវសេចក្តីសុខ តាំងពីជាតិនោះមករហូតអស់មួយសែនកប្ប ទើបជាតិចុងក្រោយនេះ បានមកកើតជាព្រះសាគតត្ថេរ ។

ចំណែកការរំលត់ខន្ធបរិនិព្វានរបស់លោកវិញ មិនបានឃើញមានសម្តែងប្រាកដទុកក្នុងគម្ពីរណាថា លោកបរិនិព្វាននៅក្នុងទីណាទេ ឃើញមានត្រឹមតែពោលថា កាលព្រះសាគតត្ថេរទ្រទ្រង់អាយុសង្ខារមកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅ ។

( ជីវប្រវត្តិរបស់ព្រះសាគតត្ថេរ ចប់ )

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ រោច ខែពិសាខ ព.ស ២៥៥១

**ដោយខ្ញុំព្រះករុណាអាត្មាភាព យង់ សុផាត**